# ក្រមរដ្ឋប្បវេណី

## ភាគ ៣

បោះពុម្ពនៅក្នុងខែ មីនា ឆ្នាំ ២០១២

# អារម្ភកថា

សៀវភៅនេះ ត្រូវបានចងក្រងឡើង តាមផ្នែកនៃ "**ក្រមរដ្ឋប្បវេណី**" ហើយ នេះ គឺជាសៀវភៅភាគទី ៣ ដែលគ្របដណ្តប់លើ ***មូលដ្ឋាននៃនីតិកិច្ចសន្យា***។

សៀវភៅនេះ ត្រូវបានបង្កើតឡើងដោយសមាជិកក្រុមការងារដែលរួមមានអនាគតគ្រូបណ្តុះបណ្តាលនៃសាលាភូមិន្ទចៅក្រម ដោយមានការឧបត្ថម្ភគាំទ្រពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) និង នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃវិទ្យាស្ថានស្រាវជ្រាវ និង បណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន (ICD) ។

សមាជិកនៃក្រុមការងារមានដូចខាងក្រោម:

| | | |
|---|---|---|
| លោក **អ៊ិន វ៉ានវិបុល** | លោកស្រី **ចាំង ស៊ីណាត** | លោកស្រី **សែម សក្តិភូឡា** |
| លោក **សេង នាង** | លោក **ម្លង់ សំណាង** | លោក **តាំង ស៊ុនឡាយ** |
| លោក **យូ ប៊ុនណា** | លោក **ខួន រតនា** | លោក **គង់ តារាឆាត** |
| លោក **ម៉ុង មុនីសោភា** | លោក **ហួត ហ៊ាង** | លោក **ជា សុខហៀង** |
| លោក **ហេង សុខណា** | លោកស្រី **យ៉េត ម៉ូលីន** | លោក **ខួន វុទ្ធី** |
| កញ្ញា **ថ្លាង ផារ៉ែណត** | លោកស្រី **ស្រ៊ុន ឈន់វលក្ខណ៍** | កញ្ញា **ស៊ី លីនណា** |
| លោក **ភេត សុជាតិ** | លោក **ចំន្ទ រង្សី** | លោកស្រី **ខៀវ សុខា** |
| លោក **រស់ ពិសិដ្ឋ** | លោក **ស៊ិន សុវណ្ណរ័ត្ន** | លោក **ហេង ចន្ទស៊ីបូរិន** |
| លោក **ឆែ វិរៈ** | លោក **អ៊ី ថាវរៈ** | លោក **ភេង សុម៉ារិទ្ធ** |
| លោក **ឈុន ចំន្ទសីហា** | លោក **យាប់ មេត្តា** | លោក **ឆែ វិទស្សនៈ** |
| លោកស្រី **វ៉ា សក្តា** | លោក **សំម ឫទ្ធីវាសនា** | |

សមាជិកក្រុមការងារទាំងអស់ សង្ឃឹមថា កំរងភាគនីមួយ ៗ នៃ "ក្រមរដ្ឋប្បវេណី" នេះ អាចនឹងជួយដល់អ្នកអានអោយយល់ដឹង និង សិក្សាអំពីមូលដ្ឋាននៃក្រមរដ្ឋប្បវេណីនាពេលបច្ចុប្បន្ន ។

**កំណត់សំគាល់ :** ខ្លឹមសារនៃសៀវភៅនេះ ត្រូវបានចងក្រងឡើង ដោយសមាជិកក្រុមការងារ និង មិនបានឆ្លុះបញ្ចាំងពីទស្សនៈផ្លូវការរបស់អាជ្ញាធរពាក់ព័ន្ធណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ ។

សៀវភៅនេះ បោះពុម្ពលើកទី ១ នៅក្នុងខែ មីនា ឆ្នាំ ២០១២ ។

# មាតិកា

ទំព័រ

**ជំពូកទី ៤ នីតិកិច្ចសន្យា** ........ ១

**ផ្នែកទី ១ សេចក្ដីផ្ដើម** ........ ១

១. តើអ្វីទៅជា "សិទ្ធិទាមទារ" និង "កាតព្វកិច្ច"? ........ ១

១.១ និយមន័យនៃកាតព្វកិច្ច ........ ១

១.២ ភាពខុសគ្នារវាងកាតព្វកិច្ច និង សិទ្ធិប្រត្យក្ស ........ ១

១.៣ ទិដ្ឋភាពទូទៅនៃសិទ្ធិលើបំណុល និង កាតព្វកិច្ច ........ ១

២. ប្រភពនៃកាតព្វកិច្ច ........ ២

២.១ កាតព្វកិច្ចដែលកើតឡើងដោយឆន្ទៈរបស់ភាគី ........ ២

២.២ កាតព្វកិច្ចដែលកំណត់ដោយច្បាប់ ........ ២

៣. កម្មវត្ថុនៃកាតព្វកិច្ច ........ ៣

៣.១ កម្មវត្ថុនៃកាតព្វកិច្ច ដែលមានជាញឹកញាប់ គឺជាការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់លើវត្ថុ ឬ ប្រាក់ ........ ៣

៣.២ ធ្វើសកម្មភាពជាក់លាក់ណាមួយ ........ ៣

៣.៣ មិនអោយធ្វើសកម្មភាពជាក់លាក់ណាមួយ ........ ៣

៤. ប្រភេទនៃកាតព្វកិច្ច ........ ៣

៤.១ កាតព្វកិច្ចមានគោលបំណងឱ្យធ្វើសកម្មភាព / កាតព្វកិច្ចមានគោលបំណងមិនឱ្យធ្វើសកម្ម ........ ៤

៤.២ កាតព្វកិច្ចប្រគល់ / កាតព្វកិច្ចធ្វើសកម្មភាព ........ ៤

៤.៣ កាតព្វកិច្ចជាប្រាក់ / កាតព្វកិច្ចមិនមែនជាប្រាក់ ........ ៤

៤.៤ កាតព្វកិច្ចប្រគល់វត្ថុដែលបានកំណត់ជាក់លាក់ / កាតព្វកិច្ចដែលបានកំណត់ប្រភេទនៃវត្ថុ ........ ៤

៤.៥ ទំនាក់ទំនងរវាងកាតព្វកិច្ច និង ការអនុវត្តដោយបង្ខំ ........ ៥

**ផ្នែកទី ២ វិធានទូទៅនៃកិច្ចសន្យា** ........ **៦**

១. គោលគំនិតនៃកិច្ចសន្យា ........ ៦

២. ចំណាត់ថ្នាក់នៃកិច្ចសន្យា ........ ៦

២.១ កិច្ចសន្យាដែលយកតំលៃថ្នូរ / កិច្ចសន្យាដែលមិនយកតំលៃថ្នូរ ........ ៦

២.២ កិច្ចសន្យាទ្វេភាគី / កិច្ចសន្យាឯកតោភាគី ........ ៦

២.៣ កិច្ចសន្យាមានឈ្មោះ / កិច្ចសន្យាគ្មានឈ្មោះ ........ ៧

២.៤ កិច្ចសន្យាត្រឹមការព្រមព្រៀង / កិច្ចសន្យាអាស្រ័យលើការប្រគល់វត្ថុ / កិច្ចសន្យាជាលក្ខណៈទម្រង់ ........ ៧
២.៥ កិច្ចសន្យាអនុវត្តម្តង / កិច្ចសន្យាអនុវត្តបន្តបន្ទាប់ ........ ៧
២.៦ ចំណាត់ថ្នាក់នៃកិច្ចសន្យាមានឈ្មោះ ........ ៨
២.៧ លក្ខណៈនៃកិច្ចសន្យាមានឈ្មោះ ........ ៨
៣. លក្ខខណ្ឌដើម្បីបង្កើតអានុភាពនៃកិច្ចសន្យា ........ ៨
៣.១ លក្ខខណ្ឌទូទៅទាក់ទងនឹងភាគី ........ ៨
៣.២ លក្ខខណ្ឌទូទៅទាក់ទងនឹងខ្លឹមសារ ........ ៩
**ផ្នែកទី ៣ ការបង្កើតកិច្ចសន្យា** ........ ១១
១. គោលការណ៍នៃការបង្កើតកិច្ចសន្យា ........ ១១
១.១ តើ "សំណើ" គឺជាអ្វី ? ........ ១១
១.២ តើ "ស្វីការ" គឺជាអ្វី ? ........ ១១
១.៣ សំណើមាន ឬ គ្មានកំណត់អំឡុងពេលសម្រាប់ស្វីការ ........ ១២
២. ករណីលើកលែង : ការជូញដូរអចលនវត្ថុ ........ ១៣
**ផ្នែកទី ៤ អានុភាពនៃកិច្ចសន្យាទ្វេភាគី** ........ ១៤
១. លក្ខណៈទៅវិញទៅមកក្នុងការបង្កើតកិច្ចសន្យាទ្វេភាគី : អលទ្ធភាពតាំងពីដំបូង ........ ១៤
២. លក្ខណៈ "ទៅវិញទៅមក" នៅក្នុងការអនុវត្តកិច្ចសន្យាទ្វេភាគី ........ ១៥
២.១ ការតវ៉ាអោយអនុវត្តព្រមគ្នា ........ ១៥
២.២ ការតវ៉ាដោយមានការបារម្ភ ........ ១៩
៣. លក្ខណៈទៅវិញទៅមក នៅក្នុងអត្ថិភាពដែលត្រូវបានបន្ត ........ ២១
៣.១ គោលគំនិតនៃការទទួលបន្ទុកហានិភ័យ ........ ២១
***សេចក្តីពន្យល់ទី១ : វត្ថុដែលបានកំណត់ជាក់លាក់ និង វត្ថុដែលមិនបានកំណត់ជាក់លាក់** ........ ២៤
៣.២ គោលការណ៍ទូទៅនៃការទទួលបន្ទុកហានិភ័យ ........ ២៥
៣.៣. ករណីលើកលែង ........ ៣២
**ផ្នែកទី ៥ ការរំលាយកិច្ចសន្យា** ........ ៣៦
១. ប្រភពនៃសិទ្ធិរំលាយកិច្ចសន្យា ........ ៣៦
១.១ សិទ្ធិរំលាយកិច្ចសន្យា ដែលបានកំណត់នៅក្នុងច្បាប់ ........ ៣៦
១.២ សិទ្ធិរំលាយកិច្ចសន្យា ដែលបានកំណត់នៅក្នុងកិច្ចសន្យា ........ ៣៦

១.៣ សិទ្ធិរំលាយកិច្ចសន្យា ដោយផ្អែកទៅលើបញ្ញត្តិពិសេស ........ ៣៦
២. ប្រព័ន្ធប្រហាក់ប្រហែលទៅនឹងការរំលាយកិច្ចសន្យា ........ ៣៧
២.១ ការរំលាយកិច្ចសន្យាដោយការព្រមព្រៀង ........ ៣៧
២.២ ការលុបចោលកិច្ចសន្យា ........ ៣៧
៣.លក្ខខណ្ឌនៃការរំលាយកិច្ចសន្យា ........ ៣៨
៣.១ ការរំលាយកិច្ចសន្យាដោយមូលហេតុការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ........ ៣៨
៣.២ ការរំលាយកិច្ចសន្យា ដោយសារការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ក្នុងករណីដែលពេលវេលាគឺជាចំណុចសំខាន់ ........ ៤១
៣.៣. ការរំលាយកិច្ចសន្យាដោយមូលហេតុអលទ្ធភាពនៃការអនុវត្តកាតព្វកិច្ច ........ ៤២
៣.៤ ការរំលាយកិច្ចសន្យាដោយមូលហេតុបាត់បង់ជំនឿចិត្តរវាងគូភាគី ........ ៤៣
៤. វិធីអនុវត្តសិទ្ធិរំលាយកិច្ចសន្យា ........ ៤៣
៥. អានុភាពនៃការរំលាយកិច្ចសន្យា ........ ៤៤
៥.១ ទ្រឹស្តីនៃអានុភាពនៃការរំលាយកិច្ចសន្យា ........ ៤៤
៥.២ ការរលត់នូវទំនាក់ទំនងក្នុងកិច្ចសន្យា ........ ៤៧
៥.៣ កាតព្វកិច្ចក្នុងការធ្វើបដិទានទៅស្ថានភាពដើម ........ ៤៨
៥.៤ ករណីយកិច្ចសងការខូចខាត ........ ៥០
៦. ការរលត់នូវសិទ្ធិរំលាយកិច្ចសន្យា ........ ៥៣
៦.១ នៅក្នុងករណីដែលការខូចខាត ជាអាទិ៍ នៃកម្មវត្ថុនៃកិច្ចសន្យា កើតឡើងដោយចេតនា ........ ៥៣
៦.២ ការរលត់ដោយសារអាជ្ញាយុកាល ........ ៥៣
៦.៣ ការរលត់ដោយសារការអនុវត្តកាតព្វកិច្ច ឬ ដោយសារសំណើរផ្តល់ការអនុវត្តកាតព្វកិច្ច ........ ៥៤
៧. ការរំលាយកិច្ចសន្យា និង តតិយជន ........ ៥៤
**ផ្នែកទី ៦ កិច្ចសន្យាលក់ទិញ ........ ៦០**
១. គោលគំនិត ........ ៦០
២. លក្ខខណ្ឌ ........ ៦០
៣. ករណីយកិច្ច និង សិទ្ធិរបស់អ្នកលក់ ........ ៦១
៣.១ ករណីយកិច្ចទូទៅរបស់អ្នកលក់ ........ ៦២
៣.២ ករណីយកិច្ចត្រូវពន្យល់ ........ ៦៤
៣.៣ ករណីយកិច្ចផ្ទេរសិទ្ធិ ........ ៦៤
៤. ការទទួលខុសត្រូវក្នុងការធានា ........ ៦៥

៤.១ ទិដ្ឋភាពទូទៅនៃការទទួលខុសត្រូវក្នុងការធានា........................................................... ៦៥

៤.២ ការទទួលខុសត្រូវក្នុងការធានារបស់អ្នកលក់ ក្នុងករណីដែលសិទ្ធិដែលត្រូវបានលក់ជាសិទ្ធិរបស់អ្នកដទៃ........................................................................................................................... ៦៥

៤.៣ ការទទួលខុសត្រូវក្នុងការធានាចំពោះវិការៈ.................................................................. ៦៧

៤.៤ ក្នុងករណីដែលសិទ្ធិដែលត្រូវបានលក់ ត្រូវបានកំរិតដោយច្បាប់ ........................................... ៧២

៥. ករណីយកិច្ច និង សិទ្ធិរបស់អ្នកទិញ.................................................................................. ៧៧

៥.១ ករណីយកិច្ចទូទៅរបស់អ្នកទិញ.................................................................................... ៧៧

៥.២ សិទ្ធិទូទៅរបស់អ្នកទិញ............................................................................................... ៧៩

៥.៣ សិទ្ធិបដិសេធមិនបង់ថ្លៃទិញ........................................................................................ ៧៩

**ផ្នែកទី ៧ ប្រទានកម្ម**.......................................................................................................... **៨២**

១. គោលគំនិតនៃប្រទានកម្ម................................................................................................ ៨២

២. លក្ខខណ្ឌ.................................................................................................................... ៨២

៣. ករណីយកិច្ចរបស់ទាយក ................................................................................................ ៨៣

៣.១ កាតព្វកិច្ចផ្ទេរសិទ្ធិ ................................................................................................... ៨៣

៣.២ ការបន្ថយនូវការទទួលខុសត្រូវក្នុងការធានា.................................................................... ៨៣

៤. ការលុបចោលប្រទានកម្ម ................................................................................................ ៨៤

៤.១ នៅក្នុងករណីប្រទានកម្ម ដែលមិនធ្វើជាលាយល័ក្ខណ៍អក្សរ............................................... ៨៤

៤.២ នៅក្នុងករណីនៃការរំលោភលើសេចក្ដីទុកចិត្ត ជាអាទិ៍...................................................... ៨៥

៤.៣ នៅក្នុងករណីភាពទីទ័លក្ររបស់ទាយក........................................................................... ៨៥

៤.៤ អានុភាពនៃការលុបចោល ............................................................................................ ៨៦

៥. ប្រភេទពិសេសនៃប្រទានកម្ម............................................................................................ ៨៦

៥.១ ប្រទានកម្មដោយមានកំណត់ពេល .................................................................................. ៨៦

៥.២ ប្រទានកម្មដែលមានភ្ជាប់បន្ទុក...................................................................................... ៨៧

៥.៣ ប្រទានកម្មដោយមូលហេតុមរណភាពរបស់ទាយក................................................................ ៨៨

**ផ្នែកទី ៨ ភតិសន្យា** ........................................................................................................ **៩១**

១. គោលគំនិតនៃភតិសន្យា.................................................................................................. ៩១

១.១ និយមន័យ .................................................................................................................. ៩១

១.២ លក្ខខណ្ឌ.................................................................................................................... ៩១

១.៣ លក្ខខណ្ឌតតាំង ........................................................................................................... ៩១

១.៤ អំឡុងពេលជួល ............................................................ ៩២
២. សិទ្ធិ និង ករណីយកិច្ចរបស់ភតិបតី............................................ ៩២
២.១ ករណីយកិច្ចធ្វើអោយភតិកៈប្រើប្រាស់ និង អាស្រ័យផល ដោយផ្អែកវិធីប្រើប្រាស់ធម្មតា...... ៩២
២.២ ករណីយកិច្ចជួសជុល............................................................ ៩២
២.៣ ករណីយកិច្ចសងវិញនូវសោហ៊ុយចំណាយ............................................ ៩៣
២.៤ ការទទួលខុសត្រូវក្នុងការធានារបស់ភតិបតី........................................ ៩៥
៣. សិទ្ធិ និង ករណីយកិច្ចរបស់ភតិកៈ ................................................ ៩៧
៣.១ ករណីយកិច្ចបង់ថ្លៃឈ្នួល.......................................................... ៩៧
៣.២ សិទ្ធិ និង ករណីយកិច្ចនៃការប្រើប្រាស់ និង អាស្រ័យផល ផ្អែកតាមវិធីប្រើប្រាស់ .............. ៩៨
៣.៣ ករណីយកិច្ចរបស់ភតិកៈ នៅក្នុងការថែរក្សាវត្ថុជួល ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ ............................................................ ៩៨
៣.៤ សិទ្ធិទាមទារអោយសងវិញ នូវសោហ៊ុយរបស់ភតិកៈ........................................ ៩៩
៣.៥ សិទ្ធិទាមទារឱ្យបន្ថយថ្លៃឈ្នួល ឬ សិទ្ធិរំលាយភតិសន្យា ...................................... ៩៩
៣.៦. អនុប្បទានសិទ្ធិជួល និង ការជួលបន្តនូវវត្ថុជួល........................................ ១០០
៤. ការរំលាយភតិសន្យា ............................................................ ១០៣
៤.១ ប្រភពនៃការបញ្ចប់ភតិសន្យា.................................................... ១០៣
៤.២ ការបញ្ចប់ភតិសន្យា ដោយសារការផុតអំឡុងពេលកំណត់........................................ ១០៣
៤.៣ ការស្នើសុំអោយរំលាយភតិសន្យាដែលពុំមានកំណត់អំឡុងពេល.................................. ១០៥
៤.៤ ការបញ្ចប់ដោយសារបាត់បង់នូវវត្ថុជួល............................................ ១០៦
៤.៥ ការរំលាយភតិសន្យា ដោយសារការមិនអនុវត្តកាតព្វកិច្ច........................................ ១០៦
**ផ្នែកទី ៩ ការខ្ចីបរិភោគ ................................................................ ១០៨**
១. គោលបំណង............................................................ ១០៨
២. លក្ខខណ្ឌ............................................................ ១០៨
៣. កាតព្វកិច្ច និង សិទ្ធិរបស់អ្នកអោយខ្ចី ................................................ ១០៩
៣.១ កាតព្វកិច្ចអោយខ្ចីវត្ថុដែលជាកម្មវត្ថុ................................................ ១០៩
៣.២ ការទទួលខុសត្រូវក្នុងការធានារបស់អ្នកអោយខ្ចី........................................ ១០៩
៣.៣ ការទាមទារឱ្យសងមកវិញ នៅក្នុងករណីដែលស្ថានភាពសេដ្ឋកិច្ចរបស់អ្នកខ្ចី បានធ្លាក់ចុះយ៉ាងខ្លាំង............................................................ ១១១
៤. កាតព្វកិច្ចរបស់អ្នកខ្ចី ............................................................ ១១២

៤.១ករណីយកិច្ចត្រូវសងវត្ថុ ........................................................................ ១១២

៤.២ កាតព្វកិច្ចបង់ការប្រាក់ ........................................................................ ១១៥

៥. ការខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់ ........................................................ ១១៥

៥.១ គោលគំនិត ........................................................................ ១១៥

៥.២ អត្រាការប្រាក់ ........................................................................ ១១៦

៥.៣ ពេលវេលានៃការបង់ការប្រាក់ និង ការប្រាក់សមាសដែលកំណត់ដោយច្បាប់ ................ ១១៩

**ផ្នែកទី ១០ អាណត្តិ** ........................................................................ **១២១**

១. គោលគំនិត ........................................................................ ១២១

២. លក្ខខណ្ឌ ........................................................................ ១២២

៣. ទំនាក់ទំនងជាមួយនឹងការតំណាង ........................................................ ១២២

៤. កាតព្វកិច្ចរបស់អាណត្តិគាហក ........................................................ ១២៣

៤.១ ករណីយកិច្ចប្រុងប្រយ័ត្ន ........................................................ ១២៣

៤.២ ករណីយកិច្ចរាយការណ៍ ........................................................ ១២៤

៤.៣ កាតព្វកិច្ចប្រគល់ ........................................................ ១២៥

៤.៤ ការទទួលខុសត្រូវសងសំណងការខូចខាតដែលបានប្រើប្រាស់ ........................ ១២៥

៤.៥ ករណីយកិច្ចសង្គ្រោះបន្ទាន់នៅក្រោយពេលបញ្ចប់អាណត្តិ ........................ ១២៦

៥. កាតព្វកិច្ចរបស់អាណត្តិទាយក ........................................................ ១២៦

៥.១ ករណីយកិច្ចបង់កំរៃ ........................................................ ១២៦

៥.២ ករណីយកិច្ចបង់សោហ៊ុយជាមុន ........................................................ ១២៧

៥.៣ ករណីយកិច្ចសងវិញនូវសោហ៊ុយដែលបានចំណាយ ........................................ ១២៧

៥.៤ ករណីយកិច្ចសងសំណងនៃការខូចខាត ........................................................ ១២៨

៦. ការរំលាយកិច្ចសន្យាអាណត្តិ ........................................................ ១២៩

៦.១ មូលហេតុនៃការបញ្ចប់កិច្ចសន្យាអាណត្តិ ........................................ ១២៩

៦.២ អានុភាពនៃការរំលាយ ........................................................ ១៣០

**ផ្នែកទី ១១ កិច្ចសន្យាម៉ៅការ** ........................................................ **១៣១**

១. គោលគំនិត ........................................................................ ១៣១

២. លក្ខខណ្ឌក្នុងការបង្កើតកិច្ចសន្យាម៉ៅការ ........................................................ ១៣១

៣. កាតព្វកិច្ចរបស់អ្នកម៉ៅការ ........................................................ ១៣១

៣.១ ករណីយកិច្ចសម្រេចការងារដោយគ្មានវិការៈ ........................................ ១៣១

៣.២ ករណីយកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុនៃការងារ ........................................ ១៣៦
៤. កាតព្វកិច្ចរបស់ម្ចាស់ការ ........................................ ១៣៧
៤.១ ករណីយកិច្ចបង់កម្រៃ ........................................ ១៣៧
៤.២ ករណីយកិច្ចទទួលវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ........................................ ១៣៧
៥. ការបញ្ចប់កិច្ចសន្យាម៉ៅការ ........................................ ១៣៧
៥.១ សិទ្ធិរំលាយរបស់ម្ចាស់ការ នៅក្នុងពេលដែលការងារមិនទាន់បានសំរេច........................ ១៣៧
៥.២ ការរំលាយកិច្ចសន្យា ដោយផ្អែកលើការមិនអនុវត្តកាតព្វកិច្ច ........................................ ១៣៧

# ជំពូកទី ៤
# នីតិកិច្ចសន្យា
## ផ្នែកទី ១
## សេចក្តីផ្តើម

**១. តើអ្វីទៅជា "សិទ្ធិទាមទារ" និង "កាតព្វកិច្ច"?**

សិទ្ធិទាមទារ គឺជាសិទ្ធិដែលអាចទាមទារឱ្យកូនបំណុល ធ្វើសកម្មភាពកំណត់មួយ ។

កាតព្វកិច្ច គឺជាករណីយកិច្ច ដែលបុគ្គលម្នាក់មានចំពោះបុគ្គលម្នាក់ទៀត ។

**១.១ និយមន័យនៃកាតព្វកិច្ច**

កាតព្វកិច្ច គឺជាទំនាក់ទំនងគតិយុត្តិដែលចងបុគ្គលពីរនាក់ ដោយអោយបុគ្គលម្នាក់ ដែលបានកំណត់មាន ករណីយកិច្ចមួយចំនួន ចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀត ។

**១.២ ភាពខុសគ្នារវាងកាតព្វកិច្ច និង សិទ្ធិប្រត្យក្ស**

| | **សិទ្ធិប្រត្យក្ស** | **កាតព្វកិច្ច** |
|---|---|---|
| ខ្លឹមសារនៃសិទ្ធិ | គ្រប់គ្រងដោយផ្ទាល់ទៅលើវត្ថុ | ទាមទារនូវការអនុវត្តកាតព្វកិច្ច ចំពោះបុគ្គលម្នាក់ជាក់លាក់ |
| ភាពផ្តាច់មុខ | ប្រភេទសិទ្ធិប្រត្យក្សដែលមានខ្លឹមសារដូចគ្នាមិនអាចមានលើវត្ថុតែមួយនោះទេ | បុគ្គលតែមួយ អាចមានកាតព្វកិច្ចដូចគ្នាច្រើន |
| វិសាលភាពនៃបុគ្គលអាចទាមទារបាន | គ្រប់បុគ្គល | បុគ្គលដែលបានកំណត់ (កូនបំណុល) |
| លក្ខណៈនៃសិទ្ធិ | ដាច់ខាត | មិនដាច់ខាត |

**១.៣ ទិដ្ឋភាពទូទៅនៃសិទ្ធិលើបំណុល និង កាតព្វកិច្ច**

**សូមមើលឧបសម្ព័ន្ធ ១**

## ២. ប្រភពនៃកាតព្វកិច្ច

### ២.១ កាតព្វកិច្ចដែលកើតឡើងដោយឆន្ទៈរបស់ភាគី

វា គឺជាកាតព្វកិច្ច ដែលកើតឡើងដោយកិច្ចសន្យា និង ដោយសកម្មភាពឯកតោភាគី (មាត្រា ៣០៩ កថាខណ្ឌទី ២) ។

ក- កិច្ចសន្យា (មាត្រា ៣១១) : គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬ ច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬ រំលត់នូវកាតព្វកិច្ច ។

ខ- សកម្មភាពឯកតោភាគី (មាត្រា ៣១២) : គឺជាសកម្មភាពដែលបង្កើត កែប្រែ រឺ រំលត់នូវកាតព្វកិច្ច

១) ដោយបង្ហាញឆន្ទៈ នៃការចាត់ចែងទ្រព្យដោយភាគីម្ខាង

ឬ

២) ដោយអនុវត្តសិទ្ធិដែលបានទទួលតាម 1)កិច្ចសន្យា ឬ 2) បញ្ញត្តិនៃច្បាប់ ។

តាមរយៈសកម្មភាពឯកតោភាគី វា មិនចាំបាច់មានការយល់ព្រមពីភាគីម្ខាងទៀតទេ ។

ឧទាហរណ៍នៃចំណុច ១)

- ការលើកលែងកាតព្វកិច្ចមាត្រា ៤៧៣ : ក្នុងករណីដែលម្ចាស់បំណុល បង្ហាញឆន្ទៈលើកលែងកាតព្វកិច្ចចំពោះកូនបំណុល ដោយមិនមានការយល់ព្រមពីកូនបំណុល ក៏កាតព្វកិច្ចនោះ ត្រូវរលត់ដែរ ។
- អច្ច័យទានមាត្រា ១១៩៩ : ម្ចាស់បណ្តាំ អោយទ្រព្យសម្បត្តិ តាមរយៈមរតកសាសន៍ ដោយមិនចាំបាច់មានការយល់ព្រមរបស់អច្ច័យលាភី

ឧទាហរណ៍នៃចំណុច ២)

- 1) ការរំលាយ ដែលបានកំណត់ក្នុងកិច្ចសន្យា (មាត្រា ៤១៤ កថាខណ្ឌទី ១)
- 2) ការបង្ហាញឆន្ទៈទូទាត់ (មាត្រា ៤៦៥ កថាខណ្ឌទី ១)

### ២.២ កាតព្វកិច្ចដែលកំណត់ដោយច្បាប់

- ការគ្រប់គ្រងដោយឈឺឆ្អាល (មាត្រា ៧២៩ ដល់មាត្រា ៧៣៥)
- សេចក្តីចំរើនឥតហេតុ (មាត្រា ៧៣៦ ដល់មាត្រា ៧៤១)
- អំពើអនីត្យានុកូល (មាត្រា ៧៤២ ដល់មាត្រា ៧៦៥)
- បញ្ញត្តិផ្សេងៗ នៃច្បាប់ (ឧទាហរណ៍ កាតព្វកិច្ចបង់ពន្ធ)

## ៣. កម្មវត្ថុនៃកាតព្វកិច្ច

### ៣.១ កម្មវត្ថុនៃកាតព្វកិច្ច ដែលមានជាញឹកញាប់ គឺជាការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់លើវត្ថុ ឬ ប្រាក់

ឧទាហរណ៍ : **ក** បានលក់ម៉ូតូអោយ **ខ**

- **ក** មានកាតព្វកិច្ចផ្ទេរវត្ថុ ឬ កម្មសិទ្ធិនៃម៉ូតូ
- **ខ** មានកាតព្វកិច្ចប្រគល់ប្រាក់ថ្លៃម៉ូតូ

### ៣.២ ធ្វើសកម្មភាពជាក់លាក់ណាមួយ

នេះ គឺជាកាតព្វកិច្ចមានគោលបំណងអោយធ្វើសកម្មភាព។ ឧទាហរណ៍ ករណីកិច្ចរបស់អាណត្តិគាហក (មាត្រា ៦៤០)

### ៣.៣ មិនអោយធ្វើសកម្មភាពជាក់លាក់ណាមួយ

កាតព្វកិច្ច ដែលមានកម្មវត្ថុមិនអោយធ្វើសកម្មភាពណាមួយ ដែលត្រូវបានអោយឈ្មោះថា "កាតព្វកិច្ចមានគោលបំណងមិនឱ្យធ្វើសកមម្មភាព"។ ក្រមរដ្ឋប្បវេណី មិនមានចែងពីបញ្ញត្តិនេះទេ ប៉ុន្តែវា មានសុពលភាព ដោយផ្អែកទៅលើគោលការណ៍សេរីភាពក្នុងការបង្កើតកិច្ចសន្យា។

ឧទាហរណ៍ : កិច្ចសន្យារវាងអ្នកចម្រៀង និង ផលិតកម្មថតសំលេង ដោយហាមអ្នកចម្រៀង មិនអោយច្រៀងអោយផលិតកម្មផ្សេង។

## ៤. ប្រភេទនៃកាតព្វកិច្ច

- កាតព្វកិច្ចមានគោលបំណងឱ្យធ្វើសកម្មភាព
  - កាតព្វកិច្ចផ្ទេរ
    - កាតព្វកិច្ចជាប្រាក់
    - កាតព្វកិច្ចមិនមែនជាប្រាក់
      - កាតព្វកិច្ចប្រគល់វត្ថុដែលបានកំណត់
      - កាតព្វកិច្ចដែលបានកំណត់ប្រភេទនៃវត្ថុ
  - កាតព្វកិច្ចធ្វើសកម្មភាព
- កាតព្វកិច្ចមានគោលបំណងមិនឱ្យធ្វើសកម្មភាព

### ៩.១ កាតព្វកិច្ចមានគោលបំណងអោយធ្វើសកម្មភាព / កាតព្វកិច្ចមានគោលបំណងមិនអោយធ្វើសកម្មភាព

កាតព្វកិច្ចមានគោលបំណងអោយធ្វើសកម្មភាព គឺជាកាតព្វកិច្ចធ្វើសកម្មភាពជាកលាក់ណាមួយ ចំណែកឯ កាតព្វកិច្ចមានគោលបំណងមិនអោយសកម្មភាព គឺជាកាតព្វកិច្ចមិនធ្វើសកម្មភាពជាក់លាក់ណាមួយ ។

### ៩.២ កាតព្វកិច្ចប្រគល់ / កាតព្វកិច្ចធ្វើសកម្មភាព

កាតព្វកិច្ចមានគោលបំណងអោយធ្វើសកម្មភាព អាចត្រូវបានគេចែកចេញជាពីរ គឺកាតព្វកិច្ចប្រគល់ និង កាតព្វកិច្ចធ្វើសកម្មភាព។ កាតព្វកិច្ចប្រគល់ គឺជាកាតព្វកិច្ចក្នុងការប្រគល់អ្វីមួយ ដូចជា វត្ថុជាដើម ។ កាតព្វកិច្ចធ្វើសកម្មភាព គឺជាកាតព្វកិច្ច ដែលកម្មវត្ថុរបស់វា គឺ ការធ្វើសកម្មភាព ឬ ការបំពេញការងាររបស់កូនបំណុលនោះផ្ទាល់តែម្តង ។

### ៩.៣ កាតព្វកិច្ចជាប្រាក់ / កាតព្វកិច្ចមិនមែនជាប្រាក់

#### ៩.៣.១ កាតព្វកិច្ចជាប្រាក់

កាតព្វកិច្ចជាប្រាក់ គឺជាកាតព្វកិច្ចក្នុងការសងប្រាក់ ( មាត្រា ៣១៦) ។

នៅក្នុងករណីនៃកាតព្វកិច្ចជាប្រាក់ គេ មិនអាចលើកឡើងពីអលទ្ធភាពក្នុងការអនុវត្ត ដើម្បីជៀសវាងការអនុវត្តកាតព្វកិច្ចនោះទេ ដោយផ្អែកលើមាត្រា ៣៩៩-១ ។

#### ៩.៣.២ កាតព្វកិច្ចមិនមែនជាប្រាក់

វា គឺជាកាតព្វកិច្ចអោយប្រគល់វត្ថុ ដែលមិនមែនជាប្រាក់ ។

កាតព្វកិច្ចមិនមែនជាប្រាក់ ត្រូវបានគេចែកចេញជា កាតព្វកិច្ចប្រគល់វត្ថុដែលបានកំណត់ជាក់លាក់ និង កាតព្វកិច្ចដែលបានកំណត់ប្រភេទនៃវត្ថុ ។

### ៩.៤ កាតព្វកិច្ចប្រគល់វត្ថុដែលបានកំណត់ជាក់លាក់ / កាតព្វកិច្ចដែលបានកំណត់ប្រភេទនៃវត្ថុ

#### ៩.៤.១ កាតព្វកិច្ចប្រគល់វត្ថុដែលបានកំណត់ជាក់លាក់ ( មាត្រា ៣១៤)

វត្ថុដែលបានកំណត់ជាកំណត់ជាក់លាក់ សំដៅទៅលើវត្ថុ ដែលលក្ខណៈរបស់វា ត្រូវបានភាគីផ្តោតការយកចិត្តទៅលើ ។ ឧទាហរណ៍មួយនៃវត្ថុដែលបានកំណត់ជាក់លាក់ គឺ នាឡិកាដៃបុរាណ ។ ចំពោះកាតព្វកិច្ចប្រគល់វត្ថុដែលបានកំណត់ជាក់លាក់ កូនបំណុល មានករណីយកិច្ចថែរក្សាវត្ថុនោះ ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ រហូតដល់ពេលប្រគល់វត្ថុនោះ ។

### ៤.៤.២ កាតព្វកិច្ចដែលបានកំណត់ប្រភេទនៃវត្ថុ ( មាត្រា៣១៥)

វត្ថុកំណត់ដោយប្រភេទ មានន័យថា កម្មវត្ថុនៃការប្រគល់ ត្រូវបានកំណត់ដោយប្រភេទនៃវត្ថុ។ ការកំណត់ប្រភេទនៃវត្ថុ មានពីរគឺ :

- វត្ថុកំណត់មិនជាក់លាក់ ( មាត្រា ៣១៥ កថាខណ្ឌទី ១) : ក្នុងករណីដែលកម្មវត្ថុនៃកាតព្វកិច្ច ត្រូវបានកំណត់ដោយប្រភេទនៃវត្ថុ ប្រសិនបើកម្មវត្ថុ ដែលត្រូវបានផ្តល់ មានគុណភាពច្រើនយ៉ាង កូនបំណុល មានករណីយកិច្ចផ្តល់នូវវត្ថុដែលមានគុណភាពដូច ដែលគូភាគីបានកំណត់។ ក្នុងករណីគូភាគី មិនបានធ្វើការកំណត់គុណភាពទេ កូនបំណុល មានករណីយកិច្ចផ្តល់នូវវត្ថុ ដែលមានគុណភាពមធ្យម។
- វត្ថុដែលត្រូវបានកំណត់ជាក់លាក់ ( មាត្រា ៣១៥ កថាខណ្ឌទី ២) : ចំពោះកាតព្វកិច្ច ដែលបានកំណត់ប្រភេទ ក្រោយពេលដែលកូនបំណុល បានកំណត់កម្មវត្ថុ ដែលត្រូវផ្តល់ច្បាស់លាស់ និងដែលបានបញ្ចប់សកម្មភាពចាំបាច់ ដើម្បីផ្តល់នូវកម្មវត្ថុដែលបានកំណត់ហើយនោះ កូនបំណុល មានករណីយកិច្ចផ្តល់នូវវត្ថុនោះតែប៉ុណ្ណោះ។

### ៤.៥ ទំនាក់ទំនងរវាងកាតព្វកិច្ច និង ការអនុវត្តដោយបង្ខំ

វិធីនៃការអនុវត្តដោយបង្ខំ ចំពោះ កាតព្វកិច្ច គឺវា អាស្រ័យលើប្រភេទរបស់កាតព្វកិច្ចដូចជា:

*១. កាតព្វកិច្ចមានគោលបំណងអោយធ្វើសកម្មភាព*

ក. កាតព្វកិច្ចជាប្រាក់ : ការអនុវត្តដោយបង្ខំដែលមានកាតព្វកិច្ចឱ្យប្រគល់ជាប្រាក់ អាចត្រូវបានគេធ្វើឡើងតាមរយៈ ការលក់ឡៃឡុងអចលនវត្ថុ ឬ ចលនវត្ថុ។

ខ. កាតព្វកិច្ចមិនមែនជាប្រាក់ : ការអនុវត្តដោយបង្ខំ អាចត្រូវបានគេធ្វើឡើង តាមរយៈការអនុវត្តដោយផ្ទាល់។

គ. កាតព្វកិច្ចធ្វើសកម្មភាព : ការអនុវត្តដោយបង្ខំ អាចត្រូវបានគេធ្វើឡើង តាមរយៈការអនុវត្តដោយប្រយោល នៅក្នុងករណីទូទៅ។ ក៏ប៉ុន្តែ កាតព្វកិច្ចធ្វើសកម្មភាព មិនអាចអនុវត្តតាមរយៈការអនុវត្តដោយប្រយោល ឬ ការអនុវត្តដោយជំនួស នៅពេលដែលការអនុវត្តទាំងនេះ បំពានទៅលើគោលគំនិតនៃកាតព្វកិច្ច។

# ផ្នែកទី ២

# វិធានទូទៅនៃកិច្ចសន្យា

## ១. គោលគំនិតនៃកិច្ចសន្យា

**កិច្ចសន្យា** គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬ ច្រើននាក់ មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬ រំលត់នូវកាតព្វកិច្ច ( មាត្រា ៣១១) ។

## ២. ចំណាត់ថ្នាក់នៃកិច្ចសន្យា

### ២.១ កិច្ចសន្យាដែលយកតំលៃថ្នូរ / កិច្ចសន្យាដែលមិនយកតំលៃថ្នូរ

១. កិច្ចសន្យាដែលយកតំលៃថ្នូរ : ភាគីទាំងពីរ មានកាតព្វកិច្ចផ្ដល់នូវកម្រៃទៅវិញទៅមក ដែលមានតម្លៃស្មើគ្នា។ ឧទាហរណ៍ : កិច្ចសន្យាលក់ទិញ ភាគីអ្នកលក់ មានកាតព្វកិច្ចប្រគល់វត្ថុ រីឯអ្នកទិញ មានកាតព្វកិច្ចប្រគល់ប្រាក់ ។

២. កិច្ចសន្យាដែលមិនយកតំលៃថ្នូរ : កិច្ចសន្យានេះ មានន័យថា មានតែភាគីម្ខាង ផ្ដល់នូវកម្រៃ ចំណែកឯភាគីម្ខាងទៀត មិនមានកាតព្វកិច្ច ឬ មានបន្ទុកដែលមិនសមមូល ។ ឧទាហរណ៍ដ៏សាមញ្ញនៃកិច្ចសន្យានេះ គឺភាគច្រើនជាប្រទានកម្ម ។ ទាក់ទងនឹងកិច្ចសន្យាដែលមិនយកតំលៃថ្នូរ នៅក្នុងករណីនៃប្រទានកម្ម គឺវា មានលក្ខណៈបន្ធូរបន្ថយចំពោះកាតព្វកិច្ចរបស់ទាយក ។ វា មានន័យថា ជាគោលការណ៍ ទាយក មិនចាំបាច់ទទួលខុសត្រូវចំពោះវិការៈ ដែលបានកើតមានឡើងដោយសារកិច្ចសន្យានេះទេ ដោយផ្អែកទៅលើមាត្រា ៥៧៤ ។

### ២.២ កិច្ចសន្យាទ្វេភាគី / កិច្ចសន្យាឯកតោភាគី

១. កិច្ចសន្យាទ្វេរភាគី : ភាគីទាំងពីរមានកាតព្វកិច្ចអនុវត្តកិច្ចសន្យាដែលមានតម្លៃសមមូលគ្នា ។

២. កិច្ចសន្យាឯកតោភាគី : មានតែភាគីម្ខាង មានកាតព្វកិច្ច ចំណែកឯ ភាគីម្ខាង មិនមានកាតព្វកិច្ច ឬ គ្រាន់តែមានបន្ទុក តែមានតម្លៃមិនសមមូល ។ ប្រសិនបើ ភាគីម្ខាងទៀត មានបន្ទុក ប៉ុន្តែមានតម្លៃមិនសមមូល ក្រមរដ្ឋប្បវេណី បានចែងនូវមាត្រា ដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងកិច្ចសន្យាទ្វេភាគីដែរ ដូចជា ការទទួលខុសត្រូវក្នុងការធានារបស់អ្នកលក់ ការតវ៉ាអោយអនុវត្តព្រមគ្នា ការរំលាយកិច្ចសន្យា ( មាត្រា ៥៧៦ កថាខណ្ឌទី ២, ៣ និង ៥) ។

ឧទាហរណ៍ : **ក** បានធ្វើប្រទានកម្មថា នឹងប្រគល់ផ្ទះទៅអោយ **ខ** តែ **ខ** ត្រូវអោយកូនរបស់ **ក** រស់នៅលើផ្ទះនេះមួយផ្នែកដែរ ។ នៅក្នុងករណីនេះ **ខ** មានបន្ទុកក្នុងការអនុញ្ញាតអោយកូនរបស់ **ក** ប្រើប្រាស់ផ្នែកមួយនៃផ្ទះនោះ ប៉ុន្តែ វា មិនសមមូលទៅនឹងកាតព្វកិច្ចរបស់ **ក**។ ទន្ទឹមនឹងនេះ កិច្ចសន្យានេះ គឺជាកិច្ចសន្យាដែលមិនយកតម្លៃថ្នូរ ។

## ២.៣ កិច្ចសន្យាមានឈ្មោះ / កិច្ចសន្យាគ្មានឈ្មោះ

១. កិច្ចសន្យាមានឈ្មោះ : ជាកិច្ចសន្យានីមួយៗ ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ។

ឧទាហរណ៍ : កិច្ចសន្យាលក់ទិញ, កិច្ចសន្យាម៉ៅការ, កិច្ចសន្យាជួល ជាអាទិ៍ ។

២. កិច្ចសន្យាគ្មានឈ្មោះ : កិច្ចសន្យាប្រភេទនេះ មិនមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ។ កិច្ចសន្យាប្រភេទនេះ ត្រូវបានបង្កើតឡើង ដោយកិច្ចសន្យាជាច្រើនរួមបញ្ចូលគ្នាតែមួយ ដូចជាការរួមបញ្ចូលគ្នានៃកិច្ចសន្យាគ្មានឈ្មោះ និង កិច្ចសន្យាគ្មានឈ្មោះ ឬ កិច្ចសន្យាមានឈ្មោះ និង កិច្ចសន្យាគ្មានឈ្មោះ ។ ដូច្នេះ គេ មិនអាចកំណត់ច្បាស់ពីប្រភេទនៃកិច្ចសន្យានេះ ។ នៅពេលដែលធ្វើការបកស្រាយនូវកិច្ចសន្យាគ្មានឈ្មោះ វា មានលក្ខណៈសំខាន់ណាស់ក្នុងការធ្វើអោយមានភាពច្បាស់លាស់នូវអ្វី ដែលជាឆន្ទៈពិតប្រាកដរបស់ភាគី ។

ឧទាហរណ៍ : កិច្ចសន្យារវាងជាងកាត់សំលៀកបំពាក់ និង អតិថិជន ដែលបានចែងថា ជាងកាត់សំលៀកបំពាក់ ត្រូវផ្តល់នូវក្រណាត់ ។ យើង អាចឃើញថាកិច្ចសន្យានេះ មិនមានចែងពីប្រភេទនៃកិច្ចសន្យាច្បាស់ទេ ព្រោះកិច្ចសន្យានេះ កើតឡើងដោយកិច្ចសន្យាពីរបញ្ចូលគ្នាគឺ:

ក. កិច្ចសន្យាម៉ៅការ : ជាងកាត់សំលៀកបំពាក់ មានកាតព្វកិច្ចសំរេចការងាររបស់ខ្លួន និង ប្រគល់សំលៀកបំពាក់នោះ ចំណែកឯ អតិថិជន ត្រូវបង់ប្រាក់កម្រៃ ។

ខ. កិច្ចសន្យាលក់ទិញ : អតិថិជន ត្រូវបង់ប្រាក់កំរៃ ។

## ២.៤ កិច្ចសន្យាត្រឹមការព្រមព្រៀង / កិច្ចសន្យាអាស្រ័យលើការប្រគល់វត្ថុ / កិច្ចសន្យាជាលក្ខណៈទម្រង់

១. កិច្ចសន្យាត្រឹមការព្រមព្រៀង : តាមមាត្រា ៣៣៦ កថាខណ្ឌទី ១ ជាទូទៅ កិច្ចសន្យាមួយ មានសុពលភាព គឺនៅពេលសំណើត្រូវគ្នាជាមួយស្ទីការ ។

២. កិច្ចសន្យាអាស្រ័យលើការប្រគល់វត្ថុ : កិច្ចសន្យានេះ មានសុពលភាពនៅពេលប្រគល់វត្ថុ ។ ឧទារហណ៍ កិច្ចសន្យាខ្ចីប្រើ ( មាត្រា ៦២៦)

៣. កិច្ចសន្យាជាលក្ខណៈទម្រង់ : វា សំដៅទៅលើកិច្ចសន្យា ដែលមានសុពលភាព ដោយផ្អែកទៅលើទំរង់ជាក់លាក់ជាកំណត់ ។ ឧទាហរណ៍ : ការផ្ទេរលទ្ធកម្មលើកម្មសិទ្ធិ តាមរយៈកិច្ចសន្យា មានសុពលភាព លុះត្រាធ្វើជាលិខិតយថាភូត ( មាត្រា ៣៣៦ កថាខណ្ឌទី ២) ។

## ២.៥ កិច្ចសន្យាអនុវត្តម្តង / កិច្ចសន្យាអនុវត្តបន្តបន្ទាប់

១. កិច្ចសន្យាអនុវត្តម្តង គឺជាកិច្ចសន្យាដែលអនុវត្តតែម្តង គឺត្រូវបានបញ្ចប់តែម្តង។ ឧទាហរណ៍ កិច្ចសន្យាលក់ទិញ ត្រូវបានបញ្ចប់ ជាទូទៅនៅពេលដែលអ្នកលក់ ប្រគល់ទំនិញ រីឯអ្នកទិញ ប្រគល់ប្រាក់ ។

២. កិច្ចសន្យាអនុវត្តបន្តបន្ទាប់ គឺជាកិច្ចសន្យា ដែលការអនុវត្តកាតព្វកិច្ច ត្រូវបានធ្វើឡើងនៅក្នុងអំឡុងពេលវែង។ វា មានន័យថា យើងអាចពន្យាការអនុវត្តបាន។ ឧទាហរណ៍ កិច្ចសន្យាជួល, កិច្ចសន្យាអាណត្តិ គឺជាកិច្ចសន្យាអនុវត្តបន្តបន្ទាប់។

➢ ***ភាពខុសគ្នារវាងកិច្ចសន្យាអនុវត្តម្តង និងកិច្ចសន្យាអនុវត្តបន្តបន្ទាប់***

កិច្ចសន្យាអនុវត្តម្តងចប់ មានអានុភាពប្រតិសកម្ម នៅពេលរំលាយកិច្ចសន្យា (មាត្រា៤១១ កថាខណ្ឌទី១) ចំណែកឯកិច្ចសន្យាអនុវត្តបន្តបន្ទាប់ មិនមានអានុភាពប្រតិសកម្ម ជាចាំបាច់នោះទេ។ ឧទាហរណ៍ ការរំលាយភតិសន្យា ត្រូវមានអនុភាព ឆ្ពោះទៅអនាគតតែប៉ុណ្ណោះ (មាត្រា៦១៧)។

## ២.៦ ចំណាត់ថ្នាក់នៃកិច្ចសន្យាមានឈ្មោះ

១. កិច្ចសន្យាផ្ទេរសិទ្ធិលើវត្ថុ

ឧទាហរណ៍ ការលក់ទិញ ប្រទានកម្ម ការដូរ

២. កិច្ចសន្យាប្រើវត្ថុ

ឧទាហរណ៍ ការខ្ចីបរិភោគ ការជួល ការខ្ចីប្រើ

៣. កិច្ចសន្យាផ្តត់ផ្គង់សេវាកម្ម

ឧទាហរណ៍ អាណត្តិ កិច្ចសន្យាម៉ៅការ កិច្ចសន្យាការងារ

## ២.៧ លក្ខណៈនៃកិច្ចសន្យាមានឈ្មោះ

**សូមមើលឧបសម្ព័ន្ធ ២**

## ៣. លក្ខខណ្ឌដើម្បីបង្កើតអានុភាពនៃកិច្ចសន្យា

**សូមមើលឧបសម្ព័ន្ធ ៣**

## ៣.១ លក្ខខណ្ឌទូទៅទាក់ទងនឹងភាគី

១. មានសមត្ថភាពទទួលសិទ្ធិ

២. មានសមត្ថភាពខាងឆន្ទៈ

៣. មានសមត្ថភាពក្នុងការធ្វើសកម្មភាព

៤. គ្មានវិការៈក្នុងការបង្ហាញឆន្ទៈ

## ៣.២ លក្ខខណ្ឌទូទៅទាក់ទងនឹងខ្លឹមសារ

ចំពោះលក្ខខណ្ឌទូទៅទាក់ទងនឹងខ្លឹមសារ មាន៤ គឺ :

### ១. ភាពច្បាស់លាស់

ប្រសិនបើកិច្ចសន្យា មានភាពមិនច្បាស់លាស់ វា នឹងនាំអោយមោឃៈ ព្រោះ ខ្លឹមសារនៃកាតព្វកិច្ចក្នុងកិច្ចសន្យា មិនអាចយកទៅអនុវត្តបានតាមរយៈតុលាការ ។

ឧទាហរណ៍ លោក ក បានសន្យាថា បើ ខ អាយុ ១៨ ឆ្នាំ លោក ក នឹងឱ្យអ្វី១ដែលល្អដល់ ខ ។ ចំពោះខ្លឹមសារនៃការសន្យាបែបនេះ តុលាការ មិនអាចចេញសាលក្រម ឬ មិនអាចអនុវត្តកាតព្វកិច្ចដោយបង្ខំបានទេ ដោយហេតុថា ខ្លឹមសារនៃកិច្ចសន្យា មានភាពមិនច្បាស់លាស់ ។ ក៏ប៉ុន្តែ វា មិនមានភាពចាំបាច់ ក្នុងការសំរេចថារាល់ខ្លឹមសារទាំងអស់នៅក្នុងកិច្ចសន្យា ត្រូវតែមានភាពច្បាស់លាស់នោះទេ។ វា គឺមានលក្ខណៈគ្រប់គ្រាន់ដែលបង្ហាញពីភាពច្បាស់លាស់ ប្រសិនបើផ្នែកសំខាន់នៃកិច្ចសន្យា អាចត្រូវបានបង្ហាញអោយឃើញច្បាស់តាមរយៈការបកស្រាយ ។

ឧទាហរណ៍ កិច្ចសន្យាលក់ទិញរវាង ក និង ខ មិនបានកំណត់ថ្លៃ។ កិច្ចសន្យានេះ មិនត្រូវបានចាត់ទុកជាមោឃៈ ជាចាំបាច់នោះទេ ប្រសិនបើ ពួកគាត់ បានព្រមព្រៀងគ្នាពីវិធីកំណត់ថ្លៃទិញ នៅពេលអនាគត (មាត្រា ៥២១) ។ ឬនិយាយម្យ៉ាងទៀត ភាគីអាចកំណត់ប្រាក់ថ្លៃទិញ នៅពេលអនុវត្តកិច្ចសន្យាក៏បាន មិនចាំបាច់នៅពេលបង្កើតកិច្ចសន្យាទេ ។ ប្រសិនបើ មានការព្រមព្រៀងអំពីវិធីកំណត់ថ្លៃទិញ ប៉ុន្តែ ភាគី មិនអាចមានការឯកភាពលើតម្លៃលក់ទិញ នោះ ភាគី អាចប្តឹងទៅតុលាការ។ តុលាការ ត្រូវសម្រេចពីប្រាក់ថ្លៃទិញបាន ដោយធ្វើការពិចារណាទៅលើឆន្ទៈពិតប្រាកដរបស់ភាគី តម្លៃនៅលើទីផ្សារ និង ទំនៀមទំលាប់នៃកិច្ចការជំនួញ ជាអាទិ៍។

### ២. ភាពស្របច្បាប់

ប្រសិនបើខ្លឹមសារនៃកិច្ចសន្យា ផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយ នោះ វា ត្រូវបានចាត់ទុកជាមោឃៈ (មាត្រា ៣៥៤ កថាខណ្ឌទី ១ ចំណុច ក) ។ បញ្ញត្តិដែលអនុវត្តដោយបង្ខំ គឺសំដៅទៅលើបញ្ញត្តិ ដែលបដិសេធរាល់អានុភាពនៃសកម្មភាពគតិយុត្តិ ដែលបានធ្វើឡើងផ្ទុយនឹងបញ្ញត្តិនេះ។ ឧទាហរណ៍ នៅក្នុងករណីដែលគូភាគី បានព្រមព្រៀងគ្នាថា "ភាគីម្ខាង មិនអាចលុបចោលកិច្ចសន្យាបានទេ ទោះបីជាគាត់ បានបង្ហាញឆន្ទៈ ដោយសារការគំរាមកំហែងក៏ដោយ" ការព្រមព្រៀងបែបនេះ ត្រូវបានចាត់ទុកជា មោឃៈ ព្រោះ វា ផ្ទុយនឹងបញ្ញត្តិ ដែលអនុវត្តដោយបង្ខំ។

### ៣. ភាពសមស្របតាមស្ថានភាពសង្គម

លក្ខខណ្ឌនេះមានចែងនៅក្នុង មាត្រា ៣៥៤ កថាខណ្ឌ ទី ១ ចំណុច ខ នៃក្រមរដ្ឋប្បវេណី ។ វា មានន័យថា ទោះបីជាគូភាគី បង្ហាញឆន្ទៈដោយគ្មានវិការៈក៏ដោយ ក៏កិច្ចសន្យា ត្រូវបានចាត់ទុកជាមោឃៈដែរ ប្រសិនបើខ្លឹមសារនៃកិច្ចសន្យា ផ្ទុយពីស្ថានភាពសង្គម ទំនៀមទម្លាប់ល្អ។

### ៤. គ្មានការបង្ហាញឆន្ទៈមិនពិត

ឧទាហរណ៍ លោក ក លក់ដីទៅលោក ខ ដោយឃុបឃិតគ្នា នៅក្នុងគោលបំណងបញ្ចៀសនូវការរឹបអូសពីម្ចាស់បំណុល។ បន្ទាប់មក ក បានផ្ទេរការចុះបញ្ជីនៃដីទៅអោយ ខ។ នេះ គឺជាការបង្ហាញឆន្ទៈមិនពិត។ នៅក្នុងករណីនៃការបង្ហាញឆន្ទៈមិនពិត កិច្ចសន្យារវាង ក និង ខ ត្រូវបានចាត់ទុកជាមោឃៈ (មាត្រា ៣៥៣) ។

ចំពោះលក្ខខណ្ឌទាំងបួននេះ លក្ខខណ្ឌចាប់ពីលេខរៀង ២ ដល់ ៤ គឺជាលក្ខខណ្ឌសំខាន់ ព្រោះមានចែងច្បាស់លាស់នៅក្នុងក្រមរដ្ឋប្បវេណី រីឯ លក្ខខណ្ឌទី១ មិនមានសរសេរនៅក្នុងច្បាប់ទេ។ ក៏ប៉ុន្តែ ភាពច្បាស់លាស់នៅក្នុងកិច្ចសន្យា គឺត្រូវបានទទួលស្គាល់ទៅតាមលក្ខណៈនៃកាតព្វកិច្ច។

# ផ្នែកទី ៣

# ការបង្កើតកិច្ចសន្យា

## ១. គោលការណ៍នៃការបង្កើតកិច្ចសន្យា

យោងតាមមាត្រា ៣៣៦ កថាខណ្ឌទី ១ កិច្ចសន្យា មានអានុភាពដោយសារសំណើ និង ស្វីការត្រូវគ្នា។ ទន្ទឹមនឹងនេះ កិច្ចសន្យា ត្រូវបានបង្កើតឡើងនៅពេលដែលដំណឹងអំពីស្វីការ បានមកដល់អ្នកស្នើ (មាត្រា ៣៤០)។

### ១.១ តើ "សំណើ" គឺជាអ្វី ?

សំណើ គឺជាការសុំបង្កើតកិច្ចសន្យា ដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួន ជាមួយនឹងចំណងគតិយុត្ត ក្នុងករណីដែលមានស្វីការរបស់ភាគីម្ខាងទៀត ចំពោះសំណើនេះ (មាត្រា ៣៣៧ កថាខណ្ឌទី ១)។

សំណើ ត្រូវមានអានុភាព នៅពេលដែលសំណើនោះ បានដល់ភាគីម្ខាងទៀត (មាត្រា ៣៣៧ កថាខណ្ឌទី ២)។

ពាក្យថា "បានដល់" មានន័យថា ឧទាហរណ៍ដូចជា វា មិនមានភាពចាំបាច់ដែលអ្នកទទួលសំណើ បានទទួល ឬ បានបើកអានសំណើនោះទេ គឺឱ្យតែបានទៅដល់។ ឧទាហរណ៍ អ្នករស់នៅជាមួយនឹងអ្នកទទួលសំណើ បានទទួល ឬ សំណើ បានទៅដល់ប្រអប់សំបុត្រនៃផ្ទះអ្នកទទួលសំណើ (ភាគីម្ខាងទៀត)។

### ១.២ តើ "ស្វីការ" គឺជាអ្វី ?

ស្វីការ គឺជាការបង្ហាញឆន្ទៈ ដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ (មាត្រា ៣៣៧ កថាខណ្ឌទី ៣)។

> ករណីសិក្សា
>
> **ក** បានចុះកិច្ចសន្យាជាមួយនឹង **ខ** ក្នុងការលក់នូវនាឡិកាដៃបុរាណរបស់ **ក**។ តើនៅពេលណាមួយខាងក្រោមនេះ ចាប់ពី ១ ដល់ ៥ ដែលកិច្ចសន្យា ត្រូវបានបង្កើតឡើង ?
>
> ១) **ក** បានផ្ញើសំបុត្រ នៅថ្ងៃទី ១ ខែ សីហា ដើម្បីផ្តល់សំណើលក់នាឡិកាដៃ ក្នុងតំលៃ ១០០០ ដុល្លា
>
> ២) **ខ** បានទទួលសំបុត្ររបស់ **ក** ហើយ បានអាននៅថ្ងៃទី ៣ ខែ សីហា
>
> ៣) នៅថ្ងៃទី ៤ ខែ សីហា **ខ** បានទូរស័ព្ទទៅ **ក** និង បាននិយាយប្រាប់ **ក** ថា គាត់ នឹងប្រគល់ប្រាក់នៅ ផ្ទះរបស់ **ក** ដើម្បីទិញនាឡិកាដៃនោះ ក្នុងតំលៃ ១០០០ ដុល្លា។

(៤) ខ បានមកដល់ផ្ទះរបស់ ក និង បានបង់ប្រាក់ចំនួន ១០០០ ដុល្លា នៅថ្ងៃទី ៥ ខែ សីហា។ ក៏ប៉ុន្តែ នាឡិកាដៃនោះ ខូច ដូច្នេះ ខ បានស្នើសុំអោយ ក ធ្វើការជួសជុល និង យកទៅប្រគល់អោយនៅផ្ទះរបស់ ខ។ ក ក៏បានយល់ព្រម។

(៥) ក បានប្រគល់នាឡិកាដៃ នៅផ្ទះរបស់ ខ នៅថ្ងៃទី ៨ ខែ សីហា។

【សេចក្តីសន្និដ្ឋាន និង មូលហេតុសំអាង】

កិច្ចសន្យានេះ ត្រូវបានបង្កើតឡើងនៅក្នុង ចំណុចលេខ ៣។

កិច្ចសន្យា មានអានុភាពដោយសារសំណើ និង ស្វីកាត្រូវគ្នា (មាត្រា ៣៣៦ កថាខណ្ឌទី ១) ហើយ សំណើ ត្រូវមានអានុភាព នៅពេលដែលសំណើនោះ បានដល់ភាគីម្ខាងទៀត (មាត្រា ៣៣៧ កថាខណ្ឌទី ២)។ ដូច្នេះ សំណើរបស់ ក មានអានុភាពនៅថ្ងៃទី ៣ ខែ សីហា។ បន្ទាប់មក ខ បានទូរស័ព្ទទៅ ក ហើយ បានប្រាប់ថា ខ យល់ព្រមទៅនឹងសំណើរបស់ ក។ ឬនិយាយម្យ៉ាងទៀត ស្វីការរបស់ ខ បានដល់ ក ភ្លាម ។ នោះដែរ។ នៅពេលនោះ កិច្ចសន្យារវាង ក និង ខ ត្រូវបានមានអានុភាព។

## ១.៣ សំណើមាន ឬ គ្មានកំណត់អំឡុងពេលសម្រាប់ស្វីការ

សំណើ អាចជាសំណើដែលមាន ឬ គ្មាន កំណត់អំឡុងពេលសម្រាប់ស្វីការ ។

### ១.៣.១ សំណើមានការកំណត់អំឡុងពេលសម្រាប់ស្វីការ

តាមមាត្រា ៣៣៨ នៃក្រមរដ្ឋប្បវេណី សំណើ អាចភ្ជាប់ជាមួយនឹងរយៈពេលសម្រាប់ស្វីការ។ ប្រសិនបើ វា មិនមានភាពច្បាស់លាស់ ថាតើអ្នកស្នើ បាន កំណត់ថ្ងៃណាមួយនោះទេ នោះ វា ត្រូវគិតចាប់ ពីថ្ងៃដែលសំណើ ត្រូវបានផ្ញើចេញ។ សំណើនេះ ត្រូវបានធ្វើឡើង ដើម្បីជាប្រយោជន៍របស់អ្នកស្នើខ្លួនឯងផ្ទាល់ ព្រោះ អ្នកស្នើ អាច ធ្វើសំណើនេះ ទៅបុគ្គលផ្សេងទៀតបាន ប្រសិន បើគាត់ មិនបានទទួលស្វីការ នៅក្នុងអំឡុងពេលនោះ។ អ្នកស្នើ មិនចាំបាច់ដកសំណើរបស់ខ្លួននៅ ក្រោយអំឡុង ពេលសម្រាប់ស្វីការនោះទេ។ ការកំណត់អំឡុងពេលនេះ គឺដើម្បី បញ្ជាក់អំពីឆន្ទៈរបស់អ្នកស្នើក្នុងការរង់ចាំអំឡុង ពេលសម្រាប់ស្វីការ ហើយ ប្រសិនបើ អ្នកស្នើ អាចដកសំណើ នោះ នៅពេលដែលគាត់ ចង់ នោះ អ្នកទទួលសំណើ អាចទទួលរងនូវការខូចខាតដែលមិនអាចរំពឹងទុកជាមុនបាន។ ដូច្នេះ កថាខណ្ឌទី ២ នៃ មាត្រា ៣៣៨ មិនអនុញ្ញាតអោយដកសំណើវិញបាន ។ ប្រសិនបើ មិនមានការឆ្លើយតប ទៅនឹងសំណើនោះ ឬក៏ អ្នកធ្វើស្វីការ បដិសេធទៅនឹងសំណើ នៅក្នុងអំឡុងពេលនោះ សំណើនោះ នឹងបាត់បង់ អានុភាព (មាត្រា ៣៣៨ កថាខណ្ឌទី ៣)។

### ១.៣.២ សំណើដែលគ្មានកំណត់អំឡុងពេលសំរាប់ស្ទីការ

ប្រសិនបើភាគី កំពុងនិយាយចចារគ្នា ឧទាហរណ៍ដូចជា ភាគី កំពុងនិយាយទល់មុខគ្នា ឬ និយាយតាមទូរស័ព្ទ ហើយបើភាគីដែលទទួលសំណើ មិនបានឆ្លើយតបដោយភ្លាមៗ ហើយ មិនផ្តល់ស្ទីការទេ ( មាត្រា ៣៣៩ កថាខណ្ឌទី ១) សំណើនោះ នឹងបាត់បង់អនុភាព។

ឧទាហរណ៍ **ក** បានផ្តល់សំណើលក់ប៊ិចធម្មតា ទៅអោយ **ខ** នៅពេលដែលកំពុងនិយាយគ្នា។ ប្រសិនបើ **ខ** មិនបានឆ្លើយតបភ្លាមៗ នោះទេ សំណើនោះ នឹងបាត់បង់អានុភាព។

ចំពោះសំណើ ដែលភាគីមិនកំពុងនិយាយគ្នា អ្នកស្នើ មិនអាចដកសំណើរបស់ខ្លួនបានទេ ក្នុងអំឡុងពេលមួយដែលសមរម្យ ( មាត្រា ៣៣៩ កថាខណ្ឌទី ២)។ អ្នកស្នើ អាចដកសំណើរបស់ខ្លួនបាន តែពេលដែលការជូនដំណឹងអំពីការដកសំណើ បានដល់ភាគីម្ខាងទៀត មុនពេលភាគីម្ខាងទៀត ជូនដំណឹងអំពីស្ទីការទៅអ្នកស្នើ ( មាត្រា ៣៣៩ កថាខណ្ឌទី ៣)។

❊ **អំឡុងពេលសមរម្យ** : ជាការបកស្រាយផ្អែកតាមស្ថានភាពជាក់ស្តែង ខ្លឹមសារនៃកិច្ចសន្យា និង ទំហំនៃវត្ថុជាដើម ។

**ឧទាហរណ៍ ១ :** **ក** ផ្ញើសំណើលក់ប៊ិចរបស់ខ្លួនធ្វើអំពីមាសតាមសំបុត្រ ហើយ **ខ** មិនបានឆ្លើយតបទេ។ ប៉ុន្តែ **ក** មិនអាចដកសំណើបានទេ គឺត្រូវទុកពេលឱ្យ **ខ** គិតក្នុងពេលមួយសមរម្យ។

## ២. ករណីលើកលែង : ការផ្ទេរអចលនវត្ថុ

កិច្ចសន្យា មានអានុភាពដោយសារសំណើ និង ស្ទីការ ត្រូវគ្នា ( មាត្រា ៣៣៦ កថាខណ្ឌទី ១)។ នេះ គឺជាគោលការណ៍ទូទៅ ។ ប៉ុន្តែទោះបីជា មានបញ្ញត្តិនៃកថាខណ្ឌទី ១ ក្នុងមាត្រា ៣៣៦ នេះក៏ដោយ ក៏កិច្ចសន្យាដែលភាគីម្ខាង ទទួលករណីយកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិ ឬ ករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ នឹងមានអនុភាព លុះត្រាតែ បានធ្វើលិខិតយថាភូត ( មាត្រា ៣៣៦ កថាខណ្ឌទី ២)។

មូលហេតុដែល ក្រមរដ្ឋប្បវេណី ចែងថា លិខិតយថាភូត តំរូវអោយមានក្នុងការធ្វើអនុប្បទានលទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុ គឺមានដូចខាងក្រោម :

១.ការពារចំពោះអ្នកដែលមានការយល់ដឹងតិចតួចចំពោះការផ្ទេរ

២. ការពារចំពោះអ្នកទិញ ឬ អ្នកដែលមានការយល់ដឹងតិចតួច

៣. មធ្យោបាយបង្ហាញភស្តុតាងសម្រាប់បញ្ជាក់ពីអត្ថិភាព និង ខ្លឹមសារនៃកិច្ចសន្យា

# ផ្នែកទី ៤

# អានុភាពនៃកិច្ចសន្យាទ្វេភាគី

**កិច្ចសន្យាទ្វេភាគី** គឺជាកិច្ចសន្យាមួយ ដែលគូភាគី ត្រូវមានកាតព្វកិច្ចបំពេញឱ្យគ្នាទៅវិញទៅមក ។ ដូច្នេះ ភាគីនៃកិច្ចសន្យា គឺមានលក្ខណៈជិតស្និត ដោយសារតែមូលហេតុនេះ ទើបគេថា កិច្ចសន្យានេះ មានលក្ខណៈទៅវិញទៅមក។

**❋ លក្ខណៈទៅវិញទៅមកនៃកិច្ចសន្យាទ្វេភាគី មាន ០៣ គឺ :**

១. លក្ខណៈទៅវិញទៅមក ក្នុងការបង្កើតកិច្ចសន្យាទ្វេភាគី

២. លក្ខណៈទៅវិញទៅមក ក្នុងការអនុវត្តកិច្ចសន្យាទ្វេភាគី

៣. លក្ខណៈទៅវិញទៅមក នៅក្នុងអត្ថិភាពដែលត្រូវបន្ត

## ១. លក្ខណៈទៅវិញទៅមកក្នុងការបង្កើតកិច្ចសន្យាទ្វេភាគី : អលទ្ធភាពតាំងពីដំបូង

ទោះបីជាខ្លឹមសារនៃកិច្ចសន្យា មិនអាចសម្រេចបាន តាំងពីពេលដែលបង្កើតកិច្ចសន្យានោះក៏ដោយ ក៏កិច្ចសន្យានោះ មិនត្រូវបានចាត់ទុកថាជា មោឃៈដោយយកមូលហេតុនៃអលទ្ធភាពនោះដែរ (មាត្រា ៣៩៥ កថាខណ្ឌទី ១) ។

ប៉ុន្តែ បញ្ញត្តិនេះ មិនរារាំងដល់ភាគីនៅក្នុងកិច្ចសន្យា ក្នុងការលុបកិច្ចសន្យាដោយការភាន់ច្រឡំឡើយ ប្រសិនបើ លក្ខខណ្ឌនៃការភាន់ច្រឡំ បានបំពេញ។

អលទ្ធភាពមាន ០២ ផ្នែក :

- អលទ្ធភាពដោយផ្នែក
- អលទ្ធភាពទាំងស្រុង

} សួរថា តើកូនបំណុលមានកំហុសដែលនាំឱ្យមានអលទ្ធភាព

ប្រសិនបើ អលទ្ធភាពដោយផ្នែក កើតឡើង នោះ វា គឺជាបញ្ហានៃការទទួលខុសត្រូវនៅក្នុងការធានា ។

ទន្ទឹមនឹងនេះ ប្រសិនបើអលទ្ធភាពទាំងស្រុង កើតឡើដោយសារកំហុសរបស់កូនបំណុល នោះ កូនបំណុល ត្រូវទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ច ។

**អលទ្ធភាពទាំងស្រុង :** ករណីដែលកូនបំណុល ពុំមានកំហុសទេ នោះ ម្ចាស់បំណុល មិនអាចទាមទារឱ្យអនុវត្តបាន ឬ មិនអាចទាមទារសំណងការខូចខាត ឬ ជម្ងឺចិត្តបានទេ ( មាត្រា ៣៩៨ កថាខណ្ឌទី១ )

**ឧទាហរណ៍ : ក លក់ផ្ទះឱ្យ ខ**

- លទ្ធភាពតាំងពីដំបូង មាត្រា ៤១៥ ( ការលក់កាតព្វកិច្ចរបស់ភាគី )

- អលទ្ធភាពដោយសារគ្មានកំហុសរបស់កូនបំណុល មាត្រា ៤១៥ និង ៣៩៨ កថាខណ្ឌទី ២ ត្រូវយកមកអនុវត្ត

## ២. លក្ខណៈ "ទៅវិញទៅមក" នៅក្នុងការអនុវត្តកិច្ចសន្យាទ្វេភាគី

### ២.១ ការតវ៉ាអោយអនុវត្តព្រមគ្នា

#### ២.១.១ តួនាទី

យោងតាមមាត្រា ៣៨៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានចែងអំពីសិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នារវាងភាគីកូនបំណុល និង ភាគីម្ចាស់បំណុល ដូចជា : ជំរុញឱ្យមានការអនុវត្តកាតព្វកិច្ច និង ជៀសវាងនូវការខូចខាត ក្នុងករណីមិនអនុវត្តកាតព្វកិច្ច។ ជាគោលការណ៍ ប្រសិនបើច្បាប់ មិនបានចែងអំពីការតវ៉ាឱ្យអនុវត្តព្រមគ្នាក្នុងកិច្ចសន្យាអញ្ចឹមញ្ចឹនោះទេ គឺធ្វើឱ្យមានភាពមិនស្មើគ្នាកើតឡើង ក្នុងការអនុវត្តកាតព្វកិច្ច ពីព្រោះភាគីម្ខាង មិនមានសិទ្ធិតវ៉ា ក្នុងករណីដែល ភាគីម្ខាងទៀត បានអាក់ខានមិនព្រមអនុវត្តវី ប្រងើយកណ្តើយជាមួយនឹងការអនុវត្តរបស់ខ្លួន។ ឬនិយាយម្យ៉ាងទៀត បើគ្មានការតវ៉ាឱ្យអនុវត្តព្រមគ្នានោះទេ ម្ចាស់បំណុល ត្រូវអនុវត្តកាតព្វកិច្ចតប ឬ រំលាយកិច្ចសន្យា នៅពេលក្រោយ ក្នុងករណីដែលកូនបំណុល មិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួន។ នៅក្នុងករណីនេះ កូនបំណុល អាចនឹងប្រើប្រាស់នូវប្រាក់ដែលបានទទួល ឬ លក់នូវកម្មវត្ថុនៃកិច្ចសន្យា ហើយម្ចាស់បំណុល មិនអាចទទួលបាននូវកម្មវត្ថុ ដែលត្រូវបានអនុវត្តរួចរាល់ហើយ។ ដូច្នេះ ភាគី ម្ខាងនៃកិច្ចសន្យា អាចប្រកែកមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន រហូតដល់ភាគីម្ខាងទៀត អនុវត្តកាតព្វកិច្ចរបស់ខ្លួន។ ការតវ៉ាឱ្យអនុវត្តព្រមគ្នា មានតួនាទីបញ្ចៀសនូវការខូចខាត នៅក្នុងករណីនេះ។

#### ២.១.២ លក្ខខណ្ឌ

នៅក្នុងមាត្រា ៣៨៦ ក៏បានចែងពីលក្ខខណ្ឌនៃការតវ៉ាអោយអនុវត្តព្រមគ្នា មួយចំនួន ដូចជា

1) វត្តមាននៃកាតព្វកិច្ច ដែលសមមូលដែលកើតចេញពីកិច្ចសន្យាទ្វេភាគីតែមួយ

2) កាតព្វកិច្ចរបស់ភាគីម្ខាងទៀត គឺដល់ពេលកំណត់

3) ភាគីម្ខាងទៀត ទាមទារអោយអនុវត្តកាតព្វកិច្ចដោយមិនបានផ្តល់នូវការអនុវត្តកាតព្វកិច្ចរបស់ខ្លួន។

ដោយផ្អែកទៅលើវាក្យខណ្ឌទី២ នៃមាត្រា ៣៨៦ នៅក្នុងករណីដែលពេល សំរាប់អនុវត្តកាតព្វកិច្ចរបស់ភាគីម្ខាងទៀត មិនទាន់មកដល់ ភាគីនោះ មិនអាចអះអាងពីការតវ៉ាអោយអនុវត្តព្រមគ្នាបានទេ។ ភាគីនោះ មិនអាចសំរេចនូវសិទ្ធិលើបំណុលរបស់ខ្លួន តាមរយៈការអនុវត្តដោយបង្ខំទេ ព្រោះ កូនបំណុល មានផលប្រយោជន៍នៃការកំណត់ពេលវេលា ( មាត្រា ៣៣០ កថាខណ្ឌទី ១)។

### ២.១.៣ អានុភាព

#### ១. អានុភាពជាអត្ថិភាព

ក. ដរាបណាភាគី មានការតវ៉ាចំពោះការអនុវត្តព្រមគ្នានោះ ភាគី នឹងមិនស្ថិតក្នុងភាពយឺតយ៉ាវទេ ទោះបីជា ភាគី ដែលមានការតវ៉ាអោយអនុវត្តព្រមគ្នា មិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួន នៅពេលកាលបរិច្ឆេទកំណត់ ព្រោះ ភាគី មានសិទ្ធិស្របច្បាប់ក្នុងការបដិសេធមិនអនុវត្តកាតព្វកិច្ច នៅក្នុងស្ថានភាពនេះ។ ការយឺតយ៉ាវក្នុងការអនុវត្ត ក៏ជាប្រភេទមួយនៃការមិនអនុវត្តកាតព្វកិច្ចដែរ។ ការយឺតយ៉ាវក្នុងការអនុវត្តកើតឡើង ប្រសិនបើការកំណត់ពេល ត្រូវអនុវត្ត ដែលជាពេលវេលាដែលកូនបំណុល ត្រូវផ្តល់តាវកាលិកកន្លងហួស។

ការយឺតយ៉ាវក្នុងការអនុវត្ត មាន ៣ ប្រភេទ (មាត្រា ៣៩១) :

១) ប្រសិនបើ មានកំណត់ពេលពិតប្រាកដសំរាប់អនុវត្តកាតព្វកិច្ច នៅពេលដល់កាលកំណត់នោះ

២) ប្រសិនបើ មានកំណត់ពេលមិនពិតប្រាកដ សំរាប់អនុវត្តកាតព្វកិច្ច នៅពេលដែលកូនបំណុល ដឹងថាដល់ពេលកំណត់ហើយ

៣) ប្រសិនបើ មិនបានកំណត់ពេលសំរាប់អនុវត្តកាតព្វកិច្ចទេ នៅពេលដែលកូនបំណុល ទទួលការទាមទារឱ្យអនុវត្ត។

ខ. ដរាបណាភាគី មានការតវ៉ាឱ្យការអនុវត្តព្រមគ្នា ភាគីម្ខាងទៀត មិនអាចអនុវត្តការទូទាត់បានទេ (មាត្រា ៤៦៨ កថាខណ្ឌទី ១)។ ការទូទាត់ គឺជាប្រព័ន្ធមួយដើម្បីរំលត់កាតព្វកិច្ច ដោយការបង្ហាញឆន្ទៈជាឯកតោភាគីរបស់ភាគីម្ខាង ដូច្នេះ កាតព្វកិច្ចដែលភ្ជាប់នឹងសិទ្ធិតវ៉ា ត្រូវបានការពារមិនអោយធ្វើការទូទាត់ឡើយ។

#### ២. អានុភាពកើតពីការអនុវត្តការតវ៉ាឱ្យអនុវត្តព្រមគ្នានៅក្នុងនីតិវិធីបណ្តឹង

ភាគីដែលមានការតវ៉ាអោយអនុវត្តព្រមគ្នា អាចអះអាងពីការតវ៉ានេះ នៅក្នុងនីតិវិធីបណ្តឹងបាន។ នៅក្នុងករណីនេះ ប្រសិនបើតុលាការ ទទួលស្គាល់នូវការតវ៉ានេះ តុលាការ ត្រូវចេញសាលក្រមអោយអនុវត្ត ជាថ្នូរនឹងតាវកាលិកតប។ ឧទាហរណ៍ ដើមចោទ **ក** បានដាក់ពាក្យបណ្តឹងចំពោះ **ខ** ដោយទាមទារឱ្យបង់ប្រាក់ចំនួន ៥០០០ ដុល្លា ដែលជាប្រាក់ថ្លៃលក់រថយន្ត ហើយ **ខ** បានអះអាងពីការតវ៉ាអោយអនុវត្តព្រមគ្នា នៅក្នុងនីតិវិធីបណ្តឹង។ ប្រសិនបើ តុលាការ ទទួលស្គាល់នូវការតវ៉ារបស់ **ខ** នោះ សាលក្រម គឺសំរេចថា "ចុងចំលើយ ត្រូវបង់ប្រាក់ចំនួន ៥០០០ ដុល្លា ជាថ្នូរនឹងការប្រគល់រថយន្តរបស់ **ក**"។

ករណីសិក្សា

តើ ក អាចបដិសេធនូវការទាមទាររបស់ ខ ឱ្យផ្ទេរនូវកម្មវត្ថុ នៅក្នុងករណីខាងក្រោមនេះដែរ ឬ ទេ?

១) ក គឺជាម្ចាស់ហាងលក់ស្រាមួយកន្លែង។ អតិថិជន ខ បានចូលមកក្នុងហាង។ ក មិនដែលស្គាល់ ខ ទេ។ ខ ស្នើទិញស្រាបៀរចំនួន ១០ ដប ក្នុងតំលៃ ៦ ដុល្លា។ ក បានយល់ព្រមនឹងសំណើរបស់ ខ ហើយ បានរៀបចំស្រាបៀរចំនួន ១០ ដប សំរាប់ ខ។ ក៏ប៉ុន្តែ ខ បានប្រាប់ថា "ខ្ញុំ ភ្លេចយកកាបូបលុយមកហើយ។ ខ្ញុំ នឹងបង់ប្រាក់នៅពេលក្រោយ ឥឡូវនេះ សូមផ្តល់ឱ្យខ្ញុំនូវស្រាបៀរ ១០ ដបសិនមក"។

២) នៅក្នុងករណីទី ១) ខាងលើ ខ បានប្រាប់ទៅ ក "ខ្ញុំ យកកាបូបលុយមកជាមួយ តែមានតែ ១ ដុល្លាទេ។ ខ្ញុំ នឹងបង់ប្រាក់ឱ្យ ១ ដុល្លា សិន ហើយសូមផ្តល់ឱ្យខ្ញុំនូវស្រាបៀរ ១០ ដប។ ហើយខ្ញុំ នឹងបង់ប្រាក់ដែលនៅសល់នៅពេលក្រោយ"។

៣) ក បានលក់រថយន្តរបស់ខ្លួនឱ្យទៅ ខ ក្នុងតំលៃ ៥០០០ ដុល្លា។ កាលបរិច្ឆេទនៃកាតព្វកិច្ចទាំងពីរ គឺនៅថ្ងៃទី ១០ ខែ កញ្ញា។ ក៏ប៉ុន្តែ ក និង ខ មិនបានធ្វើសំណើផ្តល់ការអនុវត្តកាតព្វកិច្ចរបស់ខ្លួន នៅកាលបរិច្ឆេទកំណត់នោះទេ។ ក្រោយមក ខ បានទាមទារឱ្យ ក ប្រគល់រថយន្ត ដោយមិនបានធ្វើសំណើផ្តល់ការអនុវត្តកាតព្វកិច្ចរបស់ខ្លួនទេ។

៤) ក បានលក់រថយន្តរបស់ខ្លួនឱ្យទៅ ខ នៅក្នុងតំលៃ ៥០០០ ដុល្លា ហើយ ភាគី បានព្រមព្រៀងគ្នា ខ ត្រូវបង់ប្រាក់នៅថ្ងៃទី ១០ ខែ កញ្ញា ហើយ ក ត្រូវប្រគល់រថយន្តទៅឱ្យ ខ នៅថ្ងៃទី ៣០ ខែ កញ្ញា។ ខ បានបង់ប្រាក់នៅថ្ងៃទី ១០ ខែ កញ្ញា ទៅអោយ ក។ ក្រោយមក ខ បានទាមទារអោយ ក ប្រគល់រថយន្តនៅថ្ងៃទី ១៥ ខែ កញ្ញា។

៥) ក បានបង្កើតកិច្ចសន្យាលក់រថយន្តរបស់ខ្លួនអោយទៅ ខ ក្នុងតំលៃ ៥០០០ ដុល្លា ហើយ បានព្រមព្រៀងគ្នាថា ខ ត្រូវបង់ប្រាក់នៅថ្ងៃទី ១០ ខែ កញ្ញា និង ក ត្រូវប្រគល់រថយន្តនៅថ្ងៃទី ៣០ ខែ កញ្ញា។ ក មិនបានប្រគល់រថយន្តទៅឱ្យ ខ នៅកាលបរិច្ឆេទកំណត់នោះទេ ហើយ ខ បានទាមទារអោយ ក ប្រគល់រថយន្តនៅថ្ងៃទី ១៥ ខែ កញ្ញា ដោយមិនបានធ្វើសំណើផ្តល់ការអនុវត្តកាតព្វកិច្ចរបស់ខ្លួន។

៦) នៅក្នុងករណីទី ៥) ទាំង ក និង ខ មិនបានធ្វើសំណើផ្តល់ការអនុវត្តកាតព្វកិច្ច នៅកាលបរិច្ឆេទកំណត់។ បន្ទាប់នៅថ្ងៃទី ១ ខែ តុលា ខ បានទាមទារឱ្យ ក ប្រគល់រថយន្ត ដោយមិនបានធ្វើសំណើផ្តល់ការអនុវត្តរបស់ខ្លួន។

【សេចក្តីសន្និដ្ឋាន និង មូលហេតុសំអាង】

១) ក អាចបដិសេធការទាមទាររបស់ ខ

ដោយផ្អែកលើអង្គហេតុ និង មាត្រា ៣៨៦ វា គឺជារឿងធម្មតាសំរាប់ការអនុវត្តកាតព្វកិច្ចទូទៅ នៅក្នុងកិច្ចសន្យា នៅក្នុងប្រតិបត្តិការជំនួញធម្មតា ដូចជា នៅពេលដែលយើង ទិញវត្ថុអ្វីមួយ យើង ចាំបាច់ត្រូវបង់ប្រាក់ទៅឱ្យអ្នកលក់ និង អ្នកលក់នោះ ត្រូវប្រគល់វត្ថុនោះ ដោយអនុវត្តកាតព្វកិច្ចព្រមគ្នា។ ក៏ប៉ុន្តែ នៅក្នុងករណីទី ១) ខ បានទិញស្រាបៀពី ក ប៉ុន្តែ ខ មិនបានបង់ប្រាក់ទៅ ក ទេ ដោយសារតែ ខ ភ្លេចយកកាបូបលុយមក។ ដូច្នេះ ក

បានសិទ្ធិក្នុងការតវ៉ា និង បដិសេធមិនព្រមប្រគល់ស្រាបៀទៅអោយ ខ រហូតដល់ ខ អនុវត្តកាតព្វកិច្ចបង់ប្រាក់ឱ្យទៅ ក ដោយព្រមគ្នា។

២) ក អាចបដិសេធការទាមទាររបស់ ខ

បញ្ញត្តិ ដែលពាក់ព័ន្ធនឹងការអនុវត្តកាតព្វកិច្ច (មាត្រា ៤៣៤ រហូតដល់មាត្រា ៤៦៣) ត្រូវយកមកអនុវត្ត ចំពោះការអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យា។ ដោយផ្អែកលើមាត្រា ៤៤១ ម្ចាស់បំណុល មិនបានតំរូវឱ្យទទួលយកនូវការសងមួយភាគនោះទេ ព្រោះការសងមួយភាគ មិនត្រូវបានចាត់ទុកថា បានបំពេញនូវគោលបំណងនៃកិច្ចសន្យាឡើយ។ ដូច្នេះ ទោះបីជា ខ បានបង់ប្រាក់ចំនួន ១ ដុល្លា ក៏ដោយ ក៏ វា មិនមែនជា "ការអនុវត្តកាតព្វកិច្ចដែរ" ហើយ ក អាចបដិសេធចំពោះការទាមទាររបស់ ខ។

៣) ក អាចបដិសេធការទាមទាររបស់ ខ

នៅក្នុងករណីនេះ កាតព្វកិច្ចទាំងពីរ ត្រូវបានចាត់ទុកថា ស្ថិតនៅក្នុងលក្ខខណ្ឌដូចគ្នា គឺកាតព្វកិច្ចមិនបានកំណត់ពេល (មាត្រា ៣៩១ កថាខណ្ឌទី ៣) ព្រោះកាតព្វកិច្ចទាំងពីរ បានដល់ពេលកំណត់ដូចគ្នា។ ដូច្នេះ ក អាចបដិសេធការទាមទាររបស់ ខ បាន ប្រសិនបើ ខ បានទាមទារអោយ ក ប្រគល់រថយន្ត ដោយមិនបានធ្វើសំណើផ្តល់ការអនុវត្តកាតព្វកិច្ចរបស់ខ្លួន។

៤) ក អាចបដិសេធការទាមទាររបស់ ខ

ក មិនចាំបាច់ប្រគល់រថយន្ត រហូតដល់ថ្ងៃទី ៣០ ខែ កញ្ញា។ ឬនិយាយម្យ៉ាងទៀត ខ មិនអាចតំរូវឱ្យ ក អនុវត្តកាតព្វកិច្ច មុនពេលចាប់ផ្តើមនៃកាលកំណត់ បានមកដល់ឡើយ (មាត្រា ៣២៩ កថាខណ្ឌទី ១)។ ក មានផលប្រយោជន៍នៅក្នុងការកំណត់ពេលវេលា (មាត្រា ៣៣០)។

៥) ក មិនអាចបដិសេធការទាមទាររបស់ ខ

កាតព្វកិច្ចរបស់ ក បានមកដល់ពេលកំណត់នៅថ្ងៃទី ១០ ខែ កញ្ញា។ វា មានន័យថា កាតព្វកិច្ចរបស់ភាគីម្ខាងទៀត បានមកដល់សំរាប់ ខ។ ផ្ទុយទៅវិញ កាតព្វកិច្ចរបស់ ខ មិនទាន់ដល់ទេ នៅថ្ងៃទី ១៥ ខែ កញ្ញា។ ដូច្នេះ ក មិនអាចបដិសេធការទាមទាររបស់ ខ បានទេ ដោយផ្អែកលើ មាត្រា ៣៨៦ វាក្យខណ្ឌទី ២។

៦) ក អាចបដិសេធ / មិនអាចបដិសេធ ការទាមទាររបស់ ខ

នៅក្នុងករណីនេះ កាតព្វកិច្ចរបស់ភាគីទាំងខាង ត្រូវបានចាត់ទុកថា ស្ថិតនៅក្នុងស្ថានភាពដូចគ្នា គឺ កាតព្វកិច្ច មិនបានកំណត់ពេល ដូចនៅក្នុងករណីទី ៣) ដែរ។ ក៏ប៉ុន្តែនៅក្នុងករណីនេះ ក មានកាតព្វកិច្ច ដែលត្រូវអនុវត្តមុន ខ។ ក្រោយកាលបរិច្ឆេទកំណត់ ក ត្រូវទទួលខុសត្រូវចំពោះការយឺតយ៉ាវក្នុងការអនុវត្ត។ បញ្ហា គឺនៅត្រង់ថាតើ វា មានភាពយុត្តិធម៌ដែរ ឬ អត់ ដែលអនុញ្ញាតអោយ ជន ដូចជា ក ធ្វើការបដិសេធការទាមទាររបស់ ខ ដោយផ្អែកលើការតវ៉ាអោយអនុវត្តព្រមគ្នា។

មានគំនិត ចំនួនពីរ។ ទី ១ គឺ គំនិតដែលបដិសេធនូវការតវ៉ាឱ្យអនុវត្តព្រមគ្នារបស់ ក ព្រោះ ក មានកាតព្វកិច្ច ដែលតំរូវឱ្យអនុវត្តមុន ខ។ ទី ២ គឺគំនិតដែលគាំទ្រដល់ការតវ៉ាឱ្យអនុវត្តព្រមគ្នារបស់ ក ព្រោះ មាត្រា

៣៨៦ តំរូវឱ្យមានតែ ការមកដល់នៃពេលវេលានៃការអនុវត្តកាតព្វកិច្ចទាំងពីរ។ ជាងនេះទៅទៀត វា ហាក់ដូចជាអយុត្តិធម៌ ប្រសិនបើ ក ត្រូវអនុវត្តកាតព្វកិច្ចមុន ខ ទោះបីជាមានការព្រួយបារម្ភគួរឱ្យកត់សំគាល់ថា ខ នឹងមិនអនុវត្តកាតព្វកិច្ចតាមខ្លឹមសារនៃកាតព្វកិច្ច។

## ២.២ ការតវ៉ាដោយមានការបារម្ភ

មាត្រា ៣៨៧ បានចែងថា "ភាគីដែលត្រូវអនុវត្តកាតព្វកិច្ចជាមុន នៅក្នុងកិច្ចសន្យាអញ្ញមញ្ញ អាចប្រកែកមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនបាន ក្នុងករណីដែលមានការបារម្ភដែលគួរឱ្យកត់សំគាល់ថា ភាគីម្ខាងទៀត នឹងមិនអនុវត្តតាមខ្លឹមសារនៃកាតព្វកិច្ច។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលភាគីម្ខាងទៀត ដាក់ប្រាតិភោគ ឬ ចាត់ចែងវិធានការផ្សេងទៀតដើម្បីរំលត់ការបារម្ភនោះ"។

ឧទាហរណ៍ : ក បានលក់រថយន្តឱ្យទៅ ខ នៅថ្ងៃទី ៣១ ខែ វិច្ឆិកា ឆ្នាំ ២០១០ ហើយ ពួកគាត់ បានព្រមព្រៀងគ្នាថា ក ត្រូវប្រគល់រថយន្តរបស់ខ្លួន នៅថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១០ ហើយ ខ ត្រូវបង់ប្រាក់ឱ្យ ក នៅថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១០។ ក៏ប៉ុន្តែ នៅថ្ងៃ ០១ ខែ វិច្ឆិកា ឆ្នាំ ២០១០ ខ បានក្ស័យធន។

ក្នុងករណីនេះ ក មានការបារម្ភចំពោះការអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដោយលើកមូលហេតុ ខ បានក្ស័យធន។ ឆ្លើយតបនឹងការលើកឡើងនេះ ក គឺជាភាគី ដែលអាចអះអាងពីការតវ៉ាដោយមានការបារម្ភ និង បដិសេធក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន។

ផ្ទុយទៅវិញ បើ ខ បានដាក់ប្រាតិភោគ គឺ ក មិនអាចបដិសេធការអនុវត្តកាតព្វកិច្ចរបស់គាត់បានឡើយ។

### ២.២.១ តួនាទីនៃការតវ៉ាដោយមានការបារម្ភ

- ភាពអយុត្តិធម៌ នឹងកើតមាន ក្នុងករណីដែល មានការបារម្ភគួរអោយកត់សំគាល់ថា ខ នឹងមិនអនុវត្តកាតព្វកិច្ចបាន តែបែរជាបង្ខំឱ្យ ក ធ្វើការអនុវត្តកាតព្វកិច្ច។
- ជួយឱ្យ ក ជៀសផុតពីការខូចខាត នៅក្នុងករណីដែល ខ ពុំអាចអនុវត្តកាតព្វកិច្ចបាន។

### ២.២.២ លក្ខខណ្ឌនៃការតវ៉ាដោយមានការបារម្ភ

1. មានវត្តមាននៃកាតព្វកិច្ច ដែលភាគីម្ខាងនៃកិច្ចសន្យាទ្វេភាគី តំរូវអោយអនុវត្តមុនភាគីម្ខាងទៀត
2. មានការបារម្ភគួរអោយកត់សំគាល់ថា ភាគីម្ខាងទៀត មិនអនុវត្ត តាមខ្លឹមសារនៃកិច្ចសន្យា

មូលហេតុនៃការបារម្ភដែលអាចកើតមានដូចជា :

- ក្ស័យធន
- អសាធនីយន៍

- កង្វះទ្រព្យធននៅក្នុងរយៈពេលខ្លី

លើសពីនេះទៀត ករណីខាងក្រោមនេះ ក៏អាចចាត់ទុកថាជាការបារម្ភដែលមិនមែនជាសេដ្ឋកិច្ច :

- ការលាឈប់របស់ជំនួយការដ៏សំខាន់ណាម្នាក់

- ការចេញនូវបំរាមថ្មីរបស់រដ្ឋាភិបាល ដែលហាមឃាត់នូវការនាំចូលវត្ថុធាតុដើមដ៏សំខាន់

ឧទាហរណ៍ : ក បានលក់វត្ថុសិល្បៈទៅឱ្យ ខ ដោយមាន គ ជាអ្នកធ្វើវត្ថុសិល្បៈនោះឱ្យ ដែលជាសិប្បករគ្មានអ្នកជំនួស។ ក្រោយពីធ្វើកិច្ចសន្យាហើយ គ បានទទួលមរណភាព។ នៅក្នុងករណីនេះ បើ ក អាចរកបុគ្គលម្នាក់ផ្សេងទៀត ដែលមានទឹកដៃប្រហាក់ប្រហែល គ មកជំនួស នោះ នឹងនាំឱ្យមានការរំលត់ការបារម្ភ ដោយការចាត់វិធានការណ៍ ក្រៅពីការដាក់ប្រាតិភោគ។

ដូច្នេះ ការបារម្ភនោះ មិនត្រឹមតែផ្តោតទៅលើបញ្ហាសេដ្ឋកិច្ចនោះទេ គឺថែមទាំងផ្តោតទៅលើបញ្ហាមិនមែនសេដ្ឋកិច្ចផងដែរ ដូចជា កត្តាមនុស្ស។

វា មានន័យថា ប្រសិនបើភាគីម្ខាង បានអនុវត្តកាតព្វកិច្ចរួចហើយនោះ ការតវ៉ាដោយមានការបារម្ភ ក៏ពុំអាចកើតមានឡើយ លើកលែងតែ ករណីភាគីទាំងសងខាង ពុំទាន់មានភាគីណាមួយ អាចឈានទៅសំរេចការអនុវត្តកាតព្វកិច្ចបាន។

3. ភាគីម្ខាងទៀត មិនបានផ្តល់នូវប្រាតិភោគ ឬ ចាត់ចែងវិធានការណ៍ ដើម្បីរំលត់ការបារម្ភ

ប្រាតិភោគក្នុងករណីនេះ មិនកំណត់ន័យត្រឹមការដាក់ប្រាតិភោគ ដោយវត្ថុ ដូចជា ការបញ្ចាំ ឬ ហ៊ីប៉ូតែក គឺថែមទាំងជាប្រាតិភោគដោយបុគ្គលផងដែរ ដូចជាអ្នកធានា។

ឧទាហរណ៍ទី ១ : ក បានលក់រថយន្តរបស់ខ្លួនអោយទៅ ខ ហើយ ពួកគាត់ បានព្រមព្រៀងគ្នាថា ក ត្រូវប្រគល់រថយន្តនោះ នៅមុនការបង់ប្រាក់។ ទោះបីជា ខ បានក្ស័យធននៅពេលដែលអនុវត្តកាតព្វកិច្ចរបស់ ក ក៏ដោយ ក៏ ក មិនអាចអះអាងពីការតវ៉ាដោយមានការបារម្ភ នៅក្នុងករណីដែល ខ រកបានអ្នកធានា។

ឧទាហរណ៍ទី ២ : ក បានព្រមព្រៀងលក់ផលិតផលសិល្បៈទៅអោយ ខ ដោយមាន គ គឺជាសិប្បករម្នាក់ដ៏សំខាន់។ មិនទាន់បានធ្វើផង គ បានទទួលមរណភាព។ ក៏ប៉ុន្តែ ក មិនអាចអះអាងពីការតវ៉ាដោយមានការបារម្ភទេ ប្រសិនបើ ខ បានជួលសិប្បករថ្មី ឃ ដែលមានទឹកដៃដូច គ ដែរ។

ក្នុងឧទាហរណ៍ទី ១ និង ទី ២ គឺស្ថិតនៅក្នុងករណី **រំលត់ការបារម្ភ**។

### ២.២.៣ អានុភាពនៃការតវ៉ាដោយមានការបារម្ភ

1) ដរាបណា ភាគី មានការតវ៉ាដោយមានការបារម្ភ គាត់ អាចបដិសេធការអនុវត្តកាតព្វកិច្ចបាន រហូតដល់ភាគីម្ខាងទៀត បានផ្តល់នូវប្រាតិភោគ ឬ ចាត់ចែងវិធានការណ៍ផ្សេងៗ ដើម្បីរំលត់ការបារម្ភនោះ។

ឧទាហរណ៍ ៖ ក បានលក់រថយន្តរបស់ខ្លួនទៅអោយ ខ នៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១០ ដោយបានព្រមព្រៀងគ្នាថា ក ត្រូវប្រគល់រថយន្តនៅថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១០ ហើយ ខ ត្រូវបង់ប្រាក់ថ្លៃទិញនៅថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១០។ ក៏ប៉ុន្តែ ខ បានក្ស័យធន នៅក្រោយពេលបង្កើតកិច្ចសន្យា។




ក្នុងករណី ក បានលើកឡើងពីតវ៉ាដោយមានការបារម្ភ ប្រសិនបើ ខ ចាត់វិធានការរំលត់ការបារម្ភនៅមុនថ្ងៃទី ២៥ ខែ វិច្ឆិកា នោះ ក មិនអាចអះអាងពីការតវ៉ាដោយមានការបារម្ភទេ ហើយ គាត់ ត្រូវទទួលខុសត្រូវចំពោះការយឺតយ៉ាវនៅក្នុងការអនុវត្ត ប្រសិនបើ ក មិនអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅថ្ងៃទី ២៥ ខែ វិច្ឆិកា។

ម្យ៉ាងវិញទៀត ប្រសិនបើ ខ មិនបានដាក់ប្រាតិភោគ ឬ ចាត់វិធានការណ៍ដើម្បីរំលត់ការបារម្ភ នៅមុនថ្ងៃទី ២៥ ខែ វិច្ឆិកា ទេ ក មិនត្រូវទទួលខុសត្រូវចំពោះការយឺតយ៉ាវនៅក្នុងការអនុវត្តទេ។

2) ភាគី ដែលមានការតវ៉ាដោយមានការបារម្ភ អាចអះអាងពីការតវ៉ានេះ នៅក្នុងនីតិវិធីបណ្តឹង។

នៅក្នុងករណីដែល ខ បានអះអាង ដោយតវ៉ាតបថា ខ្លួនបានផ្តល់នូវប្រាតិភោគគ្រប់គ្រាន់ហើយ ឬ បានចាត់វិធានការណ៍ ដើម្បីរំលត់ការបារម្ភហើយ នោះ តុលាការ ត្រូវច្រានចោលការទាមទាររបស់ ក នៅក្នុងសាលក្រម។

## ៣. លក្ខណៈទៅវិញទៅមក នៅក្នុងអត្ថិភាពនៃបំណុលត្រូវបានបន្ត

### ៣.១ គោលគំនិតនៃការទទួលបន្ទុកហានិភ័យ

ឧទាហរណ៍ ៖ ក បានលក់នាឡិកាមួយតំលៃ ១០០ ដុល្លាអាមេរិក ទៅឱ្យ ខ។ ប្រសិនបើ ក បានបំផ្លាញនាឡិកានោះដោយចេតនា។ តើ ក នឹងមានផលវិបាកយ៉ាងដូចម្តេច?

- ការអនុវត្តដោយបង្ខំ
- ទាមទារការខូចខាត } ជាការសង្គ្រោះទូទៅដែល ខ ទាមទារបាន។

- ការរំលាយកិច្ចសន្យា

ករណីនាឡិកាបុរាណ មិនអាចជំនួសបាន ហើយជាវត្ថុជាក់លាក់

- ខ មិនអាចទាមទារការអនុវត្តដោយបង្ខំបានទេ
- ខ អាចទាមទារការខូចខាតបាន
- ខ អាចរំលាយកិច្ចសន្យាបាន

នៅក្នុងករណីដែល ខ ជ្រើសរើសយកការទាមទារសំណងនៃការខូចខាត កាតព្វកិច្ចក្នុងការប្រគល់វត្ថុដែល ក ត្រូវអនុវត្ត ត្រូវប្តូរទៅជាសងការខូចខាត។

នៅក្នុងករណីដែល មានកំហុសនៃការបំពានកិច្ចសន្យាធ្ងន់ធ្ងរ នោះ ក អាចរំលាយកិច្ចសន្យាបាន (មាត្រា ៤០៨ និង មាត្រា ៤០៨) និង/ឬ ទាមទារសំណងនៃការខូចខាត ក៏ប៉ុន្តែ មិនអាចទាមទារសំណងនៃការខូចខាតបានទេ។ ក៏ប៉ុន្តែ ប្រសិនបើ ខ មិនមានកំហុសទេ ក មិនអាចទាមទារសំណងនៃការខូចខាតបានទេ (មាត្រា ៣៩៨ កថាខណ្ឌទី ១)។

ហើយបន្ទាប់មក ចុះចំពោះករណីដែល ក មិនមានកំហុសចំពោះអលទ្ធភាព នៅក្នុងការអនុវត្តកិច្ចសន្យា តើវា នឹងទៅជាយ៉ាងណា ?




នៅក្នុងករណីនៃកិច្ចសន្យាទ្វេភាគី ភាគីទាំងសងខាង គឺមានកាតព្វកិច្ច និង សិទ្ធិទាមទារចំពោះគ្នា ទៅវិញទៅមក។

ឧទាហរណ៍ អ្នកលក់ ក មានកាតព្វកិច្ចផ្ទេរកម្មវត្ថុ (ក) និង សិទ្ធិទាមទារអោយបង់ប្រាក់ (គ)។ ទន្ទឹមនឹងនេះ ខ មានកាតព្វកិច្ចបង់ប្រាក់ (ឃ) និង សិទ្ធិទាមទារអោយផ្ទេរ (ខ)។ នៅក្នុងទំនាក់ទំនងនេះ កាតព្វកិច្ចផ្ទេរ (ក) និង សិទ្ធិទាមទារអោយផ្ទេរ (ខ) ហើយនិង កាតព្វកិច្ចបង់ប្រាក់ (ឃ) និង សិទ្ធិទាមទារអោយបង់ប្រាក់ (គ) គឺដូចជា "មុខពីរនៅលើកាក់តែមួយ"។ ដូច្នេះ ប្រសិនបើ កាតព្វកិច្ចផ្ទេរ (ក) ត្រូវរលត់ នោះ សិទ្ធិទាមទារអោយផ្ទេរ (ខ) ក៏ត្រូវរលត់ដែរ។

ដោយផ្អែកតាមមាត្រា ៤១៥ ប្រសិនបើ កូនបំណុល គ្មានកំហុសចំពោះអលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច នោះ កាតព្វកិច្ច ត្រូវរលត់ ហើយម្ចាស់បំណុល មិនអាចទាមទារតាវកាលិកបានទេ។ "កូនបំណុល" នៅទីនេះ សំដៅទៅលើបុគ្គល ដែលត្រូវទទួលបន្ទុកកាតព្វកិច្ចផ្ទេរកម្មវត្ថុ និង "ម្ចាស់បំណុល" សំដៅទៅលើភាគីម្ខាងទៀត។ ដូច្នេះ ប្រសិនបើ កម្មវត្ថុនៃកិច្ចសន្យាលក់ទិញ ត្រូវបានខូចខាត ដោយគ្មានកំហុសរបស់ ក នោះ កាតព្វកិច្ចផ្ទេរ (ក) ត្រូវរលត់ ហើយ ខ មិនអាចទាមទារការផ្ទេរ (ខ) កម្មវត្ថុបានទៀតទេ។

បន្ទាប់មក តើវា នឹងទៅជាយ៉ាងណាចំពោះតាវកាលិកតប ? តើ ក អាចទាមទារ ខ បង់ប្រាក់បានដែរ ឬទេ នៅក្នុងករណីខាងលើ ? បញ្ហានៃ "បន្ទុកហានិភ័យ" សំដៅទៅលើ "តើនរណា ដែលត្រូវទទួលបន្ទុកហានិភ័យ ប្រសិនបើ កាតព្វកិច្ចផ្ទេរក្លាយជាអលទ្ធភាព? កូនបំណុល ឬ ម្ចាស់បំណុល ?" ឬ និយាយម្យ៉ាងទៀត នៅក្នុងករណីដែល កម្មវត្ថុ ដែលត្រូវធ្វើការផ្ទេរ ត្រូវបានធ្វើអោយខូចខាត ដោយគ្មានកំហុសរបស់ភាគីទាំងសងខាង នោះ កាតព្វកិច្ចតប ត្រូវរលត់ ឬ អត់។

ទាក់ទងនឹងចំណុចនេះ គឺមានគោលគំនិតចំនួន ២

(១) គោលគំនិត ដែលតាវកាលិកតប ត្រូវរលត់

នៅក្នុងករណីខាងលើ ប្រសិនបើ កាតព្វកិច្ចបង់ប្រាក់របស់ ខ ត្រូវរលត់ នោះ ខ មិនបង់ប្រាក់ថ្លៃទិញទៀតទេ។ វា មានន័យថា ក គឺជាអ្នកបាត់បង់ផលប្រយោជន៍។ វា មានន័យថា ក ត្រូវទទួលបន្ទុកហានិភ័យ។

(២) គោលគំនិត ដែលតាវកាលិកតប មិនត្រូវបានរលត់

ប្រសិនបើ តាវកាលិកតប មិនត្រូវរលត់ ខ នៅតែមានកាតព្វកិច្ចបង់ប្រាក់ ទោះបីជាកម្មវត្ថុនៃកិច្ចសន្យាត្រូវបានធ្វើអោយខូចខាត និង អលទ្ធភាពក្នុងការផ្ទេរ។ វា មានន័យថា ម្ចាស់បំណុល ត្រូវទទួលបន្ទុកហានិភ័យ។

វា គឺអាស្រ័យទៅលើប្រភេទនៃកម្មវត្ថុ ដែល គោលគំនិត ត្រូវយកមកអនុវត្ត។

ដោយយោងទៅលើ មាត្រា ៤១៦ កថាខណ្ឌទី ១ ក្នុងកិច្ចសន្យាអញ្ញមញ្ញ ដែលមានអត្ថន័យផ្ទេរកម្មសិទ្ធិលើវត្ថុដែលបានកំណត់ជាក់លាក់ ក្នុងករណីដែលកម្មវត្ថុនៃកិច្ចសន្យា ត្រូវបានបាត់បង់ ឬ ខូចខាត ដោយគ្មានកំហុសរបស់ភាគីទាំងសងខាងទេ កូនបំណុល ត្រូវទទួលបន្ទុកហានិភ័យ។

ទន្ទឹមនឹងនេះ ដោយផ្អែកទៅលើតាមមាត្រា ៤១៦ កថាខណ្ឌទី ២ ចំពោះ ហានិភ័យដោយសារការបាត់បង់ ឬ ខូចខាតវត្ថុជាកម្មវត្ថុនៃកិច្ចសន្យា ត្រូវផ្ទេរទៅម្ចាស់បំណុលនៅក្នុងលក្ខខណ្ឌកំណត់មួយចំនួន។ ឧទាហរណ៍ ក បានប្រគល់នាឡិកាទៅផ្ទះរបស់ ខ តាមកាលបរិច្ឆេទកំណត់។ ក៏ប៉ុន្តែ ខ បដិសេធមិនព្រមយកនាឡិកានោះ ដោយមិនមានមូលហេតុត្រឹមត្រូវ។ ក្រោយមក នាឡិការនោះ ត្រូវបានធ្វើអោយខូចខាត ហើយ កាតព្វកិច្ចក្នុងការប្រគល់ ក្លាយជាអលទ្ធភាព។ ក្នុងករណីនេះ នៅពេលដែល ក បានប្រគល់នាឡិកា ហានិភ័យ ក៏ត្រូវបានផ្ទេរមកដែរ ដោយផ្អែកទៅលើ មាត្រា ៤១៦ កថាខណ្ឌទី ២ ចំណុច ខ។ ដូច្នេះ ខ ត្រូវបង់ប្រាក់ថ្លៃទិញ ទោះបីជា ខ មិនបានទទួលយកនាឡិកាក៏ដោយ។

ជាងនេះទៅទៀត ដោយផ្អែកទៅលើ មាត្រា ៤១៨ កថាខណ្ឌទី ១ ចំពោះកិច្ចសន្យាអញ្ញមញ្ញ ដែលមានគោលបំណងផ្ទេរកម្មសិទ្ធិលើវត្ថុ ដែលមិនបានកំណត់ជាក់លាក់ ក្នុងករណីវត្ថុដែលត្រូវផ្តល់មិនទាន់បានកំណត់ ទោះបីជាវត្ថុដែលខ្លួន បានរៀបចំដើម្បីអនុវត្តបាត់បង់ដោយគ្មានកំហុសរបស់ខ្លួនក៏ដោយ ក៏កាតព្វកិច្ចនោះ មិនត្រូវរលត់ដែរ ។ ឬនិយាយម្យ៉ាងទៀត នៅក្នុងករណីនេះ កូនបំណុល ត្រូវទទួលបន្ទុកហានិភ័យ ។

## *សេចក្តីពន្យល់ទី១ : វត្ថុដែលបានកំណត់ជាក់លាក់ និង វត្ថុដែលមិនបានកំណត់ជាក់លាក់

### 1. តើអ្វីគឺជាវត្ថុដែលបានកំណត់ជាក់លាក់

វត្ថុដែលបានកំណត់ជាក់លាក់ គឺជាវត្ថុដែលគូរភាគី បានធ្វើការកំណត់យ៉ាងច្បាស់ពីលក្ខណៈពិសេសរបស់វា ហើយមិនអាចយកវត្ថុផ្សេងមកជំនួសបាន។ ជាទូទៅ អចលនវត្ថុ ឬ វត្ថុបុរាណ ត្រូវបានចាត់ទុកថាជាវត្ថុដែលបានកំណត់ជាក់លាក់ ។ ក៏ប៉ុន្តែ ប្រសិនបើ ភាគី ធ្វើការកំណត់ដី ដោយបញ្ជាក់ពីទីតាំង ជាប់នឹងផ្លូវណាមួយ ឬ នៅជិតស្ថានីយ៍ នោះ កម្មវត្ថុ គឺជាវត្ថុដែលមិនជាក់លាក់ ដោយមានកំណត់ ។

នៅក្នុងករណីនៃកាតព្វកិច្ចប្រគល់វត្ថុ ដែលបានកំណត់ជាក់លាក់ នោះកូនបំណុល ត្រូវថែរក្សាវត្ថុនោះ

១) ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ

២) រហូតដល់ពេលប្រគល់វត្ថុនោះ ( មាត្រា ៣១៤)

### 1.1 ការថែរក្សាដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ

មាត្រា ៣១៤ ចែងថា ចំពោះកាតព្វកិច្ចប្រគល់វត្ថុ ដែលបានកំណត់ជាក់លាក់អ្វីមួយ កូនបំណុល មានករណីយកិច្ចរក្សាវត្ថុនោះ ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ រហូតដល់ពេលប្រគល់ ។ វា មានន័យថា អ្នកគ្រប់គ្រង ត្រូវថែរក្សាវត្ថុនោះ អោយបានល្អជាងទ្រព្យសម្បត្តិរបស់ខ្លួនទៅទៀត ។

គំនិតដែលផ្ទុយនឹង "ការថែរក្សាដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ" គឺ "ការថែរក្សាដោយប្រុងប្រយ័ត្នដូចទ្រព្យសម្បត្តិផ្ទាល់ខ្លួន" នៅក្នុងមាត្រា១២៦២ កថាខណ្ឌទី ២ (ការរក្សាទុក និង ការគ្រប់គ្រងមតិក, ទោះបីជានៅមុនពេលយល់ព្រម ឬ បោះបង់សន្តតិកម្មក៏ដោយ សន្តតិជន ត្រូវគ្រប់គ្រងមតិកនោះ ដោយប្រុងប្រយ័ត្ន ដូចគ្នានឹងទ្រព្យសម្បត្តិផ្ទាល់ខ្លួនផងដែរ) ។ និងមានមាត្រាមួយចំនួនទៀតដូចជា:

- មាត្រា ៦០១ (កថាខណ្ឌទី ១) : កិច្ចសន្យាជួល
- មាត្រា ៦៤០ (កថាខណ្ឌទី ១) : កិច្ចសន្យាអាណត្តិ
- មាត្រា ៧២៩ (កថាខណ្ឌទី ២) : ការគ្រប់គ្រងដោយឃើញស្តាល
- មាត្រា ៧៧៦ : សិទ្ធិឃាត់ទុក

នៅក្នុងករណីខាងលើទាំងអស់នេះ កូនបំណុល រក្សាទុកនូវទ្រព្យសម្បត្តិរបស់អ្នកដទៃ។ ដូច្នេះ គាត់ ត្រូវថែរក្សាទ្រព្យសម្បត្តិនោះ ដោយប្រុងប្រយ័ត្នជាងទ្រព្យសម្បត្តិរបស់ខ្លួន។

ខ្លឹមសារនៃ "ការថែរក្សាដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ" ត្រូវបានគេសំរេចដោយផ្អែកលើគំនិតជាសាមញ្ញថា "តើការថែរក្សាបែបណា ដែលត្រូវធ្វើឡើងជាទូទៅ" ដោយផ្អែកទិដ្ឋភាពនៃគំនិតទូទៅនៃប្រតិបត្តិការណ៍។

☆ **កំរិតនៃការគ្រប់គ្រង មាន ៤ គឺ :**

១. ការទទួលខុសត្រូវជាដាច់ខាត : ទោះបីជាអ្នកគ្រប់គ្រងគ្មានកំហុសក៏ដោយ អោយតែមានការខូចខាត អ្នកគ្រប់គ្រង ត្រូវតែទទួលខុសត្រូវ។

២. ការគ្រប់គ្រងក្នុងនាមជាអ្នកគ្រប់គ្រងល្អ : អ្នកគ្រប់គ្រង ត្រូវគ្រប់គ្រងអោយបានល្អជាងទ្រព្យរបស់ខ្លួន និង ត្រូវទទួលខុសត្រូវក្នុងករណីប្រធានស័ក្តិ។

៣. ការគ្រប់គ្រងដូចជាទ្រព្យរបស់ខ្លួនឯង

៤. គ្មានការទទួលខុសត្រូវ :

## 1.2 អត្ថន័យនៃការថែរក្សា "រហូតដល់ពេលប្រគល់"

អ្នកលក់ ឬ អ្នកគ្រប់គ្រង មានករណីយកិច្ចថែរក្សាដោយប្រុងប្រយ័ត្ន រហូតដល់ពេលប្រគល់ មិនមែនត្រឹមតែកាលបរិច្ឆេទនោះទេ។ នៅក្នុងករណីដែល កាលបរិច្ឆេទ បានកន្លងផុតដោយគ្មានការអនុវត្តកាតព្វកិច្ច ដោយសារកំហុសរបស់កូនបំណុល នោះកូនបំណុល ត្រូវមានករណីយកិច្ចសងសំណងនៃការខូចខាត តាមផលកម្មវាសនា។ ផ្ទុយមកវិញ កាលបរិច្ឆេទ បានកន្លងផុតដោយគ្មានការអនុវត្តកាតព្វកិច្ច ដោយសារកំហុសរបស់ម្ចាស់បំណុល គេអាចចាត់ទុកថា កូនបំណុល ត្រូវគ្រប់គ្រងកម្មវត្ថុ ដោយប្រុងប្រយ័ត្នដូចគ្នានឹងទ្រព្យសម្បត្តិផ្ទាល់ខ្លួនផងដែរ។

## 2. តើអ្វីគឺជាវត្ថុដែលមិនជាក់លាក់?

វត្ថុដែលមិនជាក់លាក់ : គឺជាវត្ថុ ដែលគូភាគី មិនបានធ្វើការកំណត់ពីលក្ខណៈពិសេសនៃវត្ថុនោះនៅឡើយទេ (មាត្រា ៣១៥ កថាខណ្ឌទី ១)។ ផលិតផលទ្រង់ទ្រាយធំ គឺជាវត្ថុដែលមិនជាក់លាក់ ជាទូទៅ។ វត្ថុដែលមិនជាក់លាក់ គឺមានលទ្ធភាពអាចជំនួសបាន។

កូនបំណុល ត្រូវធ្វើការសំរេច ថាតើវត្ថុណា ដែលត្រូវផ្តល់ នៅមុនពេលប្រគល់។ សកម្មភាព ដែលជ្រើសរើសកម្មវត្ថុដែលត្រូវផ្តល់ និង រៀបចំដើម្បីប្រគល់ ត្រូវបានអោយឈ្មោះថា "ការកំណត់"។ ដោយផ្អែកលើមាត្រា ៣១៥ កថាខណ្ឌទី ២ វត្ថុដែលមិនជាក់លាក់ ត្រូវបានគេធ្វើការកំណត់

១) កូនបំណុល បានកំណត់កម្មវត្ថុដែលត្រូវផ្តល់ច្បាស់លាស់

២) កូនបំណុល បានបញ្ចប់រាល់សកម្មភាពចាំបាច់ដើម្បីផ្តល់នូវកម្មវត្ថុដែលបានកំណត់នោះ

ក្រោយពីធ្វើការកំណត់ហើយ កូនបំណុល មានករណីយកិច្ចផ្តល់នូវវត្ថុនោះ តែប៉ុណ្ណោះ (មាត្រា ៣១៥ កថាខណ្ឌទី ២)។

## 2.1 ការកំណត់នូវវត្ថុដែលមិនជាក់លាក់

ការកំណត់ នឹងមានអានុភាព នៅក្នុងករណីដែលលក្ខខណ្ឌទាំងពីរខាងក្រោមនេះ ត្រូវបានបំពេញ :

១) នៅពេលដែលកូនបំណុល បានកំណត់កម្មវត្ថុដែលត្រូវផ្តល់ច្បាស់លាស់

២) នៅពេលដែលកូនបំណុល បានបញ្ចប់សកម្មភាពចាំបាច់ដើម្បីផ្តល់នូវកម្មវត្ថុដែលបានកំណត់នោះ

### (១) នៅពេលដែលកូនបំណុល បានកំណត់កម្មវត្ថុដែលត្រូវផ្តល់ច្បាស់លាស់

កូនបំណុល ត្រូវធ្វើការកំណត់នូវអត្តសញ្ញាណវត្ថុ ដែលត្រូវផ្តល់ពីក្នុងចំណោមវត្ថុដែលមិនជាក់លាក់ដ៏ច្រើនសន្ធឹកសន្ធាប់ នៅមុនពេលធ្វើការប្រគល់ ព្រោះ គេ មិនអាចធ្វើការផ្ទេរកម្មសិទ្ធិ ដោយមិនបានកំណត់នូវកម្មវត្ថុនោះទេ។

ជាទូទៅ វា មិនមានលទ្ធភាពក្នុងការពិចារណាអំពី អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចនៃវត្ថុដែលមិនជាក់លាក់ នៅមុនពេលធ្វើការកំណត់អត្តសញ្ញាណកម្មវត្ថុ។ ក៏ប៉ុន្តែ ហានិភ័យ ត្រូវបានផ្ទេរក្រោយពីការកំណត់វត្ថុ ដែលមិនជាក់លាក់ នៅក្នុងលក្ខខណ្ឌជាក់លាក់មួយចំនួន។

វា មិនមានមាត្រាណាមួយជាក់លាក់ ដែលចែងអំពី មធ្យោបាយនៅក្នុងការកំណត់ឡើយ។ ក៏ប៉ុន្តែ វា មានលក្ខណៈចាំបាច់ ដែលថា យ៉ាងហោចណាស់ កូនបំណុល បានរៀបចំដាក់ដោយឡែកនូវវត្ថុជាកលាក់មួយចំនួន ដើម្បីធ្វើការបែងចែងពីវត្ថុដទៃទៀត។ ជាគោលការណ៍ គេ ចាត់ទុកដូចជា ការកំណត់អត្តសញ្ញាណដែរ នៅក្នុងករណីដែល កូនបំណុល បានរើចេញនូវវត្ថុជាក់លាក់មួយចំនួន ឬ ធ្វើគំនូសសំគាល់នៅលើវត្ថុមួយចំនួន ដើម្បីបែងចែងពីវត្ថុដទៃទៀត។ ឧទាហរណ៍ ប្រសិនបើអ្នកផ្គត់ផ្គង់សំភារៈអគ្គិសនី បានរៀបចំទុកដាក់ដាច់ដោយឡែក ឬ ធ្វើគំនូសសំគាល់នៅលើទូរទស្សន៍ចំនួន ១០ គ្រឿង ដែលត្រូវប្រគល់ នោះ គេ អាចនិយាយបានថា គាត់ បានកំណត់កម្មវត្ថុដែលត្រូវផ្តល់ច្បាស់លាស់។

### (២) នៅពេលដែលកូនបំណុល បានបញ្ចប់សកម្មភាពចាំបាច់ ដើម្បីផ្តល់នូវកម្មវត្ថុដែលបានកំណត់

"សកម្មភាពចាំបាច់ដើម្បីផ្តល់" នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៣១៥ មានន័យថា កូនបំណុល បានធ្វើសកម្មភាពក្នុងលក្ខខណ្ឌមួយ ដែល គាត់ អាចប្រគល់បាននៅគ្រប់ពេលវេលា ប្រសិនបើម្ចាស់បំណុល ចង់បាន។

ថាតើសកម្មភាពណាមួយ ដែលឆ្លើយតបទៅនឹង "សកម្មភាពចាំបាច់ដើម្បីផ្តល់" ត្រូវបានសំរេចដោយផ្អែកទៅលើខ្លឹមសារនៃកាតព្វកិច្ចប្រគល់។ កាតព្វកិច្ចប្រគល់កម្មវត្ថុ គឺមានពីរប្រភេទ :

(ក) កាតព្វកិច្ចដែលកូនបំណុលត្រូវយកទៅប្រគល់អោយ

(ខ) កាតព្វកិច្ចដែលម្ចាស់បំណុលត្រូវមកយក

***ក) នៅក្នុងករណីកាតព្វកិច្ចដែលកូនបំណុលត្រូវយកទៅប្រគល់អោយ***

មាត្រា ៤៤៥ វាក្យខណ្ឌទី ២ បានចែងថា កាតព្វកិច្ចក្រៅពីកាតព្វកិច្ចប្រគល់វត្ថុ ដែលបានកំណត់ជាក់លាក់ ការអនុវត្តកាតព្វកិច្ច ត្រូវធ្វើឡើងនៅលំនៅឋានបច្ចុប្បន្នរបស់ម្ចាស់ បំណុល។ កាតព្វកិច្ចនេះ ត្រូវបានគេហៅថា "កាតព្វកិច្ចដែលកូនបំណុលត្រូវយកទៅប្រគល់ អោយ"។

នៅក្នុងករណីនេះ កូនបំណុល ត្រូវយកកម្មវត្ថុទៅលំនៅឋានបច្ចុប្បន្នរបស់ម្ចាស់បំណុល។ កាតព្វកិច្ច ប្រភេទនេះ ត្រូវបានគេហៅថា "កាតព្វកិច្ចដែលកូនបំណុលត្រូវយកទៅប្រគល់អោយ"។

ទាក់ទងនឹងកាតព្វកិច្ចដែលកូនបំណុលត្រូវយកទៅអោយ មានតែករណីដែលកូនបំណុល បានស្នើផ្តល់ការ អនុវត្តកាតព្វកិច្ចពិតប្រាកដ នៅលំនៅឋានរបស់ម្ចាស់បំណុលតែប៉ុណ្ណោះ ទើបត្រូវបានគេចាត់ទុកថា "បានបញ្ចប់ សកម្មភាពចាំបាច់"។ នៅក្នុងករណីដែលកូនបំណុល បញ្ជាអោយភ្នាក់ងារដឹកជញ្ជូន ធ្វើការផ្ទេរកម្មវត្ថុ នោះ ការកំណត់ មិនត្រូវកើតឡើងឡើយ បើគ្មានការស្នើផ្តល់កម្មវត្ថុជាក់ស្តែងដោយភ្នាក់ងារនោះ នៅលំនៅឋានរបស់ ម្ចាស់បំណុល។ ដូច្នេះ នៅក្នុងករណីដែលកម្មវត្ថុ ត្រូវបានបំផ្លាញ បាត់បង់ ឬ ខូចខាតនៅក្នុងការដឹកជញ្ជូន នោះ កូនបំណុល ត្រូវទទួលបន្ទុកកាតព្វកិច្ច ផ្ទេរវត្ថុដែលមានប្រភេទដូចគ្នា ព្រោះ គាត់ មិនបានកំណត់វត្ថុដែល មិនជាក់ លាក់នៅឡើយទេ។

***(ខ) នៅក្នុងករណីកាតព្វកិច្ចដែលម្ចាស់បំណុលត្រូវមកយក:***

មាត្រា ៤៤៥ វាក្យខណ្ឌទី ១ មានចែងថា ប្រសិនបើគ្មានការព្រមព្រៀងគ្នាផ្សេងអំពី កន្លែងដែលត្រូវសង ទេ ការប្រគល់វត្ថុដែលបានកំណត់ជាក់លាក់ ត្រូវធ្វើឡើង នៅទីកន្លែងដែល វត្ថុនោះបានស្ថិតនៅនាពេលសិទ្ធិលើ បំណុលកើតឡើង។ នេះ ត្រូវបានគេហៅថា "កាតព្វកិច្ចដែល ម្ចាស់បំណុលត្រូវមកយក"។ ឧទាហរណ៍ អ្នកលក់ **ក** បានលក់ថូបុរាណអោយទៅ **ខ**។ នៅពេល បង្កើតកិច្ចសន្យា **គ** បានរក្សាទុកថូបុរាណនោះសំរាប់ **ក**។ នៅក្នុងករណី នេះ **ខ** ត្រូវមកកន្លែង របស់ **គ** ដើម្បីយកថូបុរាណនោះ។

នៅក្នុងករណីនៃកាតព្វកិច្ចដែលម្ចាស់បំណុល ត្រូវមកយក កូនបំណុល ត្រូវបង្កើតឱ្យមានលក្ខខណ្ឌមួយ ដែលគាត់ អាចផ្ទេរកម្មវត្ថុអោយទៅម្ចាស់បំណុល នៅពេលណាក៏បាន អោយតែម្ចាស់បំណុល មកទទួលយក។ ជាក់លាក់ជាងនេះទៅទៀត ក្រោយពេលដែលកូនបំណុល បានកំណត់កម្មវត្ថុដែលត្រូវផ្តល់ច្បាស់លាស់ហើយ គាត់ ត្រូវរៀបចំដើម្បីប្រគល់ ដូចជា វេចខ្ចប់ ឬ ច្រកចូលក្នុងកេស។

វា អាស្រ័យទៅលើការបកស្រាយរបស់កម្ពុជា ថាតើកូនបំណុល ត្រូវជូនដំណឹងថា គាត់ បានរៀបចំរួចរាល់ ដើម្បីផ្តល់ជូនម្ចាស់បំណុលហើយ ឬ ក៏មិនចាំបាច់។ សំរាប់កាតព្វកិច្ចដែលមាន កាលបរិច្ឆេទកំណត់សង កូនបំណុល មិនចាំបាច់ជូនដំណឹងទៅម្ចាស់បំណុលទេ ព្រោះម្ចាស់បំណុល ត្រូវមកទទួលយក នៅកាលបរិច្ឆេទ ដែលបានកំណត់

ជាក់លាក់នោះ ។ ផ្ទុយទៅវិញប្រសិនបើ ភាគី មិនបានកំណត់កាលបរិច្ឆេទទេ គេ អាចបកស្រាយថា កូនបំណុល ត្រូវទទួលខុសត្រូវក្នុងការជូន ដំណឹងថា កូនបំណុល បានរៀបចំដើម្បីផ្ទេររួចរាល់ហើយ ។

## 2.2 អានុភាពនៃការកំណត់

ដោយផ្អែកលើមាត្រា ៣១៥ កថាខណ្ឌទី ២ កូនបំណុល មានករណីយកិច្ចផ្ដល់នូវវត្ថុ ដែលត្រូវបានកំណត់ច្បាស់លាស់នោះ ក្រោយពីដែលបានកំណត់រួចរាល់ហើយ ។

ហើយ អានុភាពផ្សេងមួយទៀតនៃការកំណត់ ត្រូវបានចែងដោយមាត្រាផ្សេងទៀត ឬ ការបកស្រាយ ។

### ១. ផ្ទេរកម្មសិទ្ធិ

ក្នុងករណីដែលការ ធ្វើការកំណត់បានចប់សព្វគ្រប់ហើយ នោះមានន័យថា ការផ្ទេរកម្មសិទ្ធិ ក៏ត្រូវបានផ្ទេររួចរាល់ហើយដែរ ។

ទោះបីជាការផ្ទេរ ត្រូវមានអានុភាព ដោយផ្អែកលើការព្រមព្រៀងរវាងភាគីក៏ដោយ ក៏គេ មិនអាចធ្វើការផ្ទេរកម្មសិទ្ធិនៃវត្ថុដែលមិនជាក់លាក់ដែរ ។ ដូច្នេះ នៅពេលដែល ការកំណត់ មានអានុភាព គេ អាចចាត់ទុកថា កម្មសិទ្ធិ ក៏ត្រូវបានផ្ទេរដែរ ។

### ២. ផ្ទេរនូវហានិភ័យ ដែលស្ថិតនៅក្នុងលក្ខខ័ណ្ឌជាក់លាក់មួយចំនួន

មាត្រា ៤១៨ កថាខណ្ឌទី ២ បានចែងថា ក្រោយពេលបានកំណត់កម្មវត្ថុដែលត្រូវផ្ដល់ ហើយ បញ្ញត្តិនៃមាត្រា ៤១៦ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។ បន្ទាប់មក មាត្រា ៤១៦ កថាខណ្ឌទី ១ បានចែងថា កូនបំណុលត្រូវទទួលបន្ទុកហានិភ័យ នៅពេលដែលកម្មវត្ថុ ត្រូវផ្ទេរ កម្មសិទ្ធិលើវត្ថុដែលបានកំណត់ជាក់លាក់ ។ ទន្ទឹមនឹងនេះ មាត្រា ៤១៦ កថាខណ្ឌទី ២ ចែងថា ហានិភ័យ ត្រូវផ្ទេរទៅម្ចាស់បំណុល តាមរយៈចំណុច ក រហូតដល់ចំណុច ឥ ។

### ៣. កាតព្វកិច្ចផ្ទេរ - សិទ្ធិផ្លាស់ប្ដូរ

កូនបំណុល មានករណីយកិច្ចផ្ដល់នូវវត្ថុដែលត្រូវបានកំណត់ច្បាស់លាស់តែប៉ុណ្ណោះ នៅក្រោយពេលដែលបានកំណត់រួចហើយ ( មាត្រា ៣១៥ កថាខណ្ឌទី ២) ។ ជាការពិត សិទ្ធិផ្លាស់ប្ដូរកម្មវត្ថុ ដែលត្រូវប្រគល់ អាចអនុវត្តបានចំពោះវត្ថុដែលមិនបានធ្វើការកំណត់ជាក់លាក់តែ ប៉ុណ្ណោះ ផ្ទុយទៅវិញចំពោះ វត្ថុដែលបានកំណត់ជាក់លាក់ មិនអាចអនុវត្តសិទ្ធិនេះបានទេ ព្រោះ វត្ថុដែលបានកំណត់ជាក់លាក់ គឺជាប្រភេទវត្ថុ ដែលមានតែមួយ ហើយមិនអាចធ្វើការផ្លាស់ប្ដូរបាន ។

ដូច្នេះ ប្រសិនបើកម្មវត្ថុ ត្រូវបានបំផ្លាញ ធ្វើអោយបាត់បង់ ឬ ខូចខាត ដោយកំហុសរបស់កូនបំណុល នៅក្រោយពេលកំណត់ នោះ កូនបំណុល ត្រូវទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ច ។ ក៏ប៉ុន្តែ ស្ទើតែគ្រប់ករណី

នៃវត្ថុដែលត្រូវបានគេកំណត់ជាក់លាក់ គឺនៅតែមានលទ្ធភាព ដែលគេ អាចយកវត្ថុដែលមិនជាក់លាក់ មកធ្វើការកំណត់ ទោះបីជានៅក្រោយវត្ថុ ដែលត្រូវផ្តល់អោយ ត្រូវបានគេធ្វើការកំណត់ហើយក៏ដោយ។ នៅក្នុងករណីនេះ គេ អាចគិតថា កូនបំណុល ត្រូវបានអនុញ្ញាតអោយយកកម្មវត្ថុថ្មី ហើយ ធ្វើការប្រគល់។ ចំណុចនេះ ត្រូវបានគេហៅថា "សិទ្ធិផ្លាស់ប្តូររបស់កូនបំណុល"។

ឧទាហរណ៍ អ្នកផ្គត់ផ្គង់សំភារៈអគ្គីសនី ក បានលក់ទូរទស្សន៍ ១០ គ្រឿងទៅអោយ ខ ហើយ ពួកគេ បានព្រមព្រៀងគ្នាថា ខ ត្រូវមកទទួលយកទូរទស្សន៍នោះ នៅកាលបរិច្ឆេទកំណត់។ បន្ទាប់មក ក បានរៀបចំទូរទស្សន៍ ១០ គ្រឿង ដាក់ដាច់ដោយឡែកដើម្បីប្រគល់ ហើយ បានខ្ចប់។ ក៏ប៉ុន្តែ នៅក្រោយពេលធ្វើការកំណត់រួចហើយ ទូរទស្សន៍ទាំងនោះ ត្រូវបានធ្វើ អោយខូចខាត ដោយសារកំហុសរបស់ ក។ នៅក្នុងករណីនេះ តើ ក អាចយកទូរទស្សន៍ផ្សេងទៀត ដែលមានប្រភេទដូចគ្នា ហើយ ធ្វើការប្រគល់អោយ ខ ដែរ ឬ ទេ ? ឬ ក ត្រូវទទួលខុសត្រូវចំពោះអលទ្ធភាព នៅក្នុងការអនុវត្ត ?

នៅករណីដែល មានកិច្ចព្រមព្រៀងពិសេសរវាងកូនបំណុល និង ម្ចាស់បំណុល ទាក់ទងនឹងសិទ្ធិផ្លាស់ប្តូរ កូនបំណុល អាចធ្វើការកំណត់កម្មវត្ថុថ្មី ហើយ ធ្វើការប្រគល់ ដោយផ្អែកទៅ លើការព្រមព្រៀង។

បញ្ហា គឺថាតើកូនបំណុល អាចប្តូរកម្មវត្ថុដោយគ្មានការយល់ព្រមរបស់ម្ចាស់បំណុលបានដែរ ឬ ទេ នៅក្រោយពេលធ្វើការកំណត់រួចហើយ។ គំនិតមួយដែលអាចមាន គឺបដិសេធនូវសិទ្ធិផ្លាស់ប្តូរ ដោយផ្អែកទៅលើការបកស្រាយជាលក្ខណៈទំរង់នៃមាត្រា ៣១៥ កថាខណ្ឌទី ២ ដែលចែងថា កូនបំណុល មានករណីយកិច្ចផ្តល់នូវវត្ថុនោះ**តែប៉ុណ្ណោះ** នៅក្រោយពេលកំណត់រួចរាល់ហើយ។ ក៏ប៉ុន្តែ ប្រព័ន្ធនៃការកំណត់វត្ថុ គឺជាការអនុគ្រោះដល់កូនបំណុល ក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន ហើយ វា មិនមែនចាំបាច់ថា ការកំណត់កម្មវត្ថុដែលមិនជាក់លាក់ មានន័យថា ជាការផ្លាស់ប្តូរកាតព្វកិច្ចពីវត្ថុ ដែលមិនជាក់លាក់ ទៅជាវត្ថុដែលបានកំណត់ជាក់លាក់នោះទេ។ ឬនិយាយម្យ៉ាងទៀត ទោះបីជា វត្ថុ ដែលមិនជាក់លាក់ ត្រូវបានកំណត់ក៏ដោយ ក៏វា មិនមានន័យជាចាំបាច់ថា វត្ថុដែលមិនជាក់លាក់នោះ បានក្លាយជាវត្ថុ ដែលបានកំណត់ជាក់លាក់នោះទេ។ ដូច្នេះ គេ ប្រហែលជាអាចគិតថា កូនបំណុល អាចយកកម្មវត្ថុដែលមិនជាក់លាក់ថ្មី ផ្សេងទៀត មកធ្វើការកំណត់រួចហើយប្រគល់ ដរាបណាវត្ថុ ដែលមិនជាក់លាក់ ដែលមានប្រភេទដូចគ្នា នៅតែមាន។

## ៣.២ គោលការណ៍ទូទៅនៃការទទួលបន្ទុកហានិភ័យ

ក្នុងកិច្ចសន្យាអញ្ញមញ្ញ ដែលមានអត្ថន័យផ្ទេរកម្មសិទ្ធិលើវត្ថុកំណត់ជាក់លាក់ ឬ មិនជាក់លាក់ ហើយនៅពេលដែលវា ក្លាយជាអលទ្ធភាព ឬ បាត់បង់វត្ថុនោះ ដោយសារការខូចខាត ដែលមិនមែនជាកំហុសរបស់កូនបំណុល តើការទទួលបន្ទុកហានិភ័យ ត្រូវធ្លាក់ទៅលើភាគីណាមួយ? ហើយលក្ខខណ្ឌណា ដែលតម្រូវអោយមានការទទួលបន្ទុក ឬ រួចផុតពីការ ទទួលបន្ទុកហានិភ័យ?

### ៣.២.១ ករណីផ្ទេរកម្មសិទ្ធិលើវត្ថុដែលបានកំណត់ជាក់លាក់ ( មាត្រា ៤១៦ កថាខណ្ឌទី ១)

នៅក្នុងកិច្ចសន្យាអញ្ញមញ្ញ ភាគី មានកាតព្វកិច្ចទៅវិញទៅមក ឧទាហរណ៍ដូចជា កាតព្វកិច្ចផ្ទេរ និង កាតព្វកិច្ចបង់ប្រាក់ជាដើម។ កាតព្វកិច្ចផ្ទេរកម្មវត្ថុ អាចត្រូវបានបែងចែងជាពីរប្រភេទ គឺវត្ថុដែលបានកំណត់ ជាក់លាក់ និង វត្ថុដែលបានកំណត់តាមប្រភេទ។ ឧទាហរណ៍នៃវត្ថុដែលបានកំណត់ជាក់លាក់ មានដូចជា ផ្ទាំង បុរាណ នាឡិកាបុរាណ ឬ រូបគំនូរពិសេស ។ល។

នៅពេលកិច្ចសន្យាផ្ទេរកម្មសិទ្ធិនៃវត្ថុដែលបានកំណត់ជាក់លាក់ ត្រូវបានបង្កើតឡើង ហើយ នៅក្នុងករណី ដែលកម្មវត្ថុ ត្រូវបានធ្វើអោយខូចខាត ឬ បាត់បង់ ដែលមិនមែនជាកំហុសរបស់ភាគីណាមួយទេ ហើយនាំអោយ ក្លាយជាអលទ្ធភាពក្នុងអនុវត្ត។ ករណីនេះ កូនបំណុល ត្រូវទទួលបន្ទុកហានិភ័យ។ វា មានន័យថា កូនបំណុល (អ្នកលក់) មិនអាចទាមទារតាវកាលិកតបពីអ្នកទិញបានទេ ពោលគឺកូនបំណុល មិនអាចទាមទារអោយអ្នកទិញ បង់ថ្លៃបានឡើយ។ ជាចុងក្រោយ ភាគីអ្នកលក់ ត្រូវបាត់បង់នូវវត្ថុជាកម្មវត្ថុនៃកិច្ចសន្យា ជាគោលការណ៍ ហើយ វា មានន័យថា កូនបំណុល ត្រូវទទួលបន្ទុកហានិភ័យនៃការបាត់បង់ ព្រោះអ្នកលក់ គឺជាអ្នកកាន់កាប់ ក្តាប់ទុក និង គ្រប់គ្រងលើកម្មវត្ថុនោះ នៅមុនពេលធ្វើការប្រគល់អោយទៅអ្នកទិញ។ រីឯអ្នកទិញវិញ ក៏មិនអាចទាមទារការ ខូចខាតពីអ្នកលក់បានឡើយ ព្រោះថា ការខូចខាតនៃវត្ថុជាក់លាក់នោះ គឺមិនមែនកំហុសរបស់អ្នកលក់ ។

ការទទួលបន្ទុកហានិភ័យ នៅក្នុងករណីវត្ថុដែលបានកំណត់ជាក់លាក់ ត្រូវបំពេញតាមលក្ខខណ្ឌ ដូចតទៅ :

- នៅក្នុងកិច្ចសន្យាទ្វេភាគី
- កម្មវត្ថុនៃការប្រគល់ គឺជាការផ្ទេរកម្មសិទ្ធិ លើវត្ថុដែលបានកំណត់ជាក់លាក់
- កាតព្វកិច្ចប្រគល់វត្ថុ បានក្លាយជាអលទ្ធភាព

    លក្ខខណ្ឌដែលកាតព្វកិច្ច បានក្លាយជាលទ្ធភាព គឺមិនមានចែងនៅក្នុងមាត្រាច្បាស់លាស់ ទេ ប៉ុន្តែ ការទទួលបន្ទុកហានិភ័យ គឺជាវិធានមួយ ដែលធ្វើអោយសំរេចនូវភាពយុត្តិធម៌ នៅពេលដែល កាតព្វកិច្ចមួយ បានក្លាយជាអលទ្ធភាព។

- អលទ្ធភាពនៅក្នុងការអនុវត្តកាតព្វកិច្ច គឺមិនមែនជាកំហុសរបស់ភាគីទាំងសងខាង

ប្រសិនបើ លក្ខខណ្ឌទាំងអស់នេះ ត្រូវបានបំពេញ កូនបំណុល (=អ្នកលក់) មិនអាចទាមទារតាវកាលិក តបបានទេ។ ទន្ទឹមនឹងនេះ ម្ចាស់បំណុល (=អ្នកទិញ) អាចរំលាយកិច្ចសន្យាបាន (មាត្រា ៤០៧ និង មាត្រា ៤០៨ កថាខណ្ឌទី ១ ចំណុច គ)

| ករណីសិក្សា |
| --- |
| **ក** បានបង្កើតកិច្ចសន្យាលក់ផ្ទាំងបុរាណទៅអោយ **ខ** នៅក្នុងតំលៃ ៥០.០០០ ដុល្លា។ ក្រោយពីការបង្កើតកិច្ចសន្យា ផ្ទាំងបុរាណនោះ ត្រូវបានធ្វើអោយខូចខាត ដោយគ្មានកំហុសរបស់ **ក** ឬ **ខ**។ តើ **ក** អាចអះអាងអ្វី ចំពោះ **ខ** បាន នៅក្នុងករណីនេះ ? ហើយចំពោះ **ខ** វិញ ? |

【សេចក្តីសន្និដ្ឋាន និង មូលហេតុសំអាង】

នៅក្នុងករណីនេះ កាតព្វកិច្ចរបស់ ក ត្រូវរលត់ ព្រោះ កាតព្វកិច្ចផ្ទេរ បានក្លាយជាអលទ្ធភាព ដោយគ្មានកំហុសរបស់ ក ( មាត្រា ៤១៥) ។

ប្រភេទនៃកាតព្វកិច្ច ដែល ក ត្រូវទទួលបន្ទុក គឺជាកាតព្វកិច្ចផ្ទេរវត្ថុដែលបានកំណត់ជាក់លាក់ ( មាត្រា ៣១៤) និង កាតព្វកិច្ចរបស់ ក បានក្លាយជាអលទ្ធភាព ដោយគ្មានកំហុសរបស់ភាគីណាមួយឡើយ ។ នៅក្នុងករណីនេះ មាត្រា ៤១៦ កថាខណ្ឌទី ១ ត្រូវយកមកអនុវត្ត ។

មាត្រា ៤១៦ កថាខណ្ឌទី ១ បានចែងថា នៅក្នុងករណីដែលកាតព្វកិច្ចក្លាយជាលទ្ធភាព ដោយសារការបំផ្លាញ ការបាត់បង់ ឬ ការខូចខាត ដោយគ្មានកំហុសរបស់ភាគីនៅក្នុងកិច្ចសន្យាអញ្ញមញ្ញ កូនបំណុល ត្រូវទទួលបន្ទុកហានិភ័យ ហើយ មិនអាចទាមទារតាវកាលិកតបបានទេ ។ ឬនិយាយម្យ៉ាងទៀត តាវកាលិកតប ដែល ខ ត្រូវទទួលបន្ទុក គឺបង់ប្រាក់ថ្លៃទិញ ហើយ វា ត្រូវរលត់ ។ ដូច្នេះ ក មិនអាចទាមទារអោយ ខ បង់ប្រាក់ថ្លៃទិញបានទេ ហើយ ការបាត់បង់នេះ គឺជាបន្ទុករបស់ ក ដែលជាកូនបំណុល ។ ក បាត់បង់ផ្ទះបុរាណ ដែលមានតំលៃ ៥០.០០០ ដុល្លា ។ នេះ មានន័យថា "ហានិភ័យ" ។

ផ្ទុយទៅវិញ ខ អាចរំលាយកិច្ចសន្យា ដើម្បីទទួលបានប្រាក់ថ្លៃទិញមកវិញ ប្រសិនជា គាត់ បានបង់ប្រាក់ថ្លៃទិញរួចរាល់ហើយ ។ ក៏ប៉ុន្តែ ខ មិនអាចទាមទារសំណងនៃការខូចខាតបានទេ ព្រោះ ក មិនទទួលខុសត្រូវចំពោះអលទ្ធភាពនេះទេ ។

### ៣.២.២ ករណីដែលផ្ទេរកម្មសិទ្ធិនៃវត្ថុដែលមិនបានកំណត់ជាក់លាក់ ( មាត្រា ៤១៨ កថាខណ្ឌទី១)

នៅក្នុងករណីដែល កម្មវត្ថុនៃកិច្ចសន្យាអញ្ញមញ្ញ មានអត្ថន័យផ្ទេរកម្មសិទ្ធិលើវត្ថុ ដែលមិនបានកំណត់ជាក់លាក់ នៅមុនពេលធ្វើការកំណត់ ហើយ កូនបំណុល (=អ្នកលក់) បានធ្វើអោយខូចខាត ឬ បាត់បង់ ដោយសារខ្លួនមិនមានកំហុសក៏ដោយ ក៏អ្នកលក់ ត្រូវមានកាតព្វកិច្ចប្រគល់វត្ថុដែលមិនបានកំណត់ជាក់លាក់នោះ អោយទៅម្ចាស់បំណុល (=អ្នកទិញ) ដែរ ។ វា មានន័យថា កាតព្វកិច្ចនោះ មិនត្រូវរលត់ឡើយ ហើយ កូនបំណុលនោះ នៅតែមានកាតព្វកិច្ចអនុវត្ត ។

ឧទាហរណ៍ : ក បានលក់ស្រូវ ១ តោន ទៅអោយ ខ ដោយបានបង្កើតកិច្ចសន្យាលក់ទិញ ។ នៅមុនពេលប្រគល់ស្រូវទៅអោយអ្នកទិញ ស្រូវនោះ ត្រូវបានឆេះអស់ ដោយសារការលួចដុតរបស់តតិយជន ។ នៅក្នុងករណីនេះ អ្នកលក់ ត្រូវទទួលបន្ទុកហានិភ័យ ហើយ កាតព្វកិច្ចរបស់អ្នកលក់ មិនត្រូវរលត់ឡើយ ។ ដូច្នេះ អ្នកលក់ ត្រូវរកស្រូវ ១ តោន សារជាថ្មី ហើយ ប្រគល់ទៅអោយអ្នកទិញ ។

ការទទួលបន្ទុកហានិភ័យ ត្រូវបំពេញតាមលក្ខខណ្ឌដូចតទៅ :

ក. នៅក្នុងកិច្ចសន្យាទ្វេភាគី

ខ. កម្មវត្ថុនៃកិច្ចសន្យា គឺជាវត្ថុដែលមិនបានកំណត់ជាក់លាក់

គ. មុនពេលធ្វើការកំណត់

ឃ. បានបាត់បង់ ឬ ខូចខាត ដោយមិនមានកំហុសរបស់កូនបំណុល ។

### ៣.៣. ករណីលើកលែង

ទោះបីការទទួលបន្ទុកហានិភ័យ ត្រូវកើតឡើងចំពោះកូនបំណុលជាទូទៅក៏ដោយ ក៏មានករណីលើកលែងខ្លះ ដែលហានិភ័យ ត្រូវបានផ្ទេរទៅអោយម្ចាស់បំណុលដែរ ។

**១. នៅពេលហានិភ័យ ត្រូវបានផ្ទេរទៅម្ចាស់បំណុល នៅក្នុងកិច្ចសន្យាទ្វេភាគី ដែលមានកម្មវត្ថុ ផ្ទេរវត្ថុដែលបានកំណត់ជាក់លាក់ ( មាត្រា ៤១៦ កថាខណ្ឌទី ២)**

ជាធម្មតា កូនបំណុល គ្រប់គ្រងលើវត្ថុ ដែលបានកំណត់ជាក់លាក់ រហូតដល់ពេលប្រគល់ ។ ដូច្នេះ ក្រមរដ្ឋប្បវេណី បានចែងថា កូនបំណុល ត្រូវទទួលបន្ទុកហានិភ័យ ដែលនេះ គឺជាគោលការណ៍ ។

ក៏ប៉ុន្តែ នៅពេលដែលកម្មវត្ថុ បានស្ថិតនៅក្រោមការគ្រប់គ្រងជាក់ស្តែងរបស់ម្ចាស់បំណុល ឬក៏ វា អាចសមមូលនឹងករណីដែលកម្មវត្ថុ បានស្ថិតនៅក្រោមការគ្រប់គ្រងរបស់ម្ចាស់បំណុល នោះ ហានិភ័យ ត្រូវបានចាត់ទុកថា បានផ្ទេរពីកូនបំណុល ទៅម្ចាស់បំណុល ។

ដូច្នេះ មាត្រា ៤១៦ កថាខណ្ឌទី ២ បានចែងថា ជាគោលការណ៍ ហានិភ័យ ត្រូវបានផ្ទេរទៅម្ចាស់បំណុល នៅពេលណាមួយ ក្នុងចំណោមពេលដែលបានកំណត់ដូចខាងក្រោម :

ក - នៅពេលដែលប្រគល់ជាកម្មវត្ថុទៅម្ចាស់បំណុល ឬ ពេលដែលចុះបញ្ជីផ្ទេរអចលនវត្ថុ ឬ ពេលផ្សេងទៀត ដែលយល់ថា ការគ្រប់គ្រងជាក់ស្តែងលើវត្ថុដែលជាកម្មវត្ថុ ត្រូវបានផ្ទេរទៅម្ចាស់បំណុល ( មាត្រា ៤១៦ កថាខណ្ឌទី ២ ចំណុច ក) : នៅក្នុងករណីនេះ ការគ្រប់គ្រងជាក់ស្តែងលើកម្មវត្ថុ អាចត្រូវបានគិតថា បានផ្ទេរទៅម្ចាស់បំណុល ដូច្នេះ ម្ចាស់បំណុល ត្រូវទទួលបន្ទុកហានិភ័យជាទូទៅ ។ នៅក្នុងករណីដែលកម្មវត្ថុ គឺជាចលនវត្ថុ វា មិនមានលទ្ធភាពក្នុងការពិចារណាអំពី ការទទួលបន្ទុកហានិភ័យទេ ព្រោះកាតព្វកិច្ចផ្ទេរចលនវត្ថុ ត្រូវរលត់ជាមួយនឹងការអនុវត្តកាតព្វកិច្ចរបស់កូនបំណុល ។ ដូច្នេះ កម្មវត្ថុនៅក្នុង មាត្រា ៤១៦ កថាខណ្ឌទី ២ ចំណុច ក ត្រូវបានចាត់ទុកថា ជា អចលនវត្ថុ នៅក្នុងបរិបទនេះ ។

ខ - ពេលដែលកូនបំណុល បានស្នើផ្តល់ការអនុវត្តកាតព្វកិច្ចត្រឹមត្រូវ ប៉ុន្តែម្ចាស់បំណុល បដិសេធមិនទទួលការប្រគល់នោះ ( មាត្រា ៤១៦ កថាខណ្ឌទី ២ ចំណុច ខ) ។

ចំណុចនេះ បានចែងថា នៅក្នុងករណីដែលម្ចាស់បំណុល បដិសេធមិនទទួលការប្រគល់ ទោះបីជាកូនបំណុល បានស្នើផ្តល់ការអនុវត្តកាតព្វកិច្ចត្រឹមត្រូវហើយនោះ ម្ចាស់បំណុល ត្រូវទទួលបន្ទុក

ហានិភ័យ ដោយមិនបានទទួលកម្មវត្ថុ ព្រោះម្ចាស់បំណុល អាចនឹងបានទទួលកម្មវត្ថុ នៅពេលដែលមានការស្នើផ្តល់ការអនុវត្តកាតព្វកិច្ច។

គ - ពេលដែលម្ចាស់បំណុល ប្រកែកមិនព្រមទទួលការអនុវត្តរបស់កូនបំណុល ដោយគ្មានមូលហេតុត្រឹមត្រូវ ឧទាហរណ៍ដូចជា ម្ចាស់បំណុល ប្រកាសទៅកូនបំណុលថា ខ្លួនមិនទទួលនូវការអនុវត្តរបស់កូនបំណុលឡើយ ( មាត្រា ៤១៦ កថាខណ្ឌទី ២ ចំណុច គ) ។

វា ហាក់ដូចជា ចំណុច (ខ) និង ចំណុច (គ) បានចែងពីករណីដូចគ្នា ប៉ុន្តែ ចំណុច (គ) បានចែងថា ម្ចាស់បំណុល បានបដិសេធក្នុងការទទួលយកការស្នើផ្តល់ការអនុវត្តកាតព្វកិច្ច ដោយគ្មានមូលហេតុត្រឹមត្រូវជាមុន។ នៅពេលដែលម្ចាស់បំណុល បានប្រកាសថា គាត់ នឹងមិនទទួលការស្នើផ្តល់ការអនុវត្តកាតព្វកិច្ច នោះ វា ហាក់ដូចជាខ្ជះខ្ជាយពេលវេលា និង ការខំប្រឹងប្រែង របស់កូនបំណុលដែលបន្តការរៀបចំតទៅទៀត។ ដូច្នេះ ក្រមរដ្ឋប្បវេណី ចែងថា វា មានលក្ខណៈគ្រប់គ្រាន់ សំរាប់កូនបំណុល ក្នុងការជូនដំណឹងទៅម្ចាស់បំណុលថា ការរៀបចំដើម្បីអនុវត្ត ត្រូវបានបញ្ចប់ ហើយទាមទារឱ្យម្ចាស់បំណុលយល់ព្រមក្នុងការទទួលយកការអនុវត្តកាតព្វកិច្ចនៅក្នុងករណីនេះ ( មាត្រា ៤៥៤ វាក្យខណ្ឌទី ២)។ ឬនិយាយម្យ៉ាងទៀត នៅក្នុងករណីចំណុច (ខ) កូនបំណុល ចាំបាច់ត្រូវស្នើផ្តល់ការអនុវត្តកាតព្វកិច្ចរបស់ខ្លួន នៅកាលបរិច្ឆេទដែលបានកំណត់ ដើម្បីផ្ទេរនូវហានិភ័យ ប៉ុន្តែនៅក្នុងករណីចំណុច (គ) អ្វីដែលគាត់ ត្រូវធ្វើ គឺការផ្តល់នូវការជូនដំណឹងថា ការរៀបចំដើម្បីអនុវត្តកាតព្វកិច្ច ត្រូវបានបញ្ចប់ និង ទាមទារអោយម្ចាស់បំណុលយល់ព្រមក្នុងការទទួលយកការអនុវត្តកាតព្វកិច្ច ជំនួសអោយការស្នើផ្តល់ការអនុវត្តកាតព្វកិច្ចជាក់ស្តែង។

**២. នៅពេលដែលកម្មវត្ថុ គឺជាវត្ថុដែលមិនបានកំណត់ជាក់លាក់**

នៅក្នុងករណីដែល កម្មវត្ថុនៃកិច្ចសន្យាអញ្ញមញ្ញ មានអត្ថន័យផ្ទេរកម្មសិទ្ធិលើវត្ថុ ដែលមិនបានកំណត់ជាក់លាក់ ហើយ បានកំណត់កម្មវត្ថុ ដែលត្រូវផ្តល់ហើយ នោះបញ្ញត្តិនៃមាត្រា ៤១៦ នឹងត្រូវយកមកអនុវត្តដូចគ្នាផងដែរ ( មាត្រា ៤១៨ កថាខណ្ឌទី ២)។ ប្រសិនបើ មិនមានការកំណត់ផ្សេងក្នុងកិច្ចសន្យាទេ ការផ្ទេរបន្ទុកហានិភ័យ គឺត្រូវធ្លាក់ទៅលើម្ចាស់បំណុលដែរ បើលក្ខខណ្ឌណាមួយនៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៤១៦ ត្រូវបានបំពេញ។

ដោយផ្អែកលើ មាត្រា ៣១៥ កថាខណ្ឌទី ២ នៅពេលដែលកូនបំណុល បានកំណត់កម្មវត្ថុដែលត្រូវផ្តល់ច្បាស់លាស់ និង បានបញ្ចប់សកម្មភាពចាំបាច់ដើម្បីផ្តល់នូវកម្មវត្ថុដែលបានកំណត់ហើយនោះ កូនបំណុល មានករណីយកិច្ចផ្តល់នូវវត្ថុនោះតែប៉ុណ្ណោះ ហើយ ថាតើសកម្មភាព ដែលឆ្លើយតបទៅនឹង "ធ្វើការកំណត់" ត្រូវបានសំរេច ដោយផ្អែកទៅលើប្រភេទនៃវត្ថុ ដែលមិនបានកំណត់ជាក់លាក់។

### ៣. អលទ្ធភាពដោយសារកំហុសរបស់ម្ចាស់បំណុល ( មាត្រា ៤២១)

ក្នុងករណីដែល អលទ្ធភាពក្នុងការអនុវត្ត បណ្ដាលមកពីកំហុសរបស់ម្ចាស់បំណុល នោះ ម្ចាស់បំណុល ត្រូវទទួលបន្ទុកហានិភ័យ ទោះបីកាតព្វកិច្ចក្នុងការប្រគល់វត្ថុ គឺជាកាតព្វកិច្ចត្រូវធ្វើ ឬ មិនធ្វើសកម្មភាពណាមួយក៏ដោយ ( មាត្រា ៤២១) ។

| |
|---|
| ករណីសិក្សា<br><br>តើ **ក** ឬ **ខ** ដែលត្រូវទទួលបន្ទុកហានិភ័យ នៅក្នុងករណីខាងក្រោមនេះ ?<br><br>១. **ក** ដែលជាម្ចាស់ហាងលក់គ្រឿងសំភារៈអគ្គិសនី និង អតិថិជន **ខ** បានចុះកិច្ចសន្យាលក់ទូរទស្សន៍ម៉ូឌែលថ្មី ចំនួន ១០គ្រឿង ដែលផលិតដោយក្រុមហ៊ុន S ហើយដែលបានស្តុកទុកក្នុងឃ្លាំងរបស់ **ក** ។ ការប្រគល់ និង កាលបរិច្ឆេទបង់ប្រាក់ គឺនៅថ្ងៃទី ០១ ខែ ធ្នូ ។<br><br>(1) ឃ្លាំងនោះ ត្រូវបានជនមិនស្គាល់បង្កអគ្គីភ័យ មុនពេលដែល **ក** បានបញ្ចប់ការរៀបចំ ហើយ ទូរទស្សន៍ទាំងអស់ ដែលនៅក្នុងឃ្លាំង ត្រូវភ្លើងឆេះអស់ នៅថ្ងៃទី ២៥ ខែ តុលា ។<br><br>(2) **ក** បានរៀបចំដាក់ទូរទស្សន៍ចំនួន ១០ គ្រឿង ដាច់ដោយឡែក ដើម្បីប្រគល់ហើយបានទុកនៅកន្លែងផ្សេងមួយទៀតនៅក្នុងឃ្លាំងដដែល កាលពីថ្ងៃទី ៣០ ខែ តុលា ។ ប៉ុន្តែឃ្លាំងនោះ ត្រូវបានជនមិនស្គាល់បង្កអគ្គីភ័យ នៅថ្ងៃទី ៣១ ខែ តុលា ហើយទូរទស្សន៍ ត្រូវភ្លើងឆេះអស់ ។<br><br>(3) **ក** និង **ខ** បានព្រមព្រៀងថា **ក** ត្រូវប្រគល់ទូរទស្សន៍ ១០គ្រឿង នៅផ្ទះរបស់ **ខ** ។ ប៉ុន្តែ **ខ** បានទូរសព្ទទៅប្រាប់ **ក** ថា "ខ្ញុំបានផ្លាស់ប្តូរគំនិត ។ ខ្ញុំមិនទទួលយកទូរទស្សន៍ទាំងនោះទេ ។ ទោះបីជាអ្នកយកមកអោយខ្ញុំ ក៏ខ្ញុំមិនព្រមទទួលយកដែរ" ។ **ក** បានសួរពីហេតុផលដែរ តែ **ខ** មិនបាននិយាយអ្វីទាំងអស់ ។ ក្រោយមកឃ្លាំងនោះ ត្រូវបានជនមិនស្គាល់មុខបង្កអគ្គីភ័យ ហើយទូរទស្សន៍ត្រូវភ្លើង ឆេះអស់ ។<br><br>២. **ក** បានចុះកិច្ចសន្យាលក់ថូបុរាណអោយទៅ **ខ** ។ **ខ** បានមកផ្ទះរបស់ **ក** ដើម្បីពិនិត្យមើលបុរាណនោះ មុនកាលបរិច្ឆេទ ហើយ **ខ** បានធ្វើអោយថូនោះធ្លាក់បែក ។ |

【សេចក្តីសន្និដ្ឋាន និង មូលហេតុសំអាង】

១-(១) **ក ត្រូវទទួលបន្ទុកហានិភ័យ** ដោយមូលហេតុថា ទូរទស្សន៍ គឺជាវត្ថុដែលមិនបានកំណត់ជាក់លាក់ ។ ទោះបីជា វត្ថុ ដែលមិនបានកំណត់ជាក់លាក់ ត្រូវបានបំផ្លាញ ដោយគ្មានកំហុសរបស់ **ក** ក៏ **ក** នៅតែត្រូវទទួលបន្ទុកហានិភ័យដែរ ។ វា មានន័យថា កាតព្វកិច្ចនោះ មិនត្រូវរលត់ឡើយ ( មាត្រា ៤១៨ កថាខណ្ឌទី ១) ។

១-(២) **ក ត្រូវទទួលបន្ទុកហានិភ័យ** ដោយមូលហេតុថា ទូរទស្សន៍ ១០ គ្រឿង ជាវត្ថុដែលមិនបានកំណត់ជាក់លាក់ ។ គ្រាន់តែបានរៀបចំ និង ទុកដោយឡែកនោះ គឺមិនទាន់គ្រប់គ្រាន់នៅឡើយទេ ព្រោះ **ក** មានកាតព្វកិច្ចប្រគល់កម្មវត្ថុនៅផ្ទះរបស់ **ខ** ( មាត្រា ៤៤៥ វាក្យខណ្ឌទី ២) ។ ដូច្នេះ នៅពេលដែល **ក** បានស្នើផ្តល់ការអនុវត្ត

កាតព្វកិច្ចនៅផ្ទះរបស់ **ខ** នោះ កម្មវត្ថុនៃកិច្ចសន្យា នឹងត្រូវបានកំណត់ ដូចឃ្លាថា "កូនបំណុល បានបញ្ចប់សកម្មភាពចាំបាច់ដើម្បីផ្តល់នូវកម្មវត្ថុដែលបានកំណត់" នៅក្នុងមាត្រា ៣១៥ កថាខណ្ឌទី ២។ វា មានន័យថា កាតព្វកិច្ច នោះ មិនត្រូវរលត់ឡើយទេ នៅក្នុងករណីនេះ ( មាត្រា ៤១៨ កថាខណ្ឌទី ១) ។

១-(៣) **ខ ត្រូវទទួលបន្ទុកហានិភ័យ** ដោយមូលហេតុថា **ខ** បានប្រកែកមិនព្រមទទួលការអនុវត្តរបស់ **ក** ដោយគ្មានមូលហេតុត្រឹមត្រូវ។ នៅក្នុងករណីនេះ **ក** មិនចាំបាច់ស្នើផ្តល់ការអនុវត្តកាតព្វកិច្ចទេ។ ដូច្នេះ **ខ** ត្រូវទទួលបន្ទុកហានិភ័យ ( មាត្រា ៤១៦ កថាខណ្ឌទី ១ ចំណុច គ ) ។

២- **ខ ត្រូវទទួលបន្ទុកហានិភ័យ** ដោយមូលហេតុថា កាតព្វកិច្ចប្រគល់ បានក្លាយជាអលទ្ធភាព ដោយសារកំហុសរបស់ **ខ** ( មាត្រា ៤២១) ។

# ផ្នែកទី ៥

# ការរំលាយកិច្ចសន្យា

## ១. ប្រភពនៃសិទ្ធិរំលាយកិច្ចសន្យា

ការរំលាយកិច្ចសន្យា សំដៅទៅលើ សកម្មភាពឯកតោភាគី ដែលធ្វើអោយភាគីទាំងសងខាងរួចផុតពីករណីយកិច្ចរបស់ខ្លួន នៅក្នុងកិច្ចសន្យា លើកលែងតែករណីយកិច្ចសងការខូចខាត ( មាត្រា ៤១១ កថាខណ្ឌទី ១) ។ ការរំលាយកិច្ចសន្យា ធ្វើឱ្យមានអានុភាពជាឯកតោភាគី ហើយ មិនចាំបាច់មានការព្រមព្រៀងពីភាគីម្ខាងទៀតទេ ព្រោះ វា គឺជាសកម្មភាពឯកតោភាគី ( មាត្រា ៣១២) ។

មានប្រភពមួយចំនួនសំរាប់សិទ្ធិរំលាយកិច្ចសន្យា

### ១.១ សិទ្ធិរំលាយកិច្ចសន្យា ដែលបានកំណត់នៅក្នុងច្បាប់

សិទ្ធិរំលាយកិច្ចសន្យា ដែលបានកំណត់នៅក្នុងច្បាប់ ត្រូវបានបញ្ញត្តិឡើងដោយមាត្រា ៤០៧ ដល់ ៤១៣។ ឧទាហរណ៍ នៅក្នុងករណីដែល **ក** មិនបានប្រគល់នូវកម្មវត្ថុនៅក្នុងអំឡុងពេលសមរម្យ នៅក្រោយកាលបរិច្ឆេទទេ ទោះបីជាមានការដាស់តឿនរបស់ **ខ** នោះ **ខ** អាចលើកឡើងពីការរំលាយកិច្ចសន្យាបាន។ នៅក្នុងករណីនេះ ការរំលាយកិច្ចសន្យារបស់ **ខ** ត្រូវបានអនុវត្តដោយផ្អែកទៅលើមាត្រា ៤០៨ កថាខណ្ឌទី ១ ចំណុច ក។

### ១.២ សិទ្ធិរំលាយកិច្ចសន្យា ដែលបានកំណត់នៅក្នុងកិច្ចសន្យា

សិទ្ធិរំលាយកិច្ចសន្យា ដែលបានកំណត់នៅក្នុងកិច្ចសន្យា គឺជាសិទ្ធិរំលាយកិច្ចសន្យា ដែលភាគីម្ខាង ឬ សងខាង អាចរំលាយកិច្ចសន្យាបាន ដោយផ្អែកទៅលើកិច្ចសន្យានោះផ្ទាល់តែម្តង។ ឧទាហរណ៍ ប្រសិនបើ ភាគី បានធ្វើការព្រមព្រៀងគ្នា នៅក្នុងកិច្ចសន្យាជាមុនថា "អ្នកទិញ អាចរំលាយកិច្ចសន្យាជាឯកតោភាគី នៅពេលណា ក៏បាន ក្នុងរយៈពេល ១ សប្តាហ៍ ក្រោយពេលប្រគល់នូវកម្មវត្ថុ" ដូច្នេះ អ្នកទិញ អាចរំលាយកិច្ចសន្យាបាន តាមលក្ខខណ្ឌ ដែលមានចែងនៅក្នុងកិច្ចសន្យានោះផ្ទាល់តែម្តង។

អានុភាព ឬ វិធីក្នុងការអនុវត្តសិទ្ធិរំលាយកិច្ចសន្យា គឺត្រូវអនុវត្តដូចគ្នាទៅនឹង សិទ្ធិរំលាយកិច្ចសន្យា ដែលបានកំណត់នៅក្នុងច្បាប់ លើកលែងតែ ភាគី បានព្រមព្រៀងគ្នាផ្សេងពីនេះ ( មាត្រា ៤១៤ កថាខណ្ឌទី ១) ។

### ១.៣ សិទ្ធិរំលាយកិច្ចសន្យា ដោយផ្អែកទៅលើបញ្ញត្តិពិសេស

បញ្ញត្តិមួយចំនួន នៅក្នុងកិច្ចសន្យាសំខាន់ៗ បានចែងអំពីសិទ្ធិរំលាយកិច្ចសន្យាពិសេស នៅក្នុងកិច្ចសន្យានីមួយៗ។ មាត្រា ៦៤៧ ទាក់ទងនឹងអាណត្តិ និង មាត្រា ៦៦៣ ទាក់ទងនឹងកិច្ចសន្យាម៉ៅការ គឺជាឧទាហរណ៍ នៅ

ក្នុងចំណុចនេះ។ ការរំលាយកិច្ចសន្យាតាមបញ្ញត្តិពិសេសទាំងនេះ នឹងត្រូវបានលើកយកមកសិក្សាលំអិត នៅពេលសិក្សាពីកិច្ចសន្យាសំខាន់ៗ។

## ២. ប្រព័ន្ធប្រហាក់ប្រហែលទៅនឹងការរំលាយកិច្ចសន្យា

វា មានប្រព័ន្ធមួយចំនួន ដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងការរំលាយកិច្ចសន្យា ប៉ុន្តែ វា មិនមែនជាការរំលាយកិច្ចសន្យានោះទេ។

### ២.១ ការរំលាយកិច្ចសន្យាដោយការព្រមព្រៀង

ការរំលាយកិច្ចសន្យាដោយការព្រមព្រៀង មានន័យថាជា ការរំលាយកិច្ចសន្យា ដោយផ្អែកទៅលើ ការព្រមព្រៀងថ្មីរបស់គូភាគី នៅក្នុងករណីដែលភាគី មិនបានចែងអំពីការរំលាយកិច្ចសន្យានេះ នៅក្នុងកិច្ចសន្យារបស់ខ្លួន។ ឧទាហរណ៍ អ្នកទិញ ខ បានទាមទារអោយរំលាយកិច្ចសន្យាលក់ទិញ ជាមុន ដោយសារតែមានភាពលំបាកនៅក្នុងការប្រមូលប្រាក់ ហើយ ក ក៏បានយល់ព្រម។ នៅក្នុងករណីនេះ ការព្រមព្រៀងថ្មីដើម្បីរំលាយកិច្ចសន្យាត្រូវបានចាត់ទុកថា បានបង្កើតឡើង។ នៅក្នុងករណីនេះ ដែលផ្ទុយនឹងការរំលាយកិច្ចសន្យាដែលបានកំណត់នៅក្នុងច្បាប់ ខ មិនអាចរំលាយកិច្ចសន្យា ដោយការបង្ហាញឆន្ទៈជាឯកតោភាគីបានឡើយ។ ការព្រមព្រៀងថ្មី ឬម្យ៉ាងទៀតត្រូវបានគេហៅថា កិច្ចសន្យាថ្មី ដែលខុសពីកិច្ចសន្យាចាស់ ត្រូវបានតំរូវអោយមានដើម្បីរំលាយកិច្ចសន្យា។ ជាងនេះទៅទៀត ការរំលាយកិច្ចសន្យាដោយការព្រមព្រៀង ដែលរំលាយកិច្ចសន្យាមុន ដោយការព្រមព្រៀងថ្មីមានលក្ខណៈខុសពីការរំលាយកិច្ចសន្យា ដែលបានកំណត់នៅក្នុងកិច្ចសន្យា ដែល ត្រូវបានអនុវត្ត ដោយផ្អែកលើការលក្ខខណ្ឌនៃការរំលាយកិច្ចសន្យា ដែលបានព្រមព្រៀងគ្នា ជាមុន នៅក្នុងកិច្ចសន្យាដើម។

### ២.២ ការលុបចោលកិច្ចសន្យា

នៅក្នុងករណីដែលកិច្ចសន្យា ត្រូវបានលុបចោល នោះ កិច្ចសន្យា ត្រូវបានចាត់ទុកថា មោឃៈ តាំងពីដំបូង (មាត្រា ៣៥៨ កថាខណ្ឌទី ២)។

ការលុបចោលកិច្ចសន្យា និង ការរំលាយកិច្ចសន្យា មានចំណុចដូចគ្នា :

i) ភាគីទាំងសងខាង ត្រូវបានរួចផុតពីកាតព្វកិច្ចនៅក្នុងកិច្ចសន្យា

ii) មានអានុភាពជាឯកតោភាគី ដោយសារ វា គឺជាសកម្មភាពឯកតោភាគី

ក៏ប៉ុន្តែ សិទ្ធិរំលាយកិច្ចសន្យា កើតឡើង ដោយផ្អែកលើមូលហេតុនៃការបំពានកិច្ចសន្យាធ្ងន់ធ្ងរ របស់ភាគីម្ខាងទៀត ក្រោយពីកិច្ចសន្យា ត្រូវបានបង្កើតឡើងដោយធម្មតា។ ផ្ទុយទៅវិញ ចំពោះការលុបចោលកិច្ចសន្យាមូលហេតុ (ការឆបោក ការបង្ខិតបង្ខំ ជាអាទិ៍) ត្រូវបានតំរូវអោយមាន នៅពេលបង្កើតកិច្ចសន្យា។

## ៣.លក្ខខណ្ឌនៃការរំលាយកិច្ចសន្យា

តាមមាត្រា ៤០៧ នៃក្រមរដ្ឋប្បវេណី លក្ខខណ្ឌនៃការរំលាយកិច្ចសន្យា ដោយមូលហេតុមិនអនុវត្ត កាតព្វកិច្ច មានដូចខាងក្រោម :

ក. នៅក្នុងកិច្ចសន្យាទ្វេភាគី

ខ. ភាគីម្ខាង បានបំពានកាតព្វកិច្ចយ៉ាងធ្ងន់ធ្ងរ

វា មិនតម្រូវឱ្យការមិនអនុវត្តកាតព្វកិច្ចនេះ កើតឡើងដោយកំហុសនោះទេ (មាត្រា ៤០៨ កថាខណ្ឌទី ២)។ មាត្រា ៤០៨ កថាខណ្ឌទី ១ បញ្ញត្តិថា ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ ត្រូវបានចាត់ទុកថា កើតមានឡើង ប្រសិនបើវា ធ្លាក់ចូលទៅក្នុងចំណុចណាមួយទាំងបួនខាងក្រោម។ ដូច្នេះ នៅពេលដែលអង្គហេតុណាមួយ ដែលបានបញ្ញត្តិ ត្រូវគេបានទទួលស្គាល់នោះ វា មិនអាចលុបចោលវិញបានឡើយ ។ម្យ៉ាងវិញទៀត ទោះជាអង្គហេតុមិនត្រូវនឹងចំណុច ដែលបានបញ្ញត្តិនៅក្នុងមាត្រា ៤០៨ កថាខណ្ឌទី ១ ក៏ដោយ ក៏គេ នៅតែអាចទទួលស្គាល់នូវអង្គហេតុផ្សេងទៀតថា "ជាការបំពានកាតព្វកិច្ចធ្ងន់ធ្ងរ" ព្រោះ រាលចំណុចនៅក្នុងមាត្រា ៤០៨ កថាខណ្ឌទី ១ គឺគ្រាន់តែជាការលើកនូវឧទាហរណ៍តែប៉ុណ្ណោះ ។

### ៣.១ ការរំលាយកិច្ចសន្យាដោយមូលហេតុការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច

យោងតាមមាត្រា ៤០៨ កថាខណ្ឌទី ១ ចំណុច ក បញ្ញត្តិថា ភាគីម្ខាង បានដាស់តឿនភាគីម្ខាង ដែលមិនបានអនុវត្តកាតព្វកិច្ច តាមពេលកំណត់ដោយ កំណត់អំឡុងពេលសមស្របដើម្បីអោយអនុវត្តកាតព្វកិច្ច ហើយ កាតព្វកិច្ច មិនត្រូវបានអនុវត្តក្នុងអំឡុងពេលនោះ ភាគី អាចរំលាយកិច្ចសន្យាបានភ្លាម។

ឧទាហរណ៍ : **ក** បានចុះកិច្ចសន្យាលក់ឡានជាមួយ **ខ** ហើយ **ក** បានប្រគល់ឡានទៅអោយ **ខ** ។ ក៏ប៉ុន្តែ **ខ** មិនទាន់បានបង់ប្រាក់ថ្លៃទិញទៅឱ្យ **ក** នាកាលបរិច្ឆេទនៅឡើយទេ។ នៅក្នុងករណីនេះ ប្រសិនបើ **ក** ដាស់តឿន **ខ** អោយបង់ប្រាក់ថ្លៃទិញ ដោយកំណត់អំឡុងពេលសមរម្យសំរាប់អនុវត្តកាតព្វកិច្ច ហើយ **ខ** មិនបានបង់ប្រាក់ថ្លៃទិញ នៅក្នុងអំឡុងពេលនោះ **ក** អាចរំលាយកិច្ចសន្យាបាន។

លក្ខខណ្ឌនោះមានចំនួន ៣ ដូចខាងក្រោម :

(១). កូនបំណុល មិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន តាមពេលកំណត់

(២). ម្ចាស់បំណុល ដាស់តឿនភាគី ដែលមិនអនុវត្តកាតព្វកិច្ចអោយអនុវត្តកាតព្វកិច្ច ដោយកំណត់អំឡុងពេលសមរម្យសំរាប់អនុវត្ត

(៣). កូនបំណុល មិនអនុវត្តកាតព្វកិច្ច នៅក្នុងអំឡុងពេលសមរម្យ

១. កូនបំណុល មិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន តាមពេលកំណត់

តាមឧទាហរណ៍ខាងលើ គឺ ខ មិនបានបង់ថ្លៃទិញ តាមពេលកំណត់

ទាក់ទងនឹងលក្ខខណ្ឌនេះ វា មានភាពចាំបាច់ ដែល ការអនុវត្តកាតព្វកិច្ច គឺអាចអនុវត្តទៅបាន។ ប្រសិនបើ កូនបំណុល មិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដោយសារតែអលទ្ធភាពនៃការអនុវត្ត នោះ វា គឺជាបញ្ហានៅក្នុងមាត្រា ៤០៨ កថាខណ្ឌទី ១ ចំណុច គ។

២. ម្ចាស់បំណុល បានដាស់តឿនភាគី ដែលមិនអនុវត្តកាតព្វកិច្ចឱ្យអនុវត្តកាតព្វកិច្ច ដោយកំណត់អំឡុងពេលសមរម្យសំរាប់អនុវត្ត :

នៅក្នុងករណីខាងលើ ប្រសិនបើ ខ មិនបានបង់ប្រាក់ថ្លៃទិញ នៅកាលបរិច្ឆេទទេ ក ត្រូវដាស់តឿន ខ ឱ្យបង់ប្រាក់ថ្លៃទិញ ដោយកំណត់អំឡុងពេលសមរម្យ។

៣. កូនបំណុល មិនអនុវត្តកាតព្វកិច្ចនៅអំឡុងពេលដែលបានដាស់តឿន :

នៅពេលដែល ខ មិនបានបង់ប្រាក់ថ្លៃទិញ នៅកាលបរិច្ឆេទកំណត់ទេ ក ត្រូវដាស់តឿនអោយ ខ អនុវត្តកាតព្វកិច្ច ដោយកំណត់អំឡុងពេលសមរម្យមួយ។ នៅក្នុងករណីដែល ខ នៅតែមិនបានអនុវត្តកាតព្វកិច្ច នៅក្នុងអំឡុងពេលសមរម្យ ដែលបានដាស់តឿននោះទេ ក អាចរំលាយកិច្ចសន្យាបាន។

ចំពោះលក្ខខណ្ឌទី ២ វាគឺជាបញ្ហាថាតើ ត្រូវដោះស្រាយបញ្ហា ដែលទាក់ទងជាមួយការយឺតយ៉ាវនៃការអនុវត្តកាតព្វកិច្ចយ៉ាងដូចម្តេច។ ប្រសិនបើមានមូលហេតុត្រឹមត្រូវចំពោះការយឺតយ៉ាវ កូនបំណុល មិនស្ថិតនៅក្នុងភាពយឺតយ៉ាវទេ។ ឧទាហរណ៍ ក បានលក់រថយន្តទៅអោយ ខ ហើយ ពួកគេ បានកំណត់កាលបរិច្ឆេទ។ នៅកាលបរិច្ឆេទ ក មិនបានប្រគល់រថយន្តរបស់ខ្លួនទេ ដោយសារតែ ខ មិនបានស្នើផ្តល់ការអនុវត្តកាតព្វកិច្ចរបស់ខ្លួន។ នៅក្នុងករណីនេះ ទាំង ក និង ខ មិនត្រូវស្ថិតនៅក្នុងភាពយឺតយ៉ាវទេ ទោះបីជាគាត់ មិនបានប្រគល់រថយន្ត ដោយសារការតវ៉ាអោយអនុវត្តព្រមគ្នា (មាត្រា ៣៨៦)។ ដូច្នេះ ក ត្រូវស្នើផ្តល់ការអនុវត្តកាតព្វកិច្ច ដើម្បីធ្វើអោយ ខ ស្ថិតនៅក្នុងភាពយឺតយ៉ាវ ប្រសិនបើ ក ចង់រំលាយកិច្ចសន្យា។ បន្ទាប់មក តើ ក ត្រូវស្នើផ្តល់ការអនុវត្តកាតព្វកិច្ច ដើម្បីធ្វើអោយ ខ ស្ថិតនៅក្នុងភាពយឺតយ៉ាវ ? តើ ក ត្រូវធ្វើការដាស់តឿនអោយអនុវត្តកាតព្វកិច្ច ដោយកំណត់អំឡុងពេលសមរម្យ នៅពេលផ្សេងគ្នា ?




* តើគួរអោយ ក ត្រូវស្នើផ្តល់ការអនុវត្តកាតព្វកិច្ច និង ដាស់តឿនឱ្យអនុវត្តកាតព្វកិច្ច ដោយដាច់ពីគ្នា ?

ចំពោះការបកស្រាយ គេ អាចគិតថា ម្ចាស់បំណុល អាចរំលាយកិច្ចសន្យាបាន ក្រោយពេលការស្នើផ្តល់ការអនុវត្តកាតព្វកិច្ច ដើម្បីធ្វើអោយកូនបំណុលស្ថិតនៅក្នុងភាពយឺតយ៉ាវ ហើយក្រោយមកដាស់តឿនឱ្យអនុវត្តកាតព្វកិច្ច។

ហើយម្យ៉ាងទៀត គេ អាចគិតថា ម្ចាស់បំណុល អាចដាស់តឿនឱ្យអនុវត្តកាតព្វកិច្ច ស្របពេលជាមួយនឹងការស្នើផ្តល់ការអនុវត្តកាតព្វកិច្ច ព្រោះមាត្រានេះ បញ្ញត្តិថា "កាតព្វកិច្ចមិនត្រូវបានអនុវត្ត នៅអំឡុងពេលនោះ មិនមែន "ករណីដែលកូនបំណុល ស្ថិតនៅក្នុងភាពយឺតយ៉ាវទេ"។

ដោយផ្អែកលើគំនិតនេះ ម្ចាស់បំណុល មិនចាំបាច់ដាស់តឿនអោយអនុវត្តកាតព្វកិច្ច ក្រោយអំឡុងពេលសមរម្យពីការស្នើផ្តល់អនុវត្តកាតព្វកិច្ច ព្រោះ "តាមរយៈការកំណត់អំឡុងពេលសមរម្យ" គឺដើម្បីផ្តល់ឱកាសចុងក្រោយដល់កូនបំណុល ថាតើគាត់ អនុវត្តកាតព្វកិច្ចដែរ ឬ ទេ ។




* **ក** អាចស្នើផ្តល់ការអនុវត្តកាតព្វកិច្ច និង ដាស់តឿនអោយ **ខ** អនុវត្តកាតព្វកិច្ច នៅពេលជាមួយគ្នា។

ហើយបន្ទាប់មក តើរយៈពេលប៉ុន្មាន ដែលត្រូវ ចាត់ទុកថា " អំឡុងពេលសមរម្យ" ? វា មានគំនិតមួយចំនួន។ គំនិតមួយនៅក្នុងចំណោមគំនិតទាំងអស់នេះ គឺជាគំនិតដែល អំឡុងពេលសមរម្យ សំដៅទៅលើអំឡុងពេល ដែលសំរាប់សំរូវអោយរៀបចំ និង អនុវត្តកាតព្វកិច្ច ក្រោយពីការដាស់តឿនរបស់ **ក**។ គំនិតមួយទៀត គឺថា គ្រាន់តែតំរូវអោយមានអំឡុងពេលសំរាប់អនុវត្តកាតព្វកិច្ច គឺគ្រប់គ្រាន់ហើយ ដោយផ្អែកលើមូលហេតុថា **ខ** បានបញ្ចប់នូវការរៀបចំរបស់ខ្លួនហើយ។



ដោយផ្អែកលើគំនិតទី ២ វា មិនមានភាពចាំបាច់ នៅក្នុងការការពារកូនបំណុល ដែលមិនគោរពកិច្ចសន្យា ហើយ សូម្បីតែ គាត់ មិនបានទាំងរៀបចំដើម្បីអនុវត្តកាតព្វកិច្ចរបស់ខ្លួន។ ឧទាហរណ៍ ក បានចុះកិច្ចសន្យាលក់ទូរទស្សន៍ចំនួន ១០ គ្រឿង ដែលជាវត្ថុមិនជាក់លាក់ អោយទៅ ខ ប៉ុន្តែ ក មិនបានប្រគល់ទូរទស្សន៍នោះ នៅកាលបរិច្ឆេទទេ។ បន្ទាប់មក ខ បានដាស់តឿនអោយ ក អនុវត្តកាតព្វកិច្ចរបស់ខ្លួន។ នៅក្នុងករណីនេះ "អំឡុងពេលសមរម្យ" ត្រូវសំរេចអោយផ្អែកលើចំណុចថា ក បានបញ្ចប់ការទុកដាក់កម្មវត្ថុ ដាច់ដោយឡែក ពីវត្ថុដទៃទៀត ហើយនិង បានបញ្ចប់នូវការរៀបចំដើម្បីប្រគល់ទៀតផង។

## ៣.២ ការរំលាយកិច្ចសន្យា ដោយសារការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ក្នុងករណីដែលពេលវេលា គឺជាចំណុចសំខាន់

នៅក្នុងករណីដែលគោលបំណងនៃកិច្ចសន្យា មិនបានសំរេច ប្រសិនបើការអនុវត្តកាតព្វកិច្ច មិនត្រូវបានបំពេញ នៅក្នុងពេលកំណត់នោះ វា ត្រូវបានគេចាត់ទុកថាជា "ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ" ប្រសិនបើកូនបំណុលមិនបានបំពេញកាតព្វកិច្ចនៅពេលកំណត់នោះ ។

នៅក្នុងចំណុចនេះវា មានកិច្ចសន្យា ០២ ប្រភេទ។

ប្រភេទទី ១ គឺកិច្ចសន្យា ដែលគោលបំណងរបស់វា មិនអាចសំរេចបានសោះ តាមលក្ខណៈរបស់កិច្ចសន្យានោះ ប្រសិនបើការអនុវត្តកាតព្វកិច្ច មិនត្រូវបានធ្វើឡើង នៅក្នុងពេលកំណត់ ។

**ឧទាហរណ៍ :** ក បញ្ជាអោយជាងកាត់សំលៀកបំពាក់ ខ កាត់សំលៀកបំពាក់អាពាហ៍ពិពាហ៍ សំរាប់ស្លៀកក្នុងពិធីរៀបអាពាហ៍ពិពាហ៍ នៅថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១០ ។ ប៉ុន្តែដល់ថ្ងៃទី ០៧ ខែ វិច្ឆិកា មកដល់ហើយ ជាងកាត់សំលៀកបំពាក់ មិនទាន់ដេររួចរាល់ទៀត ។ ក្នុងករណីនេះ ក អាចរំលាយកិច្ចសន្យាបាន ដោយសារ ខ បានបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ។ វា មានលក្ខណៈច្បាស់លាស់ថា គោលបំណងនៃកាតព្វកិច្ចនេះ មិនត្រូវបានសំរេច ប្រសិនបើការអនុវត្តកាតព្វកិច្ច មិនត្រូវបានធ្វើឡើង តាមលក្ខណៈនៃខ្លឹមសារនៃកិច្ចសន្យា។

ប្រភេទមួយទៀត គឺជាកិច្ចសន្យា ដែលត្រូវអនុវត្តកាតព្វកិច្ច នៅក្នុងពេលកំណត់ ដោយស្របទៅតាមឆន្ទៈរបស់ភាគី ។

ឧទាហរណ៍ ក បានបញ្ជាទិញស្រាបៀជាច្រើនកេស សំរាប់ពិធីជប់លៀងពេលល្ងាចរបស់ខ្លួន ប៉ុន្តែ ឈ្មួញលក់ស្រាបៀ ខ មិនអាចប្រគល់ស្រាបៀនោះ នៅថ្ងៃនៃពិធីជប់លៀង។ នៅក្នុងករណីនេះ ក ចាំបាច់ត្រូវប្រាប់ថា គាត់ ត្រូវការស្រាបៀជាច្រើនកេស នៅថ្ងៃណាមួយជាក់លាក់ ដើម្បីអះអាងថា វា ត្រូវចាត់ទុកលជាការបំពានកិច្ចសន្យាធ្ងន់ធ្ងររបស់ ខ ព្រោះ វា មិនមានភាពច្បាស់លាស់ទេថា គោលបំណងនៃកិច្ចសន្យានេះ មិនត្រូវបានសំរេច ប្រសិនបើ ការអនុវត្តកាតព្វកិច្ច មិនត្រូវបានធ្វើឡើងនៅកាលបរិច្ឆេទកំណត់។

ប្រសិនបើ ក បានប្រាប់ថា គាត់ ត្រូវការស្រាបៀជាច្រើនកេស នៅថ្ងៃជប់លៀង ទោះបីជា ខ អនុវត្ត កាតព្វកិច្ចរបស់ខ្លួន នៅពេលក្រោយមកក៏ដោយ ក៏វា គ្មានប្រយោជន៍សំរាប់ម្ចាស់បំណុលដែរ ។ ដូច្នេះ ម្ចាស់បំណុល អាចរំលាយកិច្ចសន្យាបានភ្លាម ក្រោយពេលកំណត់នោះ ។

## ៧.៧. ការរំលាយកិច្ចសន្យាដោយមូលហេតុអសទ្ធភាពនៃការអនុវត្តកាតព្វកិច្ច

មាត្រា ៤០៨ កថាខណ្ឌទី១ ចំណុច គ បានចែងថា ភាគី មិនអាចអនុវត្តករណីយកិច្ចផ្តល់គាវកាលិកចម្បង របស់ខ្លួនបាន ភាគីម្ខាងទៀត អាចរំលាយកិច្ចសន្យាបាន។

**គាវកាលិកចម្បង** គឺជាសកម្មភាព ដែលភាគី មិនអាចសម្រេចគោលបំណងនៃកិច្ចសន្យា ប្រសិនបើ គាវកាលិកនោះ មិនត្រូវបានផ្តល់អោយ។

គាវកាលិកចម្បង ត្រូវសម្រេចដោយផ្អែកលើលក្ខណៈ ឬ ខ្លឹមសារនៃកិច្ចសន្យា និង ឆន្ទៈរបស់គូភាគី។

ឧទាហរណ៍ : ក ចុះកិច្ចសន្យាលក់ទិញរថយន្តជាមួយ ខ។ ក គឺជាអ្នកលក់ ហើយ ខ គឺជាអ្នកទិញ។ ក្រោយពីបង្កើតកិច្ចសន្យារួច ខ បានបង់ថ្លៃលក់រថយន្តទៅឱ្យ ក ក៏ប៉ុន្តែ ម៉ាស៊ីនរបស់រថយន្តនោះ គឺខូច ដោយសារ ទឹកជំនន់ នៅមុនពេលប្រគល់។

នៅក្នុងករណីនេះ ទោះបីជារថយន្ត ស្ថិតនៅក្នុងទ្រង់ទ្រាយដើមក៏ដោយ ក៏កាតព្វកិច្ច ក្លាយជាលទ្ធភាពដែរ ព្រោះ ខ មិនអាចបើករថយន្តនោះ បានទៀតទេ។ ដូច្នេះ ខ អាចរំលាយកិច្ចសន្យាទិញលក់នោះបានភ្លាម ព្រោះថា ក មិនអាចប្រគល់រថយន្ត ដែលជាគាវកាលិកចម្បងនៃកិច្ចសន្យាទិញលក់ទៅឱ្យ ខ បាន។

ផ្ទុយមកវិញ នៅក្នុងករណីដែល មានកាតព្វកិច្ចបន្ទាប់បន្សំ ក្រៅពីកាតព្វកិច្ចចំបង នោះ ម្ចាស់បំណុល មិន អាចរំលាយកិច្ចសន្យា ដោយផ្អែកទៅលើការមិនអនុវត្តកាតព្វកិច្ច ទោះបីជាកូនបំណុល មិនបានអនុវត្តកាតព្វកិច្ច បន្ទាប់បន្សំនោះ។

ឧទាហរណ៍ ក បានចុះកិច្ចសន្យាលក់ដីរបស់ខ្លួន អោយទៅ ខ ហើយ ពួកគេ បានព្រមព្រៀងគ្នាថា ក ត្រូវ បង់ថ្លៃចុះបញ្ជី។ ក្រោយពីការបង្កើតកិច្ចសន្យា ខ បានបង់ថ្លៃចុះបញ្ជីជំនួស ក ប៉ុន្តែ ក មិនបានបង់ថ្លៃចុះបញ្ជីនេះ ទៅអោយ ខ ទេ។

នៅក្នុងករណីនេះ ការបង់ថ្លៃចុះបញ្ជី គឺជាកាតព្វកិច្ចបន្ទាប់បន្សំ ដូច្នេះ គេ អាចគិតពិចារណាថា ខ មិន អាចរំលាយកិច្ចសន្យា ដោយផ្អែកទៅលើមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ច។

### ៣.៤ ការរំលាយកិច្ចសន្យាដោយមូលហេតុបាត់បង់ជំនឿចិត្តរវាងគូភាគី

មាត្រា ៤០៨ កថាខណ្ឌទី ១ ចំណុច ឃ បានចែងថា បើការបំពានកិច្ចសន្យា មានភាពហួសហេតុ ដែលធ្វើឱ្យបាត់បង់នូវទំនុកចិត្តរវាងគូភាគី ហើយមិនអាចជឿជាក់ថា នឹងអនុវត្តកាតព្វកិច្ចនាអនាគតបាន ភាគីម្ខាងទៀតអាចរំលាយកិច្ចសន្យាបាន។

ក៏ប៉ុន្តែ ការរំលាយកិច្ចសន្យាប្រភេទនេះ គឺពុំមានភាពច្បាស់លាស់ឡើយ។ ទំនាក់ទំនងនៃទំនុកចិត្តនៅក្នុងកិច្ចសន្យា មានខុសគ្នា ចាប់ពីកិច្ចសន្យាលក់ទិញធ្វើឡើងដោយការជួបគ្នាទល់មុខ ដែលទំនាក់ទំនងនៃទំនុកចិត្ត គឺមិនមានសារសំខាន់ រហូតដល់ កិច្ចសន្យាលក់ទិញបន្តបន្ទាប់ ឬ កិច្ចសន្យាម៉ៅការ ដែលផ្អែកទៅលើទំនាក់ទំនងយ៉ាងខ្លាំង។

ឧទាហរណ៍ : **ក** បានលក់វត្ថុធាតុដើមសំរាប់ផលិតផល ទៅអោយ **ខ** ជាបន្តបន្ទាប់ ហើយ **ខ** បានផលិតនូវផលិតផលរបស់ខ្លួនពីវត្ថុធាតុដើមនោះ។ **ក** ផ្គត់ផ្គង់នូវវត្ថុធាតុដើមនោះ មានការយឺតយ៉ាវ ២ ទៅ ៣ ថ្ងៃ ជារឿយៗ ហើយ ជាលទ្ធផល គឺ **ខ** មិនអាចផលិតនូវផលិតផលរបស់ខ្លួនបានដែរ ដែលកើតមានជាញឹកញាប់។ វាមានលក្ខណៈលំបាកសំរាប់ **ខ** ក្នុងការរក្សានូវទំនុកចិត្តជាមួយ **ក** ទោះបីជា ការបំពានកិច្ចសន្យាម្តងៗ មិនមានលក្ខណៈធ្ងន់ធ្ងរក៏ដោយ។ ដូច្នេះ **ខ** អាចរំលាយកិច្ចសន្យា ដោយសារតែការបាត់បង់ជំនឿចិត្តរវាងគូភាគី។

ចំពោះការរំលាយកិច្ចសន្យាប្រភេទនេះ ច្រើនកើតមាននៅលើកិច្ចសន្យា ដែលធ្វើរវាងភតិកៈ និង ភតិបតី (ភតិសន្យា)។

ឧទាហរណ៍ ក្នុងការបង់ថ្លៃឈ្នួលជាដើម ហើយប្រសិនបើការខកខានបង់ប្រាក់ឈ្នួល ០១ ដង ឬ ០២ ដង យើង អាចបកស្រាយថា មិនមែនជាការបំពានកិច្ចសន្យាធ្ងន់ធ្ងរទេ (ដូច្នេះ ភតិបតី មិនអាចរំលាយកិច្ចសន្យាបានឡើយ)។ ប៉ុន្តែបើ ភតិកៈ មិនបានបង់ថ្លៃឈ្នួល ដែលមានចំនួន ០៤ ដង ទៅ ០៥ ដង យើង អាចបកស្រាយបានថា ជាការបំពានកិច្ចសន្យាធ្ងន់ធ្ងរ (ដូច្នេះ ភតិបតី អាចរំលាយកិច្ចសន្យាបាន)។ ជាការអនុវត្តនៅប្រទេសជប៉ុន ការមិនបង់ប្រាក់ឈ្នួល មានចំនួន ០៦ ដង ទើបចាត់ទុកថាបានបំពានកិច្ចសន្យាធ្ងន់ធ្ងរ។

## ៤. វិធីអនុវត្តសិទ្ធិរំលាយកិច្ចសន្យា

មាត្រា ៤០៩ បានបញ្ញត្តិក្នុងការរំលាយកិច្ចសន្យា ដូចខាងក្រោម :

ភាគីម្ខាងដែលមានសិទ្ធិរំលាយ អាចរំលាយកិច្ចសន្យាបាន ដោយបង្ហាញឆន្ទៈរំលាយ ចំពោះភាគីម្ខាងទៀតបាន។

(ក) ការបង្ហាញឆន្ទៈ អាចធ្វើនៅក្រៅតុលាការបាន និង ក្នុងតុលាការក៏បាន (មាត្រា ៤០៩ កថាខណ្ឌទី ១)

ដោយសារ វា អាចជាបន្ទុកការងារដ៏ច្រើន ប្រសិនបើ ភាគី អាចរំលាយកិច្ចសន្យាបានតែតាមផ្លូវតុលាការ នោះ ។

(ខ) ការបង្ហាញឆន្ទៈរំលាយ មិនអាចដកវិញបានទេ (មាត្រា ៤០៩ កថាខណ្ឌទី ២)

ប្រសិនបើគេ អាចដកឆន្ទៈនៃការរំលាយកិច្ចសន្យា នោះ អានុភាពនៃកិច្ចសន្យា នឹងត្រូវផ្លាស់ប្ដូរ ហើយ ជាលទ្ធផល ឋានៈរបស់ភាគីម្ខាងទៀត ឬ ភាគីដែលមានផលប្រយោជន៍ពាក់ព័ន្ធ នឹងក្លាយជាអស្ថេរភាព ។ ក៏ប៉ុន្តែ គេអាចចាត់ទុកថា ជនដែលមានសិទ្ធិរំលាយ អាចដកនូវឆន្ទៈរំលាយកិច្ចសន្យាបាន នៅក្នុងករណីដែល ការជូនដំណឹងពីការដកឆន្ទៈ បានដល់ភាគីម្ខាងទៀត នៅពេលព្រមគ្នា ឬ មុនពេលឆន្ទៈរំលាយ ព្រោះ ការរំលាយ មានអានុភាពនៅពេលដែល វា បានដល់ ។

ជាងនេះទៅទៀត បញ្ញត្តិទូទៅនៃការបង្ហាញឆន្ទៈ ត្រូវយកមកអនុវត្តចំពោះឆន្ទៈរំលាយផងដែរ ដូច្នេះ គេអាចលុបចោលឆន្ទៈបាន នៅក្នុងករណីនៃការភាន់ច្រឡំ ឆបោក ឬ គំរាមកំហែង ជាអាទិ៍ ។

(គ) ការបង្ហាញឆន្ទៈរំលាយ អាចដាក់លក្ខខណ្ឌបង្អង់បាន (មាត្រា ៤០៩ កថាខណ្ឌទី ៣)

លក្ខខណ្ឌ សំដៅទៅលើព្រឹត្តិការណ៍ដែលកើតឡើង នាពេលអនាគត ហើយដែលមិនទៀតទាត់ (មាត្រា ៣២៥ កថាខណ្ឌទី ២) ។ ទន្ទឹមនឹងនេះ លក្ខខណ្ឌបង្អង់ មានន័យថា កាតព្វកិច្ច ឬ សិទ្ធិ នឹងមានអានុភាព នៅពេលដែលលក្ខខណ្ឌ បានបំពេញ (មាត្រា ៣២៥ កថាខណ្ឌទី ៣) ។ ឧទាហរណ៍ នៅក្នុងករណីដែល ភាគី បានព្រមព្រៀងគ្នាថា "ប្រសិនបើ **ក** រៀបការ នោះ **ខ** នឹងអោយរថយន្ត ១ គ្រឿង ជាអំណោយដល់ **ក**" លក្ខខណ្ឌបង្អង់ ត្រូវបានដាក់ទៅលើកិច្ចសន្យាប្រទានកម្ម ។ នៅក្នុងករណីនៃការរំលាយកិច្ចសន្យា ឧទាហរណ៍ដូចជា អ្នកទិញ **ខ** មិនបានបង់ប្រាក់ថ្លៃទិញ នៅកាលបរិច្ឆេទប្រគល់ បន្ទាប់មក អ្នកលក់ **ក** បានបង្ហាញឆន្ទៈថា "ខ្ញុំ នឹងរំលាយកិច្ចសន្យានេះ នៅក្នុងលក្ខខណ្ឌដែល **ខ** មិនបង់ប្រាក់នៅក្នុងអំឡុងពេល ១ សប្ដាហ៍" ។ ឆន្ទៈនៃការរំលាយនេះ ត្រូវបានដាក់លក្ខខណ្ឌបង្អង់ ។

## ៥. អានុភាពនៃការរំលាយកិច្ចសន្យា

### ៥.១ ទ្រឹស្ដីនៃអានុភាពនៃការរំលាយកិច្ចសន្យា

ផ្អែកតាមមាត្រា ៤១១ អានុភាពដែលកើតចេញពីការរំលាយកិច្ចសន្យា គឺមានដូចខាងក្រោម :

ក- ការរំលាយកិច្ចសន្យានាំឱ្យគូភាគីរួចផុតពីករណីយកិច្ចក្នុងកិច្ចសន្យា លើកលែងតែករណីយកិច្ចសងការខូចខាត ។

ខ- គូភាគី មានកាតព្វកិច្ច ធ្វើបដិទានឡើងវិញទៅស្ថានភាពដើមរបស់ភាគីម្ខាងទៀត ។

គ- ភាគី ត្រូវសងប្រាក់ជាមួយនឹងការប្រាក់ ឬ បង្វិលវត្ថុជាមួយនឹងផលប្រយោជន៍ ដែលបានទទួលពីវត្ថុនោះ ។

ក៏ប៉ុន្តែ វា មិនមានបញ្ញត្តិណាមួយ ដែលចែងច្បាស់ថា ហេតុអ្វី បានជាអានុភាពទាំងនេះកើតឡើង ។

ចំពោះអានុភាពនៃការរំលាយកិច្ចសន្យានេះ មានគំនិតពីរ ដែល គំនិតទី ១ ដែលទទួលស្គាល់អានុភាពនៃការរំលាយកិច្ចសន្យា មានអានុភាពប្រតិសកម្ម (ហៅកាត់ថា គំនិត A) និងគំនិតមួយទៀត គឺមិនទទួលស្គាល់អានុភាពនៃការរំលាយកិច្ចសន្យា មានអានុភាពប្រតិសកម្ម (ហៅកាត់ថា គំនិត B)។

**១. គំនិតដែលទទួលស្គាល់អានុភាពប្រតិសកម្ម ( គំនិត A)**

ផ្អែកតាមគំនិតនេះ នៅក្នុងករណីដែលកិច្ចសន្យា ត្រូវបានរំលាយ វា ត្រូវបានចាត់ទុក គ្មានកិច្ចសន្យាតាំងពីដំបូង។ ដូច្នេះ ប្រសិនបើ ភាគី បានទទួលតាវកាលិក នៅមុនពេលរំលាយ គាត់ ត្រូវធ្វើបដិទានឡើងវិញ ទៅស្ថានភាពដើមរបស់ភាគីម្ខាងទៀត ដោយផ្អែកលើសេចក្តីចំរើនដោយឥតហេតុ។

នៅក្នុងករណីសេចក្តីចំរើនដោយឥតហេតុ កាតព្វកិច្ចត្រូវសង ជាទូទៅ ត្រូវបានកំរិតត្រឹមផលប្រយោជន៍ដែលមាន (មាត្រា ៧៣៦ កថាខណ្ឌទី ១)។ ឧទាហរណ៍ នៅក្នុងករណីដែល ខ បានទិញអង្ករ ១០ គីឡូក្រាមពី ក នៅក្នុងតំលៃ ១០០ ដុល្លា ហើយ បានបង់ប្រាក់ ៥០ ដុល្លា។ ក្រោយមក នៅពេលដែល ខ បានបរិភោគអង្ករអស់ ៤ គីឡូក្រាម ក បានរំលាយកិច្ចសន្យា ព្រោះ ខ មិនបានបង់ប្រាក់ ៥០ ដុល្លា ទៀត។ កាតព្វកិច្ចដែល ខ ត្រូវសង ក្នុងករណីសេចក្តីចំរើនដោយឥតហេតុ ត្រូវបានកំរិតត្រឹម ៦ គីឡូក្រាម ដោយផ្អែកលើមាត្រា ៧៣៦ កថាខណ្ឌទី ១។ ក៏ប៉ុន្តែ នៅក្នុងករណីនៃការរំលាយកិច្ចសន្យា ខ ត្រូវមានកាតព្វកិច្ចធ្វើបដិទានទៅស្ថានភាពដើមរបស់ ក ដោយផ្អែកលើមាត្រា ៤១១ កថាខណ្ឌទី ២។ នៅក្នុងករណីនេះ ខ ត្រូវសង ៤០ ដុល្លា ចំពោះអង្ករ ដែលបានបរិភោគ ឬ គេ អាចពិចារណាថា ខ ត្រូវសងអង្ករ ៤ គីឡូក្រាម ដែលមានគុណភាពដូចគ្នា ព្រោះ កម្មវត្ថុដើម គឺជាវត្ថុ ដែលមិនត្រូវបានកំណត់ជាក់លាក់។

ដូច្នេះ ដោយផ្អែកលើគំនិត A ទំហំនៃកាតព្វកិច្ចដែលត្រូវបដិទាន ត្រូវបានពន្លាតចាប់ពី "ផលប្រយោជន៍ទៅត្រឹមកំរិតដែលផលប្រយោជន៍នោះមាន (មាត្រា ៧៣៦ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី)" រហូតដល់ "ការធ្វើបដិទានទៅស្ថានភាពដើមរបស់ភាគី (កថាខណ្ឌទី២ មាត្រា ៤១១ នៃក្រមរដ្ឋប្បវេណី )"។

**<u>ទំនាក់ទំនងជាមួយការផ្ទេរកម្មសិទ្ធិ</u>**

ដោយផ្អែកតាមគំនិត A ការផ្ទេរកម្មសិទ្ធិត្រូវបានរលត់ ដោយប្រតិសកម្ម ព្រោះការរំលាយ មានអានុភាពប្រតិសកម្ម ។

ឧទាហរណ៍ ក បានធ្វើកិច្ចសន្យាលក់រថយន្តឱ្យទៅ ខ ហើយ ក បានប្រគល់ទៅឱ្យ ខ ប៉ុន្តែ ដល់ពេលបង់ថ្លៃលក់ ខ ខកខានមិនបានបង់ថ្លៃលក់មកឱ្យ ក ទោះបីជាមានការដាស់តឿនរបស់ ក ក៏ដោយ។ ហើយ ក បានរំលាយកិច្ចសន្យា។ គំនិតនេះ ទទួលស្គាល់ថា ការរំលាយកិច្ចន្យា មានអានុភាពប្រតិសកម្ម។ ដូច្នេះ អ្នកទិញ ខ មិនមែនជាកម្មសិទ្ធិករតាំងពីដំបូង ដោយសារការរំលាយកិច្ចសន្យា។ ឬនិយាយម្យ៉ាងទៀត កម្មសិទ្ធិ មិនត្រូវ "ប្រគល់" ត្រលប់ពី ខ ទៅ ក ទេ។ វា មានន័យថា ក ត្រូវបានចាត់ទុកថា ជាកម្មសិទ្ធិតាំងពីដំបូង។ ដូច្នេះ ក អាចទាមទារអោយប្រគល់រថយន្តមកវិញ ដោយផ្អែកលើកម្មសិទ្ធិ ប្រសិនបើ ខ កាន់កាប់រថយន្តនោះ។

## ២. គំនិតដែលមិនទទួលស្គាល់អានុភាពប្រតិសកម្ម ( គំនិត B)

ផ្អែកតាមគំនិតនេះ ការរំលាយកិច្ចសន្យា ត្រូវបានចាត់ទុកថា គ្មានអានុភាពប្រតិសកម្ម។ ដូច្នេះ សិទ្ធិលើបំណុល និង កាតព្វកិច្ចដើម ត្រូវផ្លាស់ប្តូរទៅជា សិទ្ធិទាមទារ និង កាតព្វកិច្ចធ្វើបដិទានទៅស្ថានភាពដើមរបស់គូភាគី។

តាមឧទាហរណ៍ខាងលើ ក្នុងករណីដែល ក បានរំលាយកិច្ចន្យា នោះមិនត្រូវចាត់ទុកថា ខ គ្មានកម្មសិទ្ធិតាំងពីដំបូងឡើយ ប៉ុន្តែនៅពេលដែល ក រំលាយកិច្ចសន្យា ខ ត្រូវប្រគល់រថយន្តទៅឱ្យ ក វិញ ដែលជាកាតព្វកិច្ចថ្មីដោយផ្អែកលើការរំលាយកិច្ចសន្យា។

នៅក្នុងគំនិតនេះ បញ្ញត្តិនៃការរំលាយកិច្ចសន្យា ត្រូវយកមកអនុវត្តចំពោះពេលអនាគត ហើយ ទាក់ទងនឹងកាតព្វកិច្ច ដែលមិនទាន់ត្រូវបានអនុវត្ត គឺមិនមានអត្ថិភាពទៀតទេ នៅពេលអនាគត។ ផ្ទុយទៅវិញ កាតព្វកិច្ចដែលបានអនុវត្តរួចហើយ គឺមានសុពលភាព ហើយ មិនអាចក្លាយសេចក្តីចំរើនឥតហេតុទេ។

គំនិត B រិះគន់នូវគំនិត A ដោយផ្អែកលើមូលហេតុថា គឺមិនបទបញ្ញត្តិ ចែងអំពីអានុភាពប្រតិសកម្មនៃការរំលាយកិច្ចសន្យា។ ក្នុងករណីនៃការលុបចោលកិច្ចសន្យា ក្រមរដ្ឋប្បវេណី បានចែងអំពីអត្ថិភាពភាពនៃអានុភាពប្រតិសកម្មយ៉ាងច្បាស់លាស់ (មាត្រា ៣៥៨ កថាខណ្ឌទី ២)។ មូលហេតុដែលក្រមរដ្ឋប្បវេណី ទទួលស្គាល់នូវអានុភាពប្រតិសកម្មលើការលុបចោល គឺថាវា មានវិការៈតាំងពីដំបូង។ ផ្ទុយទៅវិញ នៅក្នុងករណីនៃការរំលាយកិច្ចសន្យា កិច្ចសន្យា ត្រូវបានបង្កើតឡើងដោយមានសុពលភាពយ៉ាងពេញលេញ ប៉ុន្តែ មូលហេតុនៃការរំលាយ គឺកើតមានឡើងនៅពេលក្រោយមកទៀត។ គំនិត B បានលើកឡើងថា ដើម្បីទទួលស្គាល់នូវអានុភាពប្រតិសកម្ម ដែលបដិសេធនូវអានុភាពនៃកិច្ចសន្យា តាំងពីដំបូង នោះការអនុម័តអោយមានច្បាប់សារធាតុ គឺមានភាពចាំបាច់ត្រូវតែមាន ជាពិសេសនៅក្នុងករណីនៃការរំលាយកិច្ចសន្យា ព្រោះ វា ត្រូវបានបង្កើតឡើងដោយមានសុពលភាពយ៉ាងពេញលេញ។

### <u>ទំនាក់ទំនងជាមួយការផ្ទេរកម្មសិទ្ធិ</u>

ផ្អែកតាមគំនិត B កម្មសិទ្ធិ ត្រូវបានធ្វើបដិទាន ដោយស្វ័យប្រវត្តិដោយសារការរំលាយកិច្ចសន្យា នៅពេលដែលរំលាយកិច្ចសន្យានោះ។ ឧទាហរណ៍ កម្មសិទ្ធិ ត្រូវបានផ្ទេរទៅអ្នកទិញ ខ នៅពេលបង្កើតកិច្ចសន្យា ហើយធ្វើបដិទានទៅអោយអ្នកលក់ ក វិញ ដោយស្វ័យប្រវត្តិ នៅពេលរំលាយកិច្ចសន្យា ដែលវាជាអានុភាពនៃការរំលាយកិច្ចសន្យា។ ដូច្នេះ ខ ត្រូវមានកាតព្វកិច្ចប្រគល់កម្មវត្ថុត្រឡប់មកវិញ ប្រសិនបើ គាត់ បានទទួលវត្ថុនោះរួចហើយ។

### ៥.២ ការរលត់នូវទំនាក់ទំនងក្នុងកិច្ចសន្យា

### ៥.២.១ ការរលត់នូវករណីយកិច្ចនៃកិច្ចសន្យា

ផ្អែកតាមគំនិត A នៅពេលមានការរំលាយកិច្ចសន្យា នោះករណីយកិច្ចទាំងឡាយរបស់ភាគី ដែលកើតឡើងពីកិច្ចសន្យា ត្រូវរលត់ដោយប្រតិសកម្ម ដែលវា មានន័យថា ភាគីនៃកិច្ចសន្យា រួចផុតពីករណីយកិច្ចក្នុងកិច្ចសន្យា លើកលែងតែករណីសងការខូចខាត តាមកថាខណ្ឌទី ១ មាត្រា ៤១១។

ផ្អែកតាមគំនិត B នៅពេលមានការរំលាយកិច្ចសន្យា នោះករណីយកិច្ចទាំងឡាយរបស់ភាគី ដែលកើតឡើងពីកិច្ចសន្យា ដែលបានបំពេញរួចហើយ ត្រូវបានផ្លាស់ប្តូរទៅជាកាតព្វកិច្ចសងត្រឡប់វិញ ដូច្នេះ ភាគី ដែលបានទទួលវត្ថុតាមកិច្ចសន្យាពីភាគីម្ខាងទៀត ត្រូវផ្ទេរវត្ថុដែលបានទទួលនោះមកឱ្យវិញ។ ទន្ទឹមនឹងនេះ ចំពោះកាតព្វកិច្ចដែលភាគី នៅមិនទាន់បានបំពេញរវាងគ្នានឹងគ្នានៅឡើយ ត្រូវរលត់ ឆ្ពោះទៅអនាគត ដោយសារការរំលាយកិច្ចសន្យា។

### ៥.២.២ ការធ្វើបដិទាននៃការផ្ទេរកម្មសិទ្ធិ

ឧទាហរណ៍ ក និង ខ បានបង្កើតកិច្ចសន្យាលក់ទិញមួយ ដើម្បីលក់រថយន្តរបស់ ក អោយទៅ ខ ហើយ ក បានប្រគល់រថយន្តហើយ ប៉ុន្តែ ក បានរំលាយកិច្ចសន្យានេះ ព្រោះ ខ មិនបានបង់ប្រាក់ថ្លៃទិញ ទោះជាមានការដាស់តឿនរបស់ ក។

នៅក្នុងករណីនេះ ដោយផ្អែកតាមគំនិត A គេ ចាត់ទុកថា ខ មិនដែលទទួលបានកម្មសិទ្ធិ ហើយ ក គឺជាកម្មសិទ្ធិករតាំងពីដំបូង។ ដូច្នេះ ក អាចទាមទារអោយប្រគល់កម្មសិទ្ធិមកវិញ ដោយផ្អែកលើកម្មសិទ្ធិ។

ផ្ទុយទៅវិញ ផ្អែកតាមគំនិត B កម្មសិទ្ធិ ត្រូវបានផ្ទេរ ហើយ ការកាតព្វកិច្ចក្នុងការប្រគល់កម្មសិទ្ធិត្រលប់មកវិញ គឺជាកាតព្វកិច្ចថ្មីមួយ។ ទន្ទឹមនឹងនេះ កម្មសិទ្ធិ ត្រូវប្រគល់មកអោយ ក ដោយស្វ័យប្រវត្តិ នៅពេលរំលាយកិច្ចសន្យា។ ដូច្នេះ ក អាចទាមទារអោយប្រគល់រថយន្តមកវិញ ដោយផ្អែកលើកម្មសិទ្ធិបាន។

ភាពខុសគ្នារវាងគំនិតទាំងពីរខាងលើនេះ គឺមានឥទ្ធិពលទៅលើគំនិតនៃការការពារតតិយជន ដែលមានផលប្រយោជន៍ពាក់ពន្ធ័។

ឧទាហរណ៍ នៅក្នុងករណីខាងលើ ខ បានទទួលការប្រគល់រថយន្តពី ក ហើយ បានលក់រថយន្តនោះទៅឱ្យ គ ប៉ុន្តែ ក បានរំលាយកិច្ចសន្យាកិច្ចសន្យារវាង គ។

ដោយផ្អែកតាមគំនិត A អ្នកទិញ ក មិនមែនជាកម្មសិទ្ធិករលើរថយន្តនោះតាំងពីដំបូង ដូច្នេះ តតិយជន គ ត្រូវបានចាត់ទុកថា បានទិញរថយន្តពី ខ ដែលមិនមែនជាកម្មសិទ្ធិករលើរថយន្តនោះ ហេតុនេះ គ មិនអាចធ្វើលទ្ធកម្មកម្មសិទ្ធិលើរថយន្តនោះបានទេ។ ប៉ុន្តែ ការសន្និដ្ឋានបែបនេះ ធ្វើអោយប៉ះពាល់ដល់សុវត្ថិភាពនៃកិច្ចការ

ជំនួញរបស់ គ។ ដូច្នេះ មាត្រា ៤១១ កថាខណ្ឌទី ៤ ការពារតែតតិយជន ដែលបានបង្កើតនូវទំនាក់ទំនងនៃកិច្ចសន្យាមុនពេលរំលាយ។

ផ្ទុយទៅវិញ ដោយផ្អែកតាមគំនិត B អ្នកទិញ ខ ត្រូវចាត់ទុកថា មានកម្មសិទ្ធិរហូតដល់ពេលរំលាយកិច្ចសន្យា ហើយ នៅពេលដែលអ្នកលក់ ក បានរំលាយកិច្ចសន្យាលក់ទិញ កម្មសិទ្ធិ ត្រូវប្រគល់ត្រលប់ពីតតិយជន គ ទៅឱ្យអ្នកលក់ ក។ ដោយផ្អែកលើគំនិតនេះ គ ដែលមានវត្តមានមុនពេលរំលាយ បានទទួលនូវកម្មសិទ្ធិពី ខ។ ដូច្នេះ គំនិត B លើកឡើងថា មាត្រា ៤១១ កថាខណ្ឌ ៤ គឺគ្រាន់តែបញ្ញត្តិនៃការបញ្ជាក់បន្ថែមតែប៉ុណ្ណោះ។

ទន្ទឹមនឹងនេះ បញ្ហាដែលចោទឡើង ថាតើតតិយជន នៅក្នុងមាត្រា ៤១១ កថាខណ្ឌទី ៤ នេះ ត្រូវការពារទាំងតតិយជនដែលសុច្ចរិត និង ជនទុច្ចរិត ឬ តម្រូវឱ្យមានភាពគ្មានកំហុសបន្ថែមទៀត។ បញ្ហាទាំងនេះនឹងត្រូវទុកឱ្យដោះស្រាយតាមយុត្តិសាស្ត្រនាពេលអនាគត។ ក៏ប៉ុន្តែ នៅក្នុងកថាខណ្ឌទី ៤ នេះ ប្រើប្រាស់ពាក្យ "ផលប្រយោជន៍ត្រឹមត្រូវ" ដូច្នេះ គេ អាចពិចារណាថា មានតែតតិយជន ដែលជនសុច្ចរិត និង គ្មានកំហុសទេ ត្រូវទទួលបាននូវការការពារតាមបញ្ញត្តិនេះ ហើយ តតិយជន ដែលជាជនទុច្ចរិត ឬ សុចរិតតែមានកំហុស មិនត្រូវបានការពារទេ ព្រោះ គាត់ មិនមានផលប្រយោជន៍ត្រឹមត្រូវឡើយ ។

## ៥.៣ កាតព្វកិច្ចក្នុងការធ្វើបដិទានទៅស្ថានភាពដើម

### ៥.៣.១ លក្ខណៈនៃកាតព្វកិច្ចធ្វើបដិទាន

តាមគោលគំនិត A កាតព្វកិច្ច ដែលត្រូវធ្វើដិទានត្រឡប់មកវិញនូវវត្ថុ ដែលបានប្រគល់តាមកិច្ចសន្យាបន្ទាប់ពីមានការរំលាយកិច្ចសន្យា គឺជាករណីពិសេសនៃសេចក្តីចំរើនដោយឥតហេតុ។ ជាទូទៅ ប្រសិនបើកិច្ចសន្យាត្រូវបានរំលាយ នោះ ត្រូវចាត់ទុកថាគ្មានកិច្ចសន្យាតាំងពីដំបូង ដូច្នេះ ទំហំនៃការព្វកិច្ចក្នុងការប្រគល់ ត្រូវកំរិតត្រឹមផលប្រយោជន៍ ដែលមាន ដោយផ្អែកលើមាត្រា ៧៣៦ កថាខណ្ឌទី ២។ ក៏ប៉ុន្តែ មាត្រា ៤១១ កថាខណ្ឌទី ២ បានពង្រីកទំហំនៃកាតព្វកិច្ចធ្វើបដិទាននេះ ទៅស្ថានភាពដើមរបស់ភាគី ដូចដែលមានរៀបរាប់។

តាមគោលគំនិត B កាតព្វកិច្ច ដែលត្រូវធ្វើដិទានត្រឡប់មកវិញនូវវត្ថុ ដែលបានប្រគល់តាមកិច្ចសន្យាបន្ទាប់ពីមានការរំលាយកិច្ចសន្យា គឺជាកាតព្វកិច្ចថ្មី ដោយផ្អែកលើការរំលាយកិច្ចសន្យា ចំណែកឯ កាតព្វកិច្ច ដែលបានអនុវត្តរួចហើយ មានសុពលភាព ព្រោះថា ការរំលាយកិច្ចសន្យា មានឥទ្ធិពលឆ្ពោះទៅអនាគតតែប៉ុណ្ណោះ។

### ៥.៣.២ ខ្លឹមសារនៃកាតព្វកិច្ចធ្វើបដិទាន

ក្រោយពីរំលាយកិច្ចសន្យា ភាគី ដែលបានទទួលតាវកាលិក ត្រូវសងនូវតាវកាលិកនោះ ទៅឱ្យភាគីម្ខាងទៀត។

ជាងនេះទៅទៀត ក្រមរដ្ឋប្បវេណី បានបញ្ញត្តិថា ភាគីដែលទទួលតាវកាលិក ត្រូវសងទៅវិញមិនត្រឹមតែអ្វីដែលគាត់បានទទួលនោះទេ គឺថែមទាំងត្រូវសងការប្រាក់ ឬ ផលប្រយោជន៍ ដែលកើតមានឡើងពីសិទ្ធិលើបំណុលជាប្រាក់ ឬ កម្មវត្ថុនោះទៀតផង។

នៅក្នុងន័យនេះ កាតព្វកិច្ច ធ្វើបដិទាន មានន័យថា មិនត្រឹមតែជាការធ្វើបដិទានទៅស្ថានភាពនៅពេលបង្កើតកិច្ចសន្យាទេ ប៉ុន្តែទៅដល់ស្ថានភាពដែលអាចមាន។ វា មានលក្ខណៈសំខាន់ណាស់ ក្នុងការពិចារណាថា "ប្រសិនបើ ភាគី មិនបានបង្កើតកិច្ចសន្យាទេ តើនឹងមានអ្វីបានកើតឡើងរហូតមកដល់ពេលនេះ ?"

នៅក្នុងករណីដែល តំលៃនៃកម្មវត្ថុ មានការផ្លាស់ប្តូរយ៉ាងខ្លាំង រវាងពេលបង្កើតកិច្ចសន្យា និង ពេលរំលាយកិច្ចសន្យា វា ត្រូវបានសង ដោយការទាមទារសំណងនៃការខូចខាត ព្រោះក្រមរដ្ឋប្បវេណី បានចែងត្រឹមតែទំហំនៃការធ្វើបដិទាន ត្រូវបានកំរិតនៅក្នុងការសងមកវិញនូវកម្មវត្ថុ ជាមួយផលប្រយោជន៍ ឬ ប្រាក់ជាមួយនឹងការប្រាក់។

### ៥.៣.៣ ករណីដែលភាគីនៃកិច្ចសន្យាមិនអាចសងត្រឡប់ទៅវិញនូវវត្ថុ ( មាត្រា ៤១២)

សិទ្ធិរំលាយត្រូវរលត់ នៅក្នុងករណីដែលភាគីមានសិទ្ធិរំលាយ :

ក- បានធ្វើឱ្យមានការខូចខាត ឬ បាត់បង់ដល់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ឬ មិនអាចសងវត្ថុនោះវិញដោយចេតនា។

ខ- ធ្វើឱ្យវត្ថុនោះ ក្លាយជាវត្ថុផ្សេងដោយសារកែច្នៃ ឬ ការផ្លាស់ប្តូរទំរង់។

ឬនិយាយម្យ៉ាងទៀត នៅក្នុងករណីដែល កម្មវត្ថុ ត្រូវបានធ្វើអោយខូចខាត ឬ បាត់បង់ ឬ មិនអាចសងមកវិញបាន ដោយមិនមានចេតនា នោះ សិទ្ធិរំលាយ មិនត្រូវរលត់ទេ។ នៅក្នុងករណីដែល ភាគី ដែលមានសិទ្ធិរំលាយ ត្រូវសងជាប្រាក់នូវតំលៃដែលជាកម្មវត្ថុនោះ ត្រឹមកំរិតតំលៃ ដែលបានកំណត់នៅក្នុងកិច្ចសន្យា។

| |
|---|
| ករណីសិក្សា<br><br>**ក** បានលក់រថយន្តថ្មីទៅអោយ **ខ** ហើយ បានប្រគល់រថយន្តនោះទៅអោយ **ខ** រួចរាល់ហើយ។ **ខ** បានបង់ប្រាក់ថ្លៃទិញចំនួន ២០,០០០ ដុល្លា ទៅអោយ **ក**។ ក្រោយមក គេ បានដឹងថា រថយន្តនោះ មិនមែនជារថយន្តថ្មីទេ ហើយតំលៃរបស់វា មានត្រឹមតែ ១៥,០០០ ដុល្លា តែប៉ុណ្ណោះ។ **ខ** បានដាស់តឿនអោយ **ក** ត្រូវប្រគល់រថយន្តថ្មី ប៉ុន្តែ **ក** មិនបានប្រគល់រថយន្តថ្មី នៅក្នុងអំឡុងពេលដោយសមរម្យកំណត់នោះទេ។ បន្ទាប់មក **ខ** បានរំលាយកិច្ចសន្យា ដោយផ្អែកលើមាត្រា ៤០៨ កថាខណ្ឌទី ១ ចំណុច ក។ ក្រោយមកទៀត នៅមុនពេលអនុវត្តកាតព្វកិច្ចប្រគល់ **ខ** បានធ្វើអោយរថយន្តនោះខូចខាត ដោយអចេតនា។<br><br>តើ **ខ** អាចទាមទារអ្វីបានពី **ក** ? |

ប៉ុន្តែ គេ ក៏អាចគិតបានថា ទោះបីជា កិច្ចសន្យា ត្រូវបានរលត់តាំងពីដំបូង ដោយអានុភាពប្រតិសកម្មក៏ដោយ ក៏ការខូចខាតដោយសារការមិនអនុវត្តកាតព្វកិច្ច នៅតែមាន នៅក្រោយការរំលាយកិច្ចសន្យា។ ដោយផ្អែកលើគំនិតនេះ ខ អាចទាមទារសំណងនៃការខូចខាតចំពោះ ផលប្រយោជន៍ពីការអនុវត្ត ៥,០០០ ដុល្លា។

**<តាមគំនិត B>**

ដោយផ្អែកលើគំនិត B ភាគី ដែលមានសិទ្ធិរំលាយ អាចទាមទារសំណងនៃការខូចខាត ចំពោះផលប្រយោជន៍ពីការរំពឹងទុក (ផលប្រយោជន៍ពីការអនុវត្ត) បានជាធម្មតា ព្រោះ ការទទួលខុសត្រូវ ចំពោះការមិនអនុវត្តកាតព្វកិច្ច នៅតែមាន នៅក្រោយពេលរំលាយកិច្ចសន្យា។

**២. ទំហំនៃសំណងសំរាប់ការខូចខាត**

នៅក្នុងករណីដែល សងផលប្រយោជន៍ពីការរំពឹងទុក (ផលប្រយោជន៍ពីការអនុវត្ត) ត្រូវបានទទួលស្គាល់នោះ មាត្រា ទាក់ទងនឹងការខូចខាត ដែលផ្អែកលើការមិនអនុវត្តកាតព្វកិច្ច (មាត្រា ៣៩៨ ដល់ មាត្រា ៤០១) ត្រូវយកមកអនុវត្ត។

ក៏ប៉ុន្តែ វា គឺជាបញ្ហា ដែលនៅពេលណា គឺជាពេល ដែលត្រូវគិតពីមាត្រដ្ឋាននៃការសងការខូចខាត។ បញ្ហានេះ ត្រូវបានភ្ជាប់ទៅនឹងការបកស្រាយ ទៅនឹងទំហំនៃសំណងនៃការខូចខាត (មាត្រា ៤០១)។

នៅក្នុងករណីនេះ គេ អាចគិតថា ពេលនៃមាត្រដ្ឋាន គឺជាពេលរំលាយកិច្ចសន្យា ព្រោះ សិទ្ធិទាមទារសំណងនៃការខូចខាត គឺទាញចេញមកពីការរំលាយកិច្ចសន្យា។ ដោយផ្អែកលើគំនិតនេះ ក និង ខ ត្រូវដោះដូរគ្នានូវទឹកប្រាក់ ២០,០០០ ដុល្លា ជាមួយនឹងរថយន្ត ហើយ ខ អាចទាមទារសំណងនៃការខូចខាត ៥,០០០ ដុល្លា ដែលជាផលប្រយោជន៍ពីការរំពឹងទុក។

ទន្ទឹមនឹងនេះ គេ អាចចាត់ទុកថា មានតែនៅពេលដែល ភាគី ដែលមានសិទ្ធិរំលាយ បានលក់នូវកម្មវត្ថុនោះ ទៅអោយតតិយជន នៅមុនពេលរំលាយកិច្ចសន្យា ហើយ ការកើតឡើងនៃការខូចខាតនៅក្នុងកាលៈទេសៈពិសេស ដែលគូភាគី អាចព្យាករណ៍ជាមុន នៅពេលអនុវត្តកិច្ចសន្យា នោះតំលៃដែលលក់ ត្រូវបានទទួលស្គាល់ជាការខូចខាត (មាត្រា ៤០១ កថាខណ្ឌទី ២)។ ដោយផ្អែកលើគំនិតនេះ ខ អាចទាមទារ ១០,០០០ ដុល្លា ដែលជាផលប្រយោជន៍ពីការរំពឹងទុក ប្រសិនបើ ក និង ខ បានព្យាករណ៍ពីការកើតឡើងនៃផលប្រយោជន៍បានមកពីការលក់ម្តងទៀត នៅពេលដែលកិច្ចសន្យា ត្រូវបានអនុវត្ត។

## ៦. ការរលត់នូវសិទ្ធិរំលាយកិច្ចសន្យា

### ៦.១ នៅក្នុងករណីដែលការខូចខាត ជាអាទិ៍ នៃកម្មវត្ថុនៃកិច្ចសន្យា កើតឡើងដោយចេតនា

សិទ្ធិរំលាយ ត្រូវរលត់ នៅក្នុងករណីដែល ភាគី ដែលមានសិទ្ធិរំលាយ

(ក) ធ្វើអោយខូចខាត ឬ បាត់បង់ដល់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ឬ មិនអាចសងវត្ថុនោះវិញដោយចេតនា

(ឧទាហរណ៍ : កម្មវត្ថុនៃកិច្ចសន្យា បានលក់បន្តបាត់ ឬ បានបែកបាក់អស់ ដោយចេតនា)

ឬ

(ខ) ធ្វើអោយវត្ថុនោះក្លាយជាវត្ថុប្រភេទផ្សេង ដោយការកែច្នៃ ឬ ការផ្លាស់ទំរង់ដោយចេតនា

(ឧទាហរណ៍ : កិច្ចសន្យាទិញលក់អង្ករ តែអង្ករដែលបានទិញ-លក់ បានកិនក្លាយជាម្សៅអស់ហើយ នឹងបានផលិតជានំប៉ុង ទៅហើយ ។)

មូលហេតុដែលសិទ្ធិរំលាយកិច្ចសន្យា ត្រូវរលត់នៅក្នុងករណីទាំងពីរខាងលើនេះ គឺដោយសារតែ វា ផ្ទុយនឹង "គោលការណ៍នៃភាពសុចរិត និង ស្មោះត្រង់" (មាត្រា ៥) ប្រសិនបើ ភាគី ដែលបានធ្វើអោយខូចខាត ឬ មិនអាចសងវត្ថុនោះវិញដោយចេតនា អាចរំលាយកិច្ចសន្យាបាន ។

សិទ្ធិរំលាយកិច្ចសន្យា មិនត្រូវបានរលត់ទេ នៅក្នុងករណីដែលកម្មវត្ថុ គឺត្រូវបានធ្វើអោយខូចខាត ឬ បាត់បង់ដល់វត្ថុដែលជា កម្មវត្ថុនៃកិច្ចសន្យា ឬ មិនសងវត្ថុនោះវិញ ដោយអចេតនា ។ នៅក្នុងករណីនេះ ភាគី ដែលមានសិទ្ធិរំលាយកិច្ចសន្យា ត្រូវសងជា ប្រាក់នូវតំលៃដែលជាកម្មវត្ថុនោះ ត្រឹមកំរិតតំលៃដែលបានកំណត់ក្នុងកិច្ចសន្យា (មាត្រា ៤១២ កថាខណ្ឌទី ២) ។

### ៦.២ ការរលត់ដោយសារអាជ្ញាយុកាល

មាត្រា ៤១៣ បញ្ញត្តិថា សិទ្ធិរំលាយកិច្ចសន្យាដោយមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ច និង សិទ្ធិទាមទារបដិទាន ត្រូវរលត់ ដោយអាជ្ញាយុកាល ០៥ ឆ្នាំ ក្រោយពីពេលដែលមិនបានអនុវត្តកាតព្វកិច្ច ។

**ការមិនអនុវត្តកាតព្វកិច្ច :** ត្រូវបានគិតចាប់ពីពេលដែលមានការយឺតយ៉ាវ ។

**ឯការយឺតយ៉ាវ :** ត្រូវបានគិតចាប់ពីពេលដែល ភាគីម្ខាង បានអនុវត្តកាតព្វកិច្ចរួចរាល់ ។

ការទាមទារអោយធ្វើបដិទានឡើងវិញ ដោយផ្អែកលើការរំលាយកិច្ចសន្យា មិនត្រូវធ្វើដោយឯករាជ្យពីការរំលាយកិច្ចសន្យាទេ ហើយភាគី ដែលមានសិទ្ធិទាមទារអោយធ្វើបដិទាន ត្រូវអនុវត្តសិទ្ធិនេះ នៅមុនពេលសិទ្ធិរំលាយត្រូវរលត់ ដោយអាជ្ញាយុកាល ។

ឧទាហរណ៍ នៅក្នុងករណីដែល **ក** និង **ខ** បានចុះកិច្ចសន្យាលក់ទិញ ប៉ុន្តែ **ខ** មិនបានបង់ប្រាក់ថ្លៃទិញ ទោះបីជាមានការប្រគល់របស់ **ក** ក៏ដោយ ។ **ខ** ត្រូវស្ថិតនៅក្នុងភាពយឺតយ៉ាវ ចាប់ពីពេលដែល **ក** បានធ្វើការប្រគល់

កម្មវត្ថុ។ នៅក្នុងករណីនេះ អាជ្ញាយុកាលនៃការរំលត់ ត្រូវចាប់គិតពីពេលដែល ខ ស្ថិតនៅក្នុងភាពយឺតយ៉ាវ។ ដូច្នេះ ក ត្រូវអនុវត្តសិទ្ធិរំលាយកិច្ចសន្យា និង សិទ្ធិទាមទារបដិទាន ក្នុងអំឡុងពេល ៥ ឆ្នាំ ចាប់ពីពេលប្រគល់របស់ ក។

### ៦.៣ ការរលត់ដោយសារការអនុវត្តកាតព្វកិច្ច ឬ ដោយសារសំណើរផ្តល់ការអនុវត្តកាតព្វកិច្ច

**លក្ខខណ្ឌដើម្បីបង្កើតអានុភាពនៃការរំលាយ ដោយផ្អែកលើមូលហេតុថា ការយឺតយ៉ាវនៅក្នុងការអនុវត្តកាតព្វកិច្ច គឺ :**

i) ភាគីម្ខាងទៀត មិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួន

ii) ភាគី ដែលចង់រំលាយកិច្ចសន្យា បានដាស់តឿនឱ្យអនុវត្តកាតព្វកិច្ច ដោយកំណត់អំឡុងពេលសមរម្យ

iii) កូនបំណុល មិនបានអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួននៅក្នុងអំឡុងពេលកំណត់នោះ។

ដូច្នេះ ប្រសិនបើកូនបំណុល អនុវត្តកាតព្វកិច្ចនៅក្នុងអំឡុងពេលនោះ ហើយកាតព្វកិច្ច ត្រូវរលត់ដោយសារការសំរេចនូវគោលបំណងនោះ សិទ្ធិរំលាយ ក៏ត្រូវរលត់ដែរ។

បន្ទាប់ ចុះចំពោះករណីដែលម្ចាស់បំណុល ប្រកែកមិនព្រមទទួលយកកម្មវត្ថុ ទោះបីជា កូនបំណុល បានស្នើផ្តល់ការអនុវត្តកាតព្វកិច្ច ដោយយោងទៅតាមការដាស់តឿនរបស់ម្ចាស់បំណុល តើវា នឹងទៅជាយ៉ាងណា? នៅក្នុងករណីនេះ ប្រសិនបើ ម្ចាស់បំណុល បានទទួលនូវកម្មវត្ថុ នោះកាតព្វកិច្ច នឹងត្រូវរលត់។ ដូច្នេះ នៅក្នុងករណីនេះ គេ អាចទទួលស្គាល់ថា សិទ្ធិរំលាយរបស់ម្ចាស់បំណុល ត្រូវរលត់ ដោយសារតែការអនុវត្តកាតព្វកិច្ចរបស់កូនបំណុល ដោយផ្អែកលើគោលការណ៍នៃភាពយុត្តិធម៌។

## ៧. ការរំលាយកិច្ចសន្យា និង តតិយជន

មាត្រា ៤១១ កថាខណ្ឌទី ៤ បានចែងថា "ការរំលាយកិច្ចសន្យា មិនអាចធ្វើអោយខូចផលប្រយោជន៍ត្រឹមត្រូវរបស់តតិយជនបានឡើយ"។ ទស្សនៈនៃ "តតិយជន" សំដៅទៅលើជន ដែលក្រៅពីសាមីភាគី ឬ ជនទទួលបន្តទូទៅរបស់សាមីភាគី ដូចជា សន្តតិជន ឬ នីតិបុគ្គលដែលបានរួមបញ្ចូលគ្នា។ ដូចនេះ តើ ជនក្រៅពីសាមីភាគី អាចក្លាយជា "តតិយជន" ដែរ ឬ ទេ? មាត្រា ៤១១ កថាខណ្ឌទី ៤ បានបញ្ញត្តិថា មានតែតតិយជន ដែលមានផលប្រយោជន៍ត្រឹមត្រូវ ទើបជាតតិយជន។

ឧទាហរណ៍ នៅក្នុងករណីដែលរថយន្ត ត្រូវបានលក់ពី ក ទៅ ខ បន្ទាប់មក ពី ខ ទៅ គ។ គ មិនអាចជៀសផុតពីផលប៉ះពាល់បានទេ ប្រសិនបើ ក រំលាយកិច្ចសន្យា។ គេ អាចបែងចែងករណីទាំងនេះ ជាពីរប្រភេទដោយផ្អែកទៅលើវត្តមានរបស់តតិយជន។

ឧទាហរណ៍ ករណីទី ១ គឺនៅក្រោយពេលដែល ខ បានលក់រថយន្តឱ្យទៅ គ ហើយ ក រំលាយកិច្ចសន្យាលក់ទិញជាមួយនឹង ខ។ គ នៅក្នុងករណីនេះ ត្រូវបានគេហៅថា "តតិយជននៅមុនការរំលាយ"។ ករណីមួយទៀត

គឺ "តតិយជននៅក្រោយការរំលាយ"។ ឧទាហរណ៍ ក រំលាយកិច្ចសន្យាជាមួយនឹង ខ ប៉ុន្តែ ខ បានលក់រថយន្ត នោះបន្តអោយទៅ គ នៅក្រោយការរំលាយ។ នៅក្នុងករណីនេះ វា មានសារសំខាន់ណាស់ក្នុងការគិតថា ការលក់របស់ ខ គឺជាការកែបន្លំយកទ្រព្យ ដោយទុច្ចរិត។ ប៉ុន្តែ អានុភាពរបស់កិច្ចសន្យាលក់បន្តនេះ ត្រូវធ្វើការពិចារណាដាច់ដោយឡែកពីករណីព្រហ្មទណ្ឌ។

វាមិនមានភាពច្បាស់លាស់ថាតើ មាត្រា ៤១១ កថាខណ្ឌទី ៤ ទាមទារថា តតិយជន ត្រូវតែមានផលប្រយោជន៍ត្រឹមត្រូវ នៅមុនពេលរំលាយ និង ជនតតិយជន ដែលក្រោយកិច្ចសន្យាត្រូវបានរំលាយ ត្រូវទទួលបាននូវការការពារ ដោយមាត្រា ៤១១ កថាខណ្ឌទី ៤ ដែរ ឬ អត់។

តើត្រូវការពារតតិយជនយ៉ាងដូចម្តេចនោះ គឺអាស្រ័យទៅលើថាតើ អានុភាពប្រតិសកម្ម ត្រូវបានទទួលស្គាល់ ឬ មិនទទួលស្គាល់។

និយាយជាទូទៅ គឺមានគំនិតចំនួនពីរ ទាក់ទងនឹង អានុភាពប្រតិសកម្ម នៅក្នុងការរំលាយកិច្ចសន្យា។

- គំនិត ដែលទទួលស្គាល់អានុភាពប្រតិសកម្មនៃការរំលាយកិច្ចសន្យា (ខាងក្រោមនេះ សូមហៅកាត់ថា "គំនិត A")

- គំនិត ដែលមិនទទួលស្គាល់អានុភាពប្រតិសកម្មនៃការរំលាយកិច្ចសន្យា (ខាងក្រោមនេះ សូមហៅកាត់ថា "គំនិត B")

ករណីឧទាហរណ៍ : ក បានលក់រថយន្តរបស់ខ្លួនអោយទៅ ខ។ គ បានទិញរថយន្តនោះពី ខ។

## ១. តាមគំនិត A

តាមទស្សនៈនេះ វា ត្រូវបានចាត់ទុកថា មិនដែលមាន កិច្ចសន្យាតាំងពីដំបូង រវាងគូភាគី ដោយសារការរំលាយកិច្ចសន្យា។ នៅក្នុងករណី ដែលអ្នកលក់ បានប្រគល់វត្ថុហើយ បន្ទាប់មកកិច្ចសន្យា ត្រូវបានរំលាយ នោះអ្នកលក់ អាចទាមទារអោយអ្នកទិញ ប្រគល់វត្ថុមកវិញបាន ដោយផ្អែកលើកម្មសិទ្ធិ ដោយសារអានុភាពប្រតិសកម្ម គឺនាំអោយសិទ្ធិលើកម្មសិទ្ធិ មិនត្រូវបានផ្ទេរតាំងពីដំបូង។

ដូច្នេះ នៅក្នុងករណីខាងលើនេះ កម្មសិទ្ធិរបស់ ក គឺត្រូវបានចាត់ទុកថា មិនបានផ្ទេរពី ក ទៅ ខ ទេ។ ដូច្នេះ គ ត្រូវបានចាត់ទុកថា បានទទួលគ្រប់គ្រងបន្តលើកម្មសិទ្ធិពី ខ ដែលមិនមានកម្មសិទ្ធិ ដូច្នេះ ជាលក្ខណៈសមហេតុផល គឺ គ មិនអាចទទួលបានកម្មសិទ្ធិទេ។

ទោះបីជា តាមទសន្សៈនេះ ទទួលស្គាល់អានុភាពប្រតិសកម្ម ប៉ុន្តែតាមមាត្រា ៤១១ កថាខណ្ឌទី ៤ គឺជាបទបញ្ញត្តិពិសេស ដើម្បីការពារតតិយជន ដែលមានផលប្រយោជន៍ស្របច្បាប់ ដូច្នេះបើ តតិយជន មានផលប្រយោជន៍ស្របច្បាប់ អានុភាពនៃការរំលាយកិច្ចសន្យា មិនអាចអះអាងចំពោះតតិយជនបានទេ។

**តើតតិយជនយ៉ាងណា ដែលកំណត់ថាមានផលប្រយោជន៍ស្របច្បាប់?**

**តាមមាត្រា ៤១១ កថាខណ្ឌទី៤ ការរំលាយកិច្ចសន្យារបស់គូភាគី មិនអាចមានអានុភាពនាំអោយប៉ះពាល់ដល់ផលប្រយោជន៍របស់តតិយជន បើតតិយជននោះ ជាជនសុច្ចរិត និង គ្មានកំហុស។**

- ម៉្យាងទៀត តតិយជន ត្រូវមានទំនាក់ទំនងនៅក្នុងកិច្ចសន្យា មុនពេលរំលាយកិច្ចសន្យា ទើបអាចអះអាងពីផលប្រយោជន៍របស់ខ្លួនបាន។

- លក្ខខណ្ឌតតាំង : ចាំបាច់ / មិនចាំបាច់

គេ អាចចាត់ទុកថា តតិយជន ត្រូវទទួលបានការកាន់កាប់ (ចលនវត្ថុ) ឬ ចុះបញ្ជី (អចលនវត្ថុ) ដើម្បីទទួលបាននូវការការពារតាមមាត្រា ៤១១ កថាខណ្ឌទី ៤ ព្រោះ តតិយជន ត្រូវបានគេចាត់ទុក បានខិតខំប្រឹងប្រែងជាអតិបរមា ដើម្បីការពារសិទ្ធិរបស់ខ្លួន។ ដោយផ្អែកទៅទៅលើគំនិតនេះ ការកាន់កាប់ ឬការចុះបញ្ជី មានតួនាទីជា "លក្ខខណ្ឌដើម្បីបង្កើតអានុភាពនៃសិទ្ធិរក្សាការពារ"។
ផ្ទុយទៅវិញ គេ អាចគិតថា លក្ខខណ្ឌតតាំង គឺមានលក្ខណៈចាំបាច់សំរាប់តតិយជន ក្នុងការទទួលបានការការពារទេ ព្រោះមាត្រា ៤១១ កថាខណ្ឌទី ៤ មិនបានតំរូវអោយមានលក្ខខណ្ឌតតាំងសំរាប់តតិយជនទេ។

បន្ទាប់មក ចុះចំពោះករណីតតិយជន នៅក្រោយការរំលាយកិច្ចសន្យា តើមានលក្ខណៈដូចម្តេចដែរ ?

ដោយផ្អែកលើគំនិត A តតិយជន ដែលបានចុះកិច្ចសន្យា នៅក្រោយការរំលាយកិច្ចសន្យា មិនអាចទទួលបាននូវការការពារតាមមាត្រា ៤១១ កថាខណ្ឌទី ៤ ទេ ព្រោះ អានុភាពប្រតិសកម្ម បានកើតឡើងរួចហើយ។ តតិយជន នៅក្រោយការរំលាយកិច្ចសន្យា ត្រូវបានចាត់ទុកថា បានធ្វើទទួលកម្មសិទ្ធិពី ជនដែលមិនមានកម្មសិទ្ធិ។ ដូច្នេះ តតិយជន មិនអាចធ្វើលទ្ធកម្មកម្មសិទ្ធិទេ។ ជាការពិត នៅក្នុងករណីដែលកម្មសិទ្ធិ គឺជាចលនវត្ថុ **គ** អាចធ្វើលទ្ធកម្មកម្មសិទ្ធិ ប្រសិនបើ **គ** បានបំពេញលក្ខខណ្ឌ ដែលមានចែងនៅក្នុងមាត្រា ១៩៣។ ក៏ប៉ុន្តែ នៅក្នុងករណីកម្មវត្ថុ គឺជាអចលនវត្ថុ តតិយជន មិនអាចទទួលបានកម្មសិទ្ធិ តាមរយៈលទ្ធកម្មដោយសុចរិតនោះទេ។ ជាលទ្ធផល គឺមានគំនិតមួយ ដែលការពារតតិយជនប្រភេទនេះ តាមរយៈការអនុវត្តដែលមានលក្ខណៈស្រដៀងទៅនឹងមាត្រា ៣៥៣ កថាខណ្ឌទី ២។ ព្រោះ គេ អាចនិយាយបានថា **ក** បានបន្សល់ទុកនូវការចុះបញ្ជី ហើយ បានបង្កើតនូវទិដ្ឋភាពមួយដែលបង្ហាញថា **ខ** គឺជាកម្មសិទ្ធិករលើអចលនវត្ថុនោះ ហើយ **គ** បានជឿជាក់ថា **ខ** គឺជាម្ចាស់សិទ្ធិពិតប្រាកដមែន។

ករណីជាធម្មតានៃការអនុវត្តមាត្រា ៣៥៣ កថាខណ្ឌទី ២ (ការបង្ហាញឆន្ទៈមិនពិត) គឺ ឧទាហរណ៍ថាកូនបំណុល **ឃ** បានចាញ់ក្តីជាមួយនឹងម្ចាស់បំណុល **ឆ** ហើយ មានគោលបំណងចង់បញ្ចៀសនូវការរឹបអូសរថយន្តរបស់ខ្លួនពី **ឆ**។ **ឃ** បានប្រាប់មិត្តភក្តិរបស់ខ្លួន **ខ** នូវបញ្ហានេះ ហើយ បានឃុបឃិតជាមួយនឹង **ខ** និង បាន "លក់" ដោយក្លែងក្លាយទៅអោយ **ខ** ហើយ បានប្រគល់រថយន្តនោះ។ នៅក្នុងករណីនេះ កិច្ចសន្យាលក់ទិញរវាង **ឃ** និង **ខ** ត្រូវបានទុកជាមោឃៈ ដោយផ្អែកលើមាត្រា ៣៥៣ កថាខណ្ឌទី ១។ ជាងនេះទៅទៀត **ឃ** មិនមានឆន្ទៈក្នុងការផ្ទេរកម្មសិទ្ធិរបស់ខ្លួនអោយទៅ **ខ** ទេ ហើយ **ខ** ក៏មិនមានឆន្ទៈក្នុងការធ្វើលទ្ធកម្មកម្មសិទ្ធិដែរ។ ដូច្នេះ **ឃ**

នៅតែមានកម្មសិទ្ធិ (មាត្រា ១៣៣ : ការផ្ទេរកម្មសិទ្ធិ ការព្រមព្រៀងរបស់គូភាគីដែលត្រូវធ្វើការផ្ទេរ គឺគ្រប់គ្រាន់អោយមាន)។ ក៏ប៉ុន្តែ ខ បានបំពានទៅលើការជឿទុកចិត្តរបស់ ឃ ហើយ បានលក់រថយន្តនោះទៅអោយ ច ដែលបានជឿជាក់ ដោយសមហេតុផលថា ខ គឺជាម្ចាស់កម្មសិទ្ធិដ៏ពិតប្រាកដ។ នៅក្នុងករណីនេះ ដោយផ្អែកទៅលើមាត្រា ៣៩៣ កថាខណ្ឌទី ២ ឃ មិនអាចអះអាងនូវសិទ្ធិរបស់ខ្លួនចំពោះ ច បានទេ គឺដើម្បីការពារនូវសុវត្ថិភាពកិច្ចការជំនួញរបស់ ច។ ដើម្បីទទួលបាននូវការការពារតាមរយៈមាត្រានេះ ច ចាំបាច់ត្រូវធ្វើសកម្មភាពដោយសុចរិត និង គ្មានកំហុសធ្ងន់ធ្ងរ នៅពេលបង្កើតកិច្ចសន្យា។

មូលហេតុដែលក្រមរដ្ឋប្បវេណី ធ្វើការការពារតតិយជនដែលសុចរិត និង គ្មានកំហុសធ្ងន់ធ្ងរ ព្រោះ ជនដែលបង្កើតនូវទិដ្ឋភាពមិនពិត ដូចជា ឃ មិនមានសិទ្ធិក្នុងការអះអាងពីមោឃភាពនៃកិច្ចសន្យា ចំពោះតតិយជនដែលបានជឿជាក់ទៅលើទិដ្ឋភាពនោះ ដោយមានហេតុផល។ គោលការណ៍នេះ ទាញចេញពី "លទ្ធិដែលមានលក្ខណៈជារូបភាព"។

ចំពោះករណីនៃការរំលាយកិច្ចសន្យា គឺមិនមានការឃុបឃិតនៃឆន្ទៈដែលបង្ហាញអោយឃើញច្បាស់ រវាង ក និង ខ នៅក្នុងករណីខាងលើទេ។ ដូច្នេះ គេ មិនអាចអនុវត្តមាត្រា ៣៩៣ កថាខណ្ឌទី ២ ដោយផ្ទាល់នោះទេ។ ក៏ប៉ុន្តែ វា មានលក្ខណៈស្រដៀងទៅនឹងស្ថានភាពនៃការបង្ហាញឆន្ទៈមិនពិតដែរ ដែល ក បន្សល់ទុកនូវការការចុះបញ្ជី ដែលមិនមានការផ្លាស់ប្តូរនៅក្រោយការរំលាយកិច្ចសន្យា និង បានបង្កើតនូវទិដ្ឋភាពមួយដែលបង្ហាញថា ខ គឺជាម្ចាស់កម្មសិទ្ធិពិតប្រាកដ។ ដូច្នេះ ប្រសិនបើ គ ជឿជាក់ថា ខ គឺជាម្ចាស់កម្មសិទ្ធិដោយពិតប្រាកដ ហើយ ការជឿជាក់នោះគឺដោយសុចរិត និង គ្មានកំហុសធ្ងន់ធ្ងរ នោះ គឺមានលទ្ធភាពក្នុងការការពារ ជន ដូចជា គ តាមរយៈការអនុវត្តដែលមានលក្ខណៈស្រដៀងទៅនឹងទៅមាត្រា ៣៩៣ កថាខណ្ឌទី ២។ ដូច្នេះ ក មិនអាចលើកឡើងពីកម្មសិទ្ធិរបស់ខ្លួនចំពោះ គ ដែលជាជនសុចរិត និង គ្មានកំហុសធ្ងន់ធ្ងរបានទេ។

### ២. តាមគំនិត B

**ដោយផ្អែកលើគំនិត B ការរំលាយកិច្ចសន្យា មិនមានអានុភាពប្រតិសកម្មទេ។ ទោះបីជាមានការរំលាយកិច្ចសន្យាក៏ដោយ គ មិនត្រូវបានចាត់ទុកថាជាកម្មសិទ្ធិករតាំងពីដំបូងនោះទេ។ ប៉ុន្តែទោះបីជា ការរំលាយ មិនមានអានុភាពប្រតិសកម្ម តែពេលមានការរំលាយកិច្ចសន្យា ម្ចាស់កម្មសិទ្ធិ អាចទាមទារអោយធ្វើការផ្ទេរកម្មវត្ថុត្រឡប់មកវិញបាន ទោះបីជាវត្ថុនោះត្រូវបានផ្ទេរទៅអោយតតិយជនហើយក៏ដោយ។ ឧទាហរណ៍នៅក្នុងករណីឧទាហរណ៍ខាងលើ ប្រសិនបើ ក រំលាយកិច្ចសន្យា ខ ត្រូវមានកាតព្វកិច្ចថ្មី ក្នុងការប្រគល់ត្រឡប់នូវអ្វី ដែលគាត់បានទទួល ដោយសារតែការរំលាយកិច្ចសន្យា។**

**ផ្អែកនេះលើគំនិតនេះ ទំនាក់ទំនងរវាង ក និង គ គឺមានលក្ខណៈស្រដៀងគ្នាទៅនឹងការផ្ទេរពី ខ ពីរដងជាន់គ្នា ដោយមិនគិតថា គ បានទិញកម្មវត្ថុ នៅមុន ឬ នៅក្រោយការរំលាយកិច្ចសន្យា ដូច្នេះ បុគ្គលណាដែលបានទទួលនូវលក្ខខណ្ឌតតាំង មុនបុគ្គលផ្សេងទៀត អាចអះអាងពីកម្មសិទ្ធិរបស់ខ្លួនបាន។ វា មានន័យថា ទោះបីជាមិន**

**មានបញ្ញត្តិ ដូចជាមាត្រា ៤១១ កថាខណ្ឌទី ៤ ក៏លទ្ធផល គឺដូចគ្នានឹងការផ្ទេរពីរដងជាន់គ្នា ដូច្នេះ មាត្រា ៤១១ កថាខណ្ឌទី ៤** គឺមិនមែនជាបទបញ្ញត្តិពិសេស ដើម្បីការពារតតិយជនដែលមានផលប្រយោជន៍ស្របច្បាប់ គឺគ្រាន់តែជាបញ្ញត្តិបញ្ជាក់បន្ថែមតែប៉ុណ្ណោះ។

បន្ទាប់មក តើ គ ត្រូវចុះកិច្ចសន្យា ដោយសុចរិត និង គ្មានកំហុស (ធ្ងន់ធ្ងរ) ដែរ ឬ ទេ ? វា មិនមានចែងច្បាស់លាស់នៅក្នុងមាត្រា ៤១១ កថាខណ្ឌទី ៤ ទេ។ ឬក៏ តើ តតិយជន ត្រូវមានលក្ខខណ្ឌតតាំង ដើម្បីទទួលបាននូវការការពារ?

នៅក្នុងករណីវិការៈក្នុងការបង្ហាញឆន្ទៈ តតិយជន ចាំបាច់ត្រូវធ្វើសកម្មភាពដោយសុចរិត និង គ្មានកំហុស លើកលែងតែករណីនៃការគំរាមកំហែង (មាត្រា ៣៤៦, ៣៤៧ ជាអាទិ៍)។ ផ្ទុយទៅវិញ នៅក្នុងករណីនៃការរំលាយ វា មិនមានភាពច្បាស់លាស់ទេ ថាតើតតិយជន ត្រូវធ្វើសកម្មភាពដោយសុចរិត និង គ្មានកំហុស។

ដូចដែលបានរៀបរាប់ខាងលើ ទំនាក់ទំនងរវាង ក និង គ គឺមានលក្ខណៈស្រដៀងគ្នាទៅនឹងការផ្ទេរពីរដងជាន់គ្នា។ ដូច្នេះ គ ត្រូវទទួលបានការកាន់កាប់ អោយបានមុន ក ដើម្បីទទួលបានការការពារ។ ដូច្នេះ បញ្ហានេះអាចត្រូវបានចាត់ទុកថា វា ស្របនឹងជាមួយនឹងបញ្ហានៃ "លក្ខខណ្ឌតតាំង និង តតិយជន នៅក្នុងករណីនៃការផ្ទេរពីរដងជាន់គ្នា" (មាត្រា ១៣៤ កថាខណ្ឌទី ២)។

**<u>លក្ខខណ្ឌតតាំង</u>**

**ចំពោះការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ ការចុះបញ្ជី គឺជាលក្ខខណ្ឌតតាំង ចំពោះអចលនវត្ថុ (មាត្រា ១៣៤)។ ដូច្នេះ ទោះបីជា អ្នកលក់ បានទទួលកម្មសិទ្ធិពីអ្នកទិញ ហើយ អ្នកទិញ បានលក់កម្មវត្ថុនោះ ទៅអោយតតិយជនក៏ដោយ តែបើតតិយជន បានចុះបញ្ជីអំពីការផ្ទេរមុនអ្នកលក់ នោះតតិយជន នឹងមានអាទិភាពជាងអ្នកលក់ ហើយអ្នកលក់ មិនអាចទាមទារអោយតតិយជន ប្រគល់វត្ថុនោះមកវិញ និង លុបចោលការចុះបញ្ជីរបស់តតិយជនបានទេ។**

**ទំហំដែលចាត់ទុកថាជាតតិយជន តាមមាត្រា ១៣៤**

១- មិនកំណត់ គឺអោយតែក្រៅពីភាគី

២- ជនទុច្ចរិត មិនត្រូវបានរួមបញ្ចូលជាតតិយជន

៣-ជនទុច្ចរិត ហើយ ធ្វើសកម្មភាពទុច្ចរិតជាក់លាក់ណាមួយ មិនត្រូវបានរួមបញ្ចូលជាតតិយជន

ឧទាហរណ៍ ទោះបីប្រសិនជា គ បានចុះបញ្ជីកម្មសិទ្ធិរបស់ខ្លួនមុន ក ហើយ គ បានធ្វើសកម្មភាពគ្រាន់ តែទុច្ចរិតធម្មតា នោះ គាត់ អាចអះអាងពីកម្មសិទ្ធិរបស់ខ្លួនចំពោះ ក បាន ដោយផ្អែកទៅលើគំនិតទី ៣ ប៉ុន្តែ មិនអាចយោងទៅលើគំនិតទី ២ នោះទេ។

ចំណុចដែលត្រូវកត់ចំណាំ គឺថានៅក្នុងករណី តតិយជននៅមុនការរំលាយកិច្ចសន្យា ក នឹងមិនចាំបាច់ត្រូវរំលាយកិច្ចសន្យា ដោយសារការមិនអនុវត្តកាតព្វកិច្ចរបស់ ខ នោះទេ ហើយ ក អាចទាមទារសំណងនៃការខូច

ខាតពី ខ ដោយមិនចាំបាច់រំលាយកិច្ចសន្យា។ ឬនិយាយម្យ៉ាងទៀត ទោះបីជា គ ដឹងថា ខ ស្ថិតនៅក្នុងស្ថានភាពមិនអនុវត្តកាតព្វកិច្ច វា នៅតែមានមូលហេតុសមរម្យ ដែល គ រំពឹងទុកថា ក នឹងមិនអនុវត្តសិទ្ធិរំលាយរបស់ខ្លួន ហើយ គ អាចទទួលបានកម្មសិទ្ធិស្របច្បាប់។

ដូច្នេះ ឋានៈនៃតតិយជន នៅក្នុងករណីនៃតតិយជន នៅមុនការរំលាយកិច្ចសន្យា គឺមានលក្ខណៈខុសគ្នាទៅ តតិយជននៅក្នុងលក្ខណៈនៃការលុបចោល។ ផ្ទុយទៅវិញ នៅក្នុងករណីនៃតតិយជននៅក្រោយការរំលាយកិច្ចសន្យា កម្មវត្ថុនៃភាពសុចរិត ឬ ទុច្ចរិត គឺមិនមែនជាអង្គហេតុថា ខ ស្ថិតនៅក្នុងស្ថានភាពមិនអនុវត្តកាតព្វកិច្ច នោះទេ ប៉ុន្តែ គឺជាអង្គហេតុដែលថា កិច្ចសន្យានោះ ត្រូវបានរំលាយបាត់ទៅហើយ។ ប្រសិនបើ គ បានដឹងថា កិច្ចសន្យារវាង ក និង ខ ត្រូវបានរំលាយ នោះ វា មានន័យថា គ បានដឹងថា ខ មិនមានសិទ្ធិទេ។ នៅក្នុងករណីនេះ ភាពចាំបាច់ដើម្បីការពារ គ គឺមិនមានខ្ពស់ទេ។ ដូច្នេះ ប្រសិនបើ គ បានធ្វើសកម្មភាពដោយទុច្ចរិត គេ អាចចាត់ទុក គ ត្រូវបានដកចេញពីតតិយជន ព្រោះ គ មិនមានផលប្រយោជន៍ត្រឹមត្រូវ។

រាប់ចំណុចដែលត្រូវពិចារណា មធ្យោបាយដើម្បីការពារតតិយជន ត្រូវបានសំរេច ដោយធ្វើការពិចារណាទៅលើតុល្យភាពនៃ "តតិយជន" នៅក្នុងករណីលុបចោល និង តតិយជន នៅក្នុងករណីនៃការលក់ពីរដងជាន់គ្នា។

# ផ្នែកទី ៦

# កិច្ចសន្យាលក់ទិញ

## ១. គោលគំនិត

តាមមាត្រា ៥១៥នៃក្រមរដ្ឋប្បវេណី បានចែងថា : កិច្ចសន្យាលក់ទិញ គឺជាកិច្ចសន្យាមួយដែលភាគីម្ខាង ហៅថា "អ្នកលក់" មានករណីយកិច្ចត្រូវផ្ទេរនូវកម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀតលើទ្រព្យសម្បត្តិ ទៅអោយភាគីម្ខាងទៀតហៅថា "អ្នកទិញ" ហើយអ្នកទិញ មានករណីយកិច្ចត្រូវចេញថ្លៃជា ប្រាក់អោយអ្នកលក់វិញ។

ផ្អែកតាមមាត្រានេះ ឃើញថា អ្នកលក់ និង អ្នកទិញមានករណីយកិច្ចចំពោះគ្នាទៅវិញទៅមក ហើយចំពោះអ្នកលក់ មិនត្រឹមតែមានករណីយកិច្ចត្រូវផ្ទេរនូវកម្មសិទ្ធិប៉ុណ្ណោះទេ គឺត្រូវសិទ្ធិផ្សេងទៀតលើទ្រព្យសម្បត្តិទៅអោយអ្នកទិញ ប្រសិនបើមាន សិទ្ធិនោះមានដូចជា : សិទ្ធិជួលអចិន្ត្រៃយ៍ (មាត្រា ២៥២) និង សិទ្ធិទាមទារ (មាត្រា ៥០១) ជាដើម។

កិច្ចសន្យាលក់ទិញ គឺជាកិច្ចសន្យាដែលយកតម្លៃថ្នូរ និង ជាកិច្ចសន្យាទ្វេភាគី។

បទបញ្ញត្តិនៃកិច្ចសន្យាលក់ទិញ ត្រូវយកមកអនុវត្តដូចគ្នាចំពោះ កិច្ចសន្យាដែលយកតម្លៃថ្នូរ ក្រៅពីកិច្ចសន្យាលក់ទិញ ដូចជា កិច្ចសន្យាដូរ ភតិសន្យា កិច្ចសន្យាម៉ៅការ និង កិច្ចសន្យាការងារ ជាអាទិ៍ (មាត្រា ៥២៣)។

## ២. លក្ខខណ្ឌ

### 1. ការព្រមព្រៀង

ជាគោលការណ៍ អោយតែមានមានការព្រមព្រៀងគ្នារវាងគូភាគី នោះកិច្ចសន្យាលក់ទិញ អាចត្រូវបានបង្កើតឡើងបានហើយ ហើយគូភាគី អាចកំណត់ការធ្វើលិខិតយថាភូត រឺ លិខិតឯកជនជាលក្ខខណ្ឌ សំរាប់បង្កើតកិច្ចសន្យាតាមការជ្រើសរើសរបស់ខ្លួនក៏បាន ប៉ុន្តែមានករណី លើកលែងដែល មានបញ្ញត្តិពិសេសនៅក្នុងច្បាប់។ ឧទាហរណ៍ កិច្ចសន្យាលក់ទិញអចលនវត្ថុ នៅក្នុងមាត្រា ៣៣៦ កថាខណ្ឌទី ២ បានកំណត់ថា កិច្ចសន្យាលក់ទិញអចលនវត្ថុ ត្រូវធ្វើដោយលិខិតយថាភូត។ ដូចនេះ នៅក្នុងករណីនៃកិច្ចសន្យាលក់ទិញអចលនវត្ថុ ការព្រមព្រៀងរវាងគូភាគីតែមួយនោះ ពុំមានអានុភាពទេ ទាល់តែគូភាគី ធ្វើជាលិខិតយថាភូត។

### 2. ថ្លៃលក់ទិញដែលត្រូវបានកំណត់

នៅក្នុងកិច្ចសន្យាលក់ទិញ ភាគីនៃកិច្ចសន្យា ត្រូវកំណត់ចំនួនប្រាក់នៃថ្លៃលក់ទិញ រឺ វិធីកំណត់ចំនួនប្រាក់នោះនៅក្នុងកិច្ចសន្យា។ ចំនួនប្រាក់នៃថ្លៃលក់ទិញ អាចត្រូវបានកំណត់ ដោយយោលទៅលើតំលៃនៃទំនិញណាមួយ

លើទីផ្សារក្នុងពេលបច្ចុប្បន្ន រឺ អនាគត រឺ ដោយផ្អែកលើការវាយតម្លៃ ដែលធ្វើដោយតតិយជន ដែលត្រូវបានជ្រើសរើសតាមរបៀបកំណត់ ដោយគូភាគី។ ក្នុងករណីដែលការវាយតម្លៃរបស់តតិយជន ត្រូវបានធ្វើឡើង ដោយភាន់ច្រឡំ រឺ ករណីដែលការវាយតម្លៃនោះ ច្បាស់ជាផ្ទុយនឹងសមភាព ភាគីនៃកិច្ចសន្យា ដែលទទួលរងការខូចខាតផលប្រយោជន៍របស់ខ្លួន ដោយសារការវាយតម្លៃនោះ អាចតវ៉ាចំពោះការវាយតម្លៃនោះបាន ( មាត្រា ៥២១ ) ។

ថ្លៃលក់ទិញ ជាកត្តាមួយសំខាន់ណាស់នៅក្នុងកិច្ចសន្យាលក់ទិញ ដូចនេះកិច្ចសន្យា នឹងមិនកើតមានឡើយ បើមិនកំណត់នូវថ្លៃលក់ទិញ។ ម្យ៉ាងទៀត ភាគីនៃកិច្ចសន្យា ក៏អាចកំណត់ចំនួនថ្លៃលក់ទិញ ដោយបង្ហាញចំនួនថ្លៃដើមពិតប្រាកដ ឬ ដោយអោយអ្នកទិញ បង់ធនលាភដែលមិនកំណត់ពេល ឬ ធនលាភមួយជីវិតបាន។ ឧទាហរណ៍ លក់ដី ដែលអោយបង់ប្រាក់ ដោយភាគរហូតដល់អ្នកលក់ ពេញចិត្ត ឬ មរណភាពរបស់អ្នកលក់ ឬ អ្នកទិញ។ នៅក្នុងករណីនេះ តតិយជន ដែលត្រូវបានជ្រើសរើសដោយវិធី ដែលបានកំណត់ដោយគូភាគី អាចកំណត់នូវចំនួននៃថ្លៃលក់ទិញបាន ប៉ុន្តែ ថ្លៃលក់ទិញនេះ ត្រូវបានកំណត់ដោយបង្ហាញចំនួនថ្លៃដើមពិតប្រាកដ លើកលែងតែករណីដែល គូភាគី ប្រគល់សិទ្ធិទៅអោយតតិយជន ដោយជាក់លាក់ ( មាត្រា ៥២១ កថាខណ្ឌទី ៣ ) ។

### 3. សោហ៊ុយក្នុងការលក់ទិញ

ក្នុងការធ្វើកិច្ចសន្យាលក់ទិញ ភាគីទាំងសងខាង ត្រូវចេញស្មើគ្នានូវសោហ៊ុយធ្វើលិខិត ឬ សោហ៊ុយផ្សេងៗ ដែលត្រូវចំណាយក្នុងការធ្វើកិច្ចសន្យាលក់ទិញ លើកលែងតែមានការកំណត់ផ្សេងរបស់គូភាគី ( មាត្រា ៥២២ ) ។ ឧទាហរណ៍ សោហ៊ុយក្នុងការជួលមេធាវី ធ្វើឯកសារកិច្ចសន្យាលក់ទិញ គឺជាសោហ៊ុយក្នុងការលក់ទិញ។

ចំពោះសោហ៊ុយ សំរាប់នីតិវិធីចាំបាច់ដើម្បីអោយ អ្នកទិញ បានធ្វើលទ្ធកម្មនូវសិទ្ធិដោយពិតប្រាកដ ដូចជាការចុះបញ្ជី ដែលជាលក្ខខណ្ឌតាំងនៃការផ្ទេរសិទ្ធិប្រត្យក្ស ដែលនេះ ជាសោហ៊ុយសំរាប់អនុវត្តកាតព្វកិច្ច មិនមែនជាសោហ៊ុយ សំរាប់បង្កើតកិច្ចសន្យាទេ ហេតុនេះបើគ្មានការព្រមព្រៀងរវាងភាគីទេ នេះ ជាបន្ទុករបស់អ្នកលក់ (តាមមាត្រា ៤៤៦ សោហ៊ុយនៃការសង) ។ សោហ៊ុយនៃការសង ជាសោហ៊ុយសំរាប់ចាយវាយ ក្នុងការអនុវត្តកាតព្វកិច្ច។

មូលហេតុដែលសោហ៊ុយក្នុងការលក់ទិញ ត្រូវជាបន្ទុកស្មើគ្នារបស់គូភាគី គឺដោយសារកិច្ចសន្យាលក់ទិញ ត្រូវធ្វើឡើង សំរាប់ផលប្រយោជន៍របស់ភាគីទាំងសងខាង។

### ៣. ករណីយកិច្ច និង សិទ្ធិរបស់អ្នកលក់

នៅក្នុងកិច្ចសន្យាលក់ទិញ ភាគីទាំងសងខាង ត្រូវមានកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមក ព្រោះ កិច្ចសន្យាលក់ទិញ គឺជាកិច្ចសន្យាទ្វេភាគី។

### ៣.១ ករណីយកិច្ចទូទៅរបស់អ្នកលក់

#### ៣.១.១ ករណីយកិច្ចទូទៅ

ករណីយកិច្ចទូទៅរបស់អ្នកលក់ មានចែងពីមាត្រា ៥២៩ ដល់មាត្រា ៥៣១ និង ពីមាត្រា ៥៤៩ ដល់មាត្រា ៥៥៣ នៃក្រមរដ្ឋប្បវេណី។ ករណីយកិច្ចទាំងនោះ មានដូចតទៅ :

**១. ករណីយកិច្ចផ្ទេរសិទ្ធិ**

អ្នកលក់ ត្រូវមានករណីយកិច្ចផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិ ដែលខ្លួនបានលក់ (មាត្រា ៥៣០)។ ការផ្ទេរកម្មសិទ្ធិនេះ នាំអោយមានការផ្លាស់ប្តូរកម្មសិទ្ធិករនៃទ្រព្យផងដែរ។

ការផ្ទេរកម្មសិទ្ធិ គឺជាករណីយកិច្ចដ៏សំខាន់ នៅក្នុងកិច្ចសន្យាលក់ទិញ ពីព្រោះ កិច្ចសន្យាលក់ទិញ ធ្វើឡើងក្នុងគោលបំណង ដើម្បីផ្ទេរកម្មសិទ្ធិពីអ្នកលក់ទៅអោយអ្នកទិញ ដូចនេះ អ្នកលក់ មានករណីយកិច្ចត្រូវតែផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិដែលជាកម្មវត្ថុ នៃការកិច្ចសន្យាលក់ទិញទៅអោយអ្នកទិញ (មាត្រា ៥៣១ កថាខណ្ឌ ទី ១)។ ការផ្ទេរកម្មសិទ្ធិក្នុងកិច្ចសន្យាលក់ទិញ ត្រូវអនុវត្តតាមគោលការណ៍ទូទៅ ដែលបានកំណត់ នៅក្នុងមាត្រា ១៣៣, ១៣៤, ១៣៥, ១៦០, និង ១៨៧ លើកលែងតែកម្មវត្ថុនៃកិច្ចសន្យាលក់ទិញ ជាសិទ្ធិលើទ្រព្យសម្បត្តិ ក្រៅពីកម្មសិទ្ធិ ដែលការផ្ទេរសិទ្ធិទាំងនោះ ត្រូវអនុវត្តតាមគោលការណ៍ទូទៅ ដែលទាក់ទងនឹងការផ្ទេរសិទ្ធិនីមួយៗ នោះ (មាត្រា ៥២៨ កថាខណ្ឌទី ១)។

ដូចនេះជារួម សិទ្ធិដែលខ្លួនបានលក់ ត្រូវបានផ្ទេរ ដូចនៅក្នុងករណីខាងក្រោម :

- កិច្ចសន្យាលក់ទិញលើកម្មសិទ្ធិនៃអចលនវត្ថុ : នៅពេលផ្ទេរការចុះបញ្ជី ត្រូវបានធ្វើឡើង
- កិច្ចសន្យាលក់ទិញក្រៅពីកម្មសិទ្ធិនៃអចលនវត្ថុ : នៅពេលព្រមព្រៀង។

**២. ករណីយកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុ**

ការប្រគល់វត្ថុ ត្រូវបានធ្វើឡើងតាមវិធីច្រើនយ៉ាងដូចខាងក្រោម (មាត្រា ៥៥០ វាក្យខណ្ឌទី ១, មាត្រា ២២៩) :

- ការប្រគល់ជាក់ស្តែង
- ការប្តូរលក្ខណៈនៃការកាន់កាប់
- ការប្រគល់ដោយសង្ខេប
- ការផ្ទេរការកាន់កាប់ដោយបញ្ជា

ទន្ទឹមនឹងនេះ មាត្រា ៥៥០ វាក្យខណ្ឌទី ២ ក៏បានចែងដូចខាងក្រោម :

- ការប្រគល់ជាពិសេសសំរាប់អចលនវត្ថុ : ការប្រគល់សោរនៃអគារ រឺ ប្រគល់ប័ណ្ណបញ្ជាក់សិទ្ធិ។

"ប័ណ្ណបញ្ជាក់សិទ្ធិ" សំដៅទៅលើឯកសារដែល បញ្ជាក់ពីសិទ្ធិស្របច្បាប់ក្នុងការប្រើប្រាស់វត្ថុនោះ ។ "សិទ្ធិដែលនាំអោយមានមូលហេតុគតិយុត្តិ" សំដៅទៅលើសិទ្ធិ ដែលធ្វើឱ្យការក្តាប់ទុកវត្ថុមានភាពត្រឹមត្រូវតាមច្បាប់ ដូចជា កម្មសិទ្ធិ សិទ្ធិជួល ( មាត្រា ២៤១ កថាខណ្ឌទី ១) ។ ឧទាហរណ៍ ប័ណ្ណសំគាល់កម្មសិទ្ធិ ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ អាចត្រូវបានចាត់ទុកថាជា "ប័ណ្ណបញ្ជាក់សិទ្ធិ" ។

**៣. ករណីយកិច្ចរក្សាទុកវត្ថុដែលជាកម្មវត្ថុ**

អ្នកលក់ ត្រូវមានករណីយកិច្ចថែរក្សាទុកវត្ថុ ដែលជាកម្មវត្ថុនៃការលក់ទិញ ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ រហូតដល់ពេលប្រគល់វត្ថុនោះទៅអោយអ្នកទិញ ( មាត្រា ៥៥២ កថាខណ្ឌទី ១) ។ ក្នុងករណីដែលអ្នកលក់ធ្វើអោយបាត់បង់ ឬ ធ្វើអោយខូចខាតកម្មវត្ថុ ដោយសារខ្លួនធ្វេសប្រហែស អ្នកលក់ ត្រូវទទួលខុសត្រូវសងសំណងនៃការខូចខាត ( មាត្រា ៥៥២ កថាខណ្ឌទី ២) ។ ផ្ទុយទៅវិញ ប្រសិនបើ ការខូចខាតដោយករណីប្រធានសក្តិ នោះ អ្នកលក់ ត្រូវរួចផុតពីការទទួលខុសត្រូវ ។

**៤. ករណីយកិច្ចប្រគល់លិខិតផ្សេងៗ ដែលចាំបាច់ដើម្បីបញ្ជាក់នូវសិទ្ធិ**

អ្នកលក់ មានកាតព្វកិច្ចត្រូវប្រគល់រាល់លិខិតផ្សេងៗ ដែលចាំបាច់ដើម្បីបញ្ជាក់នូវសិទ្ធិ ( មាត្រា ៥៣០) ។ "លិខិតផ្សេងៗ ដែលចាំបាច់ដើម្បីបញ្ជាក់សិទ្ធិ" គឺជាប័ណ្ណបញ្ជាក់សិទ្ធិដែលមានចែងនៅក្នុងមាត្រា ៥៥០. លិខិតកិច្ចសន្យា ឬ ឯកសារចាំបាច់សម្រាប់ចុះបញ្ជី ។

### ៣.១.២ សិទ្ធិទូទៅ

**១. សិទ្ធិទាមទារឱ្យបង់ប្រាក់ថ្លៃទិញ**

បើអ្នកទិញ មិនទាន់បង់ប្រាក់ទៅអោយអ្នកលក់ទេ នោះអ្នកលក់ មានសិទ្ធិទាមទារប្រាក់ថ្លៃទិញបាន ។

**២. ការតវ៉ា**

**ក. ការតវ៉ាឱ្យអនុវត្តព្រមគ្នា ( មាត្រា ៥៥១ កថាខណ្ឌទី ១)**

អ្នកលក់ អាចប្រកែកមិនព្រមផ្ទេរសិទ្ធិដែលជាកម្មវត្ថុ និង មិនព្រមប្រគល់វត្ថុ ដែលជាកម្មវត្ថុទៅអ្នកទិញ បានរហូតដល់អ្នកទិញ បានផ្តល់ការសង ចំពោះកាតព្វកិច្ចបង់ថ្លៃលក់ ។ ប៉ុន្តែបញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកាតព្វកិច្ចរបស់អ្នកទិញ ពុំទាន់ដល់ពេលកំណត់ត្រូវសង ឬ ករណីដែលមានការព្រមព្រៀងគ្នាអំពីការអនុវត្តករណីយកិច្ចផ្ទេរសិទ្ធិ ឬ កាតព្វកិច្ចប្រគល់ជាមុន ។

### ខ. ការតវ៉ាដោយមានការបារម្ភ ( មាត្រា ៥៤១ កថាខណ្ឌទី ២)

មាត្រា ៥៤១ កថាខណ្ឌទី ២ បានចែងយ៉ាងលំអិតទៅលើមាត្រា ៣៨៧។ អត្ថន័យនៃឃ្លា "អ្នកលក់ បាន អនុញ្ញាតឱ្យអ្នកទិញ មានពេលកំណត់ដើម្បីសងថ្លៃកម្មវត្ថុ" គឺថា អ្នកលក់ បានអនុញ្ញាតអោយបង់ ក្រោយពេលធ្វើការប្រគល់ចលនវត្ថុ។

### ៣. សិទ្ធិទទួលផល

លើកលែងតែមានការព្រមព្រៀងគ្នា អ្នកលក់ អាចទទួលបានផលធម្មជាតិ ឬ ផលស៊ីវិល នៅមុនពេលប្រគល់។ មាត្រានេះ រក្សានូវតុល្យភាពរវាងមាត្រា ៥៥៦ ដែលបញ្ញត្តិថា អ្នកទិញ មិនចាំបាច់បង់ការប្រាក់នៃថ្លៃទិញរហូតដល់ គាត់ទទួលនូវការប្រគល់វត្ថុដែលជាកម្មវត្ថុ។

### ៣.២ ករណីយកិច្ចត្រូវពន្យល់

អ្នកលក់ មានកាតព្វកិច្ចត្រូវពន្យល់អោយបានច្បាស់លាស់ អំពីព័តិមានសំខាន់ ទាក់ទងនឹងកម្មវត្ថុ។ "ខ្លឹមសារនៃកាតព្វកិច្ច ដែលត្រូវទទួលបន្ទុកដោយអ្នកលក់" សំដៅទៅលើឧទាហរណ៍ដូចជា ថាតើអ្នកលក់ ធានាថា វត្ថុដែលជា កម្មវត្ថុនៃការលក់នោះ ត្រូវស្របនឹងគោលបំណងធម្មតា ក្នុងអំឡុងពេលដែលបានកំណត់ ក្រោយការប្រគល់ ( មាត្រា ៥៤០ កថាខណ្ឌទី ៣) ឬ អ្នកលក់ ធានានូវភាពត្រឹមត្រូវនៃទំហំ ដែលបានបញ្ជាក់ ( មាត្រា ៥៤៦ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ២) ជាអាទិ៍។

ប្រសិនបើអ្នកលក់ បំពានលើករណីយកិច្ចនេះ ហើយធ្វើឱ្យមានការខូចខាតនោះ អ្នកលក់ ត្រូវទទួលខុសត្រូវសងនូវការខូចខាត។ នៅក្នុងករណីដែលអ្នកលក់ ប្រាប់នូវហេតុផលមិនពិត រឺលាក់បាំងនូវហេតុពិតប្រាកដដោយចេតនា ហើយអ្នកទិញ បានបង្ហាញឆន្ទៈ ដោយផ្អែកទៅលើការយល់ច្រឡំនេះ នោះ អ្នកទិញ អាចរំលាយកិច្ចសន្យាលក់ទិញ ដោយផ្អែកលើមាត្រា ដែលទាក់ទងនឹងវិការៈនៅក្នុងការបង្ហាញឆន្ទៈ។

### ៣.៣ ករណីយកិច្ចផ្ទេរសិទ្ធិ

ករណីយកិច្ចដែលសំខាន់បំផុតរបស់អ្នកលក់ គឺជាករណីយកិច្ចផ្ទេរកម្មសិទ្ធិ រឺ សិទ្ធិផ្សេងទៀតនៅលើទ្រព្យសម្បត្តិទៅឱ្យអ្នកទិញ ( មាត្រា ៥៣១ កថាខណ្ឌទី ១)។

ទោះបីជាអ្នកលក់ បានលក់នូវកម្មវត្ថុ ដែលជាកម្មសិទ្ធិរបស់តតិយជននោះ កិច្ចសន្យាលក់ទិញនោះផ្ទាល់ គឺមានសុពលភាព ព្រោះ វា អាចមានលទ្ធភាព ដែលអ្នកលក់ អាចធ្វើលទ្ធកម្មលើសិទ្ធិនោះ ហើយ ផ្ទេរសិទ្ធិនោះ ទៅអោយអ្នកទិញ។

ឧទាហរណ៍ វា អាចមានលទ្ធភាពដែល ក លក់រថយន្តអោយទៅ ខ ដែលរថយន្តនោះ គឺជាកម្មសិទ្ធិរបស់ គ។ នៅក្នុងករណីនេះ ក មានកាតព្វកិច្ច ត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិលើរថយន្តនោះពី គ ហើយ ផ្ទេរសិទ្ធិនោះ ទៅ

អោយ ខ។ ប្រសិនបើ ក មិនអាចផ្ទេរកម្មសិទ្ធិលើរថយន្តនោះបានទេ ក ត្រូវទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ច។

## ៩. ការទទួលខុសត្រូវក្នុងការធានា

**សូមមើលឧបសម្ព័ន្ធ ៩**

### ៩.១ ទិដ្ឋភាពទូទៅនៃការទទួលខុសត្រូវក្នុងការធានា

ការទទួលខុសត្រូវក្នុងការធានា គឺជាប្រព័ន្ធមួយដែលផ្តល់ឱ្យភាគីនូវប្រតិបត្តិការជំនួញមួយ ដែលមានភាពយុត្តិធម៌ ព្រោះកិច្ចសន្យាលក់ទិញ គឺជាការដោះដូររវាងទ្រព្យសម្បត្តិ និង ប្រាក់ដែលមានតម្លៃស្មើគ្នា ។

ឧទាហរណ៍ នៅក្នុងករណីដែល អ្នកទិញ បានរកឃើញថា កម្មវត្ថុមានវិការៈ បន្ទាប់ពីការបង់ប្រាក់ និង ការប្រគល់ នោះ វា នឹងមានភាពអយុត្តិធម៌ ប្រសិនបើ អ្នកទិញ មិនអាចទាមទារអ្វីបានទាល់តែសោះពីអ្នកលក់។ ប្រាក់ថ្លៃទិញ និង តំលៃនៃកម្មវត្ថុនៅក្នុងកិច្ចសន្យាលក់ទិញ គឺមានតំលៃស្មើគ្នា។ ដូច្នេះ ក្រមរដ្ឋប្បវេណី បានចែងពីការទទួលខុសត្រូវ នៅក្នុងការធានា ដើម្បីកែតំរូវវិសមភាពនេះ។

### ៩.២ ការទទួលខុសត្រូវក្នុងការធានារបស់អ្នកលក់ ក្នុងករណីដែលសិទ្ធិដែលត្រូវបានលក់ជាសិទ្ធិរបស់អ្នកដទៃ

#### ៩.២.១ នៅក្នុងករណីដែលសិទ្ធិទាំងមូល ជាសិទ្ធិរបស់តតិយជន

**១. អ្វីដែលអ្នកទិញអាចទាមទារបាន ប្រសិនបើអ្នកលក់ មិនអាចទទួលបាននូវសិទ្ធិ គឺ :**

***ក. អ្នកទិញ មានសិទ្ធិរំលាយកិច្ចសន្យា :*** ប្រសិនបើអ្នកលក់ មិនអាចអនុវត្តករណីយកិច្ចផ្ទេរសិទ្ធិលើទ្រព្យសម្បត្តិ ដែលជាកម្មវត្ថុនៃការលក់ទិញទៅឱ្យអ្នកទិញបាន។ម្យ៉ាងទៀត ទោះបី អ្នកទិញបានដឹង ឬ មិនបានដឹងនៅពេលធ្វើកិច្ចសន្យាថា អ្នកលក់ មិនមែនជាកម្មសិទ្ធិករលើវត្ថុ ដែលជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញក៏ដោយ ក៏អ្នកទិញនោះ អាចទាមទារឱ្យរំលាយកិច្ចសន្យានេះបានដែរ (ចែងក្នុងមាត្រា ៥៣១ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ១)។

***ខ. ករណីអ្នកទិញមានភាពសុចរិត :*** អ្នកទិញក៏ អាចទាមទារសំណងនៃការខូចខាត គ្រាន់តែបង្ហាញថាពេលធ្វើ កិច្ចសន្យាខ្លួនមិនបានដឹងថា សិទ្ធិដែលជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញ មិនមែនជាសិទ្ធិរបស់អ្នកលក់ទេ។ ក្រៅពីសិទ្ធិរំលាយកិច្ចសន្យា អ្នកទិញ អាចទាមទារសំណងនៃការខូចខាតបាន (ចែងក្នុងមាត្រា ៥៣១ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ២)។

**២. អ្វីដែលអ្នកលក់សុចរិតអាចធ្វើបានគឺ :**

អ្នកលក់ មានករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញនោះ ហើយផ្ទេរកម្មសិទ្ធិនោះទៅឱ្យអ្នកទិញ ។ ប៉ុន្តែប្រសិនបើ អ្នកលក់ មិនអាចធ្វើបានទេ នោះអ្នកលក់ អាចរំលាយកិច្ចសន្យាដើម្បីរួចផុតពីករណីយកិច្ចផ្ទេរសិទ្ធិនោះ បានតែក្នុងករណីដែល ***"អ្នកលក់សុចរិត"*** ប៉ុណ្ណោះ។ ដូច្នេះ អ្នកលក់សុចរិតមានករណីយកិច្ចទទួលសិទ្ធិជាអាទិ៍ :

- ***អ្នកលក់សុចរិត*** អាចរំលាយកិច្ចសន្យានោះបាន តែត្រូវសងការខូចខាត ( មាត្រា ៥៣២ កថាខណ្ឌ ទី ១ ) ។
- ***អ្នកលក់សុចរិត*** អាចរំលាយកិច្ចសន្យានោះបាន ដោយមិនចាំបាច់សងការខូចខាតទេ ប្រសិនបើ អ្នកទិញ បានដឹង នៅពេលធ្វើកិច្ចសន្យាថា សិទ្ធិលើទ្រព្យសម្បត្តិ ដែលជាកម្មវត្ថុនៃការលក់ទិញ មិនមែនជាសិទ្ធិរបស់អ្នកលក់ទេ ( មាត្រា ៥៣២ កថាខណ្ឌទី ២) ។

### ៤.២.២ នៅក្នុងករណីដែលសិទ្ធិមួយភាគ គឺជាសិទ្ធិរបស់តតិយជន

ក្នុងករណីសិទ្ធិមួយភាគក្នុងចំណោមសិទ្ធិ ដែលជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញ គឺជាសិទ្ធិរបស់អ្នកដទៃ ហើយ បើអ្នកលក់ មិនអាចទទួលសិទ្ធិនៃភាគនោះដើម្បីផ្ទេរឱ្យទៅអ្នកទិញបានទេ ករណីនេះ គឺជាការមិនអនុវត្តកាតព្វកិច្ចមួយភាគរបស់អ្នកលក់។ ដូច្នេះ បញ្ញត្តិនៃការមិនអនុវត្តកាតព្វកិច្ច ត្រូវយកមកអនុវត្ត។ ក៏ប៉ុន្តែ ប្រសិនបើ អ្នកទិញ អាចសំរេចគោលបំណងនៃកិច្ចសន្យា វា មិនមានលក្ខណៈសមរម្យ ក្នុងការទទួលស្គាល់ឱ្យរំលាយកិច្ចសន្យាទាំងមូលនោះ។ ដូច្នេះ ការទទួលខុសត្រូវក្នុងការធានា ចំពោះករណីដែលសិទ្ធិមួយភាគជាសិទ្ធិរបស់អ្នកដទៃ មានជាអាទិ៍ :

- ***អ្នកលក់*** ត្រូវមានកាតព្វកិច្ចទទួលនូវសិទ្ធិដែលនៅខ្វះ ហើយត្រូវផ្ទេរទៅអោយអ្នកទិញ ( មាត្រា ៥៣១)
- ***អ្នកទិញ*** អាចទាមទារអោយបន្ថយនូវតម្លៃតាមសមាមាត្រទៅនឹងភាគដែលខ្វះនោះ ប្រសិនបើអ្នកលក់ មិនអាចទទួលបាននូវសិទ្ធិនោះ ហើយមិនអាចផ្ទេរទៅឱ្យអ្នកទិញ ( មាត្រា ៥៣៣ កថាខណ្ឌទី ១) ។
- ***អ្នកទិញសុចរិត*** អាចរំលាយកិច្ចសន្យាបាន ប្រសិនបើធ្វើការវិនិច្ឆ័យថា អ្នកទិញ នឹងមិនទិញតែភាគ ដែលសល់តែប៉ុណ្ណោះ ( មាត្រា ៥៣៣ កថាខណ្ឌទី ២) ។
- ***អ្នកទិញសុចរិត*** អាចទាមទារសំណងនៃការខូចខាត ( មាត្រា ៥៣៣ កថាខណ្ឌទី ៣) ។

***សិទ្ធិ*** *ដែលបានបញ្ញត្តិនៅក្នុងមាត្រា ៥៣៣ កថាខណ្ឌទី ១, ទី ២ និង ទី ៣* ត្រូវអនុវត្តក្នុងអំឡុងពេល ១ ឆ្នាំ គិតចាប់ពីពេលដែលអ្នកទិញ បានដឹងការណ៍នោះ ប្រសិនបើអ្នកទិញ គឺជាជនសុចរិត ឬក្នុងអំឡុងពេល ១ឆ្នាំ គិតចាប់ពីពេលធ្វើកិច្ចសន្យា ប្រសិនបើអ្នកទិញ បានដឹងថា សិទ្ធិមួយភាគ ជាសិទ្ធិរបស់អ្នកតតិយជន ( មាត្រា

៥៣៣ កថាខណ្ឌ ទី ៤) សម្រាប់ជាប្រយោជន៍នៃការដោះស្រាយវិវាទឱ្យបានលឿន ។ម្យ៉ាងទៀត មាត្រា ៥៣៣ កថាខណ្ឌទី ៤ បានកំណត់អំឡុងពេល សម្រាប់ប្រើសិទ្ធិទាមទារឱ្យបន្ថយថ្លៃលក់ទិញ សិទ្ធិរំលាយ និង សិទ្ធិទាមទារសំណងនៃការខូចខាត មានរយៈពេលខ្លីជាងករណីធម្មតានៃការទទួលខុសត្រូវ ចំពោះការមិនអនុវត្តកាតព្វកិច្ចរបស់ភាគីក្នុងកិច្ចសន្យានោះ ផងដែរ ។

## ៤.៣ ការទទួលខុសត្រូវក្នុងការធានាចំពោះវិការៈ

### ៤.៣.១ បញ្ញត្តិទូទៅ

***អ្នកលក់*** ត្រូវមានកាតព្វកិច្ចប្រគល់វត្ថុដែលគ្មានវិការៈទៅអោយអ្នកទិញ (មាត្រា ៥៣៩ កថាខណ្ឌទី ១) ។ វត្ថុ ដែលបានប្រគល់ទៅឱ្យអ្នកទិញ ត្រូវចាត់ទុកថា មានវិការៈ ប្រសិនវា ត្រូវនឹងចំណុច ដែលមានចែងក្នុងមាត្រា ៥៣៩ កថាខណ្ឌទី ២ លើកលែងតែគូភាគី បានកំណត់ផ្សេង ។ នៅក្នុងករណីនេះ *អ្នកទិញ* ត្រូវបានទទួលខុសត្រូវក្នុងការធានាពីអ្នកលក់ ចំពោះវត្ថុទិញ ដែលមានវិការៈ។ ម្យ៉ាងទៀត អ្នកទិញ អាចទាមទារសំណងនៃការខូចខាតបាន ប្រសិនបើ អ្នកលក់ មានកំហុសចំពោះការខូចខាតនេះ ដោយផ្អែកលើមាត្រា ៣៩៨ (លក្ខខណ្ឌនៃការទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាត) ដែលចែងអំពីការមិនអនុវត្តកាតព្វកិច្ច។ ដោយផ្អែកចាប់ពីមាត្រា ៥៤០ ដល់មាត្រា ៥៤៧ អ្នកទិញ អាចទាមទារការអនុវត្តពេញលេញ ចំពោះអ្នកលក់ មានដូចជា :

- ប្រគល់នូវវត្ថុជំនួស
- កាត់បន្ថយតម្លៃ
- ជួសជុលវិការៈ និង
- រំលាយកិច្ចសន្យា ជាដើម ។

ក៏ប៉ុន្តែ ***អ្នកលក់*** មិនទទួលខុសត្រូវក្នុងការធានាទេ ប្រសិនបើអ្នកទិញ បានទិញកម្មវត្ថុ ដោយបានដឹងអំពីអត្ថិភាពនៃវិការៈ ឬ ក៏មិនបានដឹងដោយមាន**កំហុសធ្ងន់ធ្ងរ** (មាត្រា ៥៤០ កថាខណ្ឌទី ៤)។ វា មានន័យថា ***អ្នកទិញ*** ត្រូវពិនិត្យពិច័យនូវរាល់វិការៈនៃវត្ថុទិញ ដែលមានលក្ខណៈងាយស្រួលនឹងរកឃើញ មានដូចជា : មើលឃើញនឹងភ្នែក និង បានដឹងមុនថា វត្ថុដែលជាកម្មវត្ថុទិញនោះមានវិការៈ។ ប៉ុន្តែអ្នកទិញ ពុំបានពិនិត្យដោយខ្លួនឯងផ្ទាល់ នោះចាត់ទុក ថា អ្នកទិញ ដែលមិនបានដឹងអំពីវិការៈនោះ ដោយមានកំហុសធ្ងន់ធ្ងរ ហើយក៏មិនអាចរំលាយកិច្ចសន្យាបានទេ ដូច្នេះ គាត់ ក៏មិនអាចទាមទារឱ្យអ្នកលក់ ទទួលខុសត្រូវក្នុងការធានាវិការៈនេះដែរ ។

### ១. គោលគំនិតនៃវិការៈ

***វិការៈ*** នៅក្នុងការទទួលខុសត្រូវក្នុងការធានាវិការៈ ជាទូទៅគឺសំដៅទៅលើរាល់ចំណុច ដែលមានបញ្ញត្តិនៅក្នុងមាត្រា ៥៣៩ កថាខណ្ឌទី ២។ វា មិនអាចលុបចោលបានទេ ប្រសិនបើចំណុចនៅក្នុងមាត្រា ៥៣៩

កថាខណ្ឌទី ២ ត្រូវបានទទួលស្គាល់[១] ។ ក៏ប៉ុន្តែ រាល់ចំណុចនៅក្នុងកថាខណ្ឌទី ២ មាត្រា ៥៣៩ គឺគ្រាន់តែជាឧទាហរណ៍នៃ "វិការៈ" តែ ប៉ុណ្ណោះ ដូច្នេះ វា អាចមានភាពមិនសមស្របដទៃទៀត ដែលក្រៅពីចំណុចនីមួយៗ នៅក្នុងកថាខណ្ឌនេះ ត្រូវបានគេទទួលស្គាល់ថាជា "វិការៈ" ។

## ២. ពេលវេលានៃការកើតឡើងនៃវិការៈ

ការទទួលខុសត្រូវក្នុងការធានាវិការៈ កើតឡើងនៅក្នុងករណីដែលគូភាគី មិនបានដឹងពីអត្ថិភាពនៃវិការៈ នៅពេលផ្ទេរនូវហានិភ័យ ( ជាធម្មតានៅពេលធ្វើការប្រគល់ ) ។ ឧទាហរណ៍ ខ បានទិញអង្ករ ១០ គីឡូក្រាមពី ក ប៉ុន្តែ អង្ករ ៥ គីឡូក្រាមនៅក្នុងនោះ គឺខូចរលួយ នៅពេលប្រគល់ ។ នៅក្នុងករណីនេះ ក ត្រូវទទួលខុសត្រូវក្នុងការធានាវិការៈ ដោយផ្អែកទៅលើមាត្រា ៥៤០ ទោះបីជាគាត់ បានទុកអង្ករនោះ ដោយគ្មានកំហុសក៏ដោយ ។

***អ្នកលក់*** ត្រូវទទួលខុសត្រូវក្នុងការធានាវិការៈ នៅក្នុងករណីដែលវិការៈ កើតឡើងដោយសារតែការបំពានកាតព្វកិច្ចរបស់អ្នកលក់ ទោះបីជាវិការៈកើតឡើង ក្រោយការផ្ទេរហានិភ័យក៏ដោយ ( មាត្រា ៥៤០ កថាខណ្ឌទី២) ។

## ៣. សិទ្ធិជួសជុលរបស់អ្នកលក់

***អ្នកលក់*** អាចជួសជុលវិការៈ ប្រសិនបើគាត់ បានប្រគល់វត្ថុ នៅមុនពេលកំណត់ត្រូវប្រគល់ លុះត្រាតែមិនបណ្តាលឱ្យមានការខូចខាតផលប្រយោជន៍ហួសហេតុរបស់អ្នកទិញ ( មាត្រា ៥៤១ កថាខណ្ឌទី១) ។ នៅក្នុងករណីនេះ ទោះបីជាសិទ្ធិជួសជុលវិការៈរបស់អ្នកលក់ ត្រូវបានអនុវត្តក៏ដោយ ក៏អ្នកទិញ អាចទាមទារសំណងការខូចខាតបាន ប្រសិនបើមាន ( មាត្រា ៥៤១ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។

ម្យ៉ាងទៀត ***អ្នកលក់*** អាចជួសជុលវិការៈដោយចេញចំណាយដោយខ្លួនឯងបាន ទោះបីជា ក្រោយពេលកំណត់ ត្រូវប្រគល់ក៏ដោយ លុះត្រាតែមិនបណ្តាលអោយមានការខូចខាតផលប្រយោជន៍ហួសហេតុរបស់អ្នកទិញ ( មាត្រា ៥៤១ កថាខណ្ឌទី ២) ។ ហើយនៅក្នុងករណីនេះ ***អ្នកទិញ*** មានសិទ្ធិរំលាយកិច្ចសន្យា មាត្រា ៤០៨ កថាខណ្ឌទី ១ ចំណុច គ) និង សិទ្ធិទាមទារសំណងនៃការខូចខាត ( មាត្រា ៥៤៥) ដោយចាត់ទុកថា គឺការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ និង ជាការអនុវត្តកាតព្វកិច្ចមិនបានពេញលេញនៅកាលបរិច្ឆេទប្រគល់ ។

---

១. សម្រាប់ជាព័តិមានបន្ថែម ចំណុចគ ត្រូវបានបញ្ញត្តិ "ចំពោះអ្នកលក់" គឺមិនមែន "ចំពោះអ្នកទិញ" នៅក្នុងពង្រាងច្បាប់ដើមជាភាសាជប៉ុន ។ ដូច្នេះ ចំណុចនេះ នឹងត្រូវបានធ្វើវិសោធនកម្ម ដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

### ៤.៣.២ ខ្លឹមសារនៃការទទួលខុសត្រូវ

#### ១. ករណីយកិច្ចប្រគល់វត្ថុជំនួស ( មាត្រា ៥៤២ កថាខណ្ឌទី ២)

ក្នុងករណីដែល កម្មវត្ថុនៃកិច្ចសន្យាលក់ទិញមានវិការៈ អ្នកលក់ ត្រូវមានកាតព្វកិច្ចប្រគល់វត្ថុជំនួស ដែលគ្មានវិការៈឱ្យទៅអ្នកទិញសុចរិត និង គ្មានកំហុសធ្ងន់ធ្ងរ។ ក៏ប៉ុន្តែ ប្រសិនបើការរៀបចំវត្ថុដែលមានប្រភេទដូចគ្នានឹងបង្កើតបន្ទុកមិនសមរម្យហួសហេតុដល់អ្នកលក់ នោះអ្នកលក់ នឹងមិនមានករណីយកិច្ចប្រគល់វត្ថុជំនួសឡើយ ( មាត្រា ៥៤២ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២) ប៉ុន្តែ អ្នកលក់ ត្រូវមានករណីយកិច្ចសងសំណងនៃការខូចខាតចំពោះអ្នកទិញ ( មាត្រា ៥៤៥)។ ឧទាហរណ៍នៅក្នុងករណីដែល ខ បានទិញរថយន្តក្លាសិក ដែលមានតំលៃខ្ពស់ ដែលជាប្រភេទមួយ នៅចំណោមរថយន្ត ដែលមានតែ ពីរ ឬ បី នៅក្នុងពិភពលោកនេះ។ ដូច្នេះ វា មានលក្ខណៈលំបាកសំរាប់ ក ក្នុងការស្វែងរករថយន្តដែលមានប្រភេទដូចគ្នា មកជំនួស។ នៅក្នុងករណីនេះ ក មិនមានករណីយកិច្ចត្រូវប្រគល់រថយន្តជំនួស ទេ ប៉ុន្តែ ត្រូវមានករណីយកិច្ចសងសំណងនៃការខូចខាត។

#### ២. ករណីយកិច្ចជួសជុល ( មាត្រា ៥៤២ កថាខណ្ឌទី ៣)

***អ្នកលក់*** ត្រូវមានកាតព្វកិច្ចជួសជុលវត្ថុ ដែលមានវិការៈ ចំពោះអ្នកទិញដែលសុចរិត និង គ្មានកំហុសធ្ងន់ធ្ងរ នៅក្នុងករណីដែលកម្មវត្ថុនោះ មានវិការៈ។ នៅក្នុងករណីនេះ ប្រសិនបើ ការជួសជុលវិការៈ នឹងដាក់បន្ទុកមិនសមរម្យហួសហេតុដល់អ្នកលក់ នោះអ្នកលក់ មិនមានករណីយកិច្ចជួសជុលឡើយ ( មាត្រា ៥៤២ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ២) ប៉ុន្តែ អ្នកលក់ ត្រូវមានករណីយកិច្ចសងសំណងនៃការខូចខាតចំពោះអ្នកទិញ ( មាត្រា ៥៤៥)។

ការជ្រើសរើសករណីយកិច្ចចំពោះអ្នកលក់ គឺអាស្រ័យលើអ្នកទិញ ថាតើគាត់ ទាមទារឱ្យប្រគល់វត្ថុជំនួស ឬ ទាមទារឱ្យជួសជុល ។

#### ៣. ការរំលាយកិច្ចសន្យា ( មាត្រា ៥៤៣)

ប្រសិនបើអ្នកទិញ មិនអាចសម្រេចគោលបំណងនៃកិច្ចសន្យាបាន ដោយសារវត្ថុ ដែលត្រូវប្រគល់មានវិការៈ គាត់ អាចធ្វើការរំលាយកិច្ចសន្យានោះបាន ប្រសិនបើអ្នកទិញសុចរិត និង គ្មានកំហុសធ្ងន់ធ្ងរ ។

ឧទាហរណ៍ ខ បានទិញម៉ូតូ ០១គ្រឿង សំរាប់ជិះ ពីហាងរបស់ ក។ ប្រសិន ហ្វ្រាំងម៉ូតូ មានវិការៈ និង ធ្វើឱ្យ ខ មិនប្រើប្រាស់ម៉ូតូនោះបាន ប្រកបដោយប្រសិទ្ធិភាព។ គេ គិតថា ម៉ូតូនោះ មិនអាចប្រើតាមបំណងរបស់គាត់ នោះគាត់ ( **អ្នកទិញ**) អាចរំលាយកិច្ចសន្យាលក់ទិញនោះ ហើយលោក ក អាចទៅរកទិញម៉ូតូថ្មីតាមខ្លួនចង់បាន ដោយពុំចាំបាច់ប្រើពេលវេលាជួសជុលថ្មីឡើយ ។

**៤. ករណីយកិច្ចបន្ថយថ្លៃលក់ (មាត្រា ៥៤៤)**

ក្នុងករណីដែលទំនិញ ដែលត្រូវបានប្រគល់មានវិការៈ អ្នកទិញដែលសុចរិត និង គ្មានកំហុសធ្ងន់ធ្ងរ អាចទាមទារបន្ថយថ្លៃលក់ តាមសមាមាត្រនៃភាពខុសគ្នា នៅពេលប្រគល់រវាងតម្លៃនៃវត្ថុដែលគ្មានវិការៈ នៅពេលប្រគល់ និង តម្លៃនៃវត្ថុ ដែលត្រូវបានប្រគល់បានដែរ។ ឧទាហរណ៍ ខ បានទិញអង្ករចំនួន ១០០ គីឡូក្រាម ដែលមានតំលៃ ១០០ ដុល្លា ពី ក ក៏ប៉ុន្តែ មានអង្ករ ២០ គីឡូក្រាម ខូចរលួយ នៅពេលប្រគល់។ នៅក្នុងករណីនេះ ខ អាចទាមទារអោយសងប្រាក់ ២០ ដុល្លា វិញ ប្រសិនបើ គាត់ បានបង់ប្រាក់រួចហើយ ឬ បន្ថយប្រាក់ ២០ ដុល្លា ពីប្រាក់ថ្លៃទិញ ប្រសិនបើ គាត់ មិនទាន់បានបង់ប្រាក់។ ប៉ុន្តែ ក្នុងករណីដែលអ្នកលក់ បានជួសជុលវិការៈ ដោយផ្អែកលើមាត្រា ៥៤២ ដូច្នេះថ្លៃលក់ មិនត្រូវបន្ថយទេ។ ប្រសិនបើអ្នកទិញ បានប្រកែកមិនឱ្យអ្នកលក់ជួសជុលវិការៈ ដោយគ្មានហេតុផលត្រឹមត្រូវ នោះក៏មិនអាចបន្ថយតម្លៃបានដែរ (មាត្រា ៥៤៤ វាក្យខណ្ឌទី ២)។

**៥. ករណីយកិច្ចសងសំណងនៃការខូចខាត (មាត្រា ៥៤៥)**

***អ្នកលក់*** ត្រូវមានករណីយកិច្ចសងសំណងនៃការខូចខាត ប្រសិនបើ វត្ថុដែលបានប្រគល់មានវិការៈ។ អ្នកទិញ អាចទាមទារសំណងនៃការខូចខាត ដោយស្របតាមមាត្រា ៣០៨ ដល់ មាត្រា ៤០៦ ។ អ្នកទិញ អាចទាមទារឱ្យសងការខូចខាតដោយឯករាជ្យពី ឬ ជាមួយនឹងការសង្គ្រោះណាមួយ ដែលមានបញ្ញត្តិចាប់ពីមាត្រា ៥៤២ ដល់មាត្រា ៥៤៤។ មាត្រា ៥៤៥ មិនបានបញ្ញត្តិពីភាពសុចរិត ឬ ទុច្ចរិត ឬ មានកំហុស ឬ គ្មានកំហុសរបស់អ្នកទិញទេ។ ក៏ប៉ុន្តែ ប្រសិនបើ អ្នកទិញ បានដឹងពីអត្ថិភាពនៃវិការៈ នៅពេលប្រគល់នោះ គាត់ ត្រូវបានចាត់ទុកថាបានយល់ព្រមទទួល យកកម្មវត្ថុនោះជាការអនុវត្តកាតព្វកិច្ច ដែលបានបំពេញនូវគោលបំណងនៃកាតព្វកិច្ច ។

**៤.៣.៣ បញ្ញត្តិពិសេសស្តីពីដីដែលមានទំហំខ្វះ ឬ លើស**

មាត្រា ៥៤៦ បានចែងអំពីបញ្ញត្តិពិសេសនៃការទទួលខុសត្រូវក្នុងការធានាវិការៈ នៅក្នុងករណីដែលដីមានទំហំលើស ឬក៏ ខ្វះ។ ជាទូទៅ ការទិញលក់ដី ត្រូវបានធ្វើឡើងយ៉ាងហោចណាស់សំរាប់តំបន់ពាណិជ្ជកម្ម។ ជាងនេះទៅទៀត ប្រសិនបើ គូភាគី បានបញ្ជាក់ទំហំដីសរុប និង កំណត់តំលៃតាមខ្នាតដីច្បាស់លាស់ វា មានលក្ខណៈងាយស្រួល ក្នុងការគណនាគំលាតតំលៃរវាងទំហំដីពិតប្រាកដ និង ទំហំដែលបានបញ្ជាក់។ ដូច្នេះ នៅក្នុងករណីនេះ ប្រសិនបើ ទំហំដីពិតប្រាកដ តិចជាងទំហំដែលបានបញ្ជាក់ នោះអ្នកទិញ អាចទាមទារឱ្យផ្តល់តាវកាលិកនូវផ្នែកដែលខ្វះ បន្ថយនូវតំលៃដី រំលាយកិច្ចសន្យា (នៅក្នុងករណីដែលអ្នកលក់ មិនអាចសំរេចនូវគោលបំណងនៃកិច្ចសន្យា) និង/ឬ សំណងនៃការខូចខាត (មាត្រា ៥៤៦ កថាខណ្ឌទី ១)។ ផ្ទុយទៅវិញ ប្រសិនបើ ទំហំដីពិតប្រាកដ លើសពីទំហំដែលបានបញ្ជាក់ នោះអ្នកលក់ ដែលសុចរិត និង គ្មានកំហុសធ្ងន់ធ្ងរ អាចទាមទារបន្ថែមតំលៃដីដែលលើសនោះបាន លើកលែងតែមានការព្រមព្រៀងផ្សេង (មាត្រា ៥៤៦ កថាខណ្ឌទី ២)។

ផ្ទុយទៅវិញ ប្រសិនបើភាគី បានបញ្ជាក់ពីទំហំដីសរុប និង កំណត់តំលៃដីទាំងមូល ដូច្នេះ វា មានការលំបាក ក្នុងការគណនាតំលាតតំលៃរវាងទំហំដីពិតប្រាកដ និង ទំហំដែលបានបញ្ជាក់។ ដូច្នេះ ក្រមរដ្ឋប្បវេណី បានបញ្ញត្តិថា អ្នកទិញ មិនអាចទាមទារអោយផ្តល់តាវកាលិកនូវផ្នែកដែលខ្វះ បន្ថយតំលៃដី រំលាយកិច្ចសន្យា ឬទាមទារសំណងនៃការខូចខាត ទោះបី ជាទំហំដីពិតប្រាកដ តិចជាងទំហំដែលបានបញ្ជាក់ក៏ដោយ (មាត្រា ៥៤៦ កថាខណ្ឌទី ៣)។

ក៏ប៉ុន្តែ អ្នកលក់ អាចទាមទារ ការសង្គ្រោះទាំងនេះបាន ប្រសិនបើ

(ក) អ្នកលក់ បានដឹងពីការខ្វះទំហំដីនោះ

(ខ) អ្នកលក់ បានធានានូវទំហំដីនោះ

(គ) ទំហំខ្វះនោះ មានច្រើនជាង ៥ ភាគរយនៃទំហំដែលបានបញ្ជាក់ (មាត្រា ៥៤៦ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ២)។

ហើយ នៅក្នុងករណីដែលទំហំដីពិតប្រាកដ មានលើសពីទំហំដីដែលបានបញ្ជាក់ នោះ អ្នកលក់ មិនអាចទាមទារបន្ថែមតំលៃដីបានឡើយ (មាត្រា ៥៤៦ កថាខណ្ឌទី ៤)។ ក៏ប៉ុន្តែ មានតែអ្នកលក់ ដែលសុចរិត និង គ្មានកំហុស អាចទាមទារអោយបន្ថែមតំលៃដីបាន ប្រសិនបើ ទំហំដីពិតប្រាកដ លើសពីទំហំដីដែលបានបញ្ជាក់ ចំនួន ៥ ភាគរយ (មាត្រា ៥៤៦ កថាខណ្ឌទី ៤ វាក្យខណ្ឌទី ២)។

ឧទាហរណ៍ ប្រសិនបើ **ខ** បានទិញដីទំហំ ១០០ ម៉ែត្រការ៉េ ក្នុងតំលៃ ១០០០ ដុល្លា ពី **ក** ប៉ុន្តែ ទំហំដីពិតប្រាកដ មានតែ ៩៨ ម៉ែត្រការ៉េ។ ប្រសិនបើ គូភាគី បានព្រមព្រៀងថា តំលៃនៃដីនោះ គឺ ១០ ដុល្លា ក្នុង ១ ម៉ែត្រការេ នោះ **ខ** អាចទាមទារអោយផ្តល់តាវការលិកនូវផ្នែកដែលខ្វះ ឬ បន្ថយតំលើដីចំនួន ២០ ដុល្លា ឬក៏ រំលាយកិច្ចសន្យា ដែលមានតែនៅក្នុងករណីដែល **ខ** មិនសំរេចបាននូវគោលបំណងនៃកិច្ចសន្យា និង/ឬ ទាមទារសំណងនៃការខូចខាត លុះត្រាតែ **ខ** បានធ្វើសកម្មភាពដោយសុចរិត និង គ្មានកំហុសធ្ងន់ធ្ងរ។ ប្រសិនបើ គូភាគីទាំងសងខាង មិនបានសំរេចពីតំលៃតាមខ្នាតដីច្បាស់លាស់ទេ នោះ **ខ** អាចទាមទារការសង្គ្រោះទាំងនេះបាន មានតែនៅក្នុងករណីដែល **ក** បានដឹងពីការខ្វះទំហំដីនោះ, **ក** បានធានានូវទំហំដីនោះ។

### ៤.៣.៤ អំឡុងពេលដែលអាចអនុវត្តសិទ្ធិ

សិទ្ធិដែលទាក់ទងនឹងការទទួលខុសត្រូវក្នុងការធានាវិការៈ ត្រូវអនុវត្តក្នុងអំឡុងពេល ១ ឆ្នាំ (មាត្រា ៥៤៧ កថាខណ្ឌទី ១)។ អំឡុងពេលនេះ ត្រូវគិតចាប់ពី :

(ក) សំរាប់អ្នកទិញ ពេលដែលអ្នកទិញ បានដឹង ឬ គួរបានដឹងអំពីវិការៈ និង ការខូចខាត

(ខ) សំរាប់អ្នកលក់ ពេលដែលធ្វើកិច្ចសន្យា (មាត្រា ៥៤៧ កថាខណ្ឌទី ២)។

ក៏ប៉ុន្តែ សិទ្ធិទាមទារសំណង នៃការខូចខាត ដែលបានបញ្ញត្តិនៅក្នុងមាត្រា ៥៤៦ កថាខណ្ឌទី ១ និង មាត្រា ៥៤៦ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ២ ត្រូវរលត់ ស្របតាមមាត្រា ៤៨២ (អំឡុងពេលនៃអាជ្ញាយុកាលនៃ

ការរំលត់សិទ្ធិលើបំណុលទូទៅ) ។ ដូច្នេះ អំឡុងពេលនៃ អាជ្ញាយុកាល នៃការរំលត់សិទ្ធិទាមទារ អោយសងសំណង នៃការខូចខាត ដែលបានបញ្ញត្តិនៅក្នុងមាត្រា ៥៤៦ កថាខណ្ឌទី ១ និង មាត្រា ៥៤៦ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ២ គឺ ៥ ឆ្នាំ ហើយ វា គិតចាប់ពីពេល ដែលអ្នកលក់ អាចអនុវត្តសិទ្ធិរបស់ខ្លួនបាន ( មាត្រា ៤៨១ និង ៤៨២) ។

### ៩.៣.៥ កិច្ចសន្យាពិសេសដែលអនុគ្រោះ ឬ កំរិតនូវការទទួលខុសត្រូវក្នុងការធានាវិការៈ

គូភាគី អាចព្រមព្រៀងគ្នា ដើម្បីអនុគ្រោះ ឬ កំរិតនូវការទទួលខុសត្រូវក្នុងការធានារបស់អ្នកលក់បាន។ ក៏ប៉ុន្តែ អ្នកលក់ មិនអាចរួចផុតពីការទទួលខុសត្រូវក្នុងការធានាបានឡើយ ទាក់ទងនឹងករណីដែល អ្នកលក់ បានដឹង តែមិនបានប្រាប់ ដោយសារតែមានគោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ ( មាត្រា ៥) ។

### ៩.៤ ក្នុងករណីដែលសិទ្ធិដែលត្រូវបានលក់ ត្រូវបានកំរិតដោយច្បាប់

ទោះបីជាអ្នកទិញ គឺជាម្ចាស់កម្មសិទ្ធិលើកម្មវត្ថុនៃកិច្ចសន្យា ក៏មានពេលខ្លះ សិទ្ធិប្រើប្រាស់ ក៏ត្រូវបានកំរិត ដោយសិទ្ធិប្រត្យក្សដែរ ។ នៅក្នុងករណីនេះ វា មានសារសំខាន់ណាស់ក្នុងការកែតំរូវនូវអតុល្យភាពនេះ ។

### ៩.៤.១ ការទទួលខុសត្រូវក្នុងការធានា ក្នុងករណីដែលមានសិទ្ធិប្រត្យក្សជាផលុបភោគ ជាអាទិ៍ ( មាត្រា ៥៣៤)

នៅក្នុងករណីដែលកម្មវត្ថុនៃកិច្ចសន្យាលក់ទិញ ត្រូវបានជាប់បន្ទុកសំរាប់គោលបំណងនៃសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ភតិសន្យា ជាអាទិ៍ ហើយ ម្ចាស់សិទ្ធិផលុបភោគ បានចុះបញ្ជីនូវសិទ្ធិរបស់ខ្លួន នោះ ម្ចាស់កម្មសិទ្ធិករថ្មី មិនអាចប្រើប្រាស់នូវកម្មវត្ថុនោះទាំងស្រុងនោះទេ។ ឧទាហរណ៍ នៅក្នុងករណីដែល ខ បានទិញដីពី ក ប៉ុន្តែ ក បានជួលដី នោះទៅអោយ គ រួចទៅហើយ ហើយ ក ក៏បានទទួលនូវលក្ខខណ្ឌតតាំងរួចរាល់ហើយ ដូច្នេះ ខ មិន អាចទាមទារនូវការប្រើប្រាស់ដីនោះ ចំពោះ គ បានឡើយ ( មាត្រា ៥៩៨ កថាខណ្ឌទី ១) ។

### ៩.៤.២ ក្នុងករណីដែលមានសិទ្ធិប្រត្យក្សជាផលុបភោគ

នៅក្នុងករណីដែលមានសិទ្ធិប្រត្យក្សផលុបភោគ អ្នកទិញ ដែលសុចរិត អាចទាមទារសំណងការខូចខាត ( មាត្រា ៥៣៤ កថាខណ្ឌទី ១) ។ អ្នកទិញ ដែលសុចរិត ក៏អាចទាមទារអោយរំលាយកិច្ចសន្យាបានដែរ ប្រសិនបើ គាត់ មិនអាចសំរេចនូវគោលបំណងនៃកិច្ចសន្យា ដោយសារតែមាននូវសិទ្ធិប្រត្យក្សផលុបភោគនោះ។ អ្នកទិញ ត្រូវអនុវត្តសិទ្ធិរំលាយ និង សិទ្ធិសងសំណងការខូចខាត នៅក្នុងរយៈពេល ១ ឆ្នាំ គិតចាប់ពីពេលដែលអ្នកទិញ បាន ដឹងការពិត ( មាត្រា ៥៣៤ កថាខណ្ឌទី ៤) ។

### ៤.៤.៣ នៅក្នុងករណីដែលមានសិទ្ធិប្រាតិភោគប្រត្យក្ស

ម្ចាស់កម្មសិទ្ធិករលើអចលនវត្ថុ អាចលក់អចលនវត្ថុរបស់ខ្លួនបាន ទោះបីជាអចលនវត្ថុនោះ គឺជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគប្រត្យក្ស ដូចជា ឯកសិទ្ធិ ឬ ហ៊ីប៉ូតែកក៏ដោយ។ ក៏ប៉ុន្តែ នៅក្នុងករណីនេះ អ្នកទិញ ត្រូវទទួលបន្ទុកហានិភ័យ ក្នុងការបាត់បង់នូវកម្មសិទ្ធិលើអចលនវត្ថុនោះ ដោយសារតែការអនុវត្តនូវសិទ្ធិប្រត្យក្សទាំងនេះ។

ដូច្នេះ អ្នកទិញ អាចរំលាយកិច្ចសន្យាលក់ទិញ នៅពេលដែលខ្លួន បានបាត់បង់នូវកម្មសិទ្ធិ ដោយការអនុវត្តនូវសិទ្ធិប្រាតិភោគប្រត្យក្ស (មាត្រា ៥៣៥ កថាខណ្ឌទី ១)។ ជាងនេះទៅទៀត អ្នកទិញ អាចរំលាយកិច្ចសន្យាទោះបីជា អ្នកទិញ បានដឹងពីអត្ថិភាពនៃសិទ្ធិប្រាតិភោគប្រត្យក្សនោះ នៅពេលបង្កើតកិច្ចសន្យាក៏ដោយ ព្រោះម្ចាស់បំណុលរបស់អ្នកលក់ មិនអនុវត្តនូវសិទ្ធិប្រាតិភោគប្រត្យក្សជាចាំបាច់នោះទេ។ វា អាចសមហេតុផលដែលថាអ្នកទិញ ជឿថា អ្នកលក់ នឹងសងបំណុលរបស់ខ្លួន ហើយ សិទ្ធិប្រាតិភោគប្រត្យក្ស នឹងរំលត់ ក្រោយពីការបង្កើតកិច្ចសន្យាលក់ទិញ ដូច្នេះ អ្នកទិញ គឺចាំបាច់ត្រូវការពារនៅក្នុងកំរិតមួយចំនួន។ អ្នកទិញ អាចបង់ប្រាក់ ហើយធ្វើឱ្យហ៊ីប៉ូតែកនោះរលត់ តាមសំណើររបស់ម្ចាស់បំណុលហ៊ីប៉ូតែក (= ម្ចាស់បំណុល មាត្រា ៨៦៤)។ ឧទាហរណ៍ ខ បានទិញដីមួយកន្លែងពី ក ហើយ ដីនោះ គឺជាកម្មវត្ថុនៃហ៊ីប៉ូតែកសំរាប់ គ ក្នុងការធានាបំណុល ១,០០០ ដុល្លា។ ប្រសិនបើ គ ស្នើសុំអោយសងប្រាក់ ហើយ ខ បានបង់ប្រាក់ ១,០០០ ដុល្លា នោះ ហ៊ីប៉ូតែក ត្រូវរលត់សំរាប់ជាផលប្រយោជន៍របស់ ខ។

នៅក្នុងករណីនេះ ខ អាចទាមទារប្រាក់ ១,០០០ ដុល្លា ជាការសងនូវការចំណាយ ដើម្បីរក្សានូវកម្មសិទ្ធិ (មាត្រា ៥៣៥ កថាខណ្ឌទី ២)។ ខ ក៏អាចទាមទារសំណងចំពោះការខូចខាតដែលមាន (មាត្រា ៥៣៥ កថាខណ្ឌទី ៣)។

ប្រសិនបើ អ្នកទិញអចលនវត្ថុ ដែលភ្ជាប់នូវសិទ្ធិប្រាតិភោគប្រត្យក្ស ដែលបានកំណត់នៅក្នុងមាត្រា ៥៣៥ កថាខណ្ឌទី ១ បានទិញអចលនវត្ថុនោះ នៅក្នុងតំលៃ ដែលបានដកចេញនូវចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគប្រត្យក្ស នោះអ្នកទិញ មិនអាចទាមទារអោយសងថ្លៃចំណាយ និង សំណងការខូចខាតបានឡើយ (មាត្រា ៥៣៥ កថាខណ្ឌទី ៤)។ ឧទាហរណ៍ នៅក្នុងករណីខាងលើ ប្រសិនបើ តំលៃដើមនៃដីគឺ ៥,០០០ ដុល្លា ហើយ ក និង ខ បានព្រមព្រៀងគ្នាបង់ប្រាក់ថ្លៃដីចំនួន ៤,០០០ ដុល្លា ដោយគិតពិចារណាទៅលើអត្ថិភាពនៃហ៊ីប៉ូតែក នោះ ខ មិនអាចទាមទារអោយសងថ្លៃចំណាយ ឬ សំណងការខូចខាត ទោះបីជា ខ បានចំណាយអស់ ១,០០០ ដុល្លា តាមសំណើររបស់ គ ក៏ដោយ។

វា មិនមែនជាបញ្ហាទេ ថាតើ អ្នកទិញ បានធ្វើសកម្មភាពដោយសុចរិត ឬ ទុច្ចរិត ទាក់ទងនឹងការទទួលខុសត្រូវក្នុងការធានា នៅពេលដែលមានសិទ្ធិប្រាតិភោគប្រត្យក្ស។ ម្យ៉ាងទៀត វា មិនមានការកំរិតជាពិសេសណាមួយ ក្នុងការអនុវត្តសិទ្ធិរបស់អ្នកទិញ ហើយ វា ត្រូវរលត់ដោយផ្អែកទៅលើបញ្ញត្តិទូទៅនៃអាជ្ញាយុកាលនៃការរលត់ (មាត្រា ៤៨២)។

**ករណីសិក្សា**

តើអ្នកទិញ ខ អាចទាមទារអ្វីបានចំពោះ ក ទាក់ទងនឹងការទទួលខុសត្រូវក្នុងការធានា នៅក្នុងករណីខាងក្រោមនេះ ?

(១) ក បានលក់រថយន្តទៅអោយ ខ ប៉ុន្តែរថយន្តនោះ គឺជាកម្មសិទ្ធិរបស់ គ ។ ក មិនបានពន្យល់ ខ អំពីអង្គហេតុដែលថា រថយន្តនោះ គឺជាកម្មសិទ្ធិរបស់ គ ទោះបីជា ក បានដឹងអំពីអង្គហេតុនេះក៏ដោយ ។ ខ បានដឹងពីអង្គហេតុនេះ ក្រោយពីការបង្កើតកិច្ចសន្យា ហើយ បានទាមទារឱ្យប្រគល់រថយន្តនៅកាលបរិច្ឆេទ ។ ក៏ប៉ុន្តែ គ បានបំផ្លាញរថយន្តនោះចោល នៅមុនកាលបរិច្ឆេទប្រគល់ ។

(២) ក បានលក់ដីដែលជាកម្មសិទ្ធិអវិភាគ របស់ ក និង ឃ (ដែលមានចំនែកស្មើគ្នា) ប៉ុន្តែ ក មិនបានទទួលនូវការយល់ព្រមពី ឃ ឡើយ ។ ខ បានដឹងថា ដីនោះ គឺជាកម្មសិទ្ធិអវិភាគរបស់ ក និង ឃ ។ ក្រោយពីការបង្កើតកិច្ចសន្យា ក បានស្នើ សុំអោយ ឃ លក់នូវចំនែករបស់ខ្លួនមកអោយ ក ប៉ុន្តែ ឃ បានបដិសេធយ៉ាងដាច់ខាត ។

(៣) ខ បានទិញដីដើម្បីសាងសង់រោងចក្រ ។ ក៏ប៉ុន្តែ ដីនោះ បានភ្ជាប់នឹងសិទ្ធិជួលអចិន្ត្រៃយ៍របស់ ខ ហើយ ខ បានចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍របស់ខ្លួន ។ ខ បានប្រើប្រាស់ដីទាំងមូលសំរាប់ធ្វើកសិដ្ឋាន ។ ខ មិនបានដឹងថា ដីនេះ គឺមានភ្ជាប់នឹងសិទ្ធិជួលអចិន្ត្រៃយ៍ នៅពេលបង្កើតកិច្ចសន្យាឡើយ ។

(៤) ខ បានទិញរថយន្តមួយពីឈ្មួញលក់រថយន្ត ក ហើយ បានបង់ប្រាក់ថ្លៃទិញរួចរាល់ហើយ ដើម្បីជាថ្នូរនឹងការប្រគល់រថយន្ត ។ ក៏ប៉ុន្តែ ហ្វ្រាំងរបស់រថយន្តនោះ មិនដំណើរការទាល់តែសោះ ។ ទាំង ក និង ខ មិនបានដឹងពីវិការៈនេះ ដោយគ្មានកំហុសធ្ងន់ធ្ងរ ។

(៥) ក និង ខ បានចុះកិច្ចសន្យាលក់ទិញ ដែល ក ត្រូវផ្ទេរការចុះបញ្ជីដីជាមួយនឹងផ្ទះរបស់ខ្លួន នៅថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១១ ហើយ ធ្វើការប្រគល់ដី និង ផ្ទះទៅអោយ ខ ដើម្បីជាថ្នូរនឹងការបង់ប្រាក់នៅថ្ងៃទី ១ ខែ មេសា ។ ក បានផ្ទេរនូវការចុះបញ្ជីនៅថ្ងៃទី ១ ខែ មីនា ។ ក៏ប៉ុន្តែនៅមុនពេលប្រគល់ដី និង ផ្ទះនោះ សសរសំខាន់របស់ផ្ទះនោះ បានពុក ដោយសារតែកំហុសរបស់ ក នៅក្នុងកំរិតមួយដែល ខ មិនអាចរស់នៅក្នុងផ្ទះនោះបាន ប្រសិនបើសសរនោះ មិនត្រូវបានចាក់បេតុងសាជាថ្មី ។ ទាំង ក និង ខ មិនបានដឹងពីវិការៈនេះ រហូតដល់ពេលប្រគល់ ។

(៦) ខ បានទិញដីដែលមានទំហំ ១០០ ម៉ែត្រការេ ពី ក ដើម្បីប្រើប្រាស់ជាដីកសិដ្ឋាន ។ ពួកគេ បានព្រមព្រៀងគ្នាថា តំលៃសរុបនៃដីនោះ គឺ ១០,០០០ ដុល្លា សំរាប់ដីទំហំ ១០០ ម៉ែត្រការេ ហើយ ១០០ ដុល្លា ក្នុង មួយម៉ែត្រការេ ។ ខ បានបង់ប្រាក់ ១០,០០០ ដុល្លា រួចរាល់ហើយ ហើយ ក ក៏បានប្រគល់ដីនោះ ។ ប៉ុន្តែ គេ រកឃើញថាទំហំដីពិតប្រាកដ គឺមានតែ ៩០ ម៉ែត្រការេ ។ ខ មិនបានដឹងពីការខ្វះនូវទំហំដីនេះ នៅពេលធ្វើកិច្ចសន្យាឡើយ ។

【សេចក្តីសន្និដ្ឋាន និង មូលហេតុសំអាង】

(១) ខ អាចទាមទារអោយរំលាយកិច្ចសន្យា និង សំណងនៃការខូចខាត ។

ក មានកាតព្វកិច្ចក្នុងការផ្ទេរកម្មសិទ្ធិពី គ ហើយធ្វើការផ្ទេរកម្មសិទ្ធិនេះទៅអោយ ខ ( មាត្រា ៥៣១ កថាខណ្ឌទី ២) ។ ក៏ប៉ុន្តែ ក មិនអាចទទួលបាននូវកម្មសិទ្ធិទៀតទេ ព្រោះ គ បានបំផ្លាញរថយន្តនោះចោលហើយ ។

ដូច្នេះ ខ អាចរំលាយកិច្ចសន្យានេះ និង ទាមទារសំណងនៃការខូចខាត ព្រោះ ខ បានធ្វើសកម្មភាពដោយសុចរិត ( មាត្រា ៥៣១ កថាខណ្ឌទី ៣) ។

(២) ខ អាចទាមទារបានតែការបន្ថយថ្លៃតែប៉ុណ្ណោះ ។

នៅក្នុងករណីនេះ ក បានលក់ដី ដែលជាកម្មសិទ្ធិមួយផ្នែករបស់ ឃ ។ ដូច្នេះ ក ត្រូវមានកាតព្វកិច្ចទទួលយកនូវចំណែករបស់ ឃ ហើយ ធ្វើការផ្ទេរទៅអោយ ខ ។ ប៉ុន្តែ ឃ បដិសេធក្នុងការផ្ទេរចំណែករបស់ខ្លួនទៅឱ្យ ក ទេ ដូច្នេះ កាតព្វកិច្ចរបស់ ក ក្នុងការទទួលយកនូវចំណែករបស់ ឃ ក្លាយជាអលទ្ធភាព ។ ក៏ប៉ុន្តែនៅក្នុងករណីនេះ ខ បានដឹងថា ដីនោះ គឺជាកម្មសិទ្ធិអវិភាគរបស់ ក និង ឃ ។ ដូច្នេះ ខ មិនអាចទាមទារអោយរំលាយកិច្ចសន្យា ឬ សងសំណងនៃការខូចខាត ( មាត្រា ៥៣៣ កថាខណ្ឌទី ២ និង ៣) ប៉ុន្តែ អាចទាមទារបន្ថយ ៥០ ភាគរយ ពីប្រាក់ថ្លៃទិញ ( មាត្រា ៥៣៣ កថាខណ្ឌទី ១) ។

(៣) ខ អាចទាមទារអោយរំលាយកិច្ចសន្យា និង សងសំណងការខូចខាត ។

នៅក្នុងករណីនេះ កម្មវត្ថុនៃកិច្ចសន្យាលក់ទិញ គឺត្រូវបានភ្ជាប់ទៅនឹងសិទ្ធិជួលអចិន្ត្រៃយ៍សំរាប់ ១ ។ ខ អាចទាមទារសំណងនៃការខូចខាត ( មាត្រា ៥៣៤ កថាខណ្ឌទី ១) ព្រោះ ខ មិនបានដឹងពីអត្ថិភាពនៃសិទ្ធិជួលអចិន្ត្រៃយ៍ នៅពេលបង្កើតកិច្ចសន្យា ។ ហើយម្យ៉ាងទៀត គោលបំណងរបស់ ខ នៅក្នុងការទិញដីនេះ គឺដើម្បីសាងសង់រោងចក្រ ប៉ុន្តែ វា មិនអាចធ្វើបាន ដោយសារតែ ១ បានប្រើដីនោះទាំងមូលសំរាប់ធ្វើកសិដ្ឋាន ។ ដូច្នេះ ខ អាចរំលាយកិច្ចសន្យាដោយផ្អែក ទៅតាមមាត្រា ៥៣៤ កថាខណ្ឌទី ២ ។

(៤) ខ អាចទាមទារសំណងការខូចខាតដោយឡែកពី ឬក៏ជាមួយនឹង ការប្រគល់វត្ថុជំនួស ការជួសជុល រំលាយកិច្ចសន្យា ឬ ការបន្ថយថ្លៃទិញ ។

ជាធម្មតា ប្រសិនបើមានវិការៈ ជាមួយនឹងហ្វ្រាំងរបស់រថយន្ត នៅពេលប្រគល់ វា ត្រូវបានគេចាត់ទុកថាជា ឡាន ដែលមានវិការៈ ព្រោះ ហ្វ្រាំងរបស់រថយន្ត គឺមានតួនាទីយ៉ាងសំខាន់ ។ ដូច្នេះ ក ត្រូវមានករណីយកិច្ចប្រគល់វត្ថុជំនួស ជួសជុល រំលាយកិច្ចសន្យា ឬ បន្ថយថ្លៃ ( មាត្រា ៥៤០ កថាខណ្ឌទី ១) និង/ឬ សំណងនៃការខូចខាត ( មាត្រា ៥៤៥) ។ មាត្រា ៥៤២ រហូតដល់មាត្រា ៥៤៥ បញ្ញត្តិអំពីលក្ខខណ្ឌដើម្បីបង្កើតអានុភាព ។

ជាដំបូង ខ អាចទាមទារអោយ ត ត្រូវប្រគល់វត្ថុជំនួស។ នៅក្នុងករណីនេះ កាតព្វកិច្ចក្នុងការផ្តល់នូវរថយន្តថ្មី មិនត្រូវបានចាត់ទុកថាជា ករណី "ដែលការរៀបចំផ្តល់អោយវត្ថុដែលមានប្រភេទដូចគ្នា នឹងដាក់បន្ទុកយ៉ាងធ្ងន់ធ្ងរទៅដល់អ្នកលក់ទេ (មាត្រា ៥៤២ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២)" ព្រោះ ត គឺជាឈ្មួញលក់រថយន្ត។

បន្ទាប់មក ខ អាចទាមទារអោយ ត ត្រូវធ្វើការជួសជុលរថយន្ត (មាត្រា ៥៤២ កថាខណ្ឌទី ៣)។ នៅក្នុងករណីនេះ ខ ត្រូវជួលជុលប្រាំងដោយខ្លួនឯងផ្ទាល់ ឬ អោយហាងជួសជុល ធ្វើការជួសជុលរថយន្តនោះ។

ទាក់ទងនឹងការរំលាយកិច្ចសន្យា បញ្ហា គឺថាតើ អ្នកលក់ មិនអាចសំរេចនូវគោលបំណងនៃកិច្ចសន្យាលក់ទិញ ដោយសារវិការៈនោះដែរ ឬ ទេ។ វា គឺមានលក្ខណៈគ្រោះថ្នាក់ណាស់ ហើយ អ្នកទិញ ត្រូវតែបោះបង់នូវការបើកបររបស់ខ្លួន ប្រសិនបើ ប្រាំង មិនដំណើរការទាល់តែសោះ។ ដូច្នេះ នៅក្នុងករណីនេះ អ្នកទិញ អាចរំលាយកិច្ចសន្យាបាន។

ហើយ ខ អាចទាមទារអោយបន្ថយថ្លៃ ដោយស្របទៅនឹងមាត្រា ៥៤៤។ ប៉ុន្តែ ប្រសិនបើ ត បានជួសជុលនូវវិការៈនោះរួចរាល់ហើយ នោះ ខ មិនអាចទាមទារអោយបន្ថយថ្លៃបានទេ។

ប្រសិនបើ ខ ទទួលរងនូវការខូចខាត នោះ ខ អាចទាមទារនូវសំណងនៃការខូចខាត អោយស្របទៅនឹងមាត្រាដែលពាក់ព័ន្ធនឹងសំណងនៃការខូចខាត។

(៥) ខ អាចទាមទារអោយជួសជុល បន្ថយថ្លៃលក់ទិញ រំលាយកិច្ចសន្យា និង/ឬ សំណងនៃការខូចខាត។

នៅក្នុងករណីនេះ នៅពេលដែល ត ផ្ទេរការចុះបញ្ជី នោះ ហានិភ័យ ក៏ត្រូវបានផ្ទេរដែរ (មាត្រា ៤១៦ កថាខណ្ឌ ទី ២ ចំណុច ក)។ នៅក្នុងករណីនេះ មាត្រា ៥៤០ កថាខណ្ឌទី ១ មិនអាចយកមកអនុវត្តបានឡើយ ព្រោះ វិការៈ មិនបានកើតឡើងនៅឡើយ នៅពេលនៃការចុះបញ្ជី។ ក៏ប៉ុន្តែ អ្នកលក់ ត្រូវទទួលខុសត្រូវក្នុងការធានា នៅក្រោយការប្រគល់ នៅក្នុងករណីដែលវិការៈ កើតឡើងដោយសារកំហុសរបស់អ្នកលក់ (មាត្រា ៥៤០ កថាខណ្ឌទី ២)។

កម្មវត្ថុនៃកិច្ចសន្យាលក់ទិញនេះ គឺជាវត្ថុដែលបានកំណត់ជាក់លាក់។ ខ មិនអាចទាមទារអោយប្រគល់វត្ថុជំនួសបានទេ ព្រោះ វត្ថុដែលបានកំណត់ជាក់លាក់ មិនមានវត្ថុជំនួសទេ (មាត្រា ៥៤២ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២)។ ផ្ទុយទៅវិញ ខ អាចទាមទារអោយជួសជុល ព្រោះ គេ អាចជួសជុលសរសរផ្ទះនោះបាន (មាត្រា ៥៤២ កថាខណ្ឌទី ៣)។

ខ ក៏អាចទាមទារអោយរំលាយកិច្ចសន្យាបានដែរ ព្រោះ ខ មិនអាចចូលស្នាក់នៅក្នុងផ្ទះនោះ ប្រសិនបើសរសរ មិនត្រូវបានចាក់បេតុង។

ត ត្រូវមានកាតព្វកិច្ចថែរក្សាកម្មវត្ថុនោះ ដោយយកចិត្តទុកដាក់ក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ រហូតដល់ពេលដែលវត្ថុនោះ ត្រូវបានប្រគល់ (មាត្រា ៥២២ កថាខណ្ឌទី ១)។ នៅក្នុងករណីនេះ វិការៈ កើតឡើង ដោយសារ កំហុសរបស់ ត ដូច្នេះ ត មានកាតព្វកិច្ចសងនូវសំណងនៃការខូចខាត។

(៦) ខ អាចទាមទារអោយបន្ថយថ្លៃ ប្រគល់នូវផ្នែកដែលខ្វះ និង/ឬ សងសំណងនៃការខូចខាត។

នៅក្នុងករណីនេះ មាត្រា ៥៤៦ កថាខណ្ឌទី ១ អាចយកមកអនុវត្ត ដោយសារភាគីទាំងសងខាង បាន កំណត់អំពីទំហំសរុបនៃដីដែលបានកំណត់ជាក់លាក់ ហើយ តំលៃតាមខ្នាតដី។ ដូច្នេះ ខ អាចទាមទារអោយប្រគល់ ផ្នែកដែលខ្វះ បន្ថយថ្លៃទិញ ឬ រំលាយកិច្ចសន្យា និង/ឬ សំណងនៃការខូចខាត ដោយស្របនឹងមាត្រា ៥៤២ ដល់ ៥៤៥។

ជាដំបូង ក ត្រូវមានកាតព្វកិច្ចប្រគល់ដីដែលនៅខ្វះចំនួន ១០ ម៉ែត្រការេ។ ឧទាហរណ៍ ប្រសិនបើ ផ្នែក ដែលខ្វះ គឺជាកម្មសិទ្ធិរបស់តតិយជន នោះ ក ត្រូវទទួលយកកម្មសិទ្ធិពីតតិយជន ហើយ ធ្វើការប្រគល់ទៅអោយ ខ។ ក៏ប៉ុន្តែ ប្រសិនបើ វា ដាក់ជាបន្ទុកមិនសមហេតុផលទៅដល់ ក ឧទាហរណ៍ដូចជា តតិយជន បដិសេធមិនព្រម ផ្ទេរកម្មសិទ្ធិលើផ្នែកដែលខ្វះ ឬ ផ្នែកដែលខ្វះនេះ គឺជាកម្មសិទ្ធិរបស់រដ្ឋ នោះ ក នឹងមិនបំពេញកាតព្វកិច្ចនេះទេ។

ហើយ ខ អាចទាមទារអោយបន្ថយថ្លៃចំនួន ១.០០០ ដុល្លា ដោយផ្អែកលើមាត្រា ៥៤៤។

ម្យ៉ាងវិញទៀត ខ មិនអាចទារទារអោយរំលាយកិច្ចសន្យាបានទេ ព្រោះគោលបំណងនៃការទិញដីនេះ គឺ ដើម្បីប្រើប្រាស់ជាកសិដ្ឋាន ហើយ ខ នៅតែអាចប្រើប្រាស់ដីនោះ សំរាប់ធ្វើកសិដ្ឋានបានដដែល ទោះបីទំហំដីខ្វះ ១០ ភាគរយ ក៏ដោយ។

ប្រសិនបើ ខ មានការខូចខាត ដោយសារការទំហំដីខ្វះ នោះ ខ អាចទាមទារសំណងនៃការខូចខាតបាន។

## ៥. ករណីយកិច្ច និង សិទ្ធិរបស់អ្នកទិញ

### ៥.១ ករណីយកិច្ចទូទៅរបស់អ្នកទិញ

ក្រោយពីបង្កើតកិច្ចសន្យាលក់ទិញ អ្នកទិញ ត្រូវមានករណីយកិច្ចបង់ថ្លៃជាប្រាក់ ដែលបានសន្យាក្នុង កិច្ចសន្យា និងមានករណីយកិច្ចទទួលវត្ថុដែលអ្នកទិញបានទិញ ពីអ្នកលក់។

#### ៥.១.១ ករណីយកិច្ចបង់ថ្លៃទិញ

អ្នកទិញ មានករណីយកិច្ចបង់ថ្លៃទិញជាប្រាក់ តាមកាលបរិច្ឆេទ និង នៅទីកន្លែងដែលបានកំណត់ក្នុង កិច្ចសន្យា។ កាលបរិច្ឆេទ និង ទីកន្លែងនៃការបង់ប្រាក់ ត្រូវបានសំរេចដោយផ្អែកលើការព្រមព្រៀងរបស់គូភាគី ក្នុងកិច្ចសន្យា។

ក្នុងករណីដែលអ្នកទិញ បង់ប្រាក់ក្រោយកាលបរិច្ឆេទដែលកំណត់ នោះអ្នកទិញ ត្រូវទទួលខុសត្រូវចំពោះ ការយឺតយ៉ាវនៅក្នុងការអនុវត្ត។

អ្នកទិញ មិនចាំបាច់បង់ការប្រាក់នៃថ្លៃទិញ ឬ ប្រាក់សំណងនៃការខូចខាត ដោយសារការយឺតយ៉ាវ រហូតដល់ពេលដែលវត្ថុ ដែលជាកម្មវត្ថុត្រូវបានប្រគល់ ទោះបីជាកាលបរិច្ឆេទប្រគល់ បានកន្លងហួសក៏ដោយ (មាត្រា ៥៥៦)។ អ្នកទិញ មិនអាចទទួលផលពីកម្មវត្ថុ រហូតដល់ពេលប្រគល់ (មាត្រា ៥៥៣)។

ឧទាហរណ៍ **ក** បានធ្វើកិច្ចសន្យាលក់រថយន្ត ០១ គ្រឿង ទៅអោយ **ខ** ក្នុងតំលៃ ២០០០០ ដុល្លាអាមេរិក ហើយ បានកំណត់ថ្ងៃបង់ប្រាក់ថ្លៃរថយន្ត នៅថ្ងៃទី ០១ ខែ ០១ ឆ្នាំ ២០១០ និង បានកំណត់យកទីកន្លែងប្រគល់ប្រាក់ នៅផ្ទះរបស់ **ក**។ ដូច្នេះ **ខ** ត្រូវមានករណីយកិច្ចបង់ប្រាក់ថ្លៃទិញរថយន្តចំនួន ២០០០០ ដុល្លា ទៅឱ្យ **ក** នៅថ្ងៃទី ០១ ខែ ០១ ឆ្នាំ ២០១០ នៅផ្ទះរបស់ **ក** ដែលបានកំណត់ក្នុងកិច្ចសន្យា។

ប្រសិនបើ កិច្ចសន្យាលក់ទិញចលនវត្ថុ បានកំណត់តែពេលសំរាប់ធ្វើការប្រគល់កម្មវត្ថុ ពេលនោះ ត្រូវបានសន្មតថាជាពេលសំរាប់បង់ប្រាក់ថ្លៃទិញដែរ។ ទន្ទឹមនឹងនេះ នៅក្នុងករណីដែលកិច្ចសន្យាលក់ទិញអចលនវត្ថុ កំណត់តែពេលសំរាប់ធ្វើសកម្មភាពចាំបាច់ក្នុងការចុះបញ្ជីអចលនវត្ថុ ពេលនោះ ត្រូវបានសន្មតថាជាពេលសំរាប់បង់ប្រាក់ថ្លៃទិញ (មាត្រា ៥៥៥ កថាខណ្ឌទី ២)។

តាមឧទាហរណ៍ខាងលើ ប្រសិនបើ **ក** និង **ខ** បានព្រមព្រៀងកំណត់ពេលប្រគល់រថយន្ត នៅថ្ងៃទី ១០ ខែ ០១ ឆ្នាំ ២០១០ ប៉ុន្តែ មិនកំណត់ពេលនៃការបង់ថ្លៃលក់រថយន្ត នោះពេលកំណត់ដែលត្រូវបង់ថ្លៃរថយន្តរបស់ **ខ** ទៅឱ្យ **ក** គឺនៅថ្ងៃទី ១០ ខែ ០១ ឆ្នាំ ២០១០។

នៅក្នុងករណីដែល ភាគី មិនបានកំណត់ពេលប្រគល់ចលនវត្ថុ ឬ ពេលធ្វើសកម្មភាពចាំបាច់ដើម្បីចុះបញ្ជីអចលនវត្ថុ នោះ អ្នកទិញ មានករណីយកិច្ចបង់ថ្លៃទិញទៅឱ្យអ្នកលក់ នៅពេលដែលអ្នកលក់ ទាមទារឱ្យបង់ប្រាក់ (មាត្រា ៥៥៥ កថាខណ្ឌទី ៣)។

ក្នុងករណីដែលមិនមានកំណត់ទីកន្លែងដែលត្រូវបង់ថ្លៃទិញនៅក្នុងកិច្ចសន្យាទេ ប្រសិនបើការបង់ថ្លៃ ត្រូវធ្វើព្រមគ្នានឹងការប្រគល់ចលនវត្ថុដែលជាកម្មវត្ថុ ឬ ព្រមគ្នានឹងការធ្វើសកម្មភាពចាំបាច់ដើម្បីចុះបញ្ជីអចលនវត្ថុដែលជាកម្មវត្ថុនោះ អ្នកទិញ ត្រូវបង់ថ្លៃនៅទីកន្លែងដែលអ្នកលក់ ត្រូវប្រគល់ចលនវត្ថុដែលជាកម្មវត្ថុ ឬ ត្រូវធ្វើសកម្មភាពចាំបាច់ដើម្បីចុះបញ្ជីអចលនវត្ថុដែលជាកម្មវត្ថុ (មាត្រា ៥៥៥ កថាខណ្ឌទី ៤)។

### ៥.១.២ ភាពខ្វះកិច្ចបង់ការប្រាក់

ក្នុងករណីដែលអ្នកទិញ បានទទួលការប្រគល់កម្មវត្ថុនៃកិច្ចសន្យាពីអ្នកលក់រួចហើយ នោះអ្នកទិញ ត្រូវបង់ការប្រាក់នៃថ្លៃទិញ រហូតដល់ពេលបង់ប្រាក់ថ្លៃទិញចប់សព្វគ្រប់ ឬ បង់ប្រាក់សំណងនៃការខូចខាតដោយសារការយឺតយ៉ាវ (មាត្រា ៥៥៦)។ ប៉ុន្តែករណីដែល អ្នកទិញ មិនទាន់បានទទួលការប្រគល់កម្មវត្ថុពីអ្នកលក់ នោះអ្នកទិញ មិនចាំបាច់ត្រូវបង់ការប្រាក់ ឬ ប្រាក់សំណងនៃការខូចខាតដោយសារការយឺតយ៉ាវទេ។

ជាការពិត គូភាគី អាចបង្កើតកិច្ចព្រមព្រៀងពិសេស ដែលកំណត់ថា អ្នកទិញ ត្រូវទទួលខុសត្រូវបង់ការប្រាក់នៃថ្លៃទិញ ឬ បង់ប្រាក់សំណងនៃការខូចខាតដោយសារការយឺតយ៉ាវបាន នៅក្រោយកាលបរិច្ឆេទបាន។

### ៥.១.៣ ករណីយកិច្ចទទួលវត្ថុដែលខ្លួនបានទិញ

អ្នកទិញ មានករណីយកិច្ចទទួលកម្មវត្ថុ ដែលខ្លួនបានទិញ ( មាត្រា ៥៥៤) ។ ប្រសិន អ្នកលក់ បានប្រគល់កម្មវត្ថុនៃកិច្ចសន្យាមកឱ្យអ្នកទិញ ប៉ុន្តែ អ្នកទិញ បដិសេធក្នុងការទទួលវត្ថុដែលបានប្រគល់ នោះ អ្នកទិញ ត្រូវទទួលខុសត្រូវចំពោះការយឺតយ៉ាវនៅក្នុងការទទួល ( មាត្រា ៥៥៩) ។ ដូច្នេះ ប្រសិនបើ អ្នកទិញ បដិសេធក្នុងការទទួលនូវការផ្តល់នូវការអនុវត្តកាតព្វកិច្ច ដោយសារកំហុសរបស់អ្នកទិញ នោះអ្នកលក់ អាចទាមទារសំណងនៃការខូចខាត និង អ្នកលក់ អាចរំលាយកិច្ចសន្យានេះ នៅក្នុងករណីដែល ការមិនទទួលយកការអនុវត្តកាតព្វកិច្ចរបស់អ្នកលក់ គឺជា ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ( មាត្រា ៥៥៩ កថាខណ្ឌទី ១) ។

ក្នុងករណីដែល កម្មវត្ថុ ត្រូវបានបាត់បង់ ឬ ខូចខាត ដោយគ្មានកំហុសរបស់អ្នកលក់ នោះ វា គឺជាបញ្ហានៃ "ការទទួលបន្ទុកហានិភ័យ" ។ នៅក្នុងករណីនេះ អ្នកទិញ ត្រូវទទួលបន្ទុកហានិភ័យចំពោះ ការខូចខាត ឬ ការបាត់បង់ ( មាត្រា ៥៥៩ កថាខណ្ឌទី ២) ។

ទន្ទឹមនឹងនេះ ក្នុងករណីដែលអ្នកលក់ បានផ្តល់នូវការសង តែអ្នកទិញ នៅតែមិនព្រមទទួលវត្ថុដែលជាកម្មវត្ថុ អ្នកលក់ អាចតំកល់ ឬ លក់វត្ថុដែលជាកម្មវត្ថុនោះ តាមបញ្ញត្តិនៃមាត្រា ៤៩៧ និង មាត្រា ៤៩៨ ( មាត្រា ៥៥៩ កថាខណ្ឌទី ៣) ។

### ៥.២ សិទ្ធិទូទៅរបស់អ្នកទិញ

អ្នកទិញ បានសិទ្ធិទាមទារអោយប្រគល់កម្មវត្ថុ ។

ក្រោយពេលដែល អ្នកទិញ បានបង់ថ្លៃទិញហើយ នោះអ្នកទិញ អាចទទួលផល ( ការបកស្រាយផ្ទុយនឹងមាត្រា ៥៥៣) ។

### ៥.៣ សិទ្ធិបដិសេធមិនបង់ថ្លៃទិញ

ក្នុងកិច្ចសន្យាលក់ទិញ ភាគីអ្នកទិញ មានករណីយកិច្ចបង់ថ្លៃទិញទៅឱ្យអ្នកលក់ ( មាត្រា ៥៥៥) ។ ក៏ប៉ុន្តែ នៅក្នុងករណីខ្លះ ភាគីអ្នកទិញ ក៏មានសិទ្ធិបដិសេធមិនបង់ថ្លៃទិញបានដែរ ។ ករណីទាំងនោះ មានដូចជា :

### ៥.៣.១ នៅក្នុងករណីដែលតតិយជន អះអាងសិទ្ធិរបស់ខ្លួនលើវត្ថុដែលជាកម្មវត្ថុនៃការលក់ទិញ

ប្រសិនបើអ្នកទិញ នឹងបាត់បង់នូវសិទ្ធិទាំងអស់ ឬ មួយភាគដែលខ្លួនបានទិញ ដោយសារតែមានតតិយជនអះអាងពីសិទ្ធិ ដូចជា កម្មសិទ្ធិ ឬ សិទ្ធិជួលអចិន្ត្រៃយ៍នៅលើកម្មវត្ថុ អ្នកទិញអាចបដិសេធមិនបង់ថ្លៃទិញទាំងអស់ ឬ មួយភាគទៅតាមសមាមាត្រនៃទំហំនៃហានិភ័យនោះ ។ ប៉ុន្តែ អ្នកទិញ មិនអាចបដិសេធមិនបង់ថ្លៃទិញ ប្រសិនបើ អ្នកលក់ បានដាក់នូវប្រាតិភោគសមរម្យទៅអោយអ្នកទិញ ។

អ្នកទិញ អាចទាមទារអោយអ្នកលក់ ត្រូវទទួលខុសត្រូវចំពោះក្នុងការធានា (ការរំលាយកិច្ចសន្យា ការបន្ថយថ្លៃទិញ ការជួសជុល ការប្រគល់វត្ថុជំនួស ការសងសំណងនៃការខូចខាត) ប្រសិនបើ តតិយជន មានសិទ្ធិដូចជាកម្មសិទ្ធិ ឬ សិទ្ធិជួលអចិន្ត្រៃយ៍លើកម្មវត្ថុនោះ។ ហើយ ថាតើ តតិយជន មានសិទ្ធិលើកម្មវត្ថុនោះ ឬ អត់ ត្រូវសំរេចដោយតុលាការ តាមនីតិវិធីគតិយុត្តិ។ ក៏ប៉ុន្តែ ប្រសិនបើ អ្នកទិញ ត្រូវបង់ប្រាក់ថ្លៃទិញបង់ប្រាក់ថ្លៃទិញ នៅមុនពេលកំណត់សិទ្ធិ នោះ វា នឹងដាក់បន្ទុកមិនសមហេតុផល ទៅលើអ្នកទិញ ព្រោះ គាត់ ត្រូវទាមទារអោយ អ្នកលក់ សងប្រាក់ថ្លៃទិញមកវិញ ដោយសារតែការរំលាយកិច្ចសន្យា ឬ បន្ថយប្រាក់ថ្លៃទិញ។ ដូច្នេះ ក្រមរដ្ឋប្បវេណី បានទទួលស្គាល់នូវសិទ្ធិបដិសេធបង់ថ្លៃទិញ តាមសមាមាត្រទៅនឹងទំហំនៃហានិភ័យ។

លក្ខខណ្ឌនៃសិទ្ធិនេះ គឺ

(ក). អត្ថិភាពនៃហានិភ័យ ដែលអ្នកទិញ នឹងអាចបាត់បង់សិទ្ធិដែលខ្លួនបានទិញ

(ខ). អ្នកលក់ ទាមទារអោយបង់ប្រាក់

(គ). អ្នកលក់ មិនបានផ្តល់នូវប្រាតិភោគសមរម្យ

"ទំហំនៃហានិភ័យ" សំដៅទៅលើ ទំហំប៉ុន្មាននៃកម្មវត្ថុ ដែលគាត់នឹងអាចបាត់បង់ មិនមែនសំដៅទៅលើហានិភ័យខ្ពស់ប៉ុន្មាន ដែលគាត់ នឹងអាចបាត់បង់សិទ្ធិនោះទេ។ ឧទាហរណ៍ នៅក្នុងករណីដែល មានតតិយជន ដែលអះអាងពីកម្មសិទ្ធិ នៅលើផ្នែកពាក់កណ្តាលនៃកម្មវត្ថុនោះ អ្នកទិញ អាចបដិសេធមិនបង់ប្រាក់ថ្លៃទិញទាំងអស់ ប្រសិនបើ គេ ទទួលស្គាល់ អ្នកទិញ នឹងមិនទិញកម្មវត្ថុ នៅពេលវា មាននៅសល់តែពាក់កណ្តាល (មាត្រា ៥៣៣ កថាខណ្ឌទី ២)។

ជាងនេះទៅទៀត សិទ្ធិបដិសេធមិនបង់ថ្លៃទិញនេះ គឺមានតួនាទីជាការតវ៉ា។ ដូច្នេះ អ្នកទិញ មិនចាំបាច់អះអាងពីសិទ្ធិនេះ រហូតដល់អ្នកលក់ ទាមទារអោយបង់ប្រាក់ថ្លៃទិញ។

## ៥.៣.២ ការតវ៉ាអោយអនុវត្តព្រមគ្នា

អ្នកទិញ អាចមិនព្រមបង់ថ្លៃទិញបាន រហូតដល់ពេលដែលអ្នកលក់ បានផ្តល់នូវការសងចំពោះកាតព្វកិច្ចរបស់ខ្លួន។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកាតព្វកិច្ចរបស់អ្នកលក់ មិនទាន់ដល់ពេលកំណត់ត្រូវសង ឬ ករណីដែលមានការព្រមព្រៀងគ្នាអំពីការអនុវត្តកាតព្វកិច្ចបង់ថ្លៃជាមុន។

## ៥.៣.៣ ការតវ៉ាដោយមានការបារម្ភ

ទោះបីជាអ្នកទិញ បានអនុញ្ញាតឱ្យអ្នកលក់មានពេលកំណត់ដើម្បីអនុវត្តកាតព្វកិច្ចក៏ដោយ ប្រសិនបើមានការបារម្ភ យ៉ាងជាក់ស្តែងថា អ្នកលក់ នឹងមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ក៏អ្នកទិញ អាចប្រកែកមិនបង់ថ្លៃទិញបានដែរ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកលក់ បានដាក់ប្រាតិភោគ ឬ ចាត់ចែងវិធានការដើម្បីរំលត់ការបារម្ភនោះ ។

ករណីសិក្សា

ក បានលក់ទូរទស្សន៍មួយគ្រឿងទៅអោយ ខ ហើយ ក បានប្រគល់ទូរទស្សន៍នៅផ្ទះរបស់ ខ នៅកាលបរិច្ឆេទ បានមកដល់។ ក៏ប៉ុន្តែ ខ អវត្តមាននៅកាលបរិច្ឆេទនោះ ព្រោះ ខ ភ្លេចថា ក នឹងមកប្រគល់ទូរទស្សន៍ ហើយក៏បានធ្វើដំណើរកំសាន្តទៅឆ្ងាយបាត់ទៅ។ បន្ទាប់មក ក បានយកទូរទស្សន៍ត្រឡប់ទៅវិញ ហើយបានទុកនៅក្នុងឃ្លាំងដែល ក បានជួលពី គ។ ហើយ ក បានបង់ប្រាក់ ១០ ដុល្លា ទៅអោយ គ សំរាប់ជាថ្លៃជួល។ តើ ក អាចទាមទារអ្វីបាន ចំពោះ ខ ?

【សេចក្តីសន្និដ្ឋាន និង មូលហេតុសំអាង】

តាមសម្មតិកម្មខាងលើនេះ យើង ឃើញថា ដោយសារតែ ខ មានការយឺតយ៉ាវក្នុងការទទួលទូរទស្សន៍ពី ក នៅកាលបរិច្ឆេទតាមកិច្ចសន្យា ដោយសារកំហុសរបស់ ខ។ ផ្ទុយទៅវិញ ក បានបង់ប្រាក់ថ្លៃជួលឃ្លាំងចំនួន ១០ ដុល្លា ទៅអោយ គ។ ដូចនេះ ក អាចទាមទារពី ខ នូវថ្លៃជួលឃ្លាំងចំនួន ១០ ដុល្លា បាន ដោយសារការយឺតយ៉ាវក្នុងការទទួលរបស់ ខ ដោយផ្អែកតាមមាត្រា ៥៥៩ កថាខណ្ឌទី១។ ក៏ប៉ុន្តែ កំហុសរបស់ ខ មិនអាចត្រូវបានចាត់ទុកថាជា ការបំពានកិច្ចសន្យាធ្ងន់ធ្ងរទេ (មាត្រា ៤០៨) ព្រោះ ក ចាំបាច់ត្រូវធ្វើការដាស់តឿនអោយ ខ ទទួលយកទូរទស្សន៍ ដោយកំណត់អំឡុងពេលសមរម្យ ដើម្បីធ្វើអោយ ខ បានបំពានកិច្ចសន្យាធ្ងន់ធ្ងរ (មាត្រា ៤០៨ កថាខណ្ឌ ទី ១ ចំណុច ក)។ ដូច្នេះ ក អាចរំលាយកិច្ចសន្យាបានតែក្នុងករណីដែល ខ មិនទទួលយកទូរទស្សន៍នោះនៅក្នុងអំឡុងពេលនោះ។

# ផ្នែកទី ៧

# ប្រទានកម្ម

## ១. គោលគំនិតនៃប្រទានកម្ម

ប្រទានកម្ម សំដៅទៅលើកិច្ចសន្យាមួយ ដែលត្រូវមានអានុភាព ដោយភាគីម្ខាង (=ទាយក) បង្ហាញឆន្ទៈផ្តល់ទៅឱ្យភាគីម្ខាងទៀត (=បដិគ្គាហក) នូវទ្រព្យសម្បត្តិដោយមិនយកថ្លៃ ហើយភាគីម្ខាងទៀត យល់ព្រមទទួល (មាត្រា ៥៦៨)។

**- កិច្ចសន្យាមិនយកតំលៃថ្នូរ**

ប្រទានកម្ម គឺជាកិច្ចសន្យាមួយប្រភេទ ដែលឧទាហរណ៍ ដូចជា ភាគីម្ខាងផ្តល់ ទូរស័ព្ទរបស់ខ្លួន ទៅឱ្យភាគីម្ខាងទៀត ដោយមិនទាមទារតាវកាលិកតប។ នេះ មានន័យថា ប្រទានកម្ម គឺជាកិច្ចសន្យាមិនយកតំលៃថ្នូរ។

**- កិច្ចសន្យាឯកតោភាគី**

ប្រទានកម្ម គឺជាកិច្ចសន្យាឯកតោភាគី ពីព្រោះ មានតែទាយក ទទួលនូវកាតព្វកិច្ចតែឯកឯង លើការប្រគល់នូវកម្មវត្ថុនៃប្រទានកម្មទៅឱ្យបដិគ្គាហក។ ចំណែកឯ បដិគ្គាហក មិនបំពេញកាតព្វកិច្ចតបទៅវិញទេ គឺគ្រាន់តែបង្ហាញឆន្ទៈយល់ព្រមទទួលនូវកម្មវត្ថុនៃប្រទានកម្មប៉ុណ្ណោះ។

**- បញ្ញត្តិនៃកិច្ចសន្យាលក់ទិញ មិនត្រូវយកមកអនុវត្ត**

បញ្ញត្តិទាក់ទងនឹងកិច្ចសន្យាលក់ទិញ មិនត្រូវយកមកអនុវត្តដូចគ្នាទេ ព្រោះ ប្រទានកម្ម គឺជាកិច្ចសន្យាដែលមិនយកតំលៃថ្នូរ មិនមែនជាកិច្ចសន្យាដែលយកតំលៃថ្នូរនោះទេ។

## ២. លក្ខខណ្ឌ

**គោលការណ៍ : ការព្រមព្រៀង**

ប្រទានកម្ម គឺជាកិច្ចសន្យា ដែលតម្រូវឱ្យមានការព្រមព្រៀងរវាងទាយក និងបដិគ្គាហក ហើយកិច្ចសន្យាប្រទានកម្មនេះ អាចត្រូវបានបង្កើតឡើងដោយគ្រាន់តែមានការព្រមព្រៀងរវាងគូភាគីប៉ុណ្ណោះ។

ក៏ប៉ុន្តែ នៅក្នុងករណីនៃកិច្ចសន្យាប្រទានកម្មអចលនវត្ថុ វា នឹងមានអានុភាព លុះត្រាតែបានធ្វើជាលិខិតយថាភូត (មាត្រា ៥៦៩, មាត្រា ៣៣៦ កថាខណ្ឌទី ២)។

## ៣. ករណីយកិច្ចរបស់ទាយក

### ៣.១ កាតព្វកិច្ចផ្ទេរសិទ្ធិ

នៅក្នុងកិច្ចសន្យាប្រទានកម្ម ទាយក មានកាតព្វកិច្ចត្រូវផ្ទេរសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃប្រទានកម្មទៅឱ្យបដិគ្គាហក ដោយមិនយកថ្លៃ (មាត្រា ៣៦៨) ។ ចំពោះ ប្រទានកម្មលើទ្រព្យសម្បត្តិ យើងឃើញថា សិទ្ធិលើទ្រព្យសម្បត្តិ ត្រូវបានផ្ទេរពីទាយកទៅបដិគ្គាហក ហើយក្នុងចំណោមសិទ្ធិលើទ្រព្យសម្បត្តិទាំងនេះ សិទ្ធិចម្បងជាងគេគឺជា**កម្មសិទ្ធិ**។ ដូចនេះ ប្រសិនបើកម្មសិទ្ធិត្រូវបានផ្ទេរ តាមរយៈប្រទានកម្ម គឺត្រូវយកមាត្រា ១៣៣ មាត្រា ១៣៤ មាត្រា ១៣៥ មាត្រា ១៦០ និង មាត្រា ១៨៧ នៃក្រមរដ្ឋប្បវេណីមកអនុវត្ត (មាត្រា ៥៦៩) ។

ឧទាហរណ៍: **ក** ធ្វើប្រទានកម្មផ្ទះមួយល្វែងទៅឱ្យ **ខ** ហើយ **ខ** យល់ព្រមទទួលនូវប្រទានកម្មនោះ ដូចនេះ កិច្ចសន្យាប្រទានកម្ម ត្រូវបានបង្កើតឡើង។ បន្ទាប់ពីកិច្ចសន្យាប្រទានកម្ម ត្រូវបានបង្កើតឡើងហើយនោះ **ក** ត្រូវមានកាតព្វកិច្ចប្រគល់សិទ្ធិនៃកម្មសិទ្ធិលើផ្ទះល្វែងនោះទៅ **ខ**។ ការប្រគល់សិទ្ធិនៃកម្មសិទ្ធិលើផ្ទះនោះ ត្រូវធ្វើដោយមានការចុះបញ្ជីត្រឹមត្រូវ។

ផ្ទុយទៅវិញ បដិគ្គាហក មិនត្រូវទទួលបន្ទុកកាតព្វកិច្ចអ្វីទេ លើកលែងតែ ប្រទានកម្មដោយមានភ្ជាប់បន្ទុក (មាត្រា ៥៧៦) ។ ដូច្នេះ គេ អាចនិយាយថា ប្រទានកម្ម គឺសកម្មភាពអនុគ្រោះ។

### ៣.២ ការបន្ថយនូវការទទួលខុសត្រូវក្នុងការធានា

ទាយក មិនត្រូវទទួលខុសត្រូវក្នុងការធានាចំពោះវិការៈនៃគុណភាពនៃវត្ថុ ដែលជាកម្មវត្ថុនៃប្រទានកម្ម ឬ វិការៈនៃសិទ្ធិនោះ ជាទូទៅឡើយ (មាត្រា ៥៧៤) ។ ចំពោះកិច្ចសន្យាប្រទានកម្ម ដែលជាកិច្ចសន្យាមិនយកតម្លៃថ្នូរ ខុសគ្នាពីកិច្ចសន្យាលក់ទិញ និង កិច្ចសន្យាផ្សេងទៀត ដែលយកតម្លៃថ្នូរ ទោះបីជាវត្ថុ ដែលជាកម្មវត្ថុនៃប្រទានកម្មមានវិការៈនៅពេលធ្វើកិច្ចសន្យាក៏ដោយ ក៏វា មិនសមរម្យដែរ ដែលដាក់បន្ទុកធ្ងន់ទៀត ទៅលើទាយកបន្ថែមពីលើបន្ទុកចំពោះការប្រគល់នូវវត្ថុ ទៅតាមស្ថានភាពបច្ចុប្បន្នរបស់វានោះ។

ក៏ប៉ុន្តែ ប្រសិនបើទាយក បានដឹងអំពីអត្ថិភាពនៃវិការៈ ឬ ការខូចនោះ ប៉ុន្តែ មិនបានផ្តល់ដំណឹង ទាយក មិនអាចរួចផុតពីការទទួលខុសត្រូវទេ (វាក្យខណ្ឌទី ២ នៃមាត្រា ៥៧៤) ។ នេះ គឺជាសញ្ញាមួយនៃ គោលការណ៍នៃភាពសុចរិត និង ស្មោះត្រង់ (មាត្រា ៥) ។ នៅក្នុងករណីនេះ គេ អាចចាត់ទុកថា វា មិនមានលក្ខណៈសមរម្យទេ ដែល ទាយក ត្រូវទទួលខុសត្រូវដូចគ្នាទៅនឹងអ្នកលក់ដែរ ព្រោះ ប្រទានកម្ម គឺជាកិច្ចសន្យាមិនយកតំលៃថ្នូរ។ ឬនិយាយម្យ៉ាងទៀត គេ អាចថា ការទទួលខុសត្រូវរបស់អ្នកទាយក ដែលធ្វើសកម្មភាពដោយទុច្ចរិត ត្រូវបានបន្ធូរបន្ថយ បើប្រៀបធៀបទៅនឹងអ្នកលក់។

## ៩. ការលុបចោលប្រទានកម្ម

### ៩.១ នៅក្នុងករណីប្រទានកម្ម ដែលមិនធ្វើជាលាយល័ក្ខណ៍អក្សរ

ដោយសារប្រទានកម្ម ទាមទារឱ្យមានតែការព្រមព្រៀងរវាងគូភាគីតែប៉ុណ្ណោះ ដូចនេះ ប្រទានកម្ម មិនត្រូវបានតម្រូវឱ្យធ្វើជាលិខិតអ្វីនោះទេ ហើយភាគច្រើន ត្រូវបានធ្វើដោយផ្ទាល់មាត់។ ប្រសិនបើភាគី មិនបានធ្វើជាលិខិតទាក់ទងប្រទានកម្ម នោះភាគីណាមួយ ក៏អាចលុបចោលកិច្ចសន្យា ដោយដកការបង្ហាញឆន្ទៈរបស់ខ្លួន (មាត្រា ៥៧០ វាក្យខណ្ឌទី ១)។ អានុភាពនៃការលុបចោល ត្រូវបង្កើតឡើងដោយឯកតោភាគី ហើយ មិនចាំបាច់មានការយល់ព្រមទេ។ គោលដៅនៃមាត្រានេះ គឺដើម្បីធ្វើការលុបចោល ដោយមានលក្ខណៈងាយស្រួល ប្រសិនបើទាយក បានអោយទ្រព្យសម្បត្តិរបស់ខ្លួន ដោយមិនបានគិតគូរជិតដល់។ ឬនិយាយម្យ៉ាងទៀត ប្រសិនបើ ឆន្ទៈរបស់ទាយក ត្រូវបានបង្ហាញតាមរូបភាពជាលាយលក្ខណ៍អក្សរ ការបង្ហាញឆន្ទៈរបៀបនេះ គឺជាលទ្ធផលនៃការវិនិច្ឆ័យដោយប្រុងប្រយ័ត្នរបស់ទាយក ហើយឆន្ទៈនោះ អាចត្រូវបានធ្វើការបញ្ជាក់យ៉ាងច្បាស់លាស់ តាមលិខិតជាលាយលក្ខណ៍អក្សរនោះ។ ដោយហេតុនេះ បដិគ្គាហក អាចបង្ខំឱ្យទាយកអនុវត្តនូវកិច្ចសន្យាប្រទានកម្មបាន ប្រសិនបើ គូភាគី បានធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរ។

ក៏ប៉ុន្តែ គូភាគី មិនអាចដកការបង្ហាញឆន្ទៈ ចំពោះផ្នែកដែលបានអនុវត្តហើយ (មាត្រា ៥៧០ វាក្យខណ្ឌទី ២)។ មូលហេតុ ដែលក្រមរដ្ឋប្បវេណីចែងអំពីបញ្ហានេះ គឺថាប្រសិនបើទាយក បានអនុវត្តកាតព្វកិច្ចរបស់ខ្លួនហើយ នោះ ឆន្ទៈរបស់ទាយកក្នុងការឱ្យទ្រព្យសម្បត្តិ បានលេចចេញឡើងកាន់តែច្បាស់។ ដូច្នេះ **"ការអនុវត្តកាតព្វកិច្ច ត្រូវបានបញ្ចប់" មិនមែនចាំបាច់មានន័យថា ទាយក បានបញ្ចប់នូវកាតព្វកិច្ចរបស់ខ្លួនទាំងអស់នោះទេ ប៉ុន្តែ គ្រាន់តែផ្នែក**ចំបងនៃកាតព្វកិច្ច ដែលត្រូវបានអនុវត្ត។ ជាទូទៅ ការផ្ទេរចលនវត្ថុ ឬ ការចុះបញ្ជីអចលនវត្ថុ ដោយគ្មានការផ្ទេរ អាចត្រូវបានចាត់ទុកថា "ការអនុវត្តកាតព្វកិច្ច ត្រូវបានបញ្ចប់"។

**ឧទាហរណ៍ : ក** សន្យាប្រគល់សៀវភៅ ១០ ក្បាល ដែលជាវត្ថុដែលមិនបានកំណត់ជាក់លាក់ទៅឱ្យ **ខ** ប៉ុន្តែពួកគេ មិនបានធ្វើជាលាយលក្ខណ៍អក្សរទេ ទាក់ទងនឹងប្រទានកម្មនេះ។ នៅក្នុងករណីដែល **ក** បានធ្វើការកំណត់សៀវភៅ ១០ ក្បាល ចេញពីសៀវភៅដទៃទៀត **ក** អាចលុបចោលកិច្ចសន្យានេះ ព្រោះ គេ មិនអាចនិយាយថា គាត់ បានបញ្ចប់នូវកាតព្វកិច្ចចំបងទេ។ ប៉ុន្តែ ប្រសិនបើ **ក** បានប្រគល់សៀវភៅ ១០ ក្បាល អោយទៅ **ខ** នោះ **ក** មិនអាចលុបចោលកិច្ចសន្យាបានទៀតទេ។

មាត្រា ៥៧០ បានប្រើពាក្យ "ភាគីនៃកិច្ចសន្យា" ដូចនេះ មានន័យថា ទាំងទាយក និង បដិគ្គាហក អាចលុបចោលកិច្ចសន្យាប្រទានកម្មបាន។ បដិគ្គាហក មានសិទ្ធិលុបចោលកិច្ចសន្យាប្រទានកម្មបាន ដោយគ្រាន់តែដកការបង្ហាញឆន្ទៈក្នុងការព្រមព្រៀងទទួលយកប្រទានកម្មនោះប៉ុណ្ណោះ។

### ៤.២ នៅក្នុងករណីនៃការរំលោភលើសេចក្ដីទុកចិត្ត ជាអាទិ៍

ជាទូទៅ ប្រទានកម្ម ត្រូវបានធ្វើឡើងរវាងគូភាគី ដែលមានទំនាក់ទំនងជាពិសេស ដូចជា ឪពុកម្ដាយ និង កូន បងប្អូន ឬ អ្នកស្គាល់គ្នាជិតស្និត។ ដោយផ្អែកទៅលើគំនិតនេះ ទាយក អាចលុបចោលប្រទានកម្ម នៅក្នុងករណីដែលបដិគ្គាហក ធ្វើអំពើរំលោភលើសេចក្ដីទុកចិត្តធ្ងន់ធ្ងរ ចំពោះទាយក (មាត្រា ៥៧១ កថាខណ្ឌទី ១)។ "អំពើរំលោភធ្ងន់ធ្ងរ" មានន័យថាជា សកម្មភាពអកត្តញ្ញូធ្ងន់ធ្ងរ ដូចជា អំពើធ្វើទុក្ខបុកម្នេញ ឬ មិនបានបំពេញករណីយកិច្ចចិញ្ចឹមទំនុបបំរុងឪពុកម្ដាយ នៅពេលដែលពួកគាត់ មិនអាចរកស៊ីចិញ្ចឹមជីវិតបាន។ ឧទាហរណ៍ ឪពុក ក បានសន្យាប្រគល់ផ្ទះទៅឱ្យកូនប្រុសរបស់ខ្លួន ខ ។ តែ ខ មិនបានបំពេញករណីយកិច្ចចិញ្ចឹមទំនុបបំរុងឪពុកម្ដាយ ហើយ តែងតែរករឿងបង្កជំលោះជាមួយ ក ដូចនេះ ក អាចលុបចោលប្រទានកផ្ទះបាន។

នៅក្នុងករណីខាងលើ ទាយក អាចលុបចោលប្រទានកម្មដែលកាតព្វកិច្ច ត្រូវបានអនុវត្តរួចរាល់ហើយ នៅក្នុងរយៈពេល ៥ ឆ្នាំ គិតពីពេលដែលកើតមានការរំលោភលើសេចក្ដីទុកចិត្តធ្ងន់ធ្ងរ ប្រសិនបើកាតព្វកិច្ច ត្រូវបានអនុវត្តរួចរាល់ហើយ ( មាត្រា ៥៧១ កថាខណ្ឌទី ២) ។

ឧទាហរណ៍ នៅក្នុងករណីខាងលើ ក មានសិទ្ធិលុបចោលប្រទានកម្មដែលបានធ្វើរួច ក្នុងអំឡុងពេល ៥ ឆ្នាំ គិតចាប់ពីដែលមាន ខ មិនបានបំពេញករណីយកិច្ចទំនុបបំរុងឪពុកម្ដាយរបស់ខ្លួន។ នៅក្រោយពេលលុបចោល ក អាចទាមទារឱ្យ ខ សងមកខ្លួន វិញនូវផ្ទះ ដែលខ្លួនបានធ្វើប្រទានកម្មនោះ តាមបញ្ញត្តិស្ដីពីការសងនៃសេចក្ដីចម្រើនដោយឥតហេតុ ( មាត្រា ៥៧៣) ។

### ៤.៣ នៅក្នុងករណីភាពទីទ័លក្ររបស់ទាយក

នៅក្នុងករណីដែល ទាយក បានបង្ហាញឆន្ទៈរបស់ខ្លួន ក្នុងការធ្វើប្រទានកម្ម ហើយ បដិគ្គាហក បានយល់ព្រមទទួលហើយ នោះ ទាយក ត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួន ព្រោះ ប្រទានកម្ម គឺជាកិច្ចសន្យា ហើយ លទ្ធិដែលមានលក្ខណៈជារូបភាព ត្រូវយកមកអនុវត្ត។

ផ្ទុយទៅវិញ ការធ្វើប្រទានកម្ម គឺសំដៅលើសកម្មភាពមិនយកកំរៃថ្នូរ ដោយផ្អែកលើសន្ដានចិត្ត ហើយ ទាយក ប្រហែលជាមិនរំពឹងទុកនូវការបំពេញកាតព្វកិច្ចតបឡើយ។ ដូច្នេះ វា មានសារសំខាន់ណាស់ក្នុងការរៀបចំអោយមានការលុបចោលប្រទានកម្ម សំរាប់ទាយក នៅក្នុងករណីដែល ទាយក បានធ្លាក់ខ្លួននៅក្នុងស្ថានភាពទីទ័លក្រ ទោះបីជាក្នុងករណីដែល ប្រទានកម្ម ត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរក៏ដោយ។ ដូច្នេះប្រសិនបើមានស្ថានភាពផ្លាស់ប្ដូរក្រោយពេលធ្វើប្រទានកម្ម នោះទាយក អាចទាមទារឱ្យយកអំណោយនោះសងត្រឡប់មកវិញ តាមបញ្ញត្តិមាត្រា ៥៧២ ។ វា មានន័យថា ទាយក អាចលុបចោលប្រទានកម្ម នៅក្នុងករណី :

ក. ទាយក ធ្លាក់ខ្លួនក្នុងស្ថានភាពទីទ័លក្រ ក្រោយការបង្ហាញឆន្ទៈធ្វើប្រទានកម្ម

និង

ខ. គ្រិតនៃភាពក្រីក្រ បានដល់គ្រិតមួយ ដែលទាយក មិនអាចរក្សាជីវភាពរស់នៅរបស់ខ្លួនផ្ទាល់ និង បុគ្គល ដែលគាត់ ត្រូវមានកាតព្វកិច្ចផ្តល់អាហារកិច្ច ។

បុគ្គល ដែលទាយក មានកាតព្វកិច្ចផ្តល់អាហារកិច្ច គឺជាធម្មតា មានចែងនៅក្នុងមាត្រា ១១៤០ ។

គោលបំណងនៃបញ្ញត្តិនេះ គឺដើម្បីជៀសវាងក្នុងការ ដែលអោយទាយកបំពេញកាតព្វកិច្ច ដោយធ្វើការលះបង់នូវជីវិតរបស់ខ្លួន ឬ បុគ្គល ដែលខ្លួនមានកាតព្វកិច្ចផ្តល់អាហារកិច្ច នៅក្នុងករណីដែល ទាយក បានធ្លាក់ទៅក្នុងករណីទីទ័លក្រ ។

នៅក្នុងករណីខាងលើ បដិគ្គាហក អាចលុបចោលប្រទានកម្ម ដែលបានអនុវត្តនៅក្នុងរយៈពេល ៥ ឆ្នាំ គិតចាប់ពីពេលដែលបានអនុវត្ត បើយោងតាមបញ្ញត្តិមាត្រា ៥៧២ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី ។

ប្រសិនបើ ទាយក បានធ្លាក់ខ្លួនទៅក្នុងស្ថានភាពទីទ័លក្រ នៅពេលធ្វើកិច្ចសន្យាប្រទានកម្ម ឬ នៅក្រោយពេលធ្វើកិច្ចសន្យា មាត្រា ៥៧២ កថាខណ្ឌទី ១ មិនត្រូវយកមកអនុវត្តឡើយ ។

### ៤.៤ អានុភាពនៃការលុបចោល

ការលុបចោលប្រទានកម្ម គឺសំដៅទៅលើសកម្មភាពរបស់ទាយក ក្នុងការទាមទារឱ្យបដិគ្គាហកសងទ្រព្យសម្បត្តិ ដែលបានធ្វើប្រទានកម្មនោះមកវិញ ដោយផ្អែកតាមបញ្ញត្តិស្តីពីការសងនៃសេចក្តីចម្រើនដោយឥតហេតុ (មាត្រា ៥៧៣) ។ ហើយនៅក្នុងករណីនៃការលុបចោលប្រទានកម្មនេះ ត្រូវយកមកអនុវត្តតាមបញ្ញត្តិមាត្រា ៥៧១ និង មាត្រា ៥៧២ នៃក្រមរដ្ឋប្បវេណី ។

## ៥. ប្រភេទពិសេសនៃប្រទានកម្ម

### ៥.១ ប្រទានកម្មដោយមានកំណត់ពេល

*ប្រទានកម្មដោយមានកំណត់ពេល* គឺសំដៅទៅលើប្រទានកម្ម ដែលទាយកផ្តល់នូវទ្រព្យសម្បត្តិជាបន្តបន្ទាប់ ។ ឧទាហរណ៍ កិច្ចសន្យាប្រទានកម្ម ដែលចែងថា ឪពុក អោយប្រាក់ ២០០ ដុល្លាទៅកូនប្រុសរបស់ខ្លួនជារៀងរាល់ខែ ។ ស្ទើតែទាំងអស់នៃប្រទានកម្មប្រភេទនេះ មានគោលដៅដើម្បីផ្គត់ផ្គង់អ្នកណាម្នាក់ ដោយផ្អែកលើទំនាក់ទំនងជាពិសេស ដូចជាឪពុកម្តាយ និង កូន ។

ប្រទានកម្មដោយមានកំណត់ពេល ត្រូវបាត់បង់អានុភាពដោយមរណភាពរបស់ទាយក ឬ បដិគ្គាហក (មាត្រា ៥៧៥) ។ ជាទូទៅ សន្តតិជន ត្រូវទទួលបន្តនូវសិទ្ធិ និង ករណីយកិច្ចទាំងអស់ ដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជន (មាត្រា ១១៤៧ កថាខណ្ឌទី ១) ។ ក៏ប៉ុន្តែ នៅក្នុងករណី ប្រទានកម្មដោយមានកំណត់ពេល វា មានលក្ខណៈត្រឹមត្រូវ ដែលគ្មានបុគ្គលណាម្នាក់ ត្រូវទទួលបន្តនូវសិទ្ធិ និង កាតព្វកិច្ច ទាក់ទងនឹងប្រទានកម្មដោយមានកំណត់ពេល ប្រសិនបើ មានភាគីណាម្ខាង ទទួលមរណភាព ។ ឧទាហរណ៍ នៅក្នុងករណីខាងលើ ប្រសិនបើ ឪពុក ទទួលមរណភាព សន្តតិជនដទៃទៀត ដូចជា ប្រពន្ធរបស់មតកជន ឬ បងប្អូនរបស់ទាយក មិនត្រូវទទួល

បន្តនូវកាតព្វកិច្ចនៃប្រទានកម្មដោយមានកំណត់ពេលឡើយ។ មូលហេតុ គឺថា ប្រទានដោយមានកំណត់ពេល គឺជាទូទៅ ត្រូវបានបង្កើតឡើង ដោយផ្អែកលើទំនាក់ទំនងជាពិសេសរវាង ទាយក និង បដិគ្គាហក ដូចដែលបានរៀបរាប់ខាងលើ ដូច្នេះ វា អាចត្រូវបានគេចាត់ទុកថា ការបាត់បង់អានុភាពនៃប្រទានកម្ម នៅក្នុងករណីនៃមរណភាពរបស់ទាយក ឬ បដិគ្គាហក ត្រូវបានបំពេញនូវឆន្ទៈរបស់ភាគី។

## ៥.២ ប្រទានកម្មដែលមានភ្ជាប់បន្ទុក

*ប្រទានកម្មដែលមានភ្ជាប់បន្ទុក* គឺសំដៅទៅលើប្រទានកម្ម ដែលបដិគ្គាហក ត្រូវអនុវត្តកាតព្វកិច្ចជាកំណត់ជាក់លាក់ណាមួយ ដើម្បីទទួលបាននូវប្រទានកម្ម។ "បន្ទុក" ដែលបដិគ្គាហក ត្រូវអនុវត្ត នៅក្នុងករណីនៃប្រទានកម្មដោយមានភ្ជាប់បន្ទុក មិនមានតំលៃស្មើនឹងកាតព្វកិច្ចរបស់ទាយកឡើយ ព្រោះ ប្រទានកម្មដែលមានភ្ជាប់បន្ទុក គឺកិច្ចសន្យាដែលមិនយកតំលៃថ្នូរ។ ឧទាហរណ៍ នៅក្នុងករណីដែល ក និង ខ បានបង្កើតកិច្ចព្រមព្រៀងគ្នាថា ក ត្រូវអោយផ្ទះរបស់ខ្លួនទៅ ខ ជាថ្នូរនឹងការអនុញ្ញាតរបស់ ខ អោយកូនប្រុសរបស់ ក រស់នៅក្នុងផ្ទះនោះ ដែលនេះ គឺជាប្រទានកម្មដោយមានភ្ជាប់បន្ទុក។

ប្រសិនបើ បន្ទុក មានតំលៃស្មើនឹងកាតព្វកិច្ចរបស់ទាយក នោះ វា គឺជាកិច្ចសន្យា ដែលយកតំលៃថ្នូរ ដូចជា កិច្ចសន្យាលក់ទិញ ជាអាទិ៍។

ផ្ទុយទៅវិញ នៅក្នុងករណីនៃ ប្រទានកម្មដែលមានភ្ជាប់បន្ទុក ភាគីទាំងពីរ ត្រូវទទួលបន្ទុកនូវករណីយកិច្ចក្នុងការផ្ដល់តាវកាលិក ហេតុដូចនេះ ភាគីទាំងពីរ ត្រូវមានសិទ្ធិ និង ការទទួលខុសត្រូវ ស្រដៀងគ្នាទៅនឹងបញ្ញត្តិដែលទាក់ទងនឹងកិច្ចសន្យាលក់ទិញ។

### ១. ការទទួលខុសក្នុងការធានា ( មាត្រា ៥៧៦ កថាខណ្ឌទី ២)

នៅក្នុងករណីនៃប្រទានកម្មដែលមានភ្ជាប់បន្ទុក ទាយក ត្រូវទទួលខុសត្រូវក្នុងការធានា ដូចអ្នកលក់ នៅក្នុងទំហំនៃបន្ទុក។ ឧទាហរណ៍ ឪពុក ក បានបង្កើតកិច្ចព្រមព្រៀងជាមួយនឹងកូនរបស់គាត់ ខ ថា ក ត្រូវអោយដីរបស់ខ្លួន ដែលមានតំលៃ ១០,០០០ ដុល្លា ជាថ្នូរនឹង ខ ត្រូវអោយប្រាក់ ៣,០០០ ដុល្លា សំរាប់ការចំណាយក្នុងការរស់នៅរបស់ ក។ ក្រោយមក គេ បានដឹងថា ដីនោះ គឺជាកម្មសិទ្ធិអវិភាគរបស់ ក និង បងប្រុសរបស់ខ្លួន គ ហើយចំណែករបស់ ក មានតែ មួយ ភាគ បួន តែប៉ុណ្ណោះ ( វា មានន័យថា តំលៃនៃចំណែករបស់ ក គឺមានតែ ២៥០០ ដុល្លា តែប៉ុណ្ណោះ) ។ នៅក្នុងករណីនេះ តំលៃនៃបន្ទុករបស់ ខ គឺធំជាងតំលៃនៃកម្មវត្ថុនៃប្រទានកម្មដែលមានភ្ជាប់បន្ទុកទៀត។ ដូច្នេះ ដោយផ្អែកលើមាត្រា ៥៧៦ កថាខណ្ឌទី ២ ខ អាចបដិសេធក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួននៅក្នុងទំហំនៃតំលៃដែលលើស ប្រសិនបើគាត់ មិនទាន់បានអនុវត្តនូវបន្ទុករបស់ខ្លួន នៅឡើយទេ ដូច្នេះ ខ អាចបដិសេធក្នុងការបង់ប្រាក់ចំនួន ៥០០ ដុល្លា។ ប្រសិនបើ គាត់ បានអនុវត្តបន្ទុករបស់ខ្លួនរួចរាល់ហើយ គាត់ អាចទាមទារអោយ ក សងប្រាក់ ៥០០ ដុល្លា មកវិញ ដែលជាសេចក្ដីចំរើនឥតហេតុ។

## ២. សិទ្ធិទាមទារអោយផ្តល់តាវកាលិក ( មាត្រា ៥៧៦ កថាខណ្ឌទី ៣)

ប្រសិនបើភាគីម្ខាង បានផ្តល់តាវកាលិកហើយ នោះ គាត់ មានសិទ្ធិទាមទារចំពោះ ភាគីម្ខាងទៀត អោយផ្តល់តាវកាលិកបាន។ នៅក្នុងប្រទានកម្មទូទៅ មានតែ ទាយកទេ ដែលត្រូវអនុវត្តកាតព្វកិច្ច ហើយ គេ សន្មតថា ទាយក មិនអាចទាមទារអ្វីបានទាំងអស់ពីបដិគ្គាហក។ ក៏ប៉ុន្តែ នៅក្នុងករណីនៃប្រទានកម្មដែលមានភ្ជាប់បន្ទុក ទាយក អាចទាមទារអោយ បដិគ្គាហក ត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួន ប្រសិនបើ ទាយក បានអនុវត្តកាតព្វកិច្ចរបស់ខ្លួនរួចរាល់ហើយ។

## ៣. ការតវ៉ាអោយអនុវត្តព្រមគ្នា ( មាត្រា ៥៧៦ កថាខណ្ឌទី ៤)

ជាទូទៅ ការតវ៉ាអោយអនុវត្តព្រមគ្នា ត្រូវបានទទួលស្គាល់នៅក្នុងកិច្ចសន្យាទ្វេភាគី ( មាត្រា ៣៨៦) ។ ក៏ប៉ុន្តែ ភាគីនៃប្រទានកម្មដែលមានភ្ជាប់បន្ទុក មានការតវ៉ាអោយអនុវត្តព្រមគ្នា ព្រោះភាគីទាំងពីរ មានករណីយកិច្ចផ្តល់តាវកាលិក ហើយ វា ស្រដៀងគ្នាទៅនឹងកិច្ចសន្យាទ្វេភាគី។

## ៤. សិទ្ធិរំលាយកិច្ចសន្យារបស់ទាយក ( មាត្រា ៥៧៦ កថាខណ្ឌទី ៥)

ជាទូទៅ សិទ្ធិរំលាយ ត្រូវបានទាញចេញពីលក្ខណៈនៃតំលៃសមមូលនៃកិច្ចសន្យាទ្វេភាគី។ ក៏ប៉ុន្តែ នៅក្នុងករណីដែល បដិគ្គាហក មិនអនុវត្តបន្ទុករបស់ខ្លួន ទាយក អាចរំលាយកិច្ចសន្យាប្រទានកម្ម ដោយផ្អែកលើបញ្ញត្តិទាក់ទងនឹងការរំលាយ។ ឬនិយាយម្យ៉ាងទៀត ទាយក អាចរំលាយកិច្ចសន្យាបាន តែក្នុងករណីដែលការមិនអនុវត្តកាតព្វកិច្ចរបស់បដិគ្គាហក ចាត់ចូលជា "ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ"។ ឧទាហរណ៍ ឪពុក **ក** បានផ្តល់ដីមួយកន្លែងអោយទៅកូនប្រុសរបស់ខ្លួន **ខ** ដោយតាមលក្ខខណ្ឌថា **ខ** ត្រូវរស់នៅជាមួយនឹង **ក** ប៉ុន្តែ **ខ** បដិសេធ ក្រោយពីការចុះបញ្ជី។ នៅក្នុងករណីនេះ **ក** អាចរំលាយកិច្ចសន្យាប្រទានកម្ម ព្រោះ ការមិនអនុវត្តកាតព្វកិច្ចរបស់ **ខ** អាចត្រូវបានចាត់ទុកថាជា "ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ"។

## ៥.៣ ប្រទានកម្មដោយមូលហេតុមរណភាពរបស់ទាយក

ប្រទានកម្មដោយមូលហេតុមរណភាពរបស់ទាយក សំដៅទៅលើប្រទានកម្ម ដែលយកមរណភាពរបស់ទាយកជាល័ក្ខខណ្ឌ ដើម្បីបង្កើតអានុភាព។ បញ្ញត្តិទាក់ទងនឹងអច្ច័យទាន ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអានុភាពនៃប្រទានកម្មដោយមូលហេតុមរណភាព ( មាត្រា ៥៧៧ កថាខណ្ឌទី ២) ។

អច្ច័យទាន ( មាត្រា ១១៩៥) គឺជាប្រទានកម្ម ដែលម្ចាស់បណ្តាំអោយនូវទ្រព្យសម្បត្តិរបស់ខ្លួន តាមរយៈមតកសាសន៍។ មតកសាសន៍ នឹងបង្កើតអានុភាព ចាប់ពីពេលដែលម្ចាស់បណ្តាំ បានទទួលមរណភាព ( មាត្រា ១១៩៤ កថាខណ្ឌទី ១) ។ ដូច្នេះ ប្រទានកម្មដោយមូលហេតុមរណភាពរបស់ទាយក និង អច្ច័យទាន មានលក្ខណៈដូចគ្នា គឺថា វា មានអានុភាព ចាប់ពីពេលមរណភាពរបស់ម្ចាស់បណ្តាំ។

ក៏ប៉ុន្តែ នៅក្នុងករណីនៃប្រទានកម្មដោយមូលហេតុមរណភាពរបស់ទាយក ការព្រមព្រៀងរវាងទាយក និង បដិគ្គាហក គឺត្រូវឱ្យមានដើម្បីបង្កើតប្រទានកម្មនេះ ព្រោះ វា គឺជាកិច្ចសន្យា។ ផ្ទុយទៅវិញ ការព្រមព្រៀង គឺមិនតម្រូវអោយមានទេ នៅក្នុងករណីនៃអច្ច័យទាន ព្រោះ វា គឺជាសកម្មភាពឯកតោភាគី។ ជាងនេះទៅទៀត បញ្ញត្តិទាក់ទងនឹង ការបោះបង់ (មាត្រា ១២០១) ឬ ការទទួលស្គាល់ (មាត្រា ១២០២ និង ១២០៣) មិនត្រូវយកមកអនុវត្តដូចគ្នា ចំពោះប្រទានកម្មដោយមូលហេតុមរណភាពរបស់ទាយកឡើយ ព្រោះ វា មិនអាចទទួលស្គាល់នូវការអនុវត្តបញ្ញត្តិទាំងនេះ។

**ករណីសិក្សា**

ឪពុកម្តាយ បានអោយដីមួយកន្លែងទៅកូនប្រុសរបស់ខ្លួន ហើយ បន្ទាប់មកកូនប្រុសនោះ បានសាងសង់ផ្ទះនៅលើដីនោះ។ ការផ្ទេរកម្មសិទ្ធិ ត្រូវបានចុះបញ្ជី។ ក្រោយមក ឪពុកម្តាយ ទាមទារអោយប្រគល់ដីត្រឡប់មកវិញ ព្រោះ ពួកគាត់ បានខឹងនឹងកូនប្រុសនោះ។ តើឪពុកម្តាយ អាចលុបចោលប្រទានកម្ម បានដែរ ឬ ទេ?

(១) នៅក្នុងករណីដែល ឪពុកម្តាយ ខឹងជាមួយនឹងកូនប្រុសរបស់ខ្លួន ព្រោះ កូនប្រុសនោះ តែងតែផ្លាស់ប្តូរការងារពីមួយកន្លែង ទៅមួយកន្លែងទៀត។

(២) នៅក្នុងករណីដែល ឪពុកម្តាយ ខឹងជាមួយនឹងកូនប្រុសរបស់ខ្លួន ព្រោះ ឪពុកម្តាយ បានអោយដីនោះ ជាមួយនឹងការសន្យាថា កូនប្រុសរបស់គាត់ នឹងត្រូវមើលថែរក្សាពួកគាត់។ ប៉ុន្តែ កូនប្រុសរបស់គាត់ បានបដិសេធមិនព្រមចិញ្ចឹម និង ថែរក្សាពួកគាត់ទេ។

【សេចក្តីសន្និដ្ឋាន និង មូលហេតុសំអាង】

ជាគោលការណ៍ ការផ្ទេរកម្មសិទ្ធិនៃអចលនវត្ថុ តាមរយៈកិច្ចសន្យាប្រទានកម្ម ត្រូវអនុលោម មាត្រា ១៣៥ (មាត្រា ៥៦៨)។ ដូច្នេះ ការផ្ទេរកម្មសិទ្ធិ ត្រូវបង្កើតអានុភាព នៅពេលដែលការផ្ទេរកម្មសិទ្ធិនោះ ត្រូវបានចុះបញ្ជី។ នៅក្នុងករណីនេះ ការចុះបញ្ជី ត្រូវបានធ្វើរួចរាល់ហើយ។

(១) ឪពុកម្តាយ មិនអាចលុបចោលប្រទានកម្មបានទេ។

នៅក្នុងករណីទី ១ នេះ ឪពុកម្តាយ ខឹងនឹងកូនប្រុសរបស់គាត់ គ្រាន់តែដោយសារតែមូលហេតុ ដែលកូនប្រុសរបស់គាត់ ឧស្សាហ៍ផ្លាស់ប្តូរការងារពីកន្លែងមួយទៅកន្លែងមួយទៀត។ ហើយ វា ក៏មិនមានលក្ខខណ្ឌក្នុងការអោយដីនោះដែរ ដូច្នេះ ពួកគាត់ មិនអាចលុបចោលប្រទានកម្មនេះបានទេ ដោយផ្អែកលើមាត្រា ៥៧១។

(២) ឪពុកម្តាយ អាចលុបចោល ឬ រំលាយកិច្ចសន្យាប្រទានកម្មបាន។

នៅក្នុងករណីទី ២ នេះ គឺមានមធ្យោបាយពីរ ដែលអាចធ្វើទៅបាន។ ប្រសិនបើ សកម្មភាពរបស់កូនប្រុសនោះ ត្រូវគ្នានឹងមាត្រា ៥៧១ នោះ ពួកគាត់ អាចលុបចោលប្រទានកម្មបាន។ ដូចដែលបានរៀបរាប់ ដើម្បីទទួលស្គាល់នូវ "ការបំពានធ្ងន់ធ្ងរ" វា មិនទាន់គ្រប់គ្រាន់ទេ ដែលគ្រាន់តែបដិគ្គាហក ប្រឆាំងនឹងឆន្ទៈរបស់ទាយកលុះត្រាតែ បដិគ្គាហក ប្រព្រឹត្តអំពើអកត្តញ្ញូធ្ងន់ធ្ងរ។ នៅក្នុងករណីទី ២ គេ អាចចាត់ទុកថា ឪពុកម្តាយ រំពឹងទុកនូវការចិញ្ចឹម និង ការមើលថែរក្សា ពីកូនប្រុសរបស់ពួកគាត់ ហើយ កូនប្រុសរបស់គាត់ ក៏បានដឹងអំពីចំណុចនេះដែរ។ ដូច្នេះ ការមិនអនុវត្តករណីយកិច្ចចិញ្ចឹម និង មើលថែរក្សាពួកគាត់ ត្រូវបានចាត់ទុកថា គឺជាការបំពានយ៉ាងធ្ងន់ធ្ងរទៅលើទំនុកចិត្តរបស់ឪពុកម្តាយ។

គំនិតដែលអាចគិតបានមួយផ្សេងទៀត គឺថា ករណីយកិច្ចក្នុងការចិញ្ចឹម និង មើលថែរក្សា គឺជាបន្ទុកនៅក្នុងប្រទានកម្មដែលមានភ្ជាប់បន្ទុក។ ប្រសិនបើ បដិគ្គាហក មិនអនុវត្តករណីយកិច្ចរបស់ខ្លួនទេ នោះ គេនឹងចាត់ទុកថា វា គឺជាការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ហើយ ឪពុកម្តាយ អាចរំលាយកិច្ចសន្យាប្រទានកម្មបាន (មាត្រា ៥៧៦ កថាខណ្ឌទី ៥)។ នៅក្នុងករណីនេះ កូនប្រុស បានសន្យាថា នឹងចិញ្ចឹម និង មើលថែរក្សាពួកគាត់ ប៉ុន្តែ កូនប្រុសនោះ បែរជាបដិសេធមិនអនុវត្តករណីយកិច្ចរបស់ខ្លួនទៅវិញ ហើយ ដែលជាទូទៅ វា ត្រូវបានចាត់ទុកថាជា ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ។ ដូច្នេះ ឪពុកម្តាយ អាចរំលាយកិច្ចសន្យាប្រទានកម្ម ដោយផ្អែកលើបញ្ញត្តិទាក់ទងនឹងការរំលាយកិច្ចសន្យា។

# ផ្នែកទី ៤

# ភតិសន្យា

## ១. គោលគំនិតនៃភតិសន្យា

### ១.១ និយមន័យ

ភតិសន្យា សំដៅទៅលើកិច្ចសន្យាដែលភាគីម្ខាង អនុញ្ញាតអោយភាគីម្ខាងទៀត ប្រើប្រាស់ និង អាស្រ័យផលពីវត្ថុណាមួយ ដោយយកថ្លៃ ( មាត្រា ៥៩៦) ។ ភតិបតី មិនចាំបាច់ត្រូវតែមានកម្មសិទ្ធិនោះទេ ប៉ុន្តែ គ្រាន់តែមានសិទ្ធិប្រើ និង អាស្រ័យផល ។ ឧទាហរណ៍ អ្នកជួលអចិន្ត្រៃយ៍ ម្ចាស់សិទ្ធិផលុបភោគ ឬ ភតិកៈ អាចជួលបន្តនូវកម្មវត្ថុនោះបាន ដោយស្ថិតនៅក្រោមលក្ខខណ្ឌកំណត់ជាក់លាក់ ( មាត្រា ២៥២ កថាខណ្ឌទី ២ មាត្រា ២៦៤ និង មាត្រា ៦០៨ កថាខណ្ឌទី ១) ។

### ១.២ លក្ខខណ្ឌ

ភតិសន្យា ត្រូវបានបង្កើតឡើងដោយការព្រមព្រៀងរវាងគូភាគី ។ ការធ្វើជាលាយលក្ខណ៍អក្សរ មិនតម្រូវអោយមាននោះទេ ។

ទោះបីជាភាគី មិនបានកំណត់ពីអំឡុងពេលនៃការជួលក៏ដោយ ក៏កិច្ចសន្យានោះ នៅតែមានសុពលភាព ។ ក៏ប៉ុន្តែ ការកំណត់តំលៃឈ្នួល គឺតម្រូវអោយមាន ។

### ១.៣ លក្ខខណ្ឌតទាំង

ភតិបតី មានកម្មសិទ្ធិនៅលើកម្មវត្ថុនៃការជួល ដូច្នេះ ភតិបតី អាចធ្វើអនុប្បទានកម្មវត្ថុនៃការជួលបាន ។ ម្ចាស់កម្មសិទ្ធិថ្មី ត្រូវទទួលបាននូវកម្មសិទ្ធិ ហើយ អាចអះអាងពីកម្មសិទ្ធិរបស់ខ្លួនបាន ចំពោះគ្រប់បុគ្គលទាំងអស់ ។ ផ្ទុយទៅវិញ ភតិសន្យា គឺជាគ្រាន់តែកិច្ចសន្យា ដែលភតិកៈ អាចអះអាងពីសិទ្ធិប្រើប្រាស់ និង អាស្រ័យផលរបស់ខ្លួន បានចំពោះតែភតិបតីប៉ុណ្ណោះ ។ ដូច្នេះ ប្រសិនបើ ម្ចាស់កម្មសិទ្ធិថ្មី ទាមទារអោយភតិកៈប្រគល់មកវិញនូវកម្មវត្ថុនៃកិច្ចសន្យា នោះជាទូទៅ ភតិកៈ ត្រូវតែប្រគល់ត្រឡប់ទៅវិញ ។

ក៏ប៉ុន្តែ វា នឹងធ្វើឱ្យភតិកៈស្ថិតនៅក្នុងស្ថានភាពដែលចាញ់ប្រៀប ឬ ខូចខាតផលប្រយោជន៍ ជាពិសេសក្នុងករណីនៃភតិសន្យាអចលនវត្ថុ ។ ដូច្នេះ ក្រមរដ្ឋប្បវេណី បានបញ្ញត្តិថា នៅក្នុងករណីនៃភតិសន្យាអចលនវត្ថុ ភតិកៈ អាចអះអាងពីសិទ្ធិរបស់ខ្លួន ទាក់ទងនឹងភតិសន្យា ចំពោះជនដែលធ្វើលទ្ធកម្មបន្តនូវសិទ្ធិប្រត្យក្សលើអចលនវត្ថុនោះបាន ដោយផ្អែកទៅលើអង្គហេតុថា ភតិកៈ បានកាន់កាប់ និង ប្រើប្រាស់ និង អាស្រ័យផលពីអចលនវត្ថុជួលនោះ ជាបន្តបន្ទាប់ ( មាត្រា ៥៩៨ កថាខណ្ឌទី ១) ។

### ១.៩ អំឡុងពេលជួល

អំឡុងពេលជួល អាចត្រូវបានកំណត់ដោយកិច្ចសន្យា។ ប្រសិនបើគ្មានអំឡុងពេល ត្រូវបានកំណត់នៅក្នុងកិច្ចសន្យាទេ នោះវា ត្រូវបានចាត់ទុកថាជាភតិសន្យា ដែលមិនកំណត់អំឡុងពេល។ ហើយម្យ៉ាងទៀត ចំពោះភតិសន្យាអចលនវត្ថុ ដែលមិនបានធ្វើជាលាយលក្ខណ៍អក្សរ ត្រូវបានចាត់ទុកថាជា ភតិសន្យាដែលគ្មានកំណត់អំឡុងពេល ( មាត្រា ៥៩៩ កថាខណ្ឌទី ២) ។

## ២. សិទ្ធិ និង ករណីយកិច្ចរបស់ភតិបតី

### ២.១ ករណីយកិច្ចធ្វើអោយភតិកៈប្រើប្រាស់ និង អាស្រ័យផល ដោយផ្អែកវិធីប្រើប្រាស់ធម្មតា

ភតិកៈ មានសិទ្ធិក្នុងការប្រើប្រាស់ និង អាស្រ័យផល ដោយផ្អែកទៅតាមវិធីប្រើប្រាស់ជាធម្មតា ( មាត្រា ៦០០ កថាខណ្ឌទី ១) ។ ផ្ទុយទៅវិញ ភតិបតី មិនត្រូវរាំងស្ទះក្នុងការប្រើប្រាស់ និង អាស្រ័យផល ដែលភតិកៈធ្វើឡើង ដោយផ្អែកតាមវិធីប្រើប្រាស់ធម្មតា។ ករណីយកិច្ចក្នុងការជួសជុលរបស់ភតិបតី ( មាត្រា ៦០២) ក៏ត្រូវបានទាញចេញពីគំនិតនេះដែរ។

### ២.២ ករណីយកិច្ចជួសជុល

ភតិបតី ត្រូវឱ្យធ្វើការជួសជុល ដូច្នេះ ភតិកៈ អាចប្រើប្រាស់ និង អាស្រ័យផលពីវត្ថុជួលបាន។ ឧទាហរណ៍ នៅក្នុងករណី ដែលផ្នែកមួយនៃកំរាលឥដ្ឋនៅក្នុងផ្ទះជួល បានខូចខាត ភតិបតី មិនចាំបាច់ជួសជុលទេ ប្រសិនបើភតិកៈ អាចរស់នៅក្នុងផ្ទះនោះបាន ជាធម្មតា។ ប៉ុន្តែផ្ទុយមកវិញ ប្រសិននៅក្នុងផ្ទះជួលនោះ មានលិចទឹកពីពិដាន នោះភតិបតី ត្រូវមានករណីយកិច្ចជួសជុល ទោះបីវាជាផ្នែកមួយនៃពិដានក៏ដោយ ព្រោះជាធម្មតា វា គឺជាឧបសគ្គក្នុងការរាំងស្ទះនូវការស្នាក់នៅ នៅក្នុងផ្ទះនោះ។

នៅក្នុងករណីខ្លះ ដើម្បីកំណត់ថាតើ ការខូចខាត ឆ្លើយតបទៅនឹង "ចាំបាច់សំរាប់ប្រើប្រាស់ និង អាស្រ័យផល" ឬអត់ គឺមានលក្ខណៈពិបាក។ ឧទាហរណ៍ នៅក្នុងករណីដែល **ក** ជួលផ្ទះចាស់បាក់បែកមួយទៅអោយ **ខ** ដោយយកតំលៃទាប ហើយ ការដាក់បន្ទុកអោយជួសជុលនូវគ្រប់ផ្នែក ដែលបានខូចខាត គឺមានលក្ខណៈតឹងតែងបំផុតចំពោះភតិបតី។ នៅក្នុងករណីនេះ ថាតើភតិបតី ត្រូវមានករណីយកិច្ចជួសជុល ឬ អត់ ត្រូវបានសំរេចដោយធ្វើការពិចារណាទៅលើអង្គហេតុ ដែលថា គឺមានលក្ខណៈសមរម្យ ឬ អត់ ក្នុងការអោយទទួលខុសត្រូវចំពោះការជួសជុល។

ការព្រមព្រៀងគ្នាពិសេស ដែលចែងថា ភតិកៈ ត្រូវមានករណីយកិច្ចជួសជុល គឺមានសុពលភាព ព្រោះមាត្រា ៦០២ គឺជាបញ្ញត្តិតាមការស្ម័គ្រចិត្ត។

ជាងនេះទៅទៀត ភតិក: មិនត្រូវបង្កជាឧបសគ្គ ឬ រារាំងដល់សកម្មភាពរបស់ភតិបតី ដែលចាំបាច់ក្នុងការថែរក្សាវត្ថុជួលនោះទេ ( មាត្រា ៦០៣) ។ វត្ថុជួល គឺជាកម្មសិទ្ធិរបស់ភតិបតី ហើយ ភតិបតី មានសិទ្ធិថែរក្សាវា ដោយរាប់បញ្ចូលទាំងការជួសជុលផងដែរ ។ ឧទាហរណ៍ នៅក្នុងករណីដែល ភតិបតី បានជួលជុលពិដាន ដែលលិចទឹក នៅក្នុងបន្ទប់មួយនៅក្នុងផ្ទះល្វែង (អាផាតមែន) ដែលជួល នោះ ភតិក: មិនអាចបដិសេធការជួសជុលនេះបានទេ ទោះបីជាគាត់ មិនអាចប្រើប្រាស់បន្ទប់នោះ បាននៅក្នុងរយៈពេលជួសជុលក៏ដោយ ។ ក៏ប៉ុន្តែប្រសិនបើ ភតិក: មិនអាចសំរេចនូវគោលបំណងនៃភតិសន្យា ដោយសារ ការជួសជុលនោះ ឧទាហរណ៍ដូចជា នៅក្នុងករណីខាងលើ ផ្ទះល្វែង (អាផាតមែន) នោះ មានតែមួយបន្ទប់ នោះ ភតិក: អាចទាមទារឱ្យបន្ថយថ្លៃឈ្នួល ឬ រំលាយកិច្ចសន្យាបាន ( មាត្រា ៦០៣ កថាខណ្ឌទី ២ ឃ្លាខាងក្រោយ) ។

## ២.៣ ករណីយកិច្ចសងវិញនូវសោហ៊ុយចំណាយ

### ២.៣.១ ករណីយកិច្ចសងនូវសោហ៊ុយចំណាយចាំបាច់

មាត្រា ៦០៤ កថាខណ្ឌទី ១ បានបញ្ញត្តិថា ប្រសិនបើ ភតិក: បានចេញនូវសោហ៊ុយចំណាយចាំបាច់ ដែលគួរជាបន្ទុករបស់ភតិបតី នោះ ភតិក: អាចទាមទារអោយសងវិញជាបន្ទាន់ពីភតិបតី ។ ឧទាហរណ៍ ការចំណាយជួសជុលវត្ថុជួល ដែលភតិបតីត្រូវទទួលបន្ទុក ត្រូវបានរាប់បញ្ចូលទាំង "សោហ៊ុយចាំបាច់" ផងដែរ ។ ហើយ ការចំណាយដែលក្រៅពីការជួសជុល អាចត្រូវបានចាត់បញ្ចូលទៅក្នុងការចំណាយចាំបាច់ ព្រោះ ភតិបតី មានកាតព្វកិច្ចក្នុងការធ្វើអោយភតិក: អាចប្រើប្រាស់ និង អាស្រ័យផលពីវត្ថុជួល ។ ឧទាហរណ៍ ប្រសិនបើ ជណ្តើរនៅខាងមុខបន្ទប់ជួល មានការខូចខាត នោះ ភតិបតី ត្រូវមានករណីយកិច្ចជួលជុលវា ទោះបីវា មិនមែនជាវត្ថុជួលនោះផ្ទាល់ក៏ដោយ ។ ហើយ ប្រសិនបើ ភតិក: បានជួសជុលវាហើយ នោះ ភតិបតី ត្រូវមានករណីយកិច្ចសងនូវថ្លៃចំណាយដែលជាសោហ៊ុយចាំបាច់ ។

ពាក្យថា "ជាបន្ទាន់" មានន័យថា ពេលជាមួយនឹងការចំណាយនៃថ្លៃឈ្នួលចាំបាច់ ។

### ២.៣.២ ករណីយកិច្ចសងសោហ៊ុយដែលបង្កើនតំលៃ

នៅពេលខ្លះ ភតិក: បានកែលំអវត្ថុជួលនៅក្នុងអំឡុងពេលជួល ។ ភតិក: មានកាតព្វកិច្ចក្នុងការធ្វើបដិទាននៃវត្ថុជួលទៅស្ថានភាពដើមវិញ ហើយ ប្រគល់នូវវត្ថុជួលនោះទៅអោយភតិបតីវិញ នៅចុងបញ្ចប់នៃភតិសន្យា ( មាត្រា ៦១៨ កថាខណ្ឌទី ១) ។ នៅក្នុងន័យម្យ៉ាងទៀត ភតិក: ត្រូវដកចេញនូវរាល់វត្ថុ ដែលខ្លួនបានភ្ជាប់ទៅនឹងវត្ថុជួល ។ ក៏ប៉ុន្តែ ការដកចេញនូវផ្នែកទាំងអស់នោះ អាចធ្វើអោយបាត់បង់នូវតំលៃជាសេដ្ឋកិច្ចបាន ។ ផ្ទុយទៅវិញ ប្រសិនបើ ភតិបតី អាចទទួលបាននូវផលប្រយោជន៍ទាំងអស់ តាមរយៈការកែលំអនោះ វា ក៏ផ្ទុយនឹងគោលការណ៍នៃសមភាព ។

ដូច្នេះ មាត្រា ៦០៤ កថាខណ្ឌទី ២ បានបញ្ញត្តិថា ភតិក: អាចទាមទារអោយសងវិញ នូវសោហ៊ុយដើម្បីបង្កើនតំលៃ

(i) ដរាបណា ការបង្កើនតំលៃនៃវត្ថុជួលនោះនៅតែមាន

(ii) នៅចុងបញ្ចប់នៃភតិសន្យា

(iii) ផ្អែកតាមការជ្រើសរើសរបស់ភតិបតីនូវចំនួនប្រាក់ ដែលបានចំណាយពិតប្រាកដ ឬ តំលៃដែលកើននោះ។

ឧទាហរណ៍ ប្រសិនបើ ភតិក: បានតំឡើងនូវម៉ាស៊ីនត្រជាក់ ដែលជាប់ក្នុងជញ្ជាំង តំលៃ ១០០០ ដុល្លា ហើយ តំលៃនៃអាគារនោះ បានកើន ៥០០ ដុល្លាបន្ថែមទៀត នៅពេលបញ្ចប់ភតិសន្យា នោះ ភតិបតី អាចបង់ប្រាក់ ៥០០ ដុល្លា ហើយ រួចផុតពីករណីយកិច្ចនេះ ដោយជំរើសរបស់ខ្លួន។ ផ្ទុយទៅវិញ ប្រសិនបើ តំលៃនៃអាគារជួល បានកើន ១,២០០ ដុល្លា នៅក្នុងករណីដដែលខាងលើនេះ ភតិបតី អាចបង់ប្រាក់ ១,០០០ ដុល្លា តាមជំរើសរបស់គាត់ផងដែរ។

ប្រសិនបើភតិបតី ត្រូវទទួលបន្ទុកសងនូងសោហ៊ុយដើម្បីបង្កើនតំលៃ នោះ ភតិក: អាចអះអាងនូវសិទ្ធិឃាត់ទុកបាន (មាត្រា ៧៧៤)។ នៅពេលខ្លះ ចំណាយបង្កើនតំលៃ អាចមានចំនួនច្រើន ហើយ ភតិបតី មិនអាចទទួលបាននូវវត្ថុជួលទេ នៅក្នុងករណីនេះ ប្រសិនបើ ភតិបតី មិនអាចសងនូវសោហ៊ុយចំណាយនោះជាបន្ទាន់។ ដូច្នេះ មាត្រា ៦០៤ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២ បានបញ្ញត្តិថា តុលាការ អាចអនុញ្ញាតអោយកំណត់អំឡុងពេលសមរម្យឱ្យសងវិញនូវសោហ៊ុយចំណាយ តាមការទាមទាររបស់ភតិបតី។ ឬនិយាយម្យ៉ាងទៀត ភតិបតី មិនចាំបាច់សងវិញនូវសោហ៊ុយចំណាយដើម្បីបង្កើនតំលៃ រហូតដល់កាលបរិច្ឆេទដែលតុលាការទទួលស្គាល់។ នៅក្នុងករណីនេះ ភតិក: មិនអាចអះអាងពីសិទ្ធិឃាត់ទុក ឬ ការតវ៉ាអោយអនុវត្តព្រមគ្នាទេ។

**ករណីសិក្សា**

**ខ** បានជួលអាគារមួយសំរាប់បើកភោជនីយដ្ឋានពី **ក**។ អំឡុងពេលនៃភតិសន្យា គឺមានរយ:ពេល ៥ ឆ្នាំ ហើយតំលៃឈ្នួល គឺ ៥០០ដុល្លារ ក្នុងមួយខែ។ ហើយវា មិនមានការព្រមព្រៀងពិសេស ទាក់ទងនឹងការជួសជុល រឺ សោហ៊ុយចំណាយ។

តើ **ខ** អាចទាមទារអោយសងនូវសោហ៊ុយពី **ក** បានដែរ រឺ ទេ? ប្រសិនជាបាន តើសោហ៊ុយចំណាយប្រភេទណា ដែល **ខ** អាចទាមទារបាន?

(១) ក្រោយពីការប្រគល់ គឺពិដានបានជ្រាបទឹក។ ដូច្នេះ **ខ** បានទិញសំភារ:សំរាប់ជួសជុល អស់ទឹកប្រាក់ ១០ ដុល្លារ គឺជួសជុលដោយខ្លួនគាត់។

(២) **ខ** បានផ្លាស់ប្តូរបំពង់ស្រូបផ្សែង ដោយសារតែបំពង់ស្រូបផ្សែងមុន ដែលមាននៅពេលប្រគល់ គឺចាស់ ហើយពេលខ្លះ មិនដំណើរការទៀត។ បំពង់ស្រូបផ្សែងថ្មី មានតំលៃ ២៥០ដុល្លារ ហើយវាគឺជាតំលៃធម្មតា។

(៣) នៅមុនពេលរំលាយកិច្ចសន្យា ខ បានទិញ និង តំឡើងទូរទឹកកកភ្ជាប់ជញ្ជាំង ក្នុងតំលៃ ៥០០០ ដុល្លារ ដែលនាំចូលពីសហរដ្ឋអាមេរិក ។ ហើយ បន្ទាប់មកភតិសន្យា ត្រូវបានរំលាយ ។

【សេចក្តីសន្និដ្ឋាន និង មូលហេតុសំអាង】

(១) ខ អាចទាមទាអោយសង ១០ ដុល្លា ដែលជាសោហ៊ុយចាំបាច់

សោហ៊ុយចំណាយ ដែល ខ អាចទាមទារបាននោះ គឺសោហ៊ុយចំណាយចាំបាច់ ។ នៅក្នុងករណីដែល ខ មិនអាចប្រើប្រាស់ ឬ អាស្រ័យផលពីវត្ថុជួលបានទេ ដោយសារតែការជ្រាបទឹកនេះ ។ ដូច្នេះ ខ បានចំណាយសោហ៊ុយចាំបាច់ អស់ ១០ ដុល្លារ ដោយផ្អែកលើមាត្រា ៦០៤ កថាខណ្ឌទី ១ ។

(២) ខ អាចទាមទារអាយសង ២៥០ ដុល្លា ដែលជាសោហ៊ុយចាំបាច់

ខ ជួលអាគារ ដើម្បីបើកជាភោជនីយដ្ឋាន ។ ដូច្នេះ បំពង់ស្រូបផ្សែង គឺជាឧបករណ៍ ដែលមានសារសំខាន់ណាស់ ក្នុងការប្រើប្រាស់ និង អាស្រ័យផលពីអាគារ ។ ដូច្នេះ សោហ៊ុយ ២៥០ ដុល្លា អាចត្រូវបានទទួលស្គាល់ថាជា សោហ៊ុយចាំបាច់ ។

(៣) ខ អាចទាមទារអោយសងនូវសោហ៊ុយបង្កើនតំលៃ

ទាក់ទងនឹងការចំណាយ ៥០០០ដុល្លារ របស់ ខ ដើម្បីទិញ និង តំឡើងទូរទឹកកកភ្ជាប់ជញ្ជាំងនោះ គឺ ក មិនអាចទាមទារសោហ៊ុយចំណាយ ដែលជាសោហ៊ុយចាំបាច់នោះបានទេ ។ ក៏ប៉ុន្តែ គេ អាចនិយាយបានថា ការតំឡើងទូរទឹកកកភ្ជាប់ជញ្ជាំងនេះ គឺជាសកម្មភាពបង្កើនតំលៃវត្ថុជួល នៅក្នុងករណីនេះ យោងតាមមាត្រា ៦០៤ កថាខណ្ឌទី ២ ក្នុងករណីដែលនៅពេលកិច្ចសន្យា ត្រូវបានរំលាយ ហើយទូរទឹកកកនោះ នៅមានតំលៃ នោះ ខ អាចទាមទារអោយសងសោហ៊ុយបាន ។ នៅក្នុងករណីនេះ ខ អាចទាមទារឱ្យសងនូវសោហ៊ុយ ដែលបានចំណាយពិតប្រាកដ ឬ ការកើនតំលៃនៃអាគារ ដោយផ្អែកលើជំរើសរបស់ ក ។

### ២.៤ ការទទួលខុសត្រូវក្នុងការធានារបស់ភតិបតី

### ២.៤.១ នៅក្នុងករណីដែលវត្ថុជួល ជារបស់អ្នកដទៃ

នៅក្នុងករណីនេះ គឺត្រូវផ្តោតទៅលើគោលការណ៍ចំនួនបី ។

ទីមួយ ភតិសន្យាដើម គឺមានសុពលភាព នៅក្នុងករណី ដែលវត្ថុជួល គឺជារបស់អ្នកដទៃ

ទីពីរ ភតិបតី មានកាតព្វកិច្ចត្រូវទទួលនូវកម្មសិទ្ធិ រី ជួលកម្មវត្ថុនោះពីម្ចាស់កម្មសិទ្ធិករ

ទីបី ក្នុងករណីដែល ភតិបតី មិនអាចបំពេញកាតព្វកិច្ចរបស់ខ្លួននោះទេ គឺ ត្រូវអនុវត្តដូចគ្នា ទៅនឹងមាត្រា ៥៣១ ទាក់ទងនឹងករណីយកិច្ចត្រូវផ្ទេរសិទ្ធិ និង ការទទួលខុសត្រូវក្នុងការធានារបស់អ្នកលក់, មាត្រា ៥៣២ សិទ្ធិ

រំលាយកិច្ចសន្យារបស់អ្នកលក់សិទ្ធិអ្នកដទៃ និង មាត្រា ៥៣៣ ការទទួលខុសត្រូវក្នុងការធានា ចំពោះករណី ដែលសិទ្ធិមួយភាគជាសិទ្ធិរបស់អ្នកដទៃ។

## ២.៤.២ ការទទួលខុសត្រូវធានាចំពោះវិការៈ

នៅក្នុងករណីដែល កម្មវត្ថុនៃភតិសន្យា មានវិការៈ នោះ ភតិបតី ត្រូវទទួលខុសត្រូវក្នុងការធានាចំពោះ វិការៈ ព្រោះ ភតិសន្យា គឺជាកិច្ចសន្យាយកតំលៃថ្នូរ។ មាត្រា ៦០៥ ត្រូវបានចែងចែកជាពីរ ករណី នៅក្នុងករណី ដែល វិការៈ អាចមើលឃើញដោយងាយស្រួល និង នៅក្នុងករណីដែលវិការៈ មានលក្ខណៈកំបាំង។

(ក) នៅក្នុងករណីដែល វិការៈ អាចដឹងដោយងាយស្រួលបើពិនិត្យ ( មាត្រា ៦០៥ កថាខណ្ឌទី ១)

នៅក្នុងករណីដែល

(i) ភតិកៈ មិនបានពិនិត្យស្ថានភាពនៃវត្ថុជួល ដែលជាកម្មវត្ថុនៃភតិសន្យាថា ត្រឹមត្រូវតាម ស្ថានភាព ដែលបានកំណត់នៅក្នុងលិខិតកិច្ចសន្យា នៅពេលទទួលការប្រគល់

និង

(ii) ភាពខុសគ្នាពីស្ថានភាព ដែលបានកំណត់នៅក្នុងលិខិតកិច្ចសន្យា ដែលខ្លួន អាចដឹងដោយ ងាយស្រួល បើពិនិត្យ

នោះ ភតិកៈ មិនអាចទាមទារអោយភតិបតី ធ្វើការទទួលខុសត្រូវបានឡើយ។

ឧទាហរណ៍ នៅក្នុងភតិសន្យា ជួលបន្ទប់មួយ នៅក្នុងផ្ទះល្វែង (អាផាតមែន) គេ បានចែងនៅក្នុង កិច្ចសន្យាថា មានម៉ាស៊ីន ត្រជាក់ចំនួន ៣ ដែលត្រូវតំឡើង ក៏ប៉ុន្តែ តាមការជាក់ស្តែង គឺមានតែម៉ាស៊ីន ចំនួន ២ ទេ ដែលបានតំឡើង ដូច្នេះ ភតិកៈ មិនអាចទាមទារអោយភតិបតី តំឡើងម៉ាស៊ីនត្រជាក់មួយទៀតទេ ប្រសិនបើ ភតិកៈ មិនបានពិនិត្យបន្ទប់នោះ។

(ខ) នៅក្នុងករណីដែលវិការៈ មានលក្ខណៈកំបាំង ( មាត្រា ៦០៥ កថាខណ្ឌទី ២ និង ទី ៥)

ប្រសិនបើក្នុងករណីដែលវិការៈមានលក្ខណៈកំបាំង ហើយភតិកៈ មិនបានដឹង នៅពេលប្រគល់នោះ គឺ ភតិកៈ អាចទាមទារអោយជួសជុលវិការៈ រឺ ទាមទារសំណងការខូចខាតនោះបាន។ ទន្ទឹមនឹងនេះ នៅក្នុងករណី ដែល ភតិកៈ មិនអាចសំរេចគោលបំណងនៃកិច្ចសន្យា ដោយសារតែមានវិការៈ នោះ ភតិកៈ អាចរំលាយកិច្ចសន្យា បាន ( មាត្រា ៦០៥ កថាខណ្ឌទី ៥)។

(គ) ខ្លឹមសារនៃការទទួលខុសត្រូវធានាចំពោះវិការៈ

នៅក្នុងករណីដែល វត្ថុជួល មានវិការៈ ភតិបតី អាចជួលជុលវិការៈនោះ ដោយសោហ៊ុយខ្លួនឯងបាន លុះត្រាតែមិនធ្វើអោយមានការខូចខាត ដោយមិនត្រឹមត្រូវនូវផលប្រយោជន៍របស់ភតិកៈ ( មាត្រា ៦០៥ កថាខណ្ឌទី ៣) ។

ទោះបីជាភតិបតី ជួលជុលវិការៈក៏ដោយ ក៏ភតិកៈ អាចទាមទារសំណងនៃការខូចខាតបានដែរ ( មាត្រា ៦០៥ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ២) ។

ប្រសិនបើ ភតិបតី មានកាតព្វកិច្ចជួសជុល ដោយផ្អែកទៅលើមាត្រា ៦០៥ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ២ នោះ ភតិកៈ អាចទាមទារឱ្យបន្ថយថ្លៃឈ្នួល ដែលសមរម្យនឹងវិការៈបាន ដោយគិតចាប់តាំងពីពេល ដែលបានប្រគល់ ( មាត្រា ៦០៥ កថាខណ្ឌទី ៤) ។

ទន្ទឹមនឹងនេះ ដូចដែលបានរៀបរាប់ខាងលើ ប្រសិនបើ ភតិកៈ មិនអាចសំរេចគោលបំណងនៃកិច្ចសន្យា ដោយសារអត្ថិភាពនៃវិការៈកំបាំងនេះ នោះ ភតិកៈ អាចរំលាយកិច្ចសន្យាបាន ។

ការទាមទារនានា ដែលទាក់ទងនឹងការទទួលខុសត្រូវធានាចំពោះវិការៈ ត្រូវអនុវត្ត នៅក្នុងអំឡុងពេល ១ ឆ្នាំ គិតចាប់ពីពេលដែលភតិកៈ បានដឹង ឬ ពេលដែលត្រូវដឹងអំពីហេតុនោះបាន ។

## ៣. សិទ្ធិ និង ករណីយកិច្ចរបស់ភតិកៈ

### ៣.១ ករណីយកិច្ចបង់ថ្លៃឈ្នួល

ជាគោលការណ៍ អ្នកជួល មានករណីយកិច្ចបង់ថ្លៃជួលទៅអោយម្ចាស់ចលនវត្ថុ និង ផ្ទះ រឺ អាគារ នៅចុងខែ ហើយសំរាប់ការជួលដី គឺនៅចុងឆ្នាំ ។

យោងទៅលើមាត្រា ៦១០ ភតិកៈ មានកាតព្វកិច្ចបង់ថ្លៃឈ្នួលទៅឱ្យភតិបតី យោងទៅតាមកិច្ចសន្យាជួលដែលមានកំណត់ពេលបង់ថ្លៃឈ្នួល ។ ប៉ុន្តែបើ នៅក្នុងកិច្ចសន្យាជួល ពុំបានកំណត់អំពីពេលវេលាបង់ថ្លៃឈ្នួលនោះទេ គឺកាតព្វកិច្ចបង់ថ្លៃឈ្នួល ត្រូវយោងទៅតាមបញ្ញត្តិច្បាប់ ដូចជាចំពោះចលនវត្ថុ និង ផ្ទះ រឺ អាគារ ត្រូវបង់នៅរៀងរាល់ចុងខែ ហើយចំពោះដីធ្លីវិញ ត្រូវបង់នៅរៀងរាល់ចុងឆ្នាំ ។ ហើយចំពោះវត្ថុ ដែលមានរដូវប្រមូលផល ត្រូវបង់នៅក្រោយពេលដែលរដូវនោះកន្លងផុត ដោយគ្មានយឺតយ៉ាវ ។ សរុបមក ការបង់ថ្លៃឈ្នួល ត្រូវអនុលោមតាមវិធីចំនួនពីរ គឺ ទីមួយ បង់ថ្លៃឈ្នួលដែលមានកំណត់ក្នុងកិច្ចសន្យា ឬ វិធីទីពីរ គឺបង់ថ្លៃឈ្នួលតាមបញ្ញត្តិច្បាប់ ។

ចំណុចនៅត្រង់នេះ គឺថា កាតព្វកិច្ចប្រគល់វត្ថុជួលរបស់ភតិបតី និង កាតព្វកិច្ចបង់ថ្លៃឈ្នួល មិនមានទំនាក់ទំនងទៅនឹងការអនុវត្តព្រមគ្នានោះទេ ។ ភតិបតី ត្រូវបញ្ចប់កាតព្វកិច្ចរបស់ខ្លួន នៅក្នុងការប្រគល់វត្ថុជួល នៅមុនពេលបង់ប្រាក់ឈ្នួល ប្រសិនបើ មិនមានការព្រមព្រៀងពិសេស ។

ទាំងភតិកៈ និង ភតិបតី មានទំនាក់ទំនងកាតព្វកិច្ចមួយផ្សេងទៀត គឺក្នុងលក្ខខណ្ឌស្មោះត្រង់ និង សុច្ចរិត បន្ទាប់ពីកិច្ចសន្យាជួល ត្រូវបានបញ្ចប់ ភតិកៈ ត្រូវប្រគល់កម្មវត្ថុជួលទៅឱ្យភតិបតីវិញក្នុងលក្ខខណ្ឌដើម។ម្យ៉ាងទៀត ប្រសិន ភតិកៈ និង ភតិបតី បន្តកិច្ចសន្យាជួល ទំនាក់ទំនងថ្មីមួយទៀត ត្រូវបានបង្កើតឡើងរវាងកាតព្វកិច្ចប្រគល់វត្ថុ និង កាតព្វកិច្ចបង់ថ្លៃឈ្នួល។

## ៣.២ សិទ្ធិ និង ករណីយកិច្ចនៃការប្រើប្រាស់ និង អាស្រ័យផល ផ្អែកតាមវិធីប្រើប្រាស់

ភតិកៈ មានសិទ្ធិ និង ករណីយកិច្ច ក្នុងការប្រើប្រាស់ និង អាស្រ័យផលពីវត្ថុជួល ដោយផ្អែកតាមវិធីប្រើប្រាស់ (មាត្រា ៦០០)។ វិធីប្រើប្រាស់ ក្នុងមាត្រា ៦០០ មានន័យថា អ្នកជួល មានសិទ្ធិ និង ករណីយកិច្ចប្រើប្រាស់ និង អាស្រ័យផលលើវត្ថុជួល ដែលមានកំណត់ និង បញ្ជាក់ពីរបៀបប្រើប្រាស់បានសរសេរក្នុងកិច្ចសន្យា ឬ ស្របទៅតាមលក្ខណៈនៃកម្មវត្ថុជួល។ ការប្រើប្រាស់អោយសមស្របទៅតាមលក្ខណៈវត្ថុ គឺសំដៅទៅលើការប្រើប្រាស់តាមគោលគំនិត ដែលវត្ថុនោះ ប្រើក្នុងលក្ខខណ្ឌធម្មតា និង ទូទៅ។ ក្នុងករណីដែលភតិកៈ បានប្រើប្រាស់ និង អាស្រ័យផល ស្របតាមវិធីប្រើប្រាស់ និង អាស្រ័យផលបានត្រឹមត្រូវហើយ នោះ ភតិបតី មិនអាចធ្វើការរាំងស្ទះក្នុងការប្រើប្រាស់ និង អាស្រ័យផលនោះ ឡើយ។ ឧទាហរណ៍ ភតិកៈ ខ បានជួលបន្ទប់ នៅក្នុងផ្ទះល្វែង (អាផាតម៉ែន) ពី ភតិបតី ក ដើម្បីស្នាក់នៅ នោះគេ ចាត់ទុកថា គឺជាការបំពានករណីយកិច្ចនេះ ប្រសិនបើ គាត់ ជួលជុលកែបន្ទប់នោះ ដោយគ្មានការយល់ព្រមរបស់ ក និង បើកជាភោជនីយដ្ឋាន។

ក្នុងករណីដែលភតិកៈ បានធ្វើខុសនឹងករណីយកិច្ចប្រើប្រាស់ និង អាស្រ័យផល ដោយផ្អែកតាមវិធីប្រើប្រាស់ នោះ ភតិបតី មានសិទ្ធរំលាយកិច្ចសន្យាបាន (មាត្រា ៦០០ កថាខណ្ឌទី ២)។ ការរំលាយកិច្ចសន្យានេះក៏អាចយោងទៅលើបញ្ញត្តិទូទៅនៃការមិនអនុវត្តកាតព្វកិច្ច និង ការបំពានកិច្ចសន្យាបានដែរ។

## ៣.៣ ករណីយកិច្ចរបស់ភតិកៈ នៅក្នុងការថែរក្សាវត្ថុជួល ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ

ភតិកៈ កាន់កាប់នូវទ្រព្យសម្បត្តិ ដែលជាកម្មសិទ្ធិរបស់អ្នកដទៃ។ ដូច្នេះ ភតិកៈ ត្រូវមានករណីយកិច្ច ថែរក្សាវត្ថុជួល ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ។ ក៏ប៉ុន្តែ ភតិកៈ មិនទទួលខុសត្រូវចំពោះការថយចុះតំលៃ ដែលកើតឡើងពីការប្រើប្រាស់វត្ថុនោះ ដោយយោងទៅលើវិធីប្រើប្រាស់ធម្មតា។ ឧទាហរណ៍ ប្រសិនបើ ភតិកៈ បានជួលភតិបតី នោះជាទូទៅ ភតិកៈ មិនចាំបាច់សងការខូចខាតចំពោះការសឹកសំបកកង់រថយន្តឡើយ។

ប្រសិនបើ ភតិកៈ បានបំពានករណីយកិច្ចនេះ ភតិបតី អាចរំលាយភតិសន្យាបាន ដោយផ្អែកទៅលើបញ្ញត្តិទូទៅនៃការរំលាយកិច្ចសន្យា។ ភតិបតី ចាំបាច់ត្រូវដាស់តឿនភតិកៈ អោយបញ្ឈប់សកម្មភាព ដែលបំពានទៅលើករណីយកិច្ចនេះ ដោយកំណត់អំឡុងពេលសមរម្យ។ ហើយ ភតិបតី អាចរំលាយភតិសន្យា ប្រសិនបើ ភតិកៈ មិនបញ្ឈប់សកម្មភាព នៅក្នុងអំឡុងពេលនោះ។ ក៏ប៉ុន្តែ នៅក្នុងករណីដែលសកម្មភាពរបស់ភតិកៈ បានធ្វើអោយបាត់

បង់នូវទំនុកចិត្តរវាងភាគី ហើយមិនអាចជឿជាក់ថា នឹងអនុវត្តកាតព្វកិច្ចនាអនាគតបាន នោះ ភតិបតី អាចរំលាយភតិសន្យាបានភ្លាម១ ( មាត្រា ៤០៨ កថាខណ្ឌទី ១ ចំណុច ឃ) ។

### ៣.៤ សិទ្ធិទាមទារអោយសងវិញ នូវសោហ៊ុយរបស់ភតិក:

ដូចបានរៀបរាប់ ភតិបតី មានកាតព្វកិច្ចសងនូវសោហ៊ុយចាំបាច់ និង សោហ៊ុយបង្កើនតំលៃ។ បើនិយាយបញ្ច្រាស់មកវិញ គឺ ភតិក: មានសិទ្ធិទាមទារអោយសងនូវសោហ៊ុយចាំបាច់ និង សោហ៊ុយបង្កើនតំលៃ ( មាត្រា ៦០៤) ។

### ៣.៥ សិទ្ធិទាមទារឱ្យបន្ថយថ្លៃឈ្នួល ឬ សិទ្ធិរំលាយភតិសន្យា

ភាគី អាចសំរេចពីចំនួននៃថ្លៃឈ្នួល ដោយការព្រមព្រៀង ដរាបណា វា មិនផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និង ទំនៀមទំលាប់ល្អ។ ក៏ប៉ុន្តែ នៅក្នុងករណីនៃកិច្ចសន្យាដែលមានរយៈពេលវែង ដូចជា ភតិសន្យា ស្ថានភាពសេដ្ឋកិច្ច នៅពេលខ្លះ អាចមានការផ្លាស់ប្តូរ។ ដូច្នេះ ក្រមរដ្ឋប្បវេណី បានបញ្ញត្ត ថា ភតិក: អាចទាមទារអោយបន្ថយថ្លៃឈ្នួល នៅក្នុងស្ថានភាពជាក់លាក់មួយចំនួន។ ផ្ទុយទៅវិញ ក្រមរដ្ឋប្បវេណី មិនអាចចែងសិទ្ធិទាមទារអោយបង្កើនតំលៃឈ្នួលរបស់ភតិបតីឡើយ។ មូលហេតុ គឺថាភតិបតី អាចធ្វើកិច្ចព្រមព្រៀងថា គូភាគី ត្រូវពិគ្រោះជាមួយភតិក: ដើម្បីកែប្រែតំលៃដោយមានកំណត់ពេល ឬ បង្កើតកិច្ចសន្យា ដែលបញ្ញត្តិពីអំឡុងពេលនៅក្នុងរយៈពេលខ្លី ដូចជា ភតិសន្យាមានអំឡុងពេល ១ ឆ្នាំ ឬ ២ ឆ្នាំ និង កំណត់ការព្រមព្រៀងថ្មី ទាក់ទងនឹងថ្លៃឈ្នួល។

ក្រមរដ្ឋប្បវេណី បានបញ្ញត្ត នូវសិទ្ធិទាមទារអោយបន្ថយថ្លៃឈ្នួល ឬ រំលាយកិច្ចសន្យា ពីរប្រភេទ

#### ៣.៥.១ នៅក្នុងករណីដែលចំណូលថយចុះ ( មាត្រា ៦០៦)

មាត្រា ៦០៦ កថាខណ្ឌទី ១ បានចែងថា ភតិក: អាចទាមទារអោយបន្ថយថ្លៃឈ្នួល រហូតដល់ត្រឹមចំនួនទឹកប្រាក់នៃការអាស្រ័យផលនោះ

(i). នៅក្នុងករណីដែលភតិក: ជួលដីដែលមានគោលបំណងអាស្រ័យផលពីដី

**និង**

(ii). ភតិក: បានទទួលផលតិចជាងថ្លៃឈ្នួល ដោយសារករណីប្រធានសក្តិ

ឧទាហរណ៍ នៅក្នុងករណីដែល ខ បានជួលដីពី ក ដើម្បីដាំស្រូវ ក្នុងតំលៃឈ្នួល ១០០០ ដុល្លា ក្នុង ១ ឆ្នាំ ប៉ុន្តែ ខ អាចទទួលបានប្រាក់ ៦០០ ដុល្លា ពីការប្រមូលផល នៅក្នុងឆ្នាំនោះ ខ អាចទាមទារអោយ ក បន្ថយថ្លៃឈ្នួលមកត្រឹម ៦០០ ដុល្លា។

ដើម្បីទទួលស្គាល់នូវសិទ្ធិនេះ វា មានភាពចាំបាច់ណាស់ ដែលភតិកៈ បានជួល "ដី ដោយមានគោលបំណងអាស្រ័យផលពីដីនោះ"។ វា មានន័យថា ភតិកៈ បានជួលដី ដោយមានគោលបំណងថា នឹងទទួលបានផលពីដីនោះផ្ទាល់តែម្តង។ ឧទាហរណ៍ ប្រសិនបើ ភតិកៈ ដែលបានជួលដី និង សាងសង់ភោជនីយដ្ឋាន បានគ្រប់គ្រងភោជនីយដ្ឋាននោះ ប៉ុន្តែ គាត់ មិនអាចទទួលបានប្រាក់ចំណូល ច្រើនជាងចំនួនថ្លៃឈ្នួល។ នៅក្នុងករណីនេះ ភតិកៈ មិនអាចទាមទារអោយបន្ថយថ្លៃឈ្នួល ព្រោះ គេ មិនអាចនិយាយថា ភតិកៈ បានជួលដី ដោយមានគោលបំណងអាស្រ័យផលពីដីឡើយ។ គោលបំណងនៃមាត្រានេះ គឺដើម្បីការពារកសិករដែលជួលដី។

ប្រសិនបើ ភតិកៈ បានទទួលផលតិចជាងថ្លៃឈ្នួល លើសពី ២ ឆ្នាំ ជាបន្តបន្ទាប់ ដោយសារករណីប្រធានសក្តិ ភតិកៈ អាចរំលាយភតិសន្យាបាន (មាត្រា ៦០៦ កថាខណ្ឌទី ២)។

### ៣.៥.២ នៅក្នុងករណីដែលបាត់បង់ ឬ វិនាសវត្ថុជួលមួយភាគ ( មាត្រា ៦០៧)

ប្រសិនបើវត្ថុជួលមួយភាគ ត្រូវបានបាត់បង់ ឬ វិនាស ហើយមិនមែនជាកំហុសរបស់ភតិកៈទេ នោះភតិកៈ អាចសុំបន្ថយថ្លៃឈ្នួលត្រឹមកំរិតសមាមាត្រានៃភាគដែលបាត់បង់ ឬ វិនាសនោះ។ ប្រសិនបើភតិកៈ មិនអាចសំរេចគោលបំណងនៃកិច្ចសន្យាបានទេ ចំពោះភាគដែលនៅសល់ ដូច្នេះ ភតិកៈ អាចសុំរំលាយកិច្ចសន្យាបាន។ (មាត្រា ៦០៧ កថាខណ្ឌទី ២)

**ឧទាហរណ៍ ខ** បានជួលបន្ទប់ចំនួន ៣ ពី **ក** ក្នុងតំលៃ ៦០០ ដុល្លា។ ក៏ប៉ុន្តែ បន្ទប់មួយ ត្រូវបានអគ្គីភ័យឆាបឆេះអស់ ដោយមិនមានកំហុសរបស់ **ខ**។ នៅក្នុងករណីនេះ **ខ** អាចទាមទារឱ្យ **ក** បន្ថយថ្លៃឈ្នួល ចំពោះបន្ទប់ជួលទី ៣ នោះ។ ដូច្នេះ **ខ** ត្រូវបង់ត្រឹមតែ ៤០០ ដុល្លា ទៅឱ្យ **ក** ប៉ុណ្ណោះ។ ប៉ុន្តែប្រសិនជា បន្ទប់ជួល ដែលនៅសល់ ២ នោះ មិនអាចឱ្យ **ខ** សម្រេចគោលបំណងរបស់ខ្លួនបានទេ នោះ **ខ** អាចរំលាយកិច្ចសន្យាបាន ។

### ៣.៦ អនុប្បទានសិទ្ធិជួល និង ការជួលបន្តនូវវត្ថុជួល

លើកលែងនៅក្នុងករណីនៃសិទ្ធិជួលអចិន្ត្រៃយ៍ (មាត្រា ២៥២ កថាខណ្ឌទី ១) ភតិកៈ ពុំត្រូវបានអនុញ្ញាតអោយធ្វើអនុប្បទាន ឬ ជួលបន្តនូវវត្ថុជួលបានឡើយ ប្រសិនជាគ្មានការយល់ព្រមពីភតិបតី (មាត្រា ៦០៨ កថាខណ្ឌទី ១)។

**- អត្ថន័យនៃអនុប្បទានសិទ្ធិជួល**

អត្ថន័យនៃអនុប្បទានសិទ្ធិជួល គឺថាភតិកៈ ធ្វើអនុប្បទាននូវឋានៈរបស់ខ្លួនជាភតិកៈ ទៅឱ្យតតិយជន។

**- អត្ថន័យនៃការជួលបន្តនូវវត្ថុជួល**

ភតិកៈ ជួលនូវវត្ថុជួលឱ្យទៅតតិយជន ។

មាត្រា ៦០៨ ចែងថា បើគ្មានការយល់ព្រមពីភតិបតីទេ ភតិកៈ ពុំអាចធ្វើអនុប្បទានសិទ្ធិជួល ឬ ជួលបន្ត នូវវត្ថុជួលនោះបានឡើយ លើកលែងតែសិទ្ធិជួលអចិន្ត្រៃយ៍ ។

បើភតិកៈ បានឱ្យតតិយជនប្រើប្រាស់ ឬ អាស្រ័យផលពីវត្ថុជួល ផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះ ភតិបតី អាចរំលាយកិច្ចសន្យាបាន ( មាត្រា ៦០៨ កថាខណ្ឌទី ២) ។

មូលហេតុ ដែលភតិកៈ ចាំបាច់ត្រូវមានការយល់ព្រមពីភតិបតី នៅក្នុងករណីនៃការធ្វើអនុប្បទាន ឬ ជួលបន្ត គឺដោយសារតែ វា មានសារសំខាន់ណាស់ សំរាប់ភតិបតី ដែលជាម្ចាស់សិទ្ធិលើការជួល ។ ឬនិយាយម្យ៉ាងទៀត ភតិបតី ជឿជាក់ទៅលើបុគ្គលលក្ខណៈរបស់ភតិកៈ ដូចជា មានសមត្ថភាពហិរញ្ញវត្ថុគ្រប់គ្រាន់ ឬ សម្បជញ្ញៈ ហើយ បានជួលនូវទ្រព្យសម្បត្តិរបស់ខ្លួន ដោយផ្អែកលើជំនឿទុកចិត្តនោះ ។ ទន្ទឹមនឹងនេះ ប្រសិនបើ គេ អាចធ្វើអនុប្បទាននូវសិទ្ធិជួល ឬ ជួលវត្ថុនោះទៅអោយតតិយជន ដោយគ្មានការយល់ព្រមពីភតិបតី នោះ ភតិបតី អាចទទួលរងនូវការខូចខាត ដែលមិនបានរំពឹងទុកជាមុន ព្រោះ កាតព្វកិច្ចបង់ថ្លៃឈ្នួល ក៏ត្រូវបានផ្ទេរទៅតតិយជន ដែលសមត្ថភាពក្នុងការបង់ថ្លៃឈ្នួល មិនត្រូវបានភតិបតីដឹងឡើយ ។

បើភតិកៈ បានជួលបន្តនូវវត្ថុជួលដោយត្រឹមត្រូវតាមច្បាប់ ភតិកៈបន្ត ត្រូវមានករណីយកិច្ចដោយផ្ទាល់ចំពោះភតិបតី ។ ចំពោះករណីយកិច្ចបង់ថ្លៃឈ្នួលជួលបន្ត ភតិកៈបន្ត ពុំអាចយកការបង់ថ្លៃជាមុនទៅឱ្យភតិកៈ មកតតាំងជាមួយភតិបតីបានឡើយ ( មាត្រា ៦០៩ កថាខណ្ឌទី ១) ។

បញ្ញត្តិនៃកថាខណ្ឌខាងលើនេះ ពុំរារាំងដល់ការអនុវត្តសិទ្ធិរបស់ភតិបតីចំពោះភតិកៈឡើយ ( មាត្រា ៦០៩ កថាខណ្ឌទី ២) ។

**ឧទាហរណ៍ ក** បានជួលផ្ទះឱ្យ **ខ** ហើយ **ខ** បានជួលផ្ទះនេះបន្តទៅឱ្យ **គ** ដោយមានការយល់ព្រមរបស់ **ក** ។ នៅក្នុងករណីនេះ **ក** ជាភតិបតី **ខ** ជាភតិកៈ រីឯ **គ** គឺជាភតិកៈបន្ត ។

នៅក្នុងករណីដែល **គ** បានបង់ថ្លៃឈ្នួលឱ្យ **ខ** រួចហើយ ហើយ **ខ** មិនបានបង់ថ្លៃឈ្នួលឱ្យ **ក** ទេ នោះ **ក** អាចទាមទារថ្លៃឈ្នួលពី **ខ** ក៏បាន ពី **គ** ក៏បាន ។ ហើយក្នុងករណីដែល **ក** ទាមទារថ្លៃឈ្នួលពី **គ** ក៏ **គ** មិនអាចបដិសេធបានដែរ នៅក្នុងករណីនេះ ។ ដូច្នេះ **គ** ត្រូវមានកាតព្វកិច្ចបង់ថ្លៃឈ្នួលទៅឱ្យ **ក** ហើយ **គ** អាចទាមទារថ្លៃឈ្នួលពី **ខ** ដោយផ្អែកលើសេចក្តីចំរើនអត់ហេតុ ។

**<u>ករណីសិក្សា</u> :**

**ក** បានជួលបន្ទប់មួយនៃផ្ទះល្វែង ( អាផាតមែន ) របស់ខ្លួនទៅឱ្យ **ខ** ។ **គ** គឺជាមិត្តភក្តិរបស់ **ខ** ។

(១). **ខ** បានបង្កើតកិច្ចសន្យាជួលបន្តមួយដើម្បីជួលបន្ទប់នោះទៅឱ្យ **គ** ដោយមិនមានការយល់ព្រមពី **ក** នៅថ្ងៃ ទី១០ ខែមេសា ឆ្នាំ២០១១ ។ **គ** មានគោលបំណងរើទៅនៅក្នុងបន្ទប់នោះ នៅថ្ងៃទី ០១ ខែ ឧសភា ។ តើ **ក** ដែលបានដឹងពីអត្ថិភាពនៃកិច្ចសន្យាជួលនេះនៅថ្ងៃទី ១៥ ខែ មេសា អាចរំលាយកិច្ចសន្យាជាមួយ **ខ** បានដែរ ឬទេ ?

(២). ខ បានជួលបន្តនូវបន្ទប់នោះអោយទៅ គ ដោយមានការយល់ព្រមរបស់ ក ហើយ គ បានរើចូលទៅនៅក្នុងបន្ទប់នោះដែរ។ ក្រោយមក គ មិនបានបង់ថ្លៃឈ្នួលអោយទៅ ក។ គ បានបង់ថ្លៃឈ្នួលរយៈពេល ១ ឆ្នាំ អោយទៅ ខ។ តើ ក អាចទាមទារអោយ គ បង់ថ្លៃឈ្នួល បានដែរ ឬ ទេ?

(៣). ខ បានជួលបន្តនូវបន្ទប់នោះទៅអោយ គ ដោយមានការយល់ព្រមរបស់ ក ហើយ គ បានរើចូលទៅនៅក្នុងបន្ទប់នោះហើយ។ ក្រោយមក ពិដានបន្ទប់នោះ ចាប់ផ្តើមជ្រាបទឹក។ តើ គ អាចទាមទារអោយ ក ជួសជុលបានដែរ ឬ ទេ ?

【សេចក្តីសន្និដ្ឋាន និង មូលហេតុសំអាង】

(១). ក មិនអាចរំលាយកិច្ចសន្យាបានទេ

ដោយផ្អែកលើកថាខណ្ឌទី ២ នៃមាត្រា ៦០៨ ភតិបតី អាចរំលាយកិច្ចសន្យាបាន តែក្នុងករណីដែលភតិកៈ បានអោយតតិយជន ប្រើប្រាស់ និង អាស្រ័យផល លើវត្ថុជួល ដោយគ្មានការយល់ព្រមពីភតិបតី។ អត្ថន័យនៃ "ការប្រើប្រាស់ ឬ អាស្រ័យផល" គឺមានន័យថា ភតិកៈ បានអោយតតិយជន ប្រើប្រាស់ និង អាស្រ័យផល តាមការជាក់ស្តែង។ នៅក្នុងករណីនេះ ខ បានបង្កើតកិច្ចសន្យាជាមួយ គ ដើម្បីជួលបន្ត ដោយគ្មានការយល់ព្រមរបស់ ក ប៉ុន្តែ ខ មិនបានអោយ គ ប្រើប្រាស់ ឬ អាស្រ័យផលនៅឡើយទេ។ ដូច្នេះ ក មិនអាចរំលាយកិច្ចសន្យានេះភ្លាមបានទេ។

(២). ក អាចទាមទារអោយ គ បង់ថ្លៃឈ្នួលបាន។

ប្រសិនបើ ភតិកៈ បានជួលបន្តនូវវត្ថុជួល ដោយស្របច្បាប់ ភតិកៈបន្ត ត្រូវមានកាតព្វកិច្ច ដោយផ្ទាល់ចំពោះភតិបតី។ ហើយ ប្រសិនបើ ភតិកៈបន្ត បានបង់ថ្លៃឈ្នួលទៅអោយភតិបតីបន្ត ជាមុន នោះ ភតិកៈបន្ត មិនលើកឡើងពីការបង់ថ្លៃឈ្នួលនេះ ចំពោះភតិបតីបានឡើយ (មាត្រា ៦០៩ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២)។ ដូច្នេះ គ មិនអាចលើកយកការបង់ថ្លៃឈ្នួលជាមុន មកតតាំងជាមួយ ក បានទេ។ ហើយ ក អាចទាមទារអោយ គ បង់ថ្លៃឈ្នួលបាន។

(៣). គ មិនអាចទាមទារអោយ ក ជួសជុលបានឡើយ។

មាត្រា ៦០៩ កថាខណ្ឌទី ១ បានចែងថា ភតិកៈបន្ត ត្រូវមានកាតព្វកិច្ចដោយផ្ទាល់ ចំពោះ ភតិបតី ប៉ុន្តែ វា មិនបានបញ្ញត្តិនូវអ្វី ដែលទាក់ទងនឹងសិទ្ធិរបស់ភតិកៈបន្ត ក្នុងការទាមទារចំពោះភតិបតីឡើយ។ ចំពោះការជាក់ស្តែង គឺវា មិនមានទំនាក់ទំនងកិច្ចសន្យារវាងភតិបតី និង ភតិកៈបន្តឡើយ។ ដូច្នេះ គ មិនអាចទាមទារអោយ ក បំពេញនូវកាតព្វកិច្ចជាភតិបតី ដោយផ្ទាល់នោះទេ ហើយ មានតែ ខ អាចទាមទារអោយ ក ជួសជុលបាន។ នៅក្នុងករណីដែល ខ បានជួសជុលពិដាន ដោយប្រើចំណាយរបស់ខ្លួន នោះ ខ អាចទាមទារអោយ ក សងនូវការចំណាយនោះមកវិញបាន។

## ៩. ការរំលាយភតិសន្យា

ករណីដែលកូនបំណុល មិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនដែលកើតចេញពីកិច្ចសន្យាទេ យោងតាមមាត្រា ៣៩០ ភាគីម្ខាងទៀត អាចទាមទារអោយអនុវត្តដោយបង្ខំ ទាមទារសំណងការខូចខាត ឬ រំលាយកិច្ចសន្យាបាន។ នៅពេលដែលភាគីណាមួយរំលាយភតិសន្យា ភតិសន្យានោះ នឹងត្រូវបញ្ចប់។

ការរំលាយភតិសន្យានេះ ពុំមានអានុភាពប្រតិសកម្មទេ គឺមានអានុភាពឆ្ពោះទៅអនាគតតែម្តង (មាត្រា ៦១៧)។ អានុភាពនៃការរំលាយភតិសន្យានេះ មានលក្ខណៈប្លែកពីកិច្ចសន្យាផ្សេង ៗ ទៀត ដែលមានអានុភាពប្រតិសកម្ម។ ឧទាហរណ៍ **ក** ជួលផ្ទះអោយ **ខ** រយៈពេល ១ ឆ្នាំ ដែលមានថ្លៃឈ្នួល ១០០ ដុល្លាក្នុង ១ ខែ។ ក៏ប៉ុន្តែក្រោយពីជួលបានរយៈពេលតែ ៥ ខែ ភតិសន្យា ត្រូវរំលាយដោយស្របច្បាប់។ ករណីនេះ **ក** មិនចាំបាច់សងនូវប្រាក់ថ្លៃឈ្នួល ៥ ខែ ទៅអោយ **ខ** វិញទេ ព្រោះ ការរំលាយភតិសន្យា មិនមានអានុភាពប្រតិសកម្មទេ។

### ៩.១ ប្រភេទនៃការបញ្ចប់ភតិសន្យា

ភតិសន្យាមួយ នឹងត្រូវបញ្ចប់ ដោយមូលហេតុដូចខាងក្រោម :

១. ការបញ្ចប់ដោយសារផុតអំឡុងពេលកំណត់ (មាត្រា ៦១២)

២. ការស្នើសុំឱ្យរំលាយភតិសន្យា ដែលពុំមានកំណត់អំឡុងពេល (៦១៥)

៣. ការបាត់បង់ ឬ ការខូចខាតធ្ងន់ធ្ងរនៃវត្ថុជួល

៤. ការរំលាយភតិសន្យា ដោយសារការមិនអនុវត្តកាតព្វកិច្ច

### ៩.២ ការបញ្ចប់ភតិសន្យា ដោយសារការផុតអំឡុងពេលកំណត់

#### ៩.២.១ គោលការណ៍

កាលណាភតិសន្យាមួយ មានកំណត់អំឡុងពេលដែលត្រូវបញ្ចប់ នោះភតិសន្យានោះ នឹងត្រូវបញ្ចប់ដោយការផុតអំឡុងពេលដែលបានកំណត់នោះ (មាត្រា ៦១២)។

ប្រសិនបើ អំឡុងពេល ដែលត្រូវបានកំណត់ដោយកិច្ចព្រមព្រៀង បានកន្លងផុតទៅ នោះ ភតិសន្យា នឹងបាត់បង់អានុភាព ហើយ ភតិកៈ ត្រូវសងវត្ថុជួលត្រឡប់មកវិញ ហើយ ភតិបតី ត្រូវមានកាតព្វកិច្ចបង់នូវចំណាយដើម្បីបង្កើនតំលៃ។

### ៤.២.២ ករណីលើកលែង

ភតិសន្យា គឺជាទំនាក់ទំនងដែលមានលក្ខណៈជាបន្ត ដោយផ្អែកទៅលើការជឿទុកចិត្តរវាង ភតិកៈ និង ភតិបតី។ ដូចដែលបានរៀបរាប់ខាងលើ ភតិសន្យា ជាគោលការណ៍ គឺ ត្រូវបាត់បង់អានុភាព ដោយសារតែការកន្លងផុតនៃអំឡុងពេលនោះ។

ក៏ប៉ុន្តែ ភាគីនៃភតិសន្យា រំពឹងទុកថា កិច្ចសន្យា នឹងអាចបន្តនៅក្នុងរយៈពេលវែង ស្ទើតែគ្រប់ករណី នៅពេលដែលពួកគេ មិនមានបញ្ហានឹងគ្នា។ ដូច្នេះ ក្រមរដ្ឋប្បវេណី បានបញ្ញត្តិពីករណីលើកលែង និង មានគោលបំណងរក្សានូវទំនាក់ទំនងនេះ អោយបានកាន់តែយូរ តាមដែលអាចធ្វើទៅបាន។

#### ក. ក្នុងករណីនៃការជួលអចលនវត្ថុ ( មាត្រា ៦១៣)

ចំពោះការជួលអចលនវត្ថុ ដែលមានកំណត់អំឡុងពេល ទោះបីជាអំឡុងពេលនៃភតិសសន្យានេះដល់កាលកំណត់បញ្ចប់ក៏ដោយ បើភាគីណាម្ខាងនៃភតិសន្យានេះ មិនបានបង្ហាញឆន្ទៈថាបដិសេធការបន្តជាថ្មីក្នុងអំឡុងពេលមួយដែលបានកំណត់ជាក់លាក់ទេ នោះភតិសន្យា ត្រូវបានបន្តសាជាថ្មី ហើយ ការបន្តថ្មីនេះ ត្រូវបានកំណត់ថាជាភតិសន្យាដែលពុំមានកំណត់អំឡុងពេល។ ហើយ ដើម្បីបញ្ចប់ភតិសន្យា ដែលពុំមានកំណត់អំឡុងពេលនេះ គូភាគី អាចស្នើសុំរំលាយ នៅពេលណាក៏បាន ដោយយោងតាមមាត្រា ៦១៥។ ជាក់ស្តែង មាត្រា ៦១៣ កំណត់ថា ដើម្បីបញ្ចប់ភតិសន្យាចំពោះអចលនវត្ថុ ភាគី ដែលចង់បញ្ចប់ ត្រូវបង្ហាញឆន្ទៈបដិសេធការបន្តជាថ្មី នៅមុនរយៈពេល ៣ ខែ មុនផុតអំឡុងពេលបញ្ចប់ក្នុងភតិសន្យា ចំពោះផ្ទះ ឬ អាគារ និង នៅមុនរយៈពេល ១ ឆ្នាំ មុនផុតអំឡុងពេលបញ្ចប់ក្នុងភតិសន្យា ចំពោះដីធ្លី។

មធ្យោបាយ នៅក្នុងការបង្ហាញឆន្ទៈបដិសេធនូវការបន្តភតិសន្យាជាថ្មី គឺមិនត្រូវបានបញ្ញត្តិច្បាស់នៅក្នុងជំពូកស្តីពីភតិសន្យាទេ ដូច្នេះ មាត្រា ៣១០ ទាក់ទងនឹងបញ្ញត្តិទូទៅនៃការបង្ហាញឆន្ទៈ ត្រូវយកមកអនុវត្ត។

ឧទាហរណ៍ ត ជួលផ្ទះឱ្យទៅ ខ រយៈពេល ១ ឆ្នាំ គិតចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១០ ដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០។ ប្រសិនបើ ត ឈប់ចង់ជួលឱ្យផ្ទះនោះ ត ត្រូវជូនដំណឹងពីឆន្ទៈបដិសេធ ការជួលបន្តជាថ្មីទៅ ខ ឱ្យបានមុនរយៈពេល ៣ ខែ មុនផុតថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០។

#### ខ. ក្នុងករណីនៃការជួលចលនវត្ថុ ( មាត្រា ៦១៤)

ចំពោះការជួលចលនវត្ថុ ដែលមានកំណត់អំឡុងពេល ទោះបីជាអំឡុងពេលនៃភតិសន្យានេះ ដល់កាលកំណត់បញ្ចប់ក៏ដោយ ប្រសិនបើ (១) ភតិបតី បានដឹងថា ភតិកៈ បន្តប្រើប្រាស់ និង អាស្រ័យផលលើវត្ថុជួលក្រោយអំឡុងពេលនៃការបញ្ចប់បានកន្លងផុត ហើយ (២) ភតិបតី ពុំបានធ្វើការតវ៉ាទេ នោះ ភតិសន្យា ត្រូវបានសន្មតថាជា ភតិសន្យាដែលបានបន្តជាថ្មី ដោយគ្មានកំណត់អំឡុងពេល ហើយ មានលក្ខខណ្ឌដូចគ្នានឹងកិច្ចសន្យាដែលបានជួលពីមុនមក លើកលែងតែអំឡុងពេលចេញ។

នៅក្នុងករណីនៃការជួលចលនវត្ថុ ដោយមានកំណត់អំឡុងពេល ភតិបតី មិនចាំបាច់បង្ហាញឆន្ទៈបដិសេធការបន្តជាថ្មី ជាមុននោះទេ ប្រសិនបើគាត់ ចង់បញ្ចប់ភតិសន្យានោះ។

ឧទាហរណ៍ ខ បានជួលរថយន្តមួយគ្រឿងពី ក រយៈពេល ៦ ខែ នៅក្នុងតំលៃ ៥០ ដុល្លា ក្នុង ១ ខែ។ ក្រោយពីរយៈពេល ៦ ខែ បានកន្លងផុតទៅ ខ នៅតែបន្តបើករថយន្តនោះទៀត ហើយ ក មិនបានធ្វើការតវ៉ា ទោះបីជាគាត់ បានដឹងថាហេតុថា អំឡុងពេល ត្រូវបានកន្លងហួស ហើយ ខ នៅតែបើកបររថយន្តនោះទៀត។ នៅក្នុងករណីនេះ ភតិសន្យា ត្រូវបានសន្មតថាជា ភតិសន្យា ដែលបានបន្តសាជាថ្មី ដោយគ្មានកំណត់អំឡុងពេល ហើយ ថ្លៃឈ្នួល គឺ ៥០ ដុល្លា ក្នុង ១ ខែ។

គោលគំនិតនៃមាត្រានេះ គឺដើម្បីការពារនូវការរំពឹងទុកជាមុនរបស់ភតិកៈ ក្នុងការបន្តការប្រើប្រាស់លើវត្ថុជួល ប្រសិនបើ ភតិបតី មិនបានធ្វើការតវ៉ា ទោះបីជាគាត់ បានដឹងថាភតិកៈ បានបន្តការប្រើប្រាស់ និង អាស្រ័យផលលើវត្ថុជួល ក្រោយពីការកន្លងផុតនៃអំឡុងពេល។ ផ្ទុយទៅវិញ ប្រសិនបើ ភតិបតី ត្រូវធ្វើការតវ៉ា នៅក្នុងអំឡុងពេលដ៏ខ្លី ដូចជា ពីរ ឬ បីម៉ោង ឬក៏ ភតិសន្យា ត្រូវបានសន្មតថាជាភតិសន្យាដែលត្រូវបានបន្តជាថ្មី ហើយ វានឹងដាក់បន្ទុកដ៏ធ្ងន់ធ្ងរដល់ភតិបតី។ ដូច្នេះ ចៅក្រម ត្រូវធ្វើការសំរេចពីអំឡុងពេលសមរម្យ ដោយធ្វើការពិចារណាទៅលើស្ថានភាពជាក់ស្តែងនៃភតិសន្យា។ សំរាប់ជាការយោង ក្រមរដ្ឋប្បវេណីប្រទេសអាឡឺម៉ង់ បញ្ញត្តថា ភតិបតី ត្រូវធ្វើការតវ៉ា នៅក្នុងអំឡុងពេល ២ សប្តាហ៍។

### ៤.៣ ការស្នើសុំអោយរំលាយភតិសន្យាដែលពុំមានកំណត់អំឡុងពេល

មានភតិសន្យាខ្លះ បានបង្កើតឡើង ដោយពុំមានកំណត់អំឡុងពេលបញ្ចប់ទេ ករណីបែបនេះ អាចបង្កជាបញ្ហាដល់ភាគីម្ខាងទៀតដែលទន់ខ្សោយ ដោយសារតែភាគីម្ខាងទៀត ចង់រំលាយភតិសន្យា ហើយ ភាគី ដែលទន់ខ្សោយនោះ មិនអាចត្រៀមលក្ខណៈដើម្បីរៀបចំខ្លួនជាមុនបាន។ ដូចនេះ ដើម្បីការពារផលវិបាក ដែលកើតមានឡើង ទើបមាត្រា ៦១៥ បានបញ្ញត្តថា បើពុំបានកំណត់អំឡុងពេលជួលនៅក្នុងកិច្ចសន្យាទេ ភាគីម្ខាងទៀត ក៏អាចសុំរំលាយភតិសន្យានៅពេលណាក៏បាន ហើយភតិសន្យានោះ នឹងត្រូវបញ្ចប់នៅក្នុង (១) អំឡុងពេល ១ ថ្ងៃ បានកន្លងផុត គិតចាប់ពីពេលស្នើសុំឱ្យរំលាយទៅចំពោះចលនវត្ថុ (២) អំឡុងពេល ៣ ខែ បានកន្លងផុតទៅ គិតចាប់ពីពេលស្នើសុំឱ្យរំលាយចំពោះអាគារ និង (៣) ១ ឆ្នាំ បានកន្លងផុតទៅគិតចាប់ពីពេលស្នើសុំឱ្យរំលាយចំពោះដីធ្លី។ ហើយ បញ្ញត្តិនេះ ក៏បានចែងថា ចំពោះភតិសន្យាដីធ្លី ដែលមានរដូវប្រមូលផល ភតិសន្យានោះ នឹងត្រូវបញ្ចប់ នៅមុនការចាប់ផ្តើមធ្វើកសិកម្ម សំរាប់រដូវបន្ទាប់។

ហើយទោះបីជាភាគី កំណត់ពេលសុំរំលាយភតិសន្យាតិចជាងអំឡុងពេល ដែលមានចែងនៅក្នុងមាត្រា ៦១៥ ក៏ដោយ ក៏ចាត់ទុកថាភតិសន្យា នឹងរំលាយតាមលក្ខខណ្ឌក្នុងមាត្រា ៦១៥ នេះដដែល។

ឧទាហរណ៍ ក ជួលអាគារមួយពី ខ ដោយពុំមានកំណត់អំឡុងពេលបញ្ចប់ទេ។ ប្រសិនបើ ក ជូនដំណឹងពីការបញ្ចប់ទៅអោយ ខ ដែលបានកំណត់ថា ក បញ្ចប់ភតិសន្យា បន្ទាប់ពីរយៈពេល ២ ខែ បានកន្លងផុតទៅ ដូច្នេះកិច្ចសន្យា មិនត្រូវបានបញ្ចប់ឡើយ នៅមុនរយៈពេល ៣ ខែ កន្លងផុត។

ទោះបីជា នៅក្នុងករណីដែលភាគី បានកំណត់អំឡុងពេលសំរាប់ការជួល ប្រសិនបើ ភាគីម្ខាង ឬ ភាគីទាំងសងខាង បានរក្សាទុកសិទ្ធិអំណាចអនុវត្តការរំលាយកិច្ចសន្យាក្នុងអំឡុងពេលជួលនោះ បញ្ញត្តិនៃមាត្រា ៦១៥ ត្រូវយកមកអនុវត្តដូចគ្នា ( មាត្រា ៦១៦) ។

## ៤.៤ ការបញ្ចប់ដោយសារបាត់បង់នូវវត្ថុជួល

ដោយសារវត្ថុជួល គឺជាវត្ថុមួយ ដែលកំណត់ជាក់លាក់ នៅពេលបាត់បង់វត្ថុជួល ភតិសន្យា ត្រូវនឹងបញ្ចប់ព្រោះតែគោលបំណងនៃភតិសន្យាមិនអាចសំរេចទៅបាន។ ទន្ទឹមនឹងនេះ នៅពេលដែលវត្ថុជួល ត្រូវបាត់បង់ ដោយសារតែកំហុសរបស់ភាគីណាមួយ យោងតាមមាត្រា ៣៩៨ កថាខណ្ឌទី ១ ភាគីដែលមានកំហុស ត្រូវទទួលខុសត្រូវសងសំណងនៃការខូចខាតដែលកើតឡើង។

ខុសគ្នាពីកិច្ចសន្យាលក់ទិញ នៅក្នុងករណីនៃកិច្ចសន្យាដែលបន្ត ដូចជាភតិសន្យា គឺមិនមានលទ្ធភាពក្នុងការពិចារណាថា មានតែកាតព្វកិច្ចបង់ថ្លៃឈ្នួល នៅមាន ប្រសិនបើកម្មវត្ថុ ត្រូវបានបាត់បង់។ ដូច្នេះ ភតិសន្យា ត្រូវបញ្ចប់ ដោយមិនមានការបង្ហាញឆន្ទៈទេ ប្រសិនបើកម្មវត្ថុនៃភតិសន្យា ត្រូវបានបាត់បង់។

ឧទាហរណ៍ ក បានជួលផ្ទះអោយទៅ ខ ប៉ុន្តែ ផ្ទះនោះ ត្រូវភ្លើងឆេះអស់ ដោយសារតែការធ្វេសប្រហែសរបស់ ក ធ្វើឱ្យចង្ក្រានហួតសផ្ទុះ។ នៅក្នុងករណីនេះ ភតិសន្យារវាង ក និង ខ ត្រូវបញ្ចប់ ហើយ ខ ត្រូវទទួលខុសត្រូវសងសំណងការខូចខាតទៅអោយ ក។

## ៤.៥ ការរំលាយភតិសន្យា ដោយសារការមិនអនុវត្តកាតព្វកិច្ច

យោងតាមមាត្រា ៤០៧ បើភាគីណាម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញ បំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ភាគីម្ខាងទៀត អាចរំលាយបានភ្លាម។ មាត្រានេះ អាចអនុវត្តចំពោះភតិសន្យាបាន ដោយសារតែភតិសន្យា គឺជាកិច្ចសន្យាអញ្ញមញ្ញ។

ឧទាហរណ៍ នៅក្នុងករណីដែល ភតិកៈ មិនបង់ថ្លៃឈ្នួលនៃភតិសន្យា អស់រយៈពេលយ៉ាងយូរ នោះភតិបតីមានសិទ្ធិរំលាយ កិច្ចសន្យានោះ ព្រោះ ការមិនបង់ថ្លៃឈ្នួល អាចត្រូវបានចាត់ទុកថាជា ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ។ នៅក្នុងករណីនេះ ការមិនអនុវត្តកាតព្វកិច្ច គឺមានលក្ខណៈជាសារធាតុ ដែល ការជំនឿទុកចិត្តរវាងភាគី ត្រូវបានបំផ្លាញ និង មិនអាចជឿជាក់ថានឹងអនុវត្តកាតព្វកិច្ចនាពេលអនាគត ដូច្នេះ ចំនុច (ឃ) នៃមាត្រា ៤០៨

កថាខណ្ឌទី ១ អាចយកមកអនុវត្ត។ ក៏ប៉ុន្តែ វា អាស្រ័យទៅលើការអនុវត្តនៅប្រទេសកម្ពុជា ដែលថា អំឡុងពេលនៃការមិនបង់ថ្លៃឈ្នួលកិរិតណា ទើបអាចចាត់ទុកថាជា ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ នៅក្នុងភតិសន្យា។

# ផ្នែកទី ៩

# ការខ្ចីបរិភោគ

## ១. គោលបំណង

ការខ្ចីបរិភោគ គឺសំដៅលើកិច្ចសន្យាដែលភាគីម្ខាង ហៅថា "អ្នកអោយខ្ចី" ដែលមានទ្រព្យផ្ទាល់ខ្លួន បានប្រគល់ទ្រព្យនោះអោយទៅភាគីម្ខាងទៀត ហៅថា "អ្នកខ្ចី" ដោយមានការព្រមព្រៀងគ្នាថា អ្នកខ្ចី ត្រូវប្រើប្រាស់ទ្រព្យដែលបានខ្ចីនោះ ហើយត្រូវសងទៅវិញ នៅពេលដែលផុតអំឡុងពេលខ្ចីនូវវត្ថុ ដែលមានប្រភេទ គុណភាព និង ចំនួនស្មើគ្នានឹងវត្ថុដែលបានទទួលពីអ្នកឱ្យខ្ចីនោះ (មាត្រា ៥៧៨)។ វា គឺជាកិច្ចសន្យាទ្វេភាគី ព្រោះអ្នកឱ្យខ្ចីត្រូវមានកាតព្វកិច្ចប្រគល់វត្ថុ និង អ្នកខ្ចី ត្រូវមានកាតព្វកិច្ចសងវត្ថុវិញផងដែរ។

**ឧទាហរណ៍** : អ្នកខ្ចី បានខ្ចីស្រូវ ហើយ អ្នកខ្ចី មានសេរីភាព ក្នុងការប្រើប្រាស់ស្រូវនោះបាន ហើយអ្នកខ្ចីមានករណីយកិច្ចសងទៅអ្នកអោយខ្ចីវិញនូវស្រូវដែលមាន ប្រភេទ គុណភាព និង បរិមាណដូចគ្នា ក្រោយពីអំឡុងពេលកំណត់សងបានកន្លងផុតទៅ។

កិច្ចសន្យាខ្ចីបរិភោគ ចែកចេញជាពីរប្រភេទ :

- កិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ គឺជាកិច្ចសន្យាដែលយកតំលៃថ្នូរ
- កិច្ចសន្យាខ្ចីបរិភោគដោយមិនយកការប្រាក់ គឺជាកិច្ចសន្យាដែលមិនយកតំលៃថ្នូរ

ភាពខុសគ្នារវាង **កិច្ចសន្យាខ្ចីបរិភោគ, ភតិសន្យា** និង **កិច្ចសន្យាអោយប្រើ** :

| **កិច្ចសន្យាខ្ចីបរិភោគ** | **ភតិសន្យា** | **កិច្ចសន្យាអោយប្រើ** |
|---|---|---|
| - ប្រគល់វិញនូវវត្ថុដែលមានប្រភេទ គុណភាព និងបរិមាណដូចគ្នា (មិនចាំបាច់វត្ថុដើមទេ) | - ត្រូវប្រគល់វិញនូវវត្ថុដដែល (វត្ថុដូចមុន) | - ត្រូវប្រគល់ទិញនូវវត្ថុដដែល (វត្ថុដូចមុន) |
| - បានទទួលនូវការផ្ទេរកម្មសិទ្ធិ | - កម្មសិទ្ធិមិនត្រូវបានផ្ទេរ | - កម្មសិទ្ធិ មិនត្រូវបានផ្ទេរ |
| - មិនយក ឬ យកតំលៃថ្នូរ | - យកតំលៃថ្នូរ | - មិនយកតំលៃថ្នូរ |

## ២. លក្ខខណ្ឌ

កិច្ចសន្យាខ្ចីបរិភោគ បង្កើតឡើងដោយការព្រមព្រៀងរបស់ភាគីទាំងសងខាង (មាត្រា ៥៧៩)។ ភាគី ក៏អាចបង្កើតកិច្ចសន្យា ដែលមានកម្មវត្ថុជាការសងការប្រាក់ តាមការព្រមព្រៀងបាន។ ក៏ប៉ុន្តែ ការព្រមព្រៀង

បង្កើតសិទ្ធិលើបំណុលនៃការប្រាក់ ពុំមានអានុភាពឡើយ ប្រសិនបើពុំបានធ្វើតាមលិខិតជាលាយល័ក្ខណ៍អក្សរ ដោយមានចុះហត្ថលេខារបស់អ្នកខ្ចី ( មាត្រា ៥៨៣ កថាខណ្ឌទី ៣) ។

ភាគី អាចបង្កើតកិច្ចសន្យាខ្ចីបរិភោគ ដោយមិនកំណត់អំឡុងពេលក្នុងការសងបាន។ ក៏ប៉ុន្តែ វា មានភាពចាំបាច់ក្នុងការកំណត់ពី គុណភាព ចំនួន និង ប្រភេទនៃកម្មវត្ថុ ដើម្បីបង្កើតកិច្ចសន្យាខ្ចីបរិភោគ។

វត្ថុដែលបានកំណត់ជាក់លាក់ ដូចជាអចលនវត្ថុ មិនអាចធ្វើជាកម្មវត្ថុនៃកិច្ចសន្យាខ្ចីបរិភោគនោះទេ ព្រោះ វា មិនអាចជំនួសបាន។

## ៣. ភារកិច្ច និង សិទ្ធិរបស់អ្នកអោយខ្ចី

### ៣.១ ភារកិច្ចអោយខ្ចីវត្ថុដែលជាកម្មវត្ថុ

អ្នកអោយខ្ចី មានករណីយកិច្ចប្រគល់វត្ថុអោយអ្នកខ្ចីប្រើប្រាស់វត្ថុ ដោយសមស្របតាមកិច្ចសន្យា រីឯអ្នកខ្ចី អាចប្រើប្រាស់ អាស្រ័យផល និង ចាត់ចែងវត្ថុ (លក់) ដោយសេរីបាន ( មាត្រា ៥៨៧) ។ អ្នកខ្ចី បានទទួលកម្មសិទ្ធិលើវត្ថុនោះ។

### ៣.២ ការទទួលខុសត្រូវក្នុងការធានារបស់អ្នកអោយខ្ចី

#### ៣.២.១ នៅក្នុងករណីដែលអ្នកអោយខ្ចីប្រគល់វត្ថុដែលជារបស់អ្នកដទៃ

***ក. ក្នុងករណីដែលការខ្ចីបរិភោគ ដោយភ្ជាប់ការប្រាក់***

ក្នុងកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់រវាងអ្នកអោយខ្ចី និង អ្នកខ្ចី ហើយនៅពេលប្រគល់វត្ថុ ដែលមិនមែនជាវត្ថុរបស់អ្នកអោយខ្ចី វា គឺជាវត្ថុរបស់តតិយជនណាម្នាក់ អ្នកអោយខ្ចី ត្រូវមានករណីយកិច្ចធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុនោះ ហើយផ្ទេរទៅអោយអ្នកខ្ចី បើធ្វើលទ្ធកម្មមិនបានទេ អ្នកអោយខ្ចី ត្រូវរកវត្ថុផ្សេងៗ ជំនួសដែលមាន ប្រភេទ គុណភាព និង បរិមាណ ដូចគ្នា ហើយដែលស្ថិតនៅក្រោមកម្មសិទ្ធិរបស់អ្នកអោយខ្ចី។ ទោះបីវត្ថុ ដែលប្រគល់នោះជារបស់អ្នកផ្សេងក៏ដោយ ក៏កិច្ចសន្យាខ្ចីបរិភោគនោះ មិនមែនក្លាយជាមោឃៈទេ។ ប៉ុន្តែ អ្នកខ្ចី មិនមានសិទ្ធិទាមទារអោយប្រគល់វត្ថុជំនួសទេ នៅក្រោយពេលដែលបរិភោគវត្ថុនោះ ( មាត្រា ៥៨៨ កថាខណ្ឌទី ១) ។

ម្យ៉ាងវិញទៀត បើអ្នកអោយខ្ចី មិនអាចប្រគល់វត្ថុនោះបាន ឬ មិនអាចរកវត្ថុផ្សេងមកជំនួសបានទេ អ្នកខ្ចី មានសិទ្ធិរំលាយកិច្ចសន្យាខ្ចីបរិភោគនោះបាន ទោះបីអ្នកខ្ចីនោះសុចរិត ឬ ទុច្ចរិតក៏ដោយ ( មាត្រា ៥៨៨ កថាខណ្ឌទី ២) ។

ទន្ទឹមនឹងនេះ ប្រសិនបើ អ្នកខ្ចី ដែលបានទទួលការប្រគល់វត្ថុខ្ចី ដោយមិនបានដឹងថា អ្នកអោយខ្ចី មិនមានកម្មសិទ្ធិទេ អាចទាមទារសំណងនៃការខូចខាតពីអ្នកអោយខ្ចីបាន ( មាត្រា ៥៨៨ កថាខណ្ឌទី ៣) ។

### ខ. កិច្ចសន្យាខ្ចីបរិភោគដោយមិនយកការប្រាក់

ចំពោះកិច្ចសន្យាខ្ចីបរិភោគដោយមិនយកការប្រាក់ ប្រសិនបើអ្នកអោយខ្ចី បានដឹងថា វត្ថុ ដែលត្រូវប្រគល់នោះជារបស់ដទៃ ប៉ុន្តែ អ្នកអោយខ្ចី មិនបានជូនដំណឹងដល់អ្នកខ្ចីទេ នោះ អ្នកអោយខ្ចី ក៏ត្រូវទទួលខុសត្រូវដូចដែលមានចែងនៅក្នុងកថាខណ្ឌទី ១ ដល់ ទី ៣ នៃមាត្រា ៥៨៨។

ចំពោះករណីទាំងពីរខាងលើ ចំណុច *ក* និង ចំណុច *ខ* បើអ្នកខ្ចី បានសងវត្ថុ ដែលត្រូវបានប្រគល់អោយ ឬ សងតំលៃនៃវត្ថុនោះ អោយទៅម្ចាស់កម្មសិទ្ធិ នោះ អ្នកខ្ចី ត្រូវបានរួចផុតពីករណីយកិច្ច សងចំពោះអ្នកអោយខ្ចី (មាត្រា ៥៨៨ កថាខណ្ឌទី ៥)។

### គ. សិទ្ធិរំលាយរបស់អ្នកអោយខ្ចីវត្ថុដទៃ

ប្រសិនបើអ្នកអោយខ្ចី បានប្រគល់វត្ថុ ដែលកម្មសិទ្ធិរបស់អ្នកដទៃ ទៅអោយអ្នកខ្ចី ដោយមិនបានដឹងថាជាវត្ថុរបស់អ្នកដទៃ ហើយ គាត់ មិនអាចផ្ទេរកម្មសិទ្ធិលើវត្ថុ ឬ វត្ថុជំនួស ទៅអោយអ្នកខ្ចីបាន នោះ គាត់ អាចរំលាយកិច្ចសន្យា។ ក៏ប៉ុន្តែ ប្រសិនបើ អ្នកខ្ចី ដែលបានធ្វើសកម្មភាពដោយសុចរិតនៅពេលប្រគល់ មានសិទ្ធិទាមទារសំណងនៃការខូចខាតបាន ដោយផ្អែកលើមាត្រា ៥៨៨ ហើយ ការរំលាយកិច្ចសន្យានេះ ត្រូវបានអនុញ្ញាត លុះត្រាតែបានសងសំណងនៃការខូចខាតនោះ (មាត្រា ៥៨៩)។

ឧទាហរណ៍ **ក** បានប្រគល់អង្ករ ដោយមិនបានដឹងថា អង្ករនោះ គឺជាកម្មសិទ្ធិរបស់ **គ**។ **ខ** គ្រប់គ្រងលើភោជនីយដ្ឋានមួយ ប៉ុន្តែ គាត់ មិនអាចបើកភោជនីយដ្ឋានបានក្នុងរយៈពេល ២ ថ្ងៃ ព្រោះ គាត់ ត្រូវសងអង្ករនោះទៅអោយ **គ** វិញ ដោយផ្អែកតាមាត្រា ៥៨៨ កថាខណ្ឌទី ៣។ នៅក្នុងករណីនេះ **ក** អាចរំលាយកិច្ចសន្យាបាន ប៉ុន្តែ គាត់ ត្រូវសងប្រាក់ចំណូលនៅក្នុងរយៈពេល ២ ថ្ងៃ ទៅអោយ **ខ** នៅមុនពេលរំលាយ។

## ៣.២.២ នៅក្នុងករណីដែលវត្ថុត្រូវបានប្រគល់នោះ មានវិការៈ

### ក. ក្នុងករណីនៃការខ្ចីបរិភោគ ដោយភ្ជាប់ការប្រាក់ :

អ្នកអោយខ្ចី ត្រូវមានកាតព្វកិច្ចប្រគល់វត្ថុ ដោយគ្មានវិការៈ (មាត្រា ៥២៣ និង មាត្រា ៥២៩)។ ដូច្នេះប្រសិនបើអ្នកអោយខ្ចី បានប្រគល់វត្ថុទៅអោយអ្នកខ្ចី តាមកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ ហើយវត្ថុ ដែលប្រគល់នោះ មានវិការៈអាថិកំបាំង និង អ្នកខ្ចី ដែលបានទទួលវត្ថុនោះ ដោយមិនបានដឹងអំពីអាថិកំបាំងនោះ អាចទាមទារអោយប្តូរជាមួយនឹងវត្ថុដែលគ្មានវិការៈ ព្រមជាមួយនឹងសំណងការខូចខាតបាន ប្រសិនបើមាន (មាត្រា ៥៩០ កថាខណ្ឌទី ១)។

### ខ. នៅក្នុងករណីនៃការខ្ចីបរិភោគដែលមិនមានការប្រាក់ :

នៅក្នុងករណីនៃការខ្ចីបរិភោគដែលមិនមានការប្រាក់ ការទទួលខុសត្រូវរបស់អ្នកអោយខ្ចី ត្រូវបានកាត់បន្ថយ ។ ជាគោលការណ៍ ប្រសិនបើ អ្នកអោយខ្ចី បានប្រគល់វត្ថុដែលមានវិការៈ ទៅអោយអ្នកខ្ចី នោះអ្នកខ្ចី អាចសងវត្ថុដែលមានវិការៈដូចគ្នាទៅអ្នកអោយខ្ចីវិញ។ ក៏ប៉ុន្តែ វា មានការលំបាក និង ពេលខ្លះវា ហាក់ដូចជា មិនសមហេតុផល ក្នុងការស្វែងរកវត្ថុ ដែលមានវិការៈប្រហាក់ប្រហែលគ្នា។ ដូច្នេះ ក្រមរដ្ឋប្បវេណី បានចែងថា អ្នកខ្ចី អាចសងជាតំលៃស្មើនឹងវត្ថុ ដែលមានវិការៈបាន ( មាត្រា ៥៩០ កថាខណ្ឌទី ២) ។ ឧទាហរណ៍ **ក** បានប្រគល់អង្ករ ១០ គីឡូក្រាមអោយទៅ **ខ** តាមរយៈការខ្ចីបរិភោគដោយគ្មានការប្រាក់ ប៉ុន្តែ នៅក្នុងនោះមានអង្ករ ២ គីឡូក្រាម មានគុណភាពអន់ ហើយដែលតំលៃរបស់វា មានតែ ១ ភាគ ១០ នៃ តំលៃទីផ្សារតែប៉ុណ្ណោះ។ នៅក្នុងករណីនេះ **ខ** អាចសងអង្ករ ៨ គីឡូក្រាម ដែលមានគុណភាពដូចអង្ករដែលគាត់ បានទទួល និង តំលៃ ១ ភាគ ១០ នៃ តំលៃទីផ្សារ ។

ទន្ទឹមនឹងនេះ ប្រសិនបើអ្នកអោយខ្ចី បានដឹងអំពីវិការៈនៃវត្ថុនោះ មុនធ្វើការប្រគល់ ហើយបានលាក់ចំពោះអ្នកខ្ចី នោះ អ្នកអោយខ្ចី ត្រូវមានកាតព្វកិច្ចប្តូរវត្ថុ ដែលគ្មានវិការៈ ហើយនិង សងសំណងការខូចខាតដល់អ្នកខ្ចី ដែលកើតឡើង ដោយសារវត្ថុដែលមានវិការៈនោះ ( មាត្រា ៥៩០ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២) ។

### ៣.៣ ការទាមទារឱ្យសងមកវិញ នៅក្នុងករណីដែលស្ថានភាពសេដ្ឋកិច្ចរបស់អ្នកខ្ចី បានធ្លាក់ចុះយ៉ាងខ្លាំង

នៅពេលកិច្ចសន្យាខ្ចីបរិភោគបានបង្កើតឡើងរវាងអ្នកអោយខ្ចី និង អ្នកខ្ចី ហើយ ស្ថានភាពសេដ្ឋកិច្ចរបស់អ្នកខ្ចីក្នុងការអនុវត្តកាតព្វកិច្ចសង ក្លាយជាមានឧបសគ្គ នៅមុនពេលប្រគល់វត្ថុដែលជាកម្មវត្ថុ អ្នកអោយខ្ចី អាចរំលាយកិច្ចសន្យានោះបាន ( មាត្រា ៥៨១) ។

បន្ទាប់ ចុះចំពោះករណី ដែលស្ថានភាពសេដ្ឋកិច្ចរបស់អ្នកខ្ចី បានធ្លាក់ចុះ នៅក្រោយពេលប្រគល់ តើវានឹងទៅជាយ៉ាងណា? តើ អ្នកអោយខ្ចី អាចទាមទារវត្ថុត្រឡប់មកវិញ នៅមុនពេលកំណត់សង ដោយផ្អែកលើមូលហេតុនៃការធ្លាក់ចុះនៃទ្រព្យធនរបស់អ្នកខ្ចីបាន ដែរ ឬ ទេ ?

អ្នកខ្ចី មានសិទ្ធិប្រើប្រាស់ វត្ថុដែលបានផ្តល់អោយ រហូតដល់ពេលប្រគល់។ ឬ និយាយម្យ៉ាងទៀត គាត់មិនចាំបាច់ប្រគល់វត្ថុ នៅមុនកាលបរិច្ឆេទសងនោះទេ។ ចំណុចនេះ ត្រូវបានអោយឈ្មោះថា "ផលប្រយោជន៍នៃការកំណត់ពេលវេលា" ។ យោងតាមមាត្រា ៥៩៤ កថាខណ្ឌទី ១ អ្នកអោយខ្ចី មិនត្រូវបានអនុញ្ញាតអោយធ្វើការទាមទារសងវត្ថុ នៅមុនកាលបរិច្ឆេទសងឡើយ ។ ក៏ប៉ុន្តែ ចំណុចនេះ មិនត្រូវយកមកអនុវត្ត ប្រសិនបើ អ្នកខ្ចី ស្ថិតនៅក្នុងស្ថានភាពនៃចំណុចណាមួយ ដែលមានចែងនៅក្នុងមាត្រា ៣៣១។ ទាក់ទងនឹង "ពេល" ដោយផ្អែកលើមាត្រា ៣៣០ កថាខណ្ឌទី ១ គឺ ការកំណត់ពេល ត្រូវបានសន្មតថា បានជាផលប្រយោជន៍របស់កូនបំណុល។ ដូច្នេះ ទោះបីជាស្ថានភាពទ្រព្យសម្បត្តិរបស់អ្នកខ្ចី ធ្លាក់ចុះយ៉ាងណាក៏ដោយ អ្នកអោយខ្ចី មិនអាចទាមទារអោយសងវត្ថុខ្ចី មកវិញបានទេ នៅមុនកាលបរិច្ឆេទប្រគល់ ។

ក៏ប៉ុន្តែ នៅក្នុងករណីដែល ស្ថានភាព ដែលមានចែងនៅក្នុងរាល់ចំណុច នៃមាត្រា ៣៣១ កើតឡើង នោះ កូនបំណុល ត្រូវបាត់បង់ផលប្រយោជន៍នៃការកំណត់ពេល ហើយជាលទ្ធផល គាត់ ត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួនជាបន្ទាន់។ ឧទាហរណ៍ ប្រសិនបើ អ្នកខ្ចី ត្រូវបានប្រកាសថាក្ស័យធន នោះ គាត់ ត្រូវសងវត្ថុខ្ចីមកវិញ ភ្លាម។

ទន្ទឹមនឹងនេះចំណុច ឃ នៃមាត្រានេះ ក៏បានចែងថា ហេតុដែលគូភាគី បានព្រមព្រៀងគ្នា បានកើតឡើង នោះ កូនបំណុល ត្រូវបានបាត់បង់ផលប្រយោជន៍នៃពេលដែរ។

**ឧទាហរណ៍** : "ហេតុដែលគូភាគី បានព្រមព្រៀងគ្នា បានកើតឡើង" ត្រូវបានរាប់បញ្ចូល ដូចជា ការព្រមព្រៀងពិសេស ដែលចែងថា "ប្រសិនបើ មានមូលហេតុ ដែលអ្នកខ្ចី មិនបានបង់ការប្រាក់ ចំនួន ៣ ខែ នោះ អ្នកអោយខ្ចី អាចទាមទារអោយបង់ភ្លាម នូវប្រាក់បំណុល ដែលនៅសល់ទាំងអស់ ដោយមិនចាំបាច់ធ្វើការជូនដំណឹងជាមុននោះទេ" ឬ "នៅក្នុងករណីដែលទ្រព្យសម្បត្តិរបស់អ្នកខ្ចី ត្រូវបានរឹបអូសដោយម្ចាស់បំណុលផ្សេងទៀត នោះ អ្នកខ្ចី ត្រូវបាត់បង់ផលប្រយោជន៍នៃការកំណត់ពេល និង ត្រូវសងបំណុលភ្លាម" ជាអាទិ៍។

## ៤. កាតព្វកិច្ចរបស់អ្នកខ្ចី

### ៤.១ ករណីយកិច្ចត្រូវសងវត្ថុ

ករណីយកិច្ចត្រូវសង គឺជាករណីយកិច្ចចម្បង និង ទូទៅបំផុតរបស់អ្នកខ្ចី ហើយករណីយកិច្ចនេះ គឺត្រូវតែបំពេញឱ្យបាន នៅពេលដែលពេលវេលាកំណត់នៃការសង បានមកដល់ មិនតែប៉ុណ្ណោះ ការសង ត្រូវធ្វើឡើងដោយគោរពតាមគោលការណ៍មួយចំនួន ដែលត្រូវបានកំណត់នៅក្នុងមាត្រា ៥៩១ រហូតដល់ មាត្រា ៥៩៥។

ជាគោលការណ៍ អ្នកខ្ចី ត្រូវមានកាតព្វកិច្ចសងទៅអ្នកឱ្យខ្ចីវិញនូវវត្ថុ ដែលមាន ប្រភេទ គុណភាព និង ចំនួនស្មើនឹងវត្ថុដែលអ្នកខ្ចីបានទទួលការប្រគល់ នៅថ្ងៃ ឬ ពេលវេលាដែលត្រូវសង (មាត្រា ៥៩១ កថាខណ្ឌទី ១)។ ឧទាហរណ៍ថា ប្រសិនបើអ្នកខ្ចី បានខ្ចីស្រូវពូជប្រភេទស្រូវផ្កាម្លិះចំនួន ៥០ គីឡូក្រាម ពីអ្នកឱ្យខ្ចី សំរាប់រយៈពេល ១ ឆ្នាំ និង សន្យាថានឹងឱ្យការប្រាក់ ១០ ភាគរយ ក្នុងមួយឆ្នាំ។ នោះនៅពេលកំណត់នៃការសង មកដល់ អ្នកខ្ចី ត្រូវតែសងនូវស្រូវពូជប្រភេទផ្កាម្លិះ ដែលមានគុណភាព ដូចជា ស្រូវពូជ ដែលខ្លួនបានខ្ចីពីអ្នកឱ្យខ្ចី ក្នុងបរិមាណ ៥០ គីឡូក្រាម និង ការប្រាក់ ៥ គីឡូក្រាម សរុប គឺ ៥៥ គីឡូក្រាម នៅថ្ងៃកំណត់សង។ អ្នកខ្ចី មិនអាចសងនូវវត្ថុ ដែលមានបរិមាណតិចជាង ហើយអ្នកឱ្យខ្ចី ក៏មិនអាចទាមទារឱ្យអ្នកខ្ចីផ្តល់នូវការសងវត្ថុ ដែលមានបរិមាណច្រើនជាងបរិមាណ ដែលបានកំណត់នៅក្នុងកិច្ចសន្យានោះទេ លើកលែងតែភាគីទាំងពីរ បានព្រមព្រៀងគ្នា។ ប្រសិនបើ ការសង មិនបានបំពេញគ្រប់លក្ខខណ្ឌ ដែលបានកំណត់ខាងលើនោះទេ អ្នកឱ្យខ្ចី អាចបដិសេធមិនទទួលយកនូវការសង ដោយមូលហេតុណាមួយ ដូចជា ភាពខុសគ្នានៃប្រភេទ ឬ បរិមាណ ឬ គុណភាព ហើយអ្នកឱ្យខ្ចី អាចទាមទារឱ្យអ្នកខ្ចីទទួលខុសត្រូវ ចំពោះការមិនអនុវត្តកាតព្វកិច្ចនោះបាន ។

មានសំណួរសួថា តើត្រូវធ្វើដូចម្តេចប្រសិនបើតម្លៃនៃវត្ថុនោះមានការប្រែប្រួលនៅមុនពេលសង?

នៅក្នុងករណីដែលបានចោទឡើងខាងលើនេះ អ្នកខ្ចីក៏នៅតែមានកាតព្វកិច្ចសងនូវវត្ថុ ឬ រូបិយវត្ថុត្រឹមកំរិត ដែលខ្លួនបានខ្ចីដដែល បើទោះជាតម្លៃនៃវត្ថុ ឬ រូបិយវត្ថុមានការកើនឡើង ឬ ថយចុះដល់កម្រិតណាក៏ដោយ (មាត្រា ៥៩៣)។ ជាឧទាហរណ៍ ប្រសិនបើនៅពេលខ្ចី មាស ១ គីឡូក្រាម មានតម្លៃ ៥០០ ដុល្លា នៅថ្ងៃទទួលការប្រគល់ ហើយអំឡុងពេលសំរាប់ការខ្ចីបរិភោគ គឺ ២ ឆ្នាំ។ នៅក្នុងករណីនេះ ទោះបីជា តំលៃមាស កើនដល់ ១,០០០ ដុល្លា ក្នុង ១ គីឡូក្រាម ក៏អ្នកខ្ចី ត្រូវសងមាស ១ គីឡូក្រាម ដដែល។

### ៩.១.១ ពេលវេលានៃការសង

ដោយហេតុថា ការខ្ចីបរិភោគ ត្រូវបានបែងចែកជា ពីរប្រភេទ គឺ ការខ្ចីបរិភោគ ដែលមានកំណត់អំឡុងពេល និង ការខ្ចីបរិភោគ ដែលពុំមានកំណត់អំឡុងពេល។ ឬនិយាយម្យ៉ាងទៀត វា មិនមានភាពចាំបាច់ក្នុងការកំណត់ពីកាលបរិច្ឆេទសង ដើម្បីបង្កើតកិច្ចសន្យាខ្ចីបរិភោគនោះទេ។

ចំពោះ **ការខ្ចីបរិភោគដែលមានកំណត់អំឡុងពេល** អ្នកឱ្យខ្ចី មិនអាចទាមទារអ្នកខ្ចីសងនូវវត្ថុ ដែលបានខ្ចីមុនកាលបរិច្ឆេទ ដែលបានកំណត់នៅក្នុងកិច្ចសន្យានោះបានឡើយ (មាត្រា ៥៩៤ កថាខណ្ឌទី ១)។ ប៉ុន្តែ ក៏នៅមានករណី លើកលែងមួយចំនួន ដែលអាចអោយអ្នកឱ្យខ្ចីទារឱ្យសងមុនពេលកំណត់មកដល់បាន ដូចជា៖ ករណីដែលកូនបំណុល (អ្នកខ្ចី) ត្រូវបានប្រកាសក្ស័យធន, កូនបំណុល បានធ្វើឱ្យខូចខាតប្រាតិភោគ (វត្ថុធានាបំណុល), កូនបំណុល មានករណីយកិច្ចត្រូវដាក់ប្រាតិភោគ ប៉ុន្តែខ្លួនមិនបានបំពេញករណីយកិច្ចនេះ ឬ ហេតុ ដែលគូភាគីបានព្រមព្រៀងគ្នាបានកើតឡើង (មាត្រា ៣៣១)។

ចំពោះ **ការខ្ចីបរិភោគដែលពុំមានកំណត់អំឡុងពេល** អ្នកឱ្យខ្ចី អាចធ្វើការដាស់តឿនដល់អ្នកខ្ចីឱ្យធ្វើការសងដោយកំណត់ "អំឡុងពេលសមរម្យ" បាន (មាត្រា ៥៩៤ កថាខណ្ឌទី ២)។ តើអំឡុងពេលសមរម្យ មានរយៈពេលប៉ុន្មាន? វា ពុំមានមាត្រាណាមួយ នៅក្នុងក្រមរដ្ឋប្បវេណី ដែលចែងអំពីការកំណត់អំឡុងពេលសមរម្យក្នុងការដាស់តឿននេះទេ ហេតុនេះ ការកំណត់អំឡុងពេលសមរម្យនេះ គឺជាអំឡុងពេល ដែលត្រូវការចាំបាច់សំរាប់អ្នកខ្ចី ក្នុងការរៀបចំ និង សងនូវវត្ថុ ក្រោយពីបានទទួលនូវការដាស់តឿនពីអ្នកឱ្យខ្ចី។ វា ត្រូវបានសំរេចដោយធ្វើការពិចារណា ទៅលើខ្លឹមសារនៃកិច្ចសន្យា ឬ ចំនួន និង ប្រភេទនៃវត្ថុ ដែលបានខ្ចី។

ចំពោះ **ការខ្ចីបរិភោគដែលគ្មានការប្រាក់** អ្នកខ្ចី អាចធ្វើការសងវត្ថុទៅអ្នកឱ្យខ្ចីវិញ នៅពេលណា ក៏បាន (មាត្រា ៥៩៤ កថាខណ្ឌទី ៣)។ ប៉ុន្តែមានសំណួរមួយ លើកឡើងថា នៅក្នុងកិច្ចសន្យាខ្ចីបរិភោគ ដែលគ្មានការប្រាក់ តើអ្នកខ្ចី អាចសងវត្ថុទៅអ្នកឱ្យខ្ចីវិញ មុនពេលកំណត់សងបាន ដែរ ឬ ទេ? គេ អាចយល់បានថា អ្នកខ្ចីមិនអាចសងវត្ថុ នៅមុនកាលបរិច្ឆេទសងបានទេ ព្រោះ ភាគី ត្រូវធ្វើតាមការព្រមព្រៀង ប្រសិនបើមាន។ ជាការពិត ប្រសិនបើ អ្នកឱ្យខ្ចី យល់ព្រមជាមួយនឹងការសងមុនពេលកំណត់ នោះ អ្នកខ្ចី អាចសងវត្ថុ នៅមុនកាលបរិច្ឆេទនៃការសង ព្រោះ ពួកគេ បានកំណត់នូវកាលបរិច្ឆេទថ្មីមួយ។

ចំពោះ **ការខ្ចីបរិភោគដែលមានការប្រាក់** អ្នកខ្ចី អាចសងវត្ថុ នៅមុនកាលបរិច្ឆេទសង ដែលបានកំណត់ដោយកិច្ចសន្យាបាន។ ប៉ុន្តែ នៅក្នុងករណីដែលធ្វើអោយមានការខូចខាត ដល់អ្នកអោយខ្ចី ដោយសារការសងនោះ អ្នកខ្ចី ត្រូវសងសំណងនៃការខូចខាត ( មាត្រា ៥៩៤ កថាខណ្ឌទី ៤) ។ ហើយ វា គឺជាបញ្ហា ថាតើ ការប្រាក់ដែលត្រូវបានគណនា រហូតដល់កាលបរិច្ឆេទនៃការសង ត្រូវបានគេរាប់បញ្ចូលទៅក្នុងការខូចខាត ដែលមានចែងនៅក្នុងមាត្រា ៥៩៤ កថាខណ្ឌទី ៤ វាក្យខណ្ឌទី ២។ ឧទាហរណ៍ ប្រសិនបើ អ្នកខ្ចី **ខ** បានខ្ចីប្រាក់ ២០,០០០ ដុល្លា ដោយមានការប្រាក់ ២០០ ដុល្លា ក្នុង ១ ខែ ( សន្មតថា អត្រាការប្រាក់នេះ មិនផ្ទុយនឹងច្បាប់ទេ) ។ ការប្រាក់នេះ គឺជាចំនួន ដ៏ច្រើនសំរាប់អ្នកឱ្យខ្ចី **ក** ហើយ **ក** បានរំពឹងទុកថា នឹងទទួលបានការប្រាក់យ៉ាងច្រើនពី **ខ**។ ក៏ប៉ុន្តែ **ខ** បានសងប្រាក់ នោះ ១ ឆ្នាំ មុនកាលបរិច្ឆេទសង ព្រោះ គាត់ មិនចង់ខាតបង់ការប្រាក់ច្រើន និង គាត់ អាចមានលទ្ធភាពក្នុងការសង។ ចំណុចនេះ បានធ្វើអោយ **ក** បាត់បង់នូវប្រាក់ដែលរំពឹងថានឹងបានទទួល។ នៅក្នុងករណីនេះ តើ **ខ** ត្រូវបង់ការប្រាក់ ២,៤០០ ដុល្លា (២០០ ដុល្លា x ១២ ខែ) ដែល **ក** បានរំពឹងទុកថានឹងបានទទួល ដែរ ឬទេ? ចំណុចនេះ វា អាស្រ័យ ទៅលើការអនុវត្តនៅកម្ពុជា ក៏ប៉ុន្តែ នៅក្នុងការអនុវត្តនៅប្រទេសជប៉ុន ការប្រាក់មិនត្រូវបានគេចាត់ទុកថា ជាការ ខូចខាតនោះទេ។ ព្រោះ ការប្រាក់ ត្រូវបានចាត់ទុកថាជា តំលៃថ្នូរនៅក្នុងការប្រើប្រាក់ ២០,០០០ ដុល្លា។ ដូច្នេះ **ខ** មិនត្រូវបង់ការប្រាក់ ២,៤០០ ដុល្លា នោះទេ ទោះបីជា គាត់ បានសងមុន ១ ឆ្នាំ ក៏ដោយ ព្រោះ **ក** អាចប្រើប្រាក់ ២០,០០០ ដុល្លា នៅមុន ១ ឆ្នាំ ដែរ។ គាត់ អាចផ្តល់ប្រាក់នេះទៅអោយបុគ្គលដទៃទៀតខ្ចីបាន ហើយ អាចទទួល បានការប្រាក់។ ដូច្នេះ នៅក្នុងការអនុវត្តនៅប្រទេសជប៉ុន ការប្រាក់មិនត្រូវបានចាត់ទុកថាជាការខូចខាតទេ។

### ៤.១.២ ទីកន្លែងនៃការសង

ភាគី អាចព្រមព្រៀងគ្នាក្នុងការកំណត់ អំពីទីកន្លែងជាក់លាក់ណាមួយ ដើម្បីធ្វើការសង ប៉ុន្តែប្រសិនបើភាគី មិនបានព្រមព្រៀងគ្នាកំណត់ អំពីទីកន្លែងនៃការសងទេ នោះទីកន្លែងនៃការសង គឺត្រូវធ្វើឡើងនៅលំនៅដ្ឋានរបស់អ្នកឱ្យខ្ចី ( មាត្រា ៥៩៥) ។ នេះ គឺជាសេចក្តីបកស្រាយមាត្រា ៤៤៥ វាក្យខណ្ឌទី ២។

### ៤.១.៣ ករណីដែលអ្នកខ្ចីមិនអាចសងវត្ថុបាន

ជាទូទៅ អ្នកខ្ចី មានកាតព្វកិច្ចត្រូវបង់ប្រាក់ដែលជាតម្លៃវត្ថុដែលបានខ្ចី នៅកាលបរិច្ឆេទនៃការសង នៅពេលវេលា និង ទីកន្លែង ដែលត្រូវសង នៅក្នុងករណីដែល អ្នកខ្ចី ពុំអាចសងនូវវត្ថុ ដែលមានប្រភេទ គុណភាព និង ចំនួន ស្មើគ្នាបាន ( មាត្រា ៥៩២ កថាខណ្ឌទី ១) ។ ឧទាហរណ៍ **ក** បានខ្ចី ត្រីសណ្តាយពី **ខ** ចំនួន ១០ គីឡូក្រាម ដោយមាន ឬ គ្មានកំណត់អឡុងពេលនៃការសង។ នៅពេលដែលត្រូវសង **ក** មិនបានសងត្រីសណ្តាយ ដែលមានប្រភេទ និង គុណភាព ស្មើនឹងត្រីសណ្តាយដែលបានទទួល ចំនួន ១០ គីឡូក្រាម ទៅ **ខ** វិញទេ ប៉ុន្តែ **ក** បែរជាសង

ប្រាក់ ១០ ម៉ឺន រៀល ទៅ **ខ** វិញ (សន្មតថាត្រីសណ្ដូត ១ គីឡូក្រាម មានតម្លៃ ១ ម៉ឺនរៀល)។ ក្នុងករណីនេះ **ខ** ត្រូវទទួលយកការសងរបស់ **ក** ។

### ៤.២ កាតព្វកិច្ចបង់ការប្រាក់

អ្នកខ្ចីមានកាតព្វកិច្ចត្រូវតែបង់ការប្រាក់ទៅអ្នកឱ្យខ្ចី ចំពោះកិច្ចសន្យាខ្ចីបរិភោគដែលមានការប្រាក់ ហើយការប្រាក់នេះទៀតសោត អ្នកខ្ចី ត្រូវបង់ដោយយោងទៅតាមប្រភេទនៃការប្រាក់ដែលកំណត់ដោយច្បាប់ ឬ ការប្រាក់ដែលកំណត់តាមកិច្ចសន្យា (មាត្រា ៥៩១ កថាខណ្ឌទី ២)។

## ៥. ការខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់

### ៥.១ គោលគំនិត

ការខ្ចីបរិភោគដោយមានភ្ជាប់ការប្រាក់នេះ គឺជាការខ្ចីបរិភោគមួយប្រភេទ ដែលគូភាគី បានព្រមព្រៀងភ្ជាប់បង្កើតនូវសិទ្ធិលើបំណុល ដែលជាការប្រាក់ ក្រៅពីប្រាក់ដើម ។

**ការប្រាក់** ត្រូវបានគេឱ្យនិយមន័យថា ជាចំនួនទឹកប្រាក់ ឬ វត្ថុផ្សេងទៀតដែលត្រូវបង់ទៅអោយ តាមសមាមាត្រនៃអំឡុងពេលនៃការប្រើប្រាស់ ក្នុងនាមជាតំលៃតបចំពោះការប្រើប្រាស់ប្រាក់ ឬ វត្ថុ ដែលត្រូវបានប្រគល់ទៅឱ្យអ្នកខ្ចី ហើយដែលត្រូវគណនា ដោយយកចំនួនទឹកប្រាក់ ឬ វត្ថុដែលបានខ្ចី មកគុណនឹងអត្រាការប្រាក់ដែលត្រូវបានកំណត់ (មាត្រា ៥៨៣ កថាខណ្ឌទី ១)។ ឧទាហរណ៍ **ខ** ខ្ចីប្រាក់ពី **ក** ចំនួន ១០០ ដុល្លា ជាមួយនឹងការប្រាក់ ២ ភាគរយ ក្នុង មួយខែ។ នៅក្នុងករណីនេះ ការប្រាក់ ដែលត្រូវបង់ គឺ 100 x 0.02 = 2$ ក្នុងមួយខែ។

**ប្រាក់ដើម ឬ វត្ថុដើម** គឺជាប្រាក់ ឬ វត្ថុ ដែលបានខ្ចី និង ត្រូវបានប្រគល់ទៅឱ្យអ្នកខ្ចី។ យោងតាមឧទាហរណ៍ ខាងលើ ប្រាក់ដើម គឺប្រាក់ ១០០ដុល្លា ដែល **ក** បានឱ្យ **ខ** ខ្ចី។

ការប្រាក់ គឺជាផលស៊ីវិល (មាត្រា ១២៧)។ ប្រសិនបើ សិទ្ធិលើបំណុល នៃប្រាក់ដើម ត្រូវបានផ្ទេរទៅអោយបុគ្គលផ្សេងទៀត នោះ សិទ្ធិលើបំណុលនៃការប្រាក់ ក៏ត្រូវបានផ្ទេរផងដែរ និង ទាំងអ្នកឱ្យខ្ចីមុន និង អ្នកឱ្យខ្ចីក្រោយ អាចទទួលបានការប្រាក់ សមាមាត្រទៅនឹងអំឡុងពេលដែលមានសិទ្ធិទទួល ដោយគណនាតាមចំនួនថ្ងៃ (មាត្រា ១២៨)។

គូភាគី អាចបង្កើតសិទ្ធិលើបំណុលនៃការប្រាក់ តាមការព្រមព្រៀងបាន។ ក៏ប៉ុន្តែ សិទ្ធិលើបំណុលនៃការប្រាក់នេះ មិនមានអានុភាពឡើយ ប្រសិនបើ មិនបានធ្វើជាលិខិតលាយលក្ខណ៍អក្សរ ដោយមានចុះហត្ថលេខារបស់អ្នកខ្ចីនោះទេ (មាត្រា ៥៨៣ កថាខណ្ឌទី ៣)។ មាត្រានេះ មានគោលបំណងក្នុងការការពារអ្នកខ្ចី។ ក៏ប៉ុន្តែ ទោះបីជាភាគី មិនធ្វើជាលិខិតលាយលក្ខណ៍អក្សរទាក់ទងនឹងការបង់ការប្រាក់ ហើយ អ្នកខ្ចី បានស្ម័គ្រចិត្តបង់ការប្រាក់ ទោះបីជាបានដឹងការណ៍ ដែលសិទ្ធិលើបំណុលនៃការប្រាក់ មិនមានអានុភាពទេនៅក្នុងករណីនេះ ក៏សិទ្ធិ

លើបំណុលនៃការប្រាក់ ត្រូវមានអានុភាព ត្រឹមកំរិតដែលបានបង់។ នេះ គឺជាបង្ហាញនូវលទ្ធិ ដែលមានលក្ខណៈជារូបភាព។

### ៥.២ អត្រាការប្រាក់

យោងតាមមាត្រា ៥៨៤ អត្រាការប្រាក់ ត្រូវបានបែងចែកជាពីរប្រភេទ គឺ អត្រាការប្រាក់ ដែលកំណត់ដោយច្បាប់ និង អត្រាការប្រាក់នៅក្នុងកិច្ចសន្យា ។

#### ៥.២.១ អត្រាការប្រាក់ដែលកំណត់ដោយច្បាប់

នៅក្នុងក្រិត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា ឆ្នាំ ១៩៨៩ មាត្រា ៥៩ បានកំណត់អំពីអត្រាការប្រាក់ នៅក្នុងកិច្ចសន្យាខ្ចី មិនឱ្យលើសពី ៥ ភាគរយ ក្នុងមួយឆ្នាំឡើយ ប៉ុន្តែ ដោយយល់ឃើញថា ការកំណត់កំរិតការប្រាក់បែបនេះ បានជះឥទ្ធិពលយ៉ាងខ្លាំងដល់វិស័យជំនួញឯកជន និង សេដ្ឋកិច្ចជាតិ ពីព្រោះយោងតាមស្ថានភាពសង្គមបច្ចុប្បន្ន អត្រាការប្រាក់ត្រឹមកំរិតនេះ គឺមានកំរិតទាបពេក ដែលធ្វើអោយអ្នកឱ្យខ្ចី មិនហ៊ានផ្តល់ប្រាក់កំចី ដោយខ្លួនទទួលបានការប្រាក់ទាបហួសហេតុ និង ប្រឈមមុខជាមួយនឹងហានិភ័យខ្ពស់។ ដើម្បីជាការបំពេញនូវការខ្វះខាតនៅក្នុងច្បាប់ចាស់ ក្រមរដ្ឋប្បវេណី បានបើកឱ្យមានការយកការប្រាក់ដោយផ្អែកលើឆន្ទៈរបស់គូភាគី ឬ តាមច្បាប់កំណត់ នៅពេលដែលគូភាគីនៃកិច្ចសន្យាខ្ចីបរិភោគ មិនបាននិយាយគ្នា។

ប្រសិនបើ គូភាគី បានព្រមព្រៀងគ្នា បង់ការប្រាក់ ប៉ុន្តែ មិនបានកំណត់អំពីអត្រាការប្រាក់ទេ នោះ អត្រាការប្រាក់ ដែលកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ឬ ច្បាប់ពិសេស ត្រូវយកមកអនុវត្ត ( មាត្រា ៥៨៤ កថាខណ្ឌទី ២) ។

ក្រមរដ្ឋប្បវេណី បានបញ្ញត្តថា អត្រាការប្រាក់ដែលកំណត់ដោយច្បាប់ គឺ ៥ ភាគរយ ក្នុង ១ ឆ្នាំ ( មាត្រា ៣១៨) ។ ហើយ គេ អាចបញ្ញត្តនូវអត្រាការប្រាក់ផ្សេងពីនេះ ដោយច្បាប់ពិសេស។

#### ៥.២.២ អត្រាការប្រាក់នៅក្នុងកិច្ចសន្យា

អត្រាការប្រាក់នៅក្នុងកិច្ចសន្យា គឺជាអត្រាការប្រាក់ ដែលបានកំណត់ ដោយផ្អែកតាមការព្រមព្រៀងរបស់គូភាគីនៅក្នុងកិច្ចសន្យាខ្ចីបរិភោគ។

ដូចបានលើកឡើងខាងលើ ដោយសារតែស្ថានភាពសង្គមមានការអភិវឌ្ឍន៍ និង ទំនើបកម្មរបស់ច្បាប់ បានអនុញ្ញាតឱ្យបុគ្គលឯកជន អាចធ្វើការកំណត់នូវអត្រាការប្រាក់តាមការព្រមព្រៀងនៅក្នុងកិច្ចសន្យា។

អត្រាការប្រាក់ ដែលបានព្រមព្រៀងដោយគូភាគី អាចខ្ពស់ជាងអត្រាការប្រាក់ ដែលកំណត់ដោយច្បាប់ ប៉ុន្តែ មិនអាចខ្ពស់ជាងអត្រាការប្រាក់ដែលបានកំរិតនោះទេ ( មាត្រា ៥៨៥ កថាខណ្ឌទី ២) ។ អត្រាការប្រាក់ ដែលត្រូវបានកំរិត គឺសំដៅទៅលើអត្រាការប្រាក់អតិបរមា ដែលអាចកំណត់បានដោយស្របច្បាប់ តាមការព្រមព្រៀងរបស់គូភាគី ដែលកំណត់ដោយច្បាប់ និង បទដ្ឋានគតិយុត្តិផ្សេងទៀត ។ អត្រាការប្រាក់ ដែលត្រូវបានកំរិត នឹងត្រូវបានកំណត់នៅក្នុងចន្លោះពី ១០ ភាគរយ ដល់ ៣០ ភាគរយ ក្នុង ១ ឆ្នាំ និង ត្រូវបានបញ្ញត្តដោយ ប្រកាសរួមគ្នារវាងក្រសួងយុត្តិធម៌ និង ធនាគារជាតិនៃកម្ពុជា ។

ដោយផ្អែកទៅលើ មាត្រា ៥៨៥ កថាខណ្ឌទី ៤ វាក្យខណ្ឌទី ១ ប្រសិនបើអ្នកខ្ចី បានសងរួចរាល់នូវការប្រាក់ ប៉ុន្តែការប្រាក់នោះ លើសពីការប្រាក់ដែលត្រូវបានកំរិត នោះប្រាក់ ដែលបានបង់លើសក្នុងនាមជាការប្រាក់ត្រូវបានចាត់ទុកជាការកាត់បំណុលទៅលើប្រាក់ដើម ។ ឧទាហរណ៍ អត្រាការប្រាក់ដែលត្រូវបានកំរិត ត្រូវបានបញ្ញត្តដោយច្បាប់ចំនួន ២០ ភាគរយ ក្នុង ១ ឆ្នាំ ប៉ុន្តែ ក បានខ្ចីប្រាក់ ខ ចំនួន ១០០ ដុល្លា ក្នុងរយៈពេល ៥ ឆ្នាំ ដោយមានអាត្រាការប្រាក់ ៤០ ភាគរយ ក្នុង ១ ឆ្នាំ ។ ខ បានបង់ការប្រាក់ ៤០០ ដុល្លា ជារៀងរាល់ឆ្នាំ ។ នៅក្នុងករណីនេះ ២០០ ដុល្លា គឺជាការប្រាក់ដែលត្រូវបានកំរិត ក្នុង រយៈពេល ១ ឆ្នាំ ដែលត្រូវបានគណនា ដោយយោងទៅលើអត្រាការប្រាក់ ដែលត្រូវបានកំរិត ។ ដូច្នេះ ប្រាក់ ២០០ ដុល្លា ( ៤០០ - ២០០) ត្រូវយកទៅកាត់បំណុលលើប្រាក់ដើម ។ បន្ទាប់មក ប្រាក់ដើមនៅក្នុង ឆ្នាំទី ២ គឺ ៨០០ ដុល្លា ( ១,០០០ - ២០០) ហើយ ការប្រាក់ ដែលត្រូវបានកំរិត គឺ ១៦០ ដុល្លា ( ៨០០ x ០.២) ។ ដូច្នេះ ប្រាក់ដើម នឹងត្រូវបានកាត់បន្ថយ ទោះបីជា អ្នកខ្ចី បានសងតែការប្រាក់ នៅក្នុងករណីដែល អ្នកខ្ចី បានបង់ប្រាក់ដែលលើសពីអត្រាការប្រាក់ ដែលត្រូវបានកំរិត ។

ជាងនេះទៅទៀត ប្រសិនបើ បានកាត់បំណុលទៅលើប្រាក់ដើម ចំពោះផ្នែកដែលលើសពីការកំរិតហើយ តែនៅមានសេសសល់ទៀត អ្នកឱ្យខ្ចី ត្រូវសងទៅអោយអ្នកខ្ចី ដោយភ្ជាប់ជាមួយនូវប្រាក់សំណងនៃការខូចខាត ។ ហើយ ការខូចខាតនេះ ត្រូវគណនា ដោយអត្រាការប្រាក់ដែលកំណត់ដោយច្បាប់ ដោយគិតចាប់ពីបង់ការប្រាក់នោះ រហូតដល់ថ្ងៃប្រគល់ ( មាត្រា ៥៨៤ កថាខណ្ឌទី ៤ វាក្យខណ្ឌទី ២) ។ ឧទាហរណ៍ ក បានអោយ ខ ខ្ចីប្រាក់ចំនួន ១,០០០ ដុល្លា ដោយមានការប្រាក់ ៨០ ភាគរយ ក្នុងមួយឆ្នាំ ទោះបីជា អាត្រាការប្រាក់ដែលត្រូវបានកំរិត គឺ ២០ ភាគរយ ហើយ ខ បានបង់ការប្រាក់អស់រយៈពេល ២ ឆ្នាំ ហើយ ។ នៅក្នុងករណីនេះ ប្រាក់ដើម ត្រូវសងអស់ហើយ នៅមានសេសសល់ថែមទៀតផង ។

(i) ឆ្នាំទី ១

១,០០០ ដុល្លា ( ប្រាក់ដើម) x ០.៨ ( អត្រាការប្រាក់ក្នុងកិច្ចសន្យា) = ៨០០ ដុល្លា

១,០០០ ដុល្លា ( ប្រាក់ដើម) x ០.២ ( អត្រាការប្រាក់ដែលត្រូវបានកំរិត) = ២០០ ដុល្លា

៨០០ ដុល្លា - ២០០ ដុល្លា = ៦០០ ដុល្លា ( ការប្រាក់ដែលលើស = ចំនួនដែលត្រូវកាត់បំណុលលើប្រាក់ដើម)

(ii) ឆ្នាំទី ២

១,០០០ ដុល្លា - ៦០០ ដុល្លា = ៤០០ ដុល្លា (ប្រាក់ដើម នៅក្នុងឆ្នាំទី ២)

៤០០ ដុល្លា x 0.២ = ៨០ ដុល្លា (ការប្រាក់ដែលត្រូវបានកំរិត នៅក្នុងឆ្នាំទី ២)

៨០០ ដុល្លា - ៨០ ដុល្លា = ៧២០ ដុល្លា (ការប្រាក់ដែលលើស = ចំនួនដែលត្រូវកាត់បំណុលលើប្រាក់ដើម)

៤០០ ដុល្លា - ៧២០ ដុល្លា = - ៣២០ ដុល្លា (នៅសេសសល់)

នៅក្នុងករណីនេះ អ្នកឱ្យខ្ចី ត្រូវសងប្រាក់ ៣២០ ដុល្លា ដោយរាប់បញ្ចូលទាំងការប្រាក់ ដែលកំណត់ដោយច្បាប់ គិតចាប់ពីថ្ងៃបង់ ដែលត្រូវចាត់ទុកថាជា ការខូចខាត។

### ៩.២.៣ ការការពារអ្នកខ្ចី

នៅក្នុងករណីនៃការខ្ចីបរិភោគ ដោយមានការប្រាក់ អ្នកឱ្យខ្ចី ដូចជា អ្នកឱ្យខ្ចីដែលមានគោលបំណងអាក្រក់ តែងតែព្យាយាមគេចវេះពីច្បាប់ ទោះបីជាច្បាប់ បានបញ្ញត្តនូវការកំរិតលើការប្រាក់ក៏ដោយ។ ដូច្នេះ ក្រមរដ្ឋប្បវេណី បានចែងនូវបញ្ញត្តិចំនួន ពីរ ដើម្បីការពារអ្នកខ្ចី។

**ក. ការកែប្រែប្រាក់ដើម**

ក្នុងករណីដែលចំនួនប្រាក់ដើមលើកិច្ចសន្យា ខុសគ្នាពីចំនួនទឹកប្រាក់នៃវត្ថុ ដែលអ្នកឱ្យខ្ចី បានប្រគល់ដោយជាក់ស្តែង ចំនួនទឹកប្រាក់នៃវត្ថុដែលអ្នកឱ្យខ្ចី បានប្រគល់ដោយជាក់ស្តែងទៅឱ្យអ្នកខ្ចី ត្រូវចាត់ទុកថា ជាចំនួនប្រាក់ដើម (មាត្រា ៥៨៥ កថាខណ្ឌទី ៥)។

ឧទាហរណ៍ **ក** និង **ខ** បានបង្កើតកិច្ចព្រមព្រៀងថា **ក** ត្រូវឱ្យ **ខ** ខ្ចីប្រាក់ចំនួន ១,០០០ ដុល្លា ក្នុងរយៈពេល ៥ ឆ្នាំ ដោយមានអត្រាការប្រាក់ ២០ ភាគរយ ក្នុង ១ ឆ្នាំ (សូមគិតថា អាត្រាការប្រាក់នេះ មិនលើសអាត្រាការប្រាក់ ដែលត្រូវបានកំរិត) ប៉ុន្តែ **ក** ប្រគល់ប្រាក់តែ ២០០ ដុល្លា ទេ ព្រោះ **ក** ព្យាយាមកាត់ប្រាក់ ៨០០ ដុល្លា ពីប្រាក់ដើម សំរាប់ជាការប្រាក់ ក្នុងរយៈពេល ៤ ឆ្នាំ។ នៅក្នុងករណីនេះ **ខ** មិនអាចប្រើប្រាក់ ១,០០០ ដុល្លា ទេ ប៉ុន្តែ គាត់ បែរជាជាប់បំណុល ចំនួន ១,០០០ ដុល្លា ទៅវិញ។ ដើម្បីចៀសវាងនូវបញ្ហានេះ មាត្រា ៥៨៥ កថាខណ្ឌទី ៥ បានកំណត់ថា ចំនួនទឹកប្រាក់នៃវត្ថុ ដែលត្រូវបានប្រគល់ដោយជាក់ស្តែង ត្រូវទុកថា ចំនួនប្រាក់ដើម។ ប្រសិនបើ អនុវត្តមាត្រានេះ នោះ ប្រាក់ដើម គឺ ២០០ ដុល្លា នៅក្នុងករណីខាងលើ។

**ខ. ត្រូវចាត់ទុកជាការប្រាក់**

ប្រាក់ និង វត្ថុផ្សេងទៀត ដែលអ្នកឱ្យខ្ចី បានទទួលក្រៅពីប្រាក់ដើម ទាក់ទងទៅនឹង កិច្ចសន្យាខ្ចីបរិភោគ ត្រូវបានចាត់ទុកថាជាការប្រាក់ (មាត្រា ៥៨៥ កថាខណ្ឌទី ៦)។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះសោហ៊ុយនៃការធ្វើកិច្ចសន្យា និង សោហ៊ុយនៃការសង (មាត្រា ៥៨៥ កថាខណ្ឌទី ៦ វាក្យខណ្ឌទី ២)។

ទោះបីជាច្បាប់ ដាក់កំរិតលើអត្រាការប្រាក់ ឬ កាត់ទូវការប្រាក់ ក៏អ្នកឱ្យខ្ចីដែលមានគោលបំណងអាក្រក់ តែងតែព្យាយាមទទួលយកប្រាក់ពីអ្នកខ្ចី ដូចជា ប្រាក់កំរៃជើងសារ កំរៃស៊ើបអង្កេត ជាអាទិ៍។ ដូច្នេះ ក្រម រដ្ឋប្បវេណី បញ្ញត្តថា ប្រសិនបើ អ្នកឱ្យខ្ចី បានទទួលប្រាក់ ឬ វត្ថុផ្សេងទៀត ក្រៅពីប្រាក់ដើម នោះ វា ត្រូវបាន ចាត់ទុកថាជា ការប្រាក់។

## ៥.៣ ពេលវេលានៃការបង់ការប្រាក់ និង ការប្រាក់សមាសដែលកំណត់ដោយច្បាប់

### ៥.៣.១ ពេលវេលានៃការបង់ការប្រាក់

គោលការណ៍ : ការប្រាក់ ត្រូវបង់នៅរៀងរាល់ពេលដែលពេលវេលា រយៈពេល ១ឆ្នាំ បានកន្លងផុតគិត ចាប់ពីពេល ដែលបានប្រគល់វត្ថុដែលជាកម្មវត្ថុ។ នេះ ពុំមែនជាបញ្ញត្តិអនុវត្តដោយបង្ខំនោះទេ មានន័យថាអាច ព្រមព្រៀងផ្សេងបាន។

**ករណីលើកលែង:**

ភាគី អាចព្រមព្រៀងផ្សេងដូចជា បង់រៀងរាល់ខែ កន្លះឆ្នាំម្តង ជាដើម។ ក៏ប៉ុន្តែ ប្រសិនបើ ត្រូវសងវត្ថុ នោះ នៅមុនពេលវេលា ១ ឆ្នាំ គិតពីការប្រគល់ នោះ ការប្រាក់ ត្រូវបង់នៅពេលប្រគល់វត្ថុដែលជាកម្មវត្ថុនោះ មកវិញ (មាត្រា ៥៨៦ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២)។

### ៥.៣.២ ការប្រាក់សមាសដែលកំណត់ដោយច្បាប់

ប្រសិនបើ អ្នកខ្ចី មិនបានបង់ការប្រាក់ សំរាប់រយៈពេលចាប់ពី ១ ឆ្នាំឡើងទៅ ហើយគាត់ នៅតែមិនបង់ ការប្រាក់ទៀត ទោះបីជាមានការដាស់តឿនពីអ្នកឱ្យខ្ចីក៏ដោយ នោះអ្នកឱ្យខ្ចី អាចបូកបញ្ចូលការប្រាក់ដែលមិនបាន បង់នោះ ចូលទៅក្នុងប្រាក់ដើមបាន។

ឧទាហរណ៍ **ក** បានអោយ **ខ** ខ្ចីប្រាក់ចំនួន ១០០០ ដុល្លា ដោយមានការប្រាក់ ២០ ភាគរយ ក្នុង ១ ឆ្នាំ (សូមគិតថាអត្រាការប្រាក់នេះ គឺជាអត្រាការប្រាក់ដែលត្រូវបានកំរិត) ប៉ុន្តែ **ខ** មិនបានបង់កាប្រាក់ ១ ឆ្នាំ កន្លះ ទោះបីជា **ក** បានដាស់តឿនអោយ **ខ** បង់ការប្រាក់ក៏ដោយ។ នៅក្នុងករណីនេះ **ក** អាចបូកបញ្ចូលការប្រាក់ ដែល មិនទាន់បានបង់ (១០០០ ដុល្លា x ០.២ = ២០០ ដុល្លា) ទៅក្នុងប្រាក់ដើមបាន។ ដូច្នេះ ប្រាក់ដើមសំរាប់ឆ្នាំទី ២ គឺ ១២០០ ដុល្លា។

ទន្ទឹមនឹងនេះ គូភាគី អាចបង្កើតកិច្ចព្រមព្រៀង ដែលកំណត់ថា ការប្រាក់ដែលមិនបានបង់ ត្រូវបូកបញ្ចូល ទៅក្នុងប្រាក់ដើម លើសពី ១ ដង ក្នុង ១ ឆ្នាំ។ ឧទាហរណ៍ នៅក្នុងករណីខាងលើ **ក** និង **ខ** បានព្រមព្រៀងគ្នាថា **ក** អាចបូកបញ្ចូលនូវការប្រាក់ដែលមិនបានបង់ ជារៀងរាល់កន្លះឆ្នាំម្តង។ នៅក្នុងករណីនេះ ចំណុចដែលគួរអោយកត់

សំគាល់ គឺថា ប្រសិនបើ ខ មិនបានបង់ការប្រាក់នៅក្នុងរយៈពេល ១ ឆ្នាំ ការប្រាក់ នឹងច្រើនជាងចំនួននៃអត្រាការប្រាក់ដែលត្រូវបានកំរិត ។

ការប្រាក់អតិបរមានៅក្នុងរយៈពេល ១ ឆ្នាំ : ១០០០ ដុល្លា x 0.២ = ២០០ ដុល្លា ( ក)

ការប្រាក់អតិបរមានៅក្នុងរយៈពេល កន្លះឆ្នាំ : ២០០ ដុល្លា / ២ = ១០០ ដុល្លា

ប្រាក់ដើមសំរាប់រយៈកន្លះឆ្នាំ ចុងឆ្នាំ : ១០០០ ដុល្លា + ១០០ ដុល្លា = ១១០០ ដុល្លា

ការប្រាក់អតិបរមាសំរាប់រយៈពេលកន្លះឆ្នាំ ចុងឆ្នាំ: ១១០០ ដុល្លា x 0.២/២ = ១១០ ដុល្លា

ការប្រាក់សរុប សំរាប់រយៈពេល ១ ឆ្នាំ : ១០០ ដុល្លា + ១១០ ដុល្លា = ២១០ ដុល្លា ( ខ)

នៅក្នុងករណីនេះ ការប្រាក់សរុបសំរាប់រយៈពេល ១ ឆ្នាំ (ខ) គឺច្រើនជាងចំនួនអត្រាការប្រាក់ដែលត្រូវបានកំរិត (ក) ទៀត ។ សេចក្តីសន្និដ្ឋាននេះ វា នឹងច្បាប់ ត្រង់ចំណុចថា អាត្រាការប្រាក់ដែលត្រូវបានកំរិត ។

ដូច្នេះ គេ អាចចាត់ទុកថា ចំនួន ដែលលើសការប្រាក់អតិបរមា (១០ ដុល្លា នៅក្នុងករណីនេះ) ត្រូវទុកជាមោឃៈ ព្រោះ វា គឺជាការរំលងច្បាប់ ប្រសិនបើ អ្នកអោយខ្ចី អាចទទួលបានការប្រាក់ ដែលច្រើនជាង អាត្រាការប្រាក់ដែលត្រូវបានកំណត់ តាមការជាក់ស្តែង ដោយគ្រាន់តែធ្វើការបូកបញ្ចូលនូវការប្រាក់ទៅក្នុងប្រាក់ដើម ។

# ផ្នែកទី ១០

# អាណត្តិ

## ១. គោលចំនិត

តើអាណត្តិជាអ្វី? មាត្រា ៦៣៧ និយមន័យអាណត្តិ

"អាណត្តិសំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាង ហៅថា អាណត្តិទាយក ប្រគល់សិទ្ធអំណាចឱ្យភាគីម្ខាងទៀតហៅថា អាណត្តិគាហក ធ្វើការចាត់ចែងកិច្ចការដើម្បីអាណត្តិទាយក" ។

**តើពាក្យថា កិច្ចការ នៅក្នុងអាណត្តិ មានន័យយ៉ាងដូចម្តេច?**

ពាក្យកិច្ចការ នៅក្នុងអាណត្តិរាប់បញ្ចូលគ្រប់កិច្ចការដូចជា ការធ្វើកិច្ចសន្យា អន្តរការីនៃអចលនវត្ថុ សិទ្ធិក្នុងការធ្វើបណ្តឹង ជាអាទិ៍។ ឧទាហរណ៍ **ក** ផ្តល់សិទ្ធិតំណាងឱ្យ **ខ** ទៅចុះកិច្ចសន្យាទិញរថយន្ត ជាមួយ **គ**។ នេះ គឺជាឧទាហរណ៍នៃការបង្កើតកិច្ចសន្យាអាណត្តិ។ ទន្ទឹមនឹងនេះ ប្រសិនបើ **ក** ស្នើសុំអោយ **ខ** ស្វែងរកអ្នកទិញដីរបស់ **ក** ហើយ **ខ** បានធ្វើជាអ្នកកណ្តាលរវាង **ក** និង អ្នកទិញ **គ**។ នេះ គឺជាឧទាហរណ៍នៃអន្តរការីនៃអចលនវត្ថុ។ នៅក្នុងករណីដែល **ក** បានផ្តល់សិទ្ធិអំណាចក្នុងការធ្វើបណ្តឹងអោយទៅ **ខ** ដែលជាមេធាវី នេះ ក៏ជាអាណត្តិដែរ។ ហើយម្យ៉ាងទៀត ទំនាក់ទំនងរវាងគ្រូពេទ្យ និង អ្នកជំងឺ ក៏ចាត់ទុកជាអាណត្តិដែរ។ ប៉ុន្តែ ការរក្សាទុកវត្ថុ មិនរាប់បញ្ចូលទៅក្នុងកិច្ចការនៅក្នុងអាណត្តិទេ គឺស្ថិតនៅក្នុងកិច្ចការបញ្ញើ។

**តើអាណត្តិ និង កិច្ចសន្យាបញ្ញើ មានទំនាក់ទំនងគ្នាយ៉ាងដូចម្តេច? មាត្រា៦៣៧**

អាណត្តិ ត្រូវបានផ្តល់និយមន័យថា "កិច្ចសន្យាមួយដែលភាគីម្ខាង ហៅថា អាណត្តិទាយក ប្រគល់សិទ្ធអំណាចឱ្យភាគីម្ខាងទៀតហៅថា អាណត្តិគាហក ធ្វើការចាត់ចែងកិច្ចការដើម្បីអាណត្តិទាយក" (មាត្រា ៦៣៧)។ ផ្ទុយមកវិញ **មាត្រា៦៦៩** បានផ្តល់និយមន័យ បញ្ញើថា "កិច្ចសន្យាដែលភាគីម្ខាង ជាអ្នកទទួលបញ្ញើ សន្យាទទួលយកវត្ថុបញ្ញើ ពីភាគីម្ខាងទៀត ជាអ្នកផ្ញើ មករក្សាទុកក្នុងអំឡុងពេលដែលបានកំណត់ ហើយ នៅក្រោយពេលដែលអំឡុងពេលរក្សាទុកនោះត្រូវបានបញ្ចប់ ត្រូវសងវត្ថុដដែលនោះទៅអ្នកផ្ញើវិញ។"

ដូចនេះ អាណត្តិ និង កិច្ចសន្យាបញ្ញើ មានទំនាក់ទំនងគ្នា ត្រង់ជាកិច្ចសន្យាផ្តល់សេវាដូចគ្នា ហើយ ខុសគ្នាត្រង់ បញ្ញើ គឺអ្នកទទួលបញ្ញើត្រូវផ្តល់នោះ គឺ "ការរក្សាទុកវត្ថុដែលបានទទួល" តែប៉ុណ្ណោះ។ ចំណែកឯ សេវាត្រូវផ្តល់នៅក្នុងកិច្ចការអាណត្តិ គឺចាត់ចែងរាល់គ្រប់កិច្ចការ ដូចជាការធ្វើកិច្ចសន្យា អន្តរការីនៃអចលនវត្ថុ សិទ្ធិអំណាចក្នុងការធ្វើបណ្តឹង ជាអាទិ៍។ នៅក្នុងន័យនេះ គេ អាចនិយាយបានថា បញ្ញើ គឺជាប្រភេទមួយនៃកិច្ចសន្យាអាណត្តិ ប៉ុន្តែ វា ត្រូវបានបញ្ញត្តិដោយឡែក នៅក្នុងក្រមរដ្ឋប្បវេណី។

**តើអាណត្តិ គឺជាកិច្ចសន្យា ដែលយកតំលៃថ្នូរ ឬ កិច្ចសន្យាមិនយកតំលៃថ្នូរ ឬ ជាប្រភេទកិច្ចសន្យាទាំងពីរ?**

មាត្រា ៦៣៨ ចែងថា "អាណត្តិ អាចធ្វើដោយយកកម្រៃ ឬ មិនយកកម្រៃបាន។ បើពុំបានបងាញឆន្ទៈអំពីការធ្វើដោយយកកម្រៃទេ ត្រូវសន្មតថាជាអាណត្តិដោយមិនយកកម្រៃ"។ នេះ មានន័យថា អាណត្តិ អាចជាកិច្ចសន្យាដែលយកតំលៃថ្នូរ ឬ កិច្ចសន្យាមិនយកតំលៃថ្នូរក្នុងន័យនេះ ហើយ អាណត្តិ គឺជាកិច្ចសន្យាដែលមិនយកតំលៃថ្នូរ បើភាគី មិនបានបង្កើតការព្រមព្រៀងទាក់ទងនឹងការយកតំលៃថ្នូរនោះទេ។ ការបងាញឆន្ទៈនេះ អាចធ្វើដោយជាក់លាក់ ឬ ដោយតុណ្ហីភាព លាយលក្សណ៍អក្សរ ឬ ផ្ទាល់មាត់ នៅពេលបង្កើតកិច្ចសន្យា។

## ២. លក្ខខណ្ឌ

អាណត្តិ គឺជាកិច្ចសន្យាត្រឹមការព្រមព្រៀង ដោយមិនតម្រូវឱ្យត្រូវធ្វើជាលាយលក្សណ៍អក្សរ ជាលក្ខខណ្ឌសុពលភាពនៃអាណត្តិនោះទេ។ វា មានន័យថា ឱ្យតែមានឆន្ទៈត្រូវគ្នារវាងភាគីទាំងសងខាង នោះ អាណត្តិ នឹងត្រូវបានបង្កើតឡើង។ ឬនិយាយម្យ៉ាងទៀត នៅក្នុងករណីដែល អាណត្តិទាយក ប្រគល់សិទ្ធអំណាចឱ្យអាណត្តិគាហក ធ្វើកិច្ចការណាមួយ ហើយ អាណត្តិគាហក ឯកភាពទទួលធ្វើកិច្ចសន្យានោះ។ ឧទាហរណ៍ ក មានដី និង ផ្ទះមួយកន្លែង ហើយ គាត់ ចង់លក់ដី និង ផ្ទះនេះ។ ដូច្នេះ គាត់ បានបង្ហាញឆន្ទៈថា គាត់ នឹងផ្តល់សិទ្ធិអំណាយអោយទៅ ខ ដើម្បីចុះកិច្ចសន្យាលក់ទិញ។ នៅពេលដែល ខ ទទួលយកសំណើរនេះ នោះ អាណត្តិ ត្រូវបានបង្កើតឡើង។

## ៣. ទំនាក់ទំនងជាមួយនឹងការតំណាង

តើអាណត្តិ និង ការតំណាង មានភាពខុសគ្នាយ៉ាងដូចម្តេច? មាត្រា ៦៣៧ បានផ្តល់និយមន័យ អាណត្តិថា "អាណត្តិ សំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាង ហៅថា អាណត្តិទាយក ប្រគល់សិទ្ធអំណាចឱ្យភាគីម្ខាងទៀត ហៅថា អាណត្តិគាហក ធ្វើការចាត់ចែងកិច្ចការដើម្បីអាណត្តិទាយក"។ ផ្ទុយទៅវិញ មាត្រា ៣៦៤ បានចែងថា "ការតំណាង សំដៅទៅលើទំនាក់ទំនងគតិយុត្តិ ដែលអានុភាពនៃកិច្ចសន្យា ត្រូវមានចំពោះម្ចាស់សិទ្ធិផ្ទាល់ ក្នុងករណីដែល អ្នកតំណាង ធ្វើកិច្ចសន្យាជាមួយភាគីម្ខាងទៀត ដោយបង្ហាញថា ការធ្វើកិច្ចសន្យានោះ គឺធ្វើសំរាប់ម្ចាស់សិទ្ធិ ក្នុងទំហំនៃសិទ្ធិតំណាង"។ ប្រព័ន្ធទាំងពីរនេះ គឺមានលក្ខណៈស្រដៀងគ្នា ប៉ុន្តែ វា មានភាពខុសគ្នាស្ថិតនៅត្រង់ចំនុចដូចខាងក្រោមនេះ :

| អាណត្តិ | ការតំណាង |
|---|---|
| ក → ខ (អាណត្តិគាហក) | ក → ខ (អ្នកតំណាង) |
| (អាណត្តិទាយក) ↓ | (ម្ចាស់សិទ្ធិ) ↓ |
| គ (ភាគីម្ខាងទៀត) | គ (ភាគីម្ខាងទៀត) |
| - នៅពេលដែល ខ បានចុះកិច្ចសន្យាលក់ទិញរថយន្ត | - នៅពេល ខ ចុះកិច្ចសន្យាទិញលក់រថយន្តជាមួយ |

| | |
|---|---|
| ជាមួយនឹង គ នោះ ខ មិនចាំបាច់ប្រាប់ទៅ គ ថា ខ្លួន ធ្វើសំរាប់ ក ឡើយ | គ ក្នុងនាមជាអ្នកតំណាងរបស់ ក នោះ ខ ចាំបាច់ ត្រូវប្រាប់ គ ថា ខ្លួន ធ្វើក្នុងនាម ក |
| -អានុភាពនៃកិច្ចសន្យាទិញលក់រថយន្តរវាង ខ និង គ មិនមានផ្ទាល់រវាង ក និង គ ឡើយ | - អានុភាពនៃកិច្ចសន្យាទិញលក់ ដែល ខ បានចុះជាមួយ គ គឺមានអានុភាពមានផ្ទាល់ទៅលើ ក |
| - ករណីយកិច្ច និង សិទ្ធិ កើតមានរវាង ខ និង គ | - ករណីយកិច្ច និង សិទ្ធិ កើតមានផ្ទាល់រវាង ក និង គ |

តើការតំណាង មានប្រភពមកពីអាណត្តិតែមួយគត់មែនទេ?

សិទ្ធិតំណាង មិនមែនមានប្រភពមកពីអាណត្តិតែមួយគត់នោះទេ វា អាចកើតចេញពីកិច្ចសន្យាការងារ និង កិច្ចសន្យាម៉ៅការ ជាអាទិ៍។

## ៤. កាតព្វកិច្ចរបស់អាណត្តិគាហក

### ៤.១ ករណីយកិច្ចប្រុងប្រយ័ត្ន

ករណីយកិច្ចនេះ មានចែងនៅក្នុង មាត្រា ៦៤០

ករណីយកិច្ចប្រុងប្រយ័ត្នរបស់អាណត្តិគាហក ត្រូវបានបញ្ញត្តិថា :

> អាណត្តិគាហក មានករណីយកិច្ចចាត់ចែងកិច្ចការអាណត្តិដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងសុចរិត ដោយផ្អែកតាមអត្ថន័យនៃអាណត្តិ។ ប៉ុន្តែបញ្ញត្តិនេះ មិនរារាំងចំពោះការបន្ថយករណីយកិច្ចប្រុងប្រយ័ត្នរបស់អាណត្តិគាហក តាមការព្រមព្រៀងរបស់ភាគីឡើយ។

កិច្ចសន្យាអាណត្តិ ត្រូវបានបង្កើតឡើងដោយផ្អែកទៅលើទំនាក់ទំនងដែលជឿទុកចិត្តរវាងអាណត្តិទាយក និង អាណត្តិគាហក ហើយ អាណត្តិទាយក បានជឿជាក់ថា អាណត្តិគាហក មានការប៉ិនប្រសប់ជាពិសេស ឬ ចំនេះដឹងជំនាញណាមួយ។

កំរិតនៃទំហំករណីយកិច្ចនេះ ត្រូវបានសំរេចដោយធ្វើការពិចារណាទៅលើអ្វី ដែលជននៅក្នុងឋានៈនេះ ត្រូវយកចិត្តទុកដាក់ និង ត្រូវយកចិត្តទុកដាក់ដោយវិធីណា ជាទូទៅ។ ឧទាហរណ៍ បុគ្គល ដែលមានជំនាញ និង ចំណេះដឹងខ្ពស់ ដូចជា គ្រូពេទ្យ ត្រូវមានករណីយកិច្ចខ្ពស់ក្នុងការចាត់ចែងកិច្ចការ។ ផ្ទុយទៅវិញ កំរិតស្តង់ដានៃករណីយកិច្ចប្រុងប្រយ័ត្នរបស់បុគ្គល ដែលស្ម័គ្រចិត្តក្នុងការមើលថែទាំកូនរបស់អ្នកជិតខាង គឺត្រូវមានតិចជាងអ្នកជំនាញ។

ទន្ទឹមនឹងនេះ កំរិត ឬ លំដាប់នៃករណីយកិច្ចប្រុងប្រយ័ត្ននេះ កើតមានមិនថាជា អាណត្តិដោយយកកម្រៃ ឬ អាណត្តិដោយមិនយកកម្រៃ ដោយសារ អាណត្តិ ត្រូវបានបង្កើតឡើងដោយឈរលើ គោលការណ៍ ជឿទុកចិត្ត

គ្នា រវាងភាគីអាណត្តិទាយក និង អាណត្តិគាហក ។ ប៉ុន្តែ កំរិត នៃករណីយកិច្ចនេះ អាចត្រូវបានបន្ថយអាស្រ័យទៅតាមការព្រមព្រៀងរបស់ភាគី ( មាត្រា ៦៤០ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។

ផលវិបាកនៅក្នុងករណីយដែលអាណត្តិគាហកបំពានករណីយកិច្ចនេះ

ដោយផ្អែកលើ មាត្រា ៦៤០ កថាខណ្ឌទី ២ ចែងថា "ក្នុងករណី ដែលអាណត្តិគាហក ធ្វើផ្ទុយនឹងករណីយកិច្ចប្រុងប្រយ័ត្ន នៃកថាខណ្ឌទី ១ ខាងលើនេះ ហើយបានធ្វើឱ្យមានការខូចខាតដល់អាណត្តិទាយក អាណត្តិទាយក អាចទាមទារសំណងនៃការខូចខាតនោះពីអាណត្តិគាហកបាន។ នៅក្នុងករណីនេះ ប្រសិនបើជា អាណត្តិដោយមិនយកកម្រៃ តុលាការ អាចបន្ថយចំនួនទឹកប្រាក់សំណងនៃការខូចខាតបាន" ។ អត្ថន័យនៃមាត្រានេះ គឺថា អាណត្តិគាហក ត្រូវទទួលខុសត្រូវដោយយោងតាម គោលការណ៍ទូទៅអំពីការមិនអនុវត្តកតព្វកិច្ច ដែលតំរូវឱ្យភាគី ដែលបង្កព្យសនកម្មដល់ភាគីម្ខាងទៀត ត្រូវបង់នូវសំណងការខូចខាត នៅក្នុងករណីដែល ការបំពាននោះ បង្កជាការខូចខាតមកពីការមិនគោរពតាមខសន្យា។ នៅក្នុងករណីនេះ ទាយក អាចទាមទារអោយរំលាយកិច្ចសន្យា និង/ឬ សំណងនៃការខូចខាត។ ប៉ុន្តែបើជា អាណត្តិដែលមិនយកកំរៃ នោះ តុលាការ អាចបន្ថយចំនួន ទឹកប្រាក់សំណងការខូចខាត ព្រោះ អាណត្តិគាហក មិនបានទទួលផលប្រយោជន៍អ្វីពីកិច្ចសន្យាអាណត្តិនេះទេ។ ដោយឈរលើទស្សនៈសមភាពរវាងភាគី បញ្ញត្តិនេះ បានកំណត់អំពីភាពខុសគ្នារវាង អាណត្តិដោយយកកម្រៃ និង អាណត្តិដោយមិនយកកម្រៃ។

## ៤.២ ករណីយកិច្ចរាយការណ៍

បើមានការទាមទាររបស់អាណត្តិទាយក អាណត្តិគាហក ត្រូវរាយការណ៍អំពីស្ថានភាពនៃកិច្ចការចាត់ចែងអាណត្តិ ទោះបីនៅពេលណាក៏ដោយ ( មាត្រា ៦៤១) ។

ករណីយកិច្ចនេះ គឺទាញចេញពីករណីយកិច្ចប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដ៏ល្អ។ វា មានសារសំខាន់ណាស់សំរាប់អាណត្តិគាហក ក្នុងដឹងអំពីដំណើរការនៃការកិច្ចការរបស់ខ្លួន ដល់កំរិតណា ដូច្នេះ គាត់ អាចឆ្លើយតបទៅនឹងបញ្ហានេះ ។

តើអាណត្តិគាហក ត្រូវរាយការណ៍អំពីស្ថានភាពដែរ ឬ ទេ ទោះបីជាអាណត្តិទាយក មិនបានស្នើសុំក៏ដោយ? ទោះបីជាអាណត្តិទាយក មិនបានស្នើសុំអោយរាយការណ៍ក៏ដោយ គេ អាចចាត់ទុកថា អាណត្តិគាហក ត្រូវរាយការណ៍អំពីស្ថានភាពបច្ចុប្បន្ននៃការចាត់ចែងនោះ នៅពេលដែលមានភាពចាំបាច់សំរាប់អាណត្តទាយក។

ផលវិបាកនៅក្នុងករណី ដែលអាណត្តិគាហក បំពានករណីយកិច្ចនេះ ពីព្រោះតែ ការរាយការណ៍ជាករណីយកិច្ចតាមផ្លូវច្បាប់ យោងតាមគោលការណ៍ទូទៅអំពីការមិនអនុវត្តកតព្វកិច្ច នោះ អាណត្តិទាយក អាចរំលាយកិច្ចសន្យា ហើយ គាត់ អាចទាមទារសំណង នៅក្នុងករណីដែលមានការខូចខាតកើតមានឡើង។

## ៤.៣ កាតព្វកិច្ចប្រគល់

មាត្រា ៦៤២ ចែងថា "អាណត្តិគាហក ត្រូវប្រគល់ប្រាក់ និងវត្ថុផ្សេងៗ ទៀតដែលទទួលបានតាមការចាត់ចែងកិច្ចការអាណត្តិអោយទៅអាណត្តិទាយក។ អាណត្តិគាហក ក៏ត្រូវប្រគល់ផលដែលប្រមូលបានឱ្យទៅអាណត្តិទាយកផងដែរ " (កថាខណ្ឌទី ១) និង "សិទ្ធិដែលអាណត្តិគាហក បានលទ្ធកម្មនៅក្នុងនាមរបស់ខ្លួន ដើម្បីអាណត្តិទាយក ត្រូវផ្ទេរសិទ្ធិនោះឱ្យទៅអាណត្តិទាយក" (កថាខណ្ឌទី ២)។

នេះក៏ដោយសារ អាត្តិទាយកប្រគល់សិទ្ធិអំណាចឱ្យអាណត្តិគាហកចាត់ចែងការងារ ដើម្បីប្រយោជន៍ខ្លួន ដូចនេះ នៅពេលអាណត្តិគាហក បញ្ចប់ការងារ គាត់ ត្រូវប្រគល់ប្រាក់ និង វត្ថុផ្សេងៗ ទៀត ដែលទទួលបានតាមការចាត់ចែងកិច្ចការអាណត្តិឱ្យទៅអាណត្តិទាយក។ លើសពីនេះ អាណត្តិគាហក ក៏ត្រូវប្រគល់ផល ដែលប្រមូលបានឱ្យទៅអាណត្តិទាយកផងដែរ។

ឧទាហរណ៍ នៅក្នុងករណីដែល **ក** បានផ្តល់អាណត្តិអោយទៅ **ខ** ដើម្បីទិញរថយន្តថ្មីមួយពី **គ** ដែលជាកាតព្វកិច្ចរបស់ខ្លួន ហើយ ទទួលបានសិទ្ធិទាមទារឱ្យ **គ** ប្រគល់រថយន្ត។ ប្រសិនបើ គ្មាន ការព្រមព្រៀងពិសេស **ខ** ត្រូវប្រគល់រថយន្តនោះ ទៅអោយ **ក** នៅក្នុងករណីដែល ខ្លួន បានទទួលរថយន្តនោះរួចហើយ ឬ ក៏ផ្ទេរនូវសិទ្ធិទាមទារអោយ **គ** ប្រគល់រថយន្ត នៅក្នុងករណីដែល គាត់ មិនទាន់បានទទួលរថយន្តនោះ នៅឡើយទេ។

## ៤.៤ ការទទួលខុសត្រូវសងសំណងការខូចខាតដែលបានប្រើប្រាក់

ដោយសារអាណត្តិគាហក បានទទួលប្រាក់ពីតតិយជន ទាក់ទងការចាត់ចែងកិច្ចការអាណត្តិ ប្រាក់នោះត្រូវប្រគល់ទៅអោយអាណត្តិទាយក។ ដូច្នេះ មាត្រា ៦៤៣ នេះចែងអំពី ករណីយកិច្ចសងការខូចខាតទៅឱ្យអាណត្តិទាយក ប្រសិនបើអាណត្តិគាហក បានប្រើប្រាស់ប្រាក់នោះ សំរាប់ផលប្រយោជន៍ផ្ទាល់ខ្លួន។ អាណត្តិគាហក មានករណីយកិច្ចសងការខូចខាត មិនមែនត្រឹមតែការប្រាក់ក្នុងអំឡុងពេលនៃការយឺតយ៉ាវប៉ុណ្ណោះទេ គឺថែមទាំងការខូចខាតដទៃទៀតផ្សេង ៗ ទៀតផងដែរ ប្រសិនបើមាន។

នេះ គឺជាទណ្ឌកម្មចំពោះការបំពានករណីយកិច្ច ដែលមានចែងនៅក្នុងមាត្រា ៦៤២។ ទន្ទឹមនឹងនេះ មាត្រានេះ ត្រូវអនុវត្តតែក្នុងករណីដែលអាណត្តិគាហក បានប្រើប្រាក់នោះ។ ប្រសិនបើ អាណត្តិគាហក បានប្រើនូវវត្ថុដទៃទៀត ក្រៅពីប្រាក់ ដែលបានត្រូវប្រគល់ទៅអោយអាណត្តិទាយក នោះ គាត់ ត្រូវទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ច ឬ អំពើអនីត្យានុកូល។

នៅក្នុងករណីនៃអាណត្តិដែលគ្មានសិទ្ធិតំណាង អាណត្តិគាហក ត្រូវធ្វើលទ្ធកម្មលើកម្មសិទ្ធិលើប្រាក់ ដែលគាត់ បានទទួលទាក់ទងនឹងកិច្ចសន្យាអាណត្តិ។ អាណត្តិគាហក មិនចាំបាច់សងប្រាក់ (ក្រដាស់ប្រាក់) ដដែលដែលគាត់បានទទួលនោះទេ ព្រោះ ប្រាក់ មានលទ្ធភាពដែលអាចជំនួសបាន។ ដូច្នេះ ទោះបីជា អាណត្តិគាហក បានប្រើប្រាក់ដែលគាត់ បានទទួលទាក់ទងនឹងកិច្ចសន្យាអាណត្តិ នោះ វា មិនមែនជាចាំបាច់ក្លាយជាករណី "ប្រើប្រាក់សំរាប់ផលប្រយោជន៍ផ្ទាល់ខ្លួននោះទេ"។ គេ អាចសំរេចដោយធ្វើការពិចារណាទៅលើ លក្ខខណ្ឌនៃសមត្ថភាពខាង

ហិរញ្ញវត្ថុរបស់អាណត្តិគាហក ហើយ ថាតើអាណត្តិគាហក អាចសងនូវចំនួនទឹកប្រាក់ ដែលគាត់ បានប្រើនោះ ដែរ ឬ ទេ។

### ៤.៥ ករណីយកិច្ចសង្គ្រោះបន្ទាន់នៅក្រោយពេលបញ្ចប់អាណត្តិ

ជាទូទៅ ប្រសិនបើអាណត្តិ ត្រូវបានរំលាយ កាតព្វកិច្ច និង សិទ្ធិទាមទារទាំងអស់ ត្រូវរលត់។ ក៏ប៉ុន្តែ វាមានសារសំខាន់ក្នុងការការពារផលប្រយោជន៍របស់អាណត្តិទាយក ពីការរងការខូចខាត ដែលកើតឡើងដោយសារហេតុការណ៍ណាមួយ ដែលមិនអាចព្យាករបាន ក្នុងអំឡុងពេលចាប់ពីការបញ្ចប់អាណត្តិរហូតដល់អាណត្តិទាយក ឬ អ្នកផ្សេងទៀត អាចចាត់ចែងកិច្ចការទាំងអស់ ដែលត្រូវបានប្រគល់ទៅអោយអាណត្តិគាហក។

ឧទាហរណ៍ នៅក្នុងករណីមរណភាពរបស់អាណត្តិគាហក កិច្ចសន្យាអាណត្តិ ត្រូវបានបញ្ចប់ (មាត្រា ៦៤៩ កថាខណ្ឌទី ១ ចំណុច ក) ប៉ុន្តែអាណត្តិទាយក អាចមានការលំបាកក្នុងការចាត់ចែងការងាររបស់ខ្លួន។ ដូច្នេះ សន្តតិជន ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់អាណត្តិគាហក ត្រូវធ្វើការចាត់ចែងកិច្ចការអាណត្តិនោះ រហូតដល់ពេលដែលអាណត្តិទាយក សន្តតិជន ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់អាណត្តិទាយក អាចចាត់ចែងកិច្ចការនោះបាន។

ទន្ទឹមនឹងនេះដែរ ឧទាហរណ៍ **ក** បានផ្តល់អាណត្តិអោយទៅ **ខ** ដើម្បីប្រមូលបំណុលដែលជាប្រាក់ពី **គ** ហើយ កិច្ចសន្យាអាណត្តិ ត្រូវបានបញ្ចប់ គ្រាន់តែនៅមុនពេលនៃការបញ្ចប់នូវអាជ្ញាយុកាលនៃការរំលត់។ នៅក្នុងករណីនេះ ដោយផ្អែកទៅលើមាត្រា ៦៥០ **ខ** ត្រូវចាត់វិធានការណ៍ដើម្បីបង្ការនូវការបញ្ចប់នូវអាជ្ញាយុកាលនៃការរំលត់ ដូចជាធ្វើការទាមទារអោយសងប្រាក់ ការផ្អាកអាជ្ញាយុកាលនៃការរំលត់ (មាត្រា ៤៨៩) ជាអាទិ៍ ទោះជានៅក្រោយការបញ្ចប់អាណត្តិក៏ដោយ។

## ៥. កាតព្វកិច្ចរបស់អាណត្តិទាយក

### ៥.១ ករណីយកិច្ចបង់កំរៃ

បើគ្មានការកំណត់ពិសេស ដែលត្រូវឱ្យអាណត្តិទាយកបង់កំរៃមកអាណត្តគាហក នាំឱ្យអាណត្តិគាហក ពុំអាចទាមទារបានឡើយ ព្រោះថា ជាគោលការណ៍ កិច្ចសន្យាអាណត្តិ មិនយកកម្រៃ។ ប៉ុន្តែមាត្រា ៦៤៤ ចែងអំពីសិទ្ធិទាមទារកម្រៃ ក្នុងករណីនៃអាណត្តិដោយយកកម្រៃ និង អំណត់អំពីគោលការណ៍នៃការបង់តាមក្រោយ។

នៅក្នុងករណីនៃអាណត្តិ ដែលយកកំម្រៃ អាណត្តិទាយក មិនចាំបាច់បង់ប្រាក់កំរៃ នៅមុនពេលអនុវត្តកាតព្វកិច្ចដែលត្រូវបានអាណត្តិនោះទេ (មាត្រា ៦៤៤ កថាខណ្ឌទី ២)។

នៅពេលដែលបានកំណត់អំឡុងពេលនៃការបង់កំរៃ នាំឱ្យអាណត្តិគាហក អាចទាមទារកំរៃតាមអំឡុងពេលនោះបាន។

ប៉ុន្តែប្រសិនបើ អាណត្តិ ត្រូវបានបញ្ចប់ការអនុវត្តនៅពាក់កណ្តាលទី ដោយគ្មានកំហុសរបស់អាណត្តិគាហកទេ នាំអោយអាណត្តិគាហក អាចទាមទារកម្រៃបាន តាមសមាមាត្រនៃភាគដែលបានអនុវត្តរួច ហើយ (មាត្រា ៦៤៤ កថាខណ្ឌទី ៣) ព្រោះ គោលបំណងនៃអាណត្តិ គឺមិនមែនសំរេចការងារ ដែលបានកំណត់ នោះទេ ដែលមានលក្ខណៈផ្សេងគ្នាពីកិច្ចសន្យាម៉ៅការ ។

### ៥.២ ករណីយកិច្ចបង់សោហ៊ុយជាមុន

ដោយផ្អែកទៅលើមាត្រា ៦៤៥ ប្រសិបើមានតម្រូវការចាំបាច់លើសោហ៊ុយសំរាប់ការចាត់ចែងកិច្ចការអាណត្តិ អាណត្តិទាយក ត្រូវបង់សោហ៊ុយនោះជាមុន តាមការទាមទាររបស់អាណត្តិគាហក។ ករណីយកិច្ចរបស់អាណត្តិទាយកក្នុងការបង់សោហ៊ុយនេះ គឺមានគោលបំណងធ្វើអោយការចាត់ចែងកិច្ចការអាណត្តិ មានដំណើរការយ៉ាងរលូន។ ទោះបីជាអាណត្តិដោយយកកម្រៃ ឬ មិនយកកំរៃក៏ដោយ ប្រសិនបើអាណត្តិគាហក ទាមទារសោហ៊ុយ ក៏អាណត្តិទាយក ត្រូវបង់សោហ៊ុយនោះជាមុនដែរ ។

ឧទាហរណ៏ ក បានផ្តល់អាណត្តិដែលគ្មានសិទ្ធិតំណាងអោយទៅ ខ ដើម្បីទិញរថយន្ត។ ខ ត្រូវបង់ថ្លៃទិញរថយន្តអោយទៅ គ។ នៅពេលខ្លះ វា គឺជាបន្ទុកដ៏ធ្ងន់ធ្ងរសំរាប់ ខ ដូច្នេះ ខ ត្រូវទាមទារអោយ ក បង់ថ្លៃទិញរថយន្តនោះមកអោយខ្លួន ដើម្បីអោយខ្លួន អាចបង់ប្រាក់នោះទៅអោយ គ បាន។

### ៥.៣ ករណីយកិច្ចសងវិញនូវសោហ៊ុយដែលបានចំណាយ

ដោយយោងទៅលើមាត្រា ៦៤៥ អាណត្តិគាហក អាចទាមទារសោហ៊ុយចាំបាច់ជាមុនបាន។ ផ្ទុយទៅវិញ ទោះបីជា អាណត្តិគាហក មិនបានស្នើសុំអោយអាណត្តិទាយកបង់សោហ៊ុយជាមុននោះទេ នោះ អាណត្តិគាហក ក៏មានសិទ្ធិទាមទារអោយសងនូវសោហ៊ុយដែលបានចំណាយ និង ការប្រាក់ពីអាណត្តិទាយកបានដែរ ប្រសិនបើ គាត់បានចំណាយសោហ៊ុយផ្ទាល់ខ្លួន សំរាប់ចាត់ចែងកិច្ចការអាណត្តិ ដែលជាប្រយោជន៏របស់អាណត្តិទាយក ។

ទន្ទឹមនឹងនេះ ប្រសិនបើ បានអនុវត្តកាតព្វកិច្ចចាំបាច់ ដើម្បីចាត់ចែងកិច្ចការអាណត្តិ នោះ អាណត្តិគាហក អាចទាមទារឱ្យអាណត្តិទាយកសងកាតព្វកិច្ចជំនួសខ្លួនបាន។

នៅក្នុងអាណត្តិដែលគ្មានសិទ្ធិតំណាង អានុភាពនៃសកម្មភាពរបស់អាណត្តិគាហក ត្រូវបានអានុភាពចំពោះអាណត្តិគាហកខ្លួនឯងផ្ទាល់។ ក៏ប៉ុន្តែ មាត្រានេះ បានចែងថា ក្នុងករណីដែលអាណត្តិគាហក ទទួលបន្ទុកកាតព្វកិច្ចចាំបាច់ នោះ គាត់ អាចទាមទារអោយអាណត្តិទាយក អនុវត្តកាតព្វកិច្ចនោះជំនួសខ្លួន។

ឧទាហរណ៏ ក បានផ្តល់អាណត្តិអោយទៅ ខ ដើម្បីទិញរថយន្ត ក្នុងតំលៃ ៥០០០ ដុល្លា។ ប្រសិនបើ ខ បានចុះកិច្ចសន្យាទិញរថយន្តនៅក្នុងតំលៃ ១០០០ ដុល្លា ជាមួយនឹង គ នោះ ខ អាចទាមទារអោយ ក បង់ប្រាក់ ១០០០ ដុល្លា ទៅអោយ គ។ ប្រសិនបើ កាតព្វកិច្ច មិនទាន់ដល់ពេលកំណត់នៅឡើយទេ នោះ ខ អាចទាមទារឱ្យ ក ដាក់ប្រាតិភោគដែលសមរម្យបាន។

ក ──────► ខ ទិញឡាន
៥,000 ដុល្លា
- ពេល ខ បានបង់ ៥,000 ដុល្លា ទៅអោយ គ
⟹ ខ អាចទាមទារឱ្យ ក បង់ប្រាក់បាន ។
- ប្រសិនបើ ខ មិនទាន់បានបង់ប្រាក់
⟹ ខ អាចទាមទារឱ្យ ក បង់ជំនួសខ្លួន ៥,000 ដុល្លា ទៅអោយ គ តែម្តង ឬ ដាក់នូវប្រាតិភោគដែលសមរម្យ ។
គ

### ៥.៤ ករណីយកិច្ចសងសំណងនៃការខូចខាត

ដោយផ្អែកលើ មាត្រា ៦៤៦ កថាខណ្ឌទី ៣ ប្រសិនបើ បានទទួលការខូចខាត ដែលមិនមែនបណ្តាលមកពីកំហុសរបស់ខ្លួនក្នុងការចាត់ចែងកិច្ចការអាណត្តិទេ នោះ អាណត្តិគាហក អាចទាមទារសំណងនៃការខូចខាតនោះពីអាណត្តិទាយកបាន ។ នេះ គឺជាការទទួលខុសត្រូវដាច់ខាតរបស់អាណត្តិទាយក ព្រោះ អាណត្តិទាយក ត្រូវទទួលបន្ទុកហានិភ័យនៃអាណត្តិ ។ ក៏ប៉ុន្តែ ប្រសិនបើ ការខូចខាតនោះ កើតឡើងដោយចេតនា ឬ កំហុសរបស់តតិយជន ពេលនោះ អាណត្តិគាហក អាចទាមទារសំណងចំពោះអាណត្តិទាយកបានត្រឹមតែកម្រិត ដែលអាណត្តិគាហក មិនបានទទួលពីតតិយជនតែប៉ុណ្ណោះ ។

ឧទាហរណ៍ ក បានផ្តល់អាណត្តិអោយទៅ ខ ដើម្បីមើលថែរក្សាកូនរបស់ ក ហើយ ឆ្កែដែលគ្មានម្ចាស់បានមកខាំក្មេងនោះ ហើយ ខ ព្យាយាមការពារកូននោះ ដែលបានធ្វើអោយគាត់រងរបួស ។

ក ──────► ខ (ឱ្យ ខ មើលថែទាំកូនរបស់ ក)

ឆ្កែខាំកូន ក ⟹ ខ ការពារពីឆ្កែខាំ ⟹ ខ រងរបួស ⟹ ខ ទាមទារសំណងពី ក
(ការទទួលខុសត្រូវដាច់ខាត)

ប្រសិនបើការខូចខាតបណ្តាលពីកំហុសរបស់តតិយជន នោះ ខ ទាមទារសំណងពី ក ត្រឹមកំរិតដែល ក មិនបានទទួលសំណងពីតតិយជននោះ ។ ដូច្នេះ ឧទាហរណ៍ ប្រសិនបើ គ បានបង្កោផ្កែឱ្យខាំកូនរបស់ ក នាំអោយ ខ រងរបួស ។ សោហ៊ុយព្យាបាលលើរបួសនេះ អស់ ១០០ ដុល្លា ។ ក៏ប៉ុន្តែ គ បានបង់អោយ ខ តែ ២០ ដុល្លាទេ ។ នៅក្នុងករណីនេះ ខ អាចទាមទារពី ក ៨០ ដុល្លា បន្ថែមទៀត ព្រោះថា ខ បានរងរបួសដោយសារកិច្ចការពារអាណត្តិចំពោះ ក ។

## ៦. ការរំលាយកិច្ចសន្យាអាណត្តិ

### ៦.១ មូលហេតុនៃការបញ្ចប់កិច្ចសន្យាអាណត្តិ

មូលហេតុនៃការបញ្ចប់កិច្ចសន្យាអាណត្តិ មានពីរប្រភេទ គឺការបញ្ចប់ដោយការរំលាយកិច្ចសន្យាអាណត្តិ និង ការបញ្ចប់ដោយផ្អែកលើក្រមរដ្ឋប្បវេណី ។

### ៦.១.១ ការបញ្ចប់ដោយសារការរំលាយកិច្ចសន្យាអាណត្តិដោយភាគី

ការរំលាយកិច្ចសន្យាអាណត្តិ អាចធ្វើឡើងពេលណាក៏បាន ( ព្រោះជាបញ្ញត្តិពិសេស) ។ ព្រោះ កិច្ចសន្យាអាណត្តិ គឺពឹងផ្អែកលើទំនាក់ទំនងនៃការទុកចិត្តគ្នារវាងគូភាគី ប៉ុន្តែ ប្រសិនបើ ភាគីណាម្ខាង បានបាត់បង់ការទុកចិត្តទៅលើភាគីម្ខាងទៀត នោះ ពួកគេ មិនអាចថែរក្សាទំនាក់ទំនងនេះបានទៀតទេ។ ដូច្នេះ ក្រមរដ្ឋប្បវេណី បានចែងថា ភាគីនីមួយៗ អាចរំលាយ កិច្ចសន្យាអាណត្តិបាន ដោយមិនចាំបាច់មានហេតុផលសមរម្យ នៅពេលណាក៏បាន ( មាត្រា ៦៤៧) ។

ក៏ប៉ុន្តែ ប្រសិនបើភាគី បានរំលាយអាណត្តិ នៅក្នុងអំឡុងពេលដែលធ្វើអោយខូចខាតដល់ភាគីម្ខាងទៀត ភាគីនោះ ត្រូវសងសំណងនៃការខូចខាតទៅភាគីម្ខាងទៀត ។ ឧទាហរណ៍ អាណត្តិគាហក រំលាយកិច្ចសន្យាអាណត្តិ នៅពេលដែលអាណត្តិទាយក មិនអាចរកបានអាណត្តិគាហកថ្មីមួយទៀត នោះ អាណត្តិគាហក ត្រូវសងសំណងនៃការខូចខាត ប្រសិនបើមាន ។ ទោះបីជាមូលហេតុនៃការរំលាយ គឺជាមូលហេតុដែលមិនអាចជៀសបាន ឧទាហរណ៍ ដូចជានៅក្នុងករណីដែលអាណត្តិគាហក មានជំងឺ ហើយ មិនអាចបន្តកិច្ចការអាណត្តិបាន នោះ អាណត្តិគាហក មិនចាំបាច់សងសំណងនៃការខូចខាតទេ ។

### ៦.១.២ ការបញ្ចប់ដែលបានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណី

ក្រៅពីការរំលាយកិច្ចសន្យាអាណត្តិ ដែលមានចែងនៅក្នុងមាត្រា ៦៤៧ អាណត្តិ ត្រូវបានបញ្ចប់ ដោយមូលហេតុដូចខាងក្រោម ( មាត្រា ៦៤៩ កថាខណ្ឌទី ១) :

- មរណភាពរបស់អាណត្តិទាយក ឬ អាណត្តិគាហក ( ចំណុច ក)
- ការប្រកាសក្ស័យធនរបស់អាណត្តិទាយក ឬ អាណត្តិគាហក ( ចំណុច ខ)
- ការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ ឬ ការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភរបស់អាណត្តិទាយក ( ចំណុច គ)
- ការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ ឬ ការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភរបស់អាណត្តិគាហក ( ចំណុច ឃ)
- អាណត្តិទាយក ឬ អាណត្តិគាហក ជានីតិបុគ្គលបានរលាយ ( ចំណុច ង)

- អាណត្តិទាយក ឬ អាណត្តិគាហក ជានីតិបុគ្គល បានរួមបញ្ចូលជាមួយនីតិបុគ្គលផ្សេង (ចំណុច ច)

- មូលហេតុផ្សេងៗ ដែលបានកំណត់តាមការព្រមព្រៀងរបស់ភាគី (ចំណុច ឆ)

មូលហេតុមួយចំនួន គឺមានលក្ខណៈជាន់គ្នាទៅនឹងមូលហេតុនៃការរលត់សិទ្ធិតំណាងដោយកិច្ចសន្យា (មាត្រា ៣៦៨)

- ទន្ទឹមនឹងនេះ ដោយសារបញ្ញត្តិខាងលើនេះ មិនមែនជាបញ្ញត្តិដែលអនុវត្តដោយបង្ខំ ដូច្នេះ ភាគី អាចព្រមព្រៀងគ្នាផ្សេងបាន។ វា មានន័យថា ភាគី អាចសន្យាបានដែរថា ទោះបីជាមានមូលហេតុណាមួយក្នុងចំណោមមូលហេតុដែលមានកំណត់នៅក្នុងមាត្រា ៦៤៩ ក៏ដោយ ក៏អាណត្តិ មិនបញ្ចប់ដែរ។ លើសពីនេះ ភាគី អាចលើកយកមូលហេតុផ្សេងក្រៅពីមូលហេតុ ដែលមានចែងក្នុងមាត្រា ៦៤៩ មកធ្វើជាមូលហេតុនៃការបញ្ចប់អាណត្តិបាន។

## ៦.២ អានុភាពនៃការរំលាយ

មាត្រា ៦៤៨ ចែងថា អានុភាពនៃការរំលាយនោះ កើតមានឡើងដោយឆ្ពោះទៅអនាគតតែប៉ុណ្ណោះ ហើយ មិនមានអានុភាពប្រតិសកម្ម ដូចកិច្ចសន្យាជាបន្តផ្សេងទៀតទេ។ មូលហេតុដែលការរំលាយអាណត្តិ មិនមានអានុភាពប្រតិសកម្ម គឺថាទំនាក់ទំនងរវាងអាណត្តិទាយក អាណត្តិគាហក និង ភាគីម្ខាងទៀត អាចនឹងមានភាពស្មុគស្មាញ ប្រសិនបើ ការរំលាយ មានអានុភាពប្រតិសកម្មនៅក្នុងករណីនៃអាណត្តិ។

ដូច្នេះ នៅពេលកិច្ចសន្យាអាណត្តិ ត្រូវបានរំលាយ អាណត្តិគាហក ត្រូវប្រគល់ប្រាក់ ឬ វត្ថុ ដែលខ្លួន បានទទួលទាក់ទងនឹងការចាត់ចែងកិច្ចការអាណត្តិ ទៅឱ្យអាណត្តិទាយក ហើយអាណត្តិទាយក ត្រូវបង់កំរៃ (នៅក្នុងករណីដែលមានការព្រមព្រៀងគ្នាពិសេស) ឬ សោហ៊ុយចាំបាច់ ទៅអោយអាណត្តិគាហក តាមសមាមាត្រនៃភាគដែលបានអនុវត្តរួចហើយ។

លក្ខខណ្ឌតតាំងនៃការបញ្ចប់អាណត្តិ (៦៥១) មានគោលបំណងដើម្បីការពារភាគីនៃកិច្ចសន្យាអាណត្តិដែលមិនដឹងអំពីការបញ្ចប់អាណត្តិ ពីការខូចខាតដែលមិនអាចព្យាករបាន។ ដូច្នេះ ប្រសិនបើភាគីណាមួយ ដែលបានបញ្ចប់អាណត្តិ ដោយមិនបានជូនដំណឹងទៅភាគីម្ខាងទៀតទេ នោះ គាត់ មិនយកអាចលើកយកមូលហេតុនៃការបញ្ចប់អាណត្តិនេះ មកតតាំងជាមួយនឹងភាគីម្ខាងទៀតបានឡើយ។

ឧទាហរណ៍ **ក** បានផ្តល់អាណត្តិអោយ **ខ** ដើម្បីទិញរថយន្ត។ ក៏ប៉ុន្តែ **ក** ត្រូវបានប្រកាសក្ស័យធន ប៉ុន្តែគាត់ មិនបានជូនដំណឹងអំពីការណ៍នេះ ទៅ **ខ** ទេ។ **ខ** ដែលមិនបានដឹងអំពីការបញ្ចប់អាណត្តិនេះ បានចុះកិច្ចសន្យាជាមួយនឹង **គ**។ នៅក្នុងករណីនេះ **ក** មិនអាចលើកឡើងអំពីការបញ្ចប់អាណត្តិបានទេ ហើយ កិច្ចសន្យា ត្រូវបានបង្កើតឡើងដោយមានសុពលភាព។

# ផ្នែកទី ១១
# កិច្ចសន្យាម៉ៅការ

## ១. គោលគំនិត

យោងតាមមាត្រា ៦៥២ កិច្ចសន្យាម៉ៅការ សំដៅទៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាង ហៅថា អ្នកម៉ៅការ មានករណីយកិច្ចសម្រេចការងារដែលបានព្រមព្រៀង ហើយភាគីម្ខាងទៀត ហៅថា ម្ចាស់ការ មានករណីយកិច្ចផ្តល់កម្រៃចំពោះ លទ្ធផលនៃការងារដែលបានធ្វើនោះ ។

ទន្ទឹមនឹងនេះ កិច្ចសន្យាម៉ៅការ គឺជាកិច្ចសន្យាដែលយកតំលៃថ្នូរ និង ជាកិច្ចសន្យាទ្វេភាគី ដែលគូភាគីនៃកិច្ចសន្យាត្រូវផ្តល់តាវកាលិកឱ្យគ្នាទៅវិញទៅមក ។

គួរកត់សំគាល់ថា កិច្ចសន្យាម៉ៅការមានអត្ថន័យខុសគ្នានឹងកិច្ចសន្យាអណត្តិ និងកិច្ចសន្យាការងារ ។ ភាពខុសគ្នា គឺមានដូចខាងក្រោម :

នៅក្នុង កិច្ចសន្យាការងារ ខ្លឹមសារនៃកិច្ចសន្យា គឺថា និយោជិត សន្យាថានឹងធ្វើពលកម្ម ហើយ និយោជកសន្យាថានឹងផ្តល់ប្រាក់ឈ្នួល ទៅលើកិច្ចការពលកម្មនោះ ។ និយោជិត មិនចាំបាច់សំរេចការងាររបស់ខ្លួនទេ ដែលជាលក្ខណៈខុសគ្នាទៅនឹងកិច្ចសន្យាម៉ៅការ ។

នៅក្នុងកិច្ចសន្យាអណត្តិ អាណត្តិគាហក ត្រូវចាត់ចែងកិច្ចការ ដែលត្រូវបានផ្តល់អាណត្តិអោយ ដោយអាណត្តិទាយក ហើយ អាណត្តិគាហក មិនចាំបាច់សំរេចកិច្ចការនោះ ដែលនេះជាចំណុចខុសពីកិច្ចសន្យាម៉ៅការដែរ ។ ទន្ទឹមនឹងនេះ កិច្ចសន្យាអាណត្តិ គឺជាកិច្ចសន្យាមិនយកតំលៃថ្នូរ ប្រសិនបើមិនមានការព្រមព្រៀងផ្សេងពីនេះ ។

## ២. លក្ខខណ្ឌក្នុងការបង្កើតកិច្ចសន្យាម៉ៅការ

កិច្ចសន្យាម៉ៅការ ពុំមានទាមទារលក្ខខណ្ឌពិសេសណាមួយទេ គឺឱ្យតែគូភាគី មានការព្រមព្រៀង ជាការគ្រប់គ្រាន់នឹងបង្កើតកិច្ចសន្យាបានហើយ ( មាត្រា ៣៣៦ កថាខណ្ឌទី ១) ។

## ៣. កាតព្វកិច្ចរបស់អ្នកម៉ៅការ

### ៣.១ ករណីយកិច្ចសម្រេចការងារដោយគ្មានវិការៈ

#### ៣.១.១ គោលគំនិត

យោងតាមមាត្រា ៦៥៤ កថាខណ្ឌទី ១ អ្នកម៉ៅការ មានករណីយកិច្ចសម្រេចការងារ ដោយគ្មានវិការៈចំពោះម្ចាស់ការ ។

វិការៈដែលមានចែងនៅក្នុងមាត្រា ៦៥៤ កថាខណ្ឌទី ២ និង ទី ៣ គឺ:

- ការងារពុំមានលក្ខណៈដូចបានព្រមព្រៀង

- ការងារពុំត្រឹមត្រូវតាមគោលដៅក្នុងការប្រើប្រាស់ដែលបានកំណត់នៅក្នុងកិច្ចសន្យា

- ការងារនោះមិនត្រឹមត្រូវក្នុងការប្រើប្រាស់ជាប្រក្រតី ប្រសិនបើដែលការប្រើប្រាស់ជាក់លាក់ មិនត្រូវបានកំណត់

- ការងារដែលបានធ្វើមិនគ្រប់ចំនួន ឬ

- អ្នកម៉ៅការបានធ្វើការផ្ទុយនឹងការបញ្ជា

ជាទូទៅ ខ្លឹមសារនៃកិច្ចសន្យាម៉ៅការ គឺសំរេចការងារ ដែលមានលក្ខណៈជាក់លាក់ ។

ឧទាហរណ៍ ម្ចាស់ការ អោយជាងគំនូរ គូររូបរបស់ខ្លួន ដូចនេះ គេ មិនអាចនិយាយបានទេថា ការងារ គឺអនុលោមទៅតាមលក្ខណៈដែលបានព្រមព្រៀង ប្រសិនបើគំនូរនោះ មិនដូចនឹងម្ចាស់ការ ។

ឧទាហរណ៍មួយទៀត គឺថា អ្នកម៉ៅការ បានសង់អាគារ ដោយផ្អែកលើកិច្ចសន្យាថា ម្ចាស់ការ នឹងប្រើប្រាស់អាគារនោះ សំរាប់បើកជាភោជនីយដ្ឋាន ប៉ុន្តែ អ្នកម៉ៅការ មិនបានបំពាក់ប្រព័ន្ធបង្ហូរទឹកសំអុយចេញ ។ នៅក្នុងករណីនេះ ការងារដែលបានសំរេចរួច គឺមិនស្របទៅនឹងការប្រើប្រាស់ ដែលបានសន្មតនៅក្នុងកិច្ចសន្យា ។

ជាងនេះទៅទៀត ប្រសិនបើម្ចាស់ការ បានអោយកាត់ស្បែកជើងមួយគូរ ដោយមិនបានកំណត់ពីវិធី ដែលត្រូវប្រើប្រាស់ ហើយបន្ទាប់មកស្បែកជើងនោះ បានរហែកជាពីរផ្នែក នៅក្រោយពេលដែលពាក់ដើរបានម្តង នោះគឺវា មិនឆ្លើយតបទៅនឹង "ប្រសិនបើការងារនេះ មិនត្រឹមត្រូវក្នុងការប្រើប្រាស់ជាប្រក្រតី" ។

ឧទាហរណ៍នៃមាត្រា ៦៥៤ កថាខណ្ឌទី ៣ គឺថា អ្នកម៉ៅការ បានកាត់ស្បែកជើងសង្រែកមួយគូរ ដែលតាមពិតទៅម្ចាស់ការ បានបញ្ជាគាត់ អោយកាត់ស្បែកជើងឃ្លុបមួយគូរ ។ នៅក្នុងករណីនេះ ការកាត់ស្បែកជើងសង្រែកមួយគូរ គឺត្រូវបានធ្វើរួចរាល់ហើយ និង ម្ចាស់ការ អាចប្រើស្បែកជើងនេះបានទៀត ប៉ុន្តែ អ្នកម៉ៅការ បានសំរេចការងារ ដែលខុសពីបញ្ជា ។

### ៣.១.២ ការទទួលខុសត្រូវរបស់អ្នកម៉ៅការ នៅក្នុងករណីដែលការងារមានវិការៈ

ក្នុងករណីដែលអ្នកម៉ៅការ បំពេញការងារដោយមានវិការៈ ម្ចាស់ការ មានសិទ្ធិទាមទារឱ្យអ្នកម៉ៅការធ្វើការអនុវត្តអោយត្រឹមត្រូវតាមកិច្ចសន្យា ឬ ជ្រើសរើសវិធីណាមួយតាមការអនុញ្ញាតរបស់ក្រមរដ្ឋប្បវេណី ។ សិទ្ធិទាមទារនេះ ត្រូវយកមកអនុវត្តនៅក្នុងអំឡុងពេល១ឆ្នាំ ដែលត្រូវផ្តើមគណនាចាប់ពីពេល ដែលម្ចាស់ការ បានដឹង ឬ គួរបានដឹងអំពីអត្ថិភាពនៃវិការៈនោះ ( មាត្រា៦៦១ ) ។

ការរៀបរាប់ខាងលើនេះ មិនអាចឱ្យអ្នកម៉ៅការរួចផុតពីកាតព្វកិច្ចបានឡើយ ទោះបីជាមានកិច្ចសន្យាពិសេសអំពីការអនុគ្រោះ ឬ កម្រិតការទទួលខុសត្រូវក៏ដោយ ប្រសិនបើអ្នកម៉ៅការ បានដឹងហើយ តែបែរជាមិនបានរាយការណ៍ប្រាប់ម្ចាស់ការ ( មាត្រា៦៦២ ) ។

### ក. ការទាមទារឱ្យអនុវត្តការងារពេញលេញរបស់ម្ចាស់ការ ( មាត្រា៦៥៥)

យោងតាមមាត្រា ៦៥៥ បើរកឃើញថាការងារមានវិការៈ ម្ចាស់ការ អាចទាមទារឱ្យអ្នកម៉ៅការ បំពេញកិច្ចការរបស់ខ្លួនឱ្យបានពេលលេញ ដោយកំណត់អំឡុងពេលសមរម្យ ( មាត្រា ៦៥៥ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១) ។

អ្នកម៉ៅការ អាចជ្រើសរើសអោយជួសជុលវិការៈនៃការងារនោះ ឬ អាចធ្វើការងារនោះសាជាថ្មីឡើងវិញ តាមការជ្រើសរើសបាន ( មាត្រា ៦៥៥ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។ ឧទាហរណ៍ ប្រសិនបើ អ្នកម៉ៅការ បានកាត់ស្បែកជើងឃ្លុបមួយគូរ តែតាមពិតទៅ ម្ចាស់ការ បានបញ្ជាគាត់អោយកាត់ស្បែកជើងស្បែកកវែង ដូច្នេះ វាមានលក្ខណៈងាយស្រួល និង ចំណាយតិច សំរាប់អ្នកម៉ៅការកាត់ស្បែកជើងនោះជាថ្មីម្តងទៀត ជៀសជាងការជួសជុល ។ នៅក្នុងករណីនេះ អ្នកម៉ៅការ អាចជ្រើសរើសកាត់ស្បែកជើងនោះម្តងទៀត ។

ប្រសិនបើ ការអនុវត្តការងារពេញលេញ ត្រូវចំណាយសោហ៊ុយច្រើនហួសហេតុ បើប្រៀបធៀបទៅនឹងការខូចខាតផលប្រយោជន៍ដោយវិការៈ នោះ អ្នកម៉ៅការ អាចបដិសេធចំពោះការអនុវត្តការងារពេញលេញបាន ( មាត្រា ៦៥៥ កថាខណ្ឌទី ២) ។ នៅក្នុងករណីនេះ ម្ចាស់ការ មិនអាចទាមទារអោយសងចំណាយលើការជួសជុលនៅក្រោយការបញ្ចប់ការជួសជុលដោយខ្លួនឯង ( មាត្រា ៦៥៦ កថាខណ្ឌទី ៤) និង មិនអាចទាមទារសំណងនៃការខូចខាត ( មាត្រា ៦៥៩ កថាខណ្ឌទី ២) ។ ដូច្នេះ ប្រសិនបើ ការអនុវត្តការងារពេញលេញ ចាំបាច់ចំណាយសោហ៊ុយច្រើនហួសហេតុ ប្រៀបធៀបនឹងទៅនឹងការខូចខាតផលប្រយោជន៍ដោយវិការៈ នោះ ម្ចាស់ការ ត្រូវទទួលរងនូវហានិភ័យនេះ។ ប្រសិនបើ ម្ចាស់ការ ចង់ជៀសវាងនូវស្ថានភាពបែបនេះ គាត់ ចាំបាច់ត្រូវបង្កើតកិច្ចព្រមព្រៀងពិសេសជាមួយនឹងអ្នកម៉ៅការ ។

ជាងនេះទៅទៀត កម្មវត្ថុ មានវិការៈ និង ចាំបាច់ត្រូវប្រគល់ត្រឡប់មកវិញ នោះ អ្នកម៉ៅការ អាចទាមទារឱ្យម្ចាស់ការសងការងារ ដែលមានវិការៈមកឱ្យខ្លួនវិញ ( មាត្រា ៦៥៥ កថាខណ្ឌទី ៣) ។

### ខ. ការជួសជុលវិការៈដោយម្ចាស់ការ ( មាត្រា៦៥៦)

ប្រសិនបើ ការងារ មានវិការៈ ម្ចាស់ការ ចាំបាច់ដាស់តឿនអោយអនុវត្តការងារអោយពេញលេញ ដោយកំណត់អំឡុងពេលជាក់លាក់ជាមុនសិន។ ហើយបន្ទាប់មក ប្រសិនបើ អ្នកម៉ៅការ មិនបានអនុវត្តការងារអោយពេញលេញនោះទេ នៅក្នុងអំឡុងពេលនោះ ម្ចាស់ការ អាចធ្វើការជួសជុលវិការៈនៃការងារដោយខ្លួនឯងផ្ទាល់ ហើយ អាចទាមទារសោហ៊ុយចាំបាច់លើការជួសជុលវិការៈនោះវិញ ( មាត្រា ៦៥៦ កថាខណ្ឌទី ១) ។

ម្ចាស់ការ ក៏អាចជួសជុលវិការៈដោយខ្លួនឯង ហើយអាចទាមទារសោហ៊ុយដែលចាំបាច់ក្នុងការជួសជុលវិការៈ ក្នុងករណីដែលការអនុវត្តការងារឱ្យពេញលេញ មិនបានសម្រេច ឬ ក្នុងករណីដែលវាយតម្លៃថា ការអនុវត្តការងារឱ្យពេញលេញដោយអ្នកម៉ៅការ នឹងធ្វើអោយមានការខូចខាតផលប្រយោជនដោយមិនត្រឹមត្រូវ ចំពោះម្ចាស់ការ ( មាត្រា ៦៥៦ កថាខណ្ឌទី ២) ។

ម្ចាស់ការ អាចទាមទារឱ្យអ្នកម៉ៅការបង់សោហ៊ុយចាំបាច់លើការជួសជុលនេះជាមុនបាន នៅក្នុងករណី ដែលម្ចាស់ការ អាចសំរេចការងារដែលមានវិការៈនោះអោយបានពេញលេញ។

ក៏ប៉ុន្តែ នៅក្នុងករណីដែល អ្នកម៉ៅការ បានបដិសេធការអនុវត្តការងារអោយពេញលេញ ដោយផ្អែកលើ មាត្រា ៦៥៥ កថាខណ្ឌទី ២ នោះ ម្ចាស់ការ មិនអាចសោហ៊ុយចាំបាច់លើការជួសជុល និង បង់សោហ៊ុយជាមុន ឡើយ ( មាត្រា ៦៥៦ កថាខណ្ឌទី ៤) ។

### គ. សិទ្ធិរំលាយរបស់ម្ចាស់ការ ( មាត្រា៦៥៧)

ប្រសិនបើ ការងារ មានវិការៈ ម្ចាស់ការ អាចប្រើសិទ្ធិរំលាយកិច្ចសន្យា ដោយផ្អែកតាមបញ្ញត្តិនៃផ្នែកទី ៤ ជំពូកទី ៤ នៃគន្ថីទី ៤ បាន (ការរំលាយកិច្ចសន្យា)។ ឬនិយាយម្យ៉ាងទៀត ម្ចាស់ការ អាចរំលាយកិច្ចសន្យា ម៉ៅការបាន តែក្នុងករណីដែល វិការៈនោះ ត្រូវគ្នានឹង "ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ"។ ឧទាហរណ៍ ប្រសិនបើ វិការៈ មានភាពធ្ងន់ធ្ងរ ហើយការអនុវត្តការងារអោយបានពេញលេញ មិនអាចធ្វើទៅបាន ឬ ប្រសិនបើការអនុវត្តការងារ អោយបានពេញលេញ គឺអាចធ្វើទៅបាន ប៉ុន្តែ ត្រូវចំណាយពេលវេលាយូរ ដូច្នេះ គេ អាចនិយាយបានថា វិការៈនៃ ការងារនេះ គឺជាការបំពានកិច្ចសន្យាធ្ងន់ធ្ងរ។

ទន្ទឹមនឹងនេះ នៅក្នុងករណីដែល ក្នុងករណីដែលការអនុវត្តការងារអោយពេញលេញ មិនបានសម្រេច ឬ ក្នុងករណីដែលវាយតម្លៃថា ការអនុវត្តការងារអោយពេញលេញ ដោយអ្នកម៉ៅការនឹងធ្វើអោយមានការខូចខាត ផលប្រយោជន៍ ដោយមិនត្រឹមត្រូវចំពោះម្ចាស់ការ នោះ ម្ចាស់ការ អាចរំលាយកិច្ចសន្យា ដោយផ្អែកលើបញ្ញត្តិ ទូទៅនៃការរំលាយកិច្ចសន្យា ( មាត្រា ៦៥៧ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។

ក៏ប៉ុន្តែ បញ្ញត្តិខាងលើនេះ មិនត្រូវយកមកអនុវត្តចំពោះអាគារ ឬ សំណង់លើដីផ្សេងទៀតឡើយ។ ប្រសិនបើ ម្ចាស់ការ ត្រូវបានអនុញ្ញាតអោយរំលាយកិច្ចសន្យាម៉ៅការ ដែលកំណត់ថា អ្នកម៉ៅការ ត្រូវសង់អាគារ ឬ សំណង់លើដីផ្សេងទៀត ហើយដោយសារតែវិការៈ អ្នកម៉ៅការ ត្រូវរុះរើអាគារចេញ នៅក្រោយការរំលាយ ទោះបីជាអាគារនោះ ត្រូវបានសាងសង់ហើយក៏ដោយ។ វា គឺជាបន្ទុកមួយដ៏ធ្ងន់ធ្ងរចំពោះអ្នកម៉ៅការ ហើយនិង ធ្វើអោយខាតបង់ដល់វិស័យសេដ្ឋកិច្ចផងដែរ។ ដូច្នេះ នៅក្នុងករណីនេះ ម្ចាស់ការ មិនអាចរំលាយកិច្ចសន្យា ទោះបី ជា ការងារ មានវិការៈក៏ដោយ ហើយ គាត់ អាចទាមទារបានតែការអនុវត្តការងារអោយបានពេញលេញ និង/ឬ សំណងនៃការខូចខាត។ ប៉ុន្តែ ប្រសិនបើសំណង់នោះ ពុំមានតម្លៃនឹងប្រើប្រាស់ចំពោះម្ចាស់ការ ដោយសារវិការៈ ធ្ងន់ធ្ងរពេក នោះ គាត់ អាចរំលាយកិច្ចសន្យាបាន ( មាត្រា ៦៥៧ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២) ។

ឧទាហរណ៍ ម្ចាស់ការ បានបញ្ជាអោយអ្នកម៉ៅការ សាងសង់ផ្ទះសំរាប់ស្នាក់នៅ ប៉ុន្តែ អាគារ ដែលអ្នក ម៉ៅការ បានសាងសង់នោះ គឺមានគ្រឹះក្រោមមិនរឹងមាំ ហើយដែលប្រឈមមុខនឹងបាក់រលំ ដូច្នេះ អាគារនេះ មិន ត្រឹមមានតំលៃក្នុងការប្រើប្រាស់សំរាប់ម្ចាស់ការទេ ថែមទាំងមិនអាចនិយាយបានថា ការរុះរើអាគារនេះ គឺជាបន្ទុក

ធ្ងន់ធ្ងររបស់អ្នកម៉ៅការ ឬ ធ្វើអោយខាតបង់សេដ្ឋកិច្ចទៀតទេ។ ដូច្នេះ នៅក្នុងករណីនេះ ម្ចាស់ការ អាចរំលាយកិច្ចសន្យាបាន។

### ឃ. សិទ្ធិទាមទារអោយបន្ថយថ្លៃរបស់ម្ចាស់ការ ( មាត្រា ៦៥៨)

ម្ចាស់ការ អាចទាមទារឱ្យបន្ថយថ្លៃ តាមការបង្ហាញឆន្ទៈចំពោះអ្នកម៉ៅការ ដោយយកវិការៈនៃការងារមកធ្វើជាមូលហេតុបាន ប្រសិនបើ ម្ចាស់ការ បានទាមទារឱ្យអនុវត្តការងារពេញលេញ ចំពោះការងារ ដែលមានវិការៈនោះ ដោយកំណត់អំឡុងពេលសមរម្យ ប៉ុន្តែអ្នកម៉ៅការ មិនបានអនុវត្តការងារពេញលេញនៅក្នុងអំឡុងពេលនោះ។ ឬនិយាយម្យ៉ាងទៀត នៅក្នុងករណីនេះ ម្ចាស់ការ អាចជួសជុលវិការៈដោយខ្លួនឯងផ្ទាល់ និង ទាមទារថ្លៃជួសជុល ( មាត្រា ៦៥៦ កថាខណ្ឌទី ១) ឬ ទាមទារអោយបន្ថយតំលៃ។

### ង. សិទ្ធិទាមទារសំណងនៃការខូចខាតរបស់ម្ចាស់ការ ( មាត្រា ៦៥៩)

ម្ចាស់ការ អាចទាមទារសំណងនៃការខូចខាត ដោយផ្អែកទៅលើបញ្ញត្តិទូទៅនៃសំណងការខូចខាត និង/ឬ អនុវត្តសិទ្ធិរបស់ខ្លួន ដែលមានចែងចាប់ពីមាត្រា ៦៥៥ ដល់ មាត្រា ៦៥៨។ ក៏ប៉ុន្តែនៅក្នុងករណីដែល ម្ចាស់ការ ទាមទារសំណងនៃការខូចខាត ជំនួសអោយការអនុវត្តការងារពេញលេញ គាត់ អាចធ្វើការទាមទារបាន តែក្នុងករណីដែលក្រោយការកន្លងផុតនៃអំឡុងពេលសមរម្យ សំរាប់អោយអ្នកម៉ៅការអនុវត្តការងារនោះ ឬ ការអនុវត្តការងារពេញលេញរបស់អ្នកម៉ៅការ មិនបានសំរេច ឬ ករណីដែលវាយតំលៃថា ការអនុវត្តការងារឱ្យបានពេញលេញដោយអ្នកម៉ៅការ នឹងធ្វើឱ្យមានការខូចខាតផលប្រយោជន៍ ដោយមិនត្រឹមត្រូវចំពោះម្ចាស់ការ។ ឬនិយាយម្យ៉ាងទៀត ប្រសិនបើ ម្ចាស់ការ ចង់ទាមទារនូវសំណងនៃការខូចខាត គាត់ ត្រូវធ្វើការទាមទារអោយអនុវត្តពេញលេញជាមុនសិន។

### ច. នៅក្នុងករណីដែលវិការៈកើតឡើងដោយសារសំភារៈ ឬ ការបញ្ជារបស់ម្ចាស់ការ ( មាត្រា ៦៦០)

នៅពេលខ្លះ ម្ចាស់ការ បានផ្តល់នូវសំភារៈ ឬ ការបញ្ជាជាក់លាក់ណាមួយ សំរាប់អោយអ្នកម៉ៅការអនុវត្តតាម។ នៅក្នុងករណីដែល វិការៈកើតឡើង ដោយសារសំភារៈ ឬ ការបញ្ជារបស់ម្ចាស់ការ នោះ អ្នកម៉ៅការ មិនចាំបាច់ទទួលខុសត្រូវទាក់ទងនឹងវិការៈនោះទេ។ ហើយ "ការបញ្ជា" ចាំបាច់ត្រូវតែរាប់បញ្ចូលនូវការណែនាំច្បាស់លាស់ មិនមែនគ្រាន់តែ "មានបំណង" នោះទេ។

ប្រសិនបើ អ្នកម៉ៅការ បានដឹងថា សំភារៈ ឬ ការបញ្ជានោះ មិនសមស្រប ប៉ុន្តែ គាត់ មិនបានផ្តល់ដំណឹងទៅដល់ ម្ចាស់ការ នោះ អ្នកម៉ៅការ មិនអាចរួចផុតពីការទទួលខុសត្រូវទាក់ទងនឹងវិការៈបានឡើយ។

## ៣.២ ករណីយកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុនៃការងារ

មាត្រា ៦៥៣ បានបញ្ញត្តិថា ប្រាក់កំរៃ ត្រូវបង់ដំណាលគ្នានឹងការប្រគល់វត្ថុដែលជាកម្មវត្ថុនៃការងារ។ នៅក្នុងន័យម្យ៉ាងទៀត អ្នកម៉ៅការ ត្រូវប្រគល់វត្ថុដែលជាកម្មវត្ថុនៃការងារ ក្រោយការបញ្ចប់ការងារ។ បន្ទាប់មក តើនៅពេលណា ដែលត្រូវទទួលបាននូវកម្មសិទ្ធិ ហើយនិង តើអ្នកណា ដែលត្រូវទទួលបានកម្មសិទ្ធិលើវត្ថុ ដែលជាកម្មវត្ថុនៃការងារនោះ ?

នៅក្នុងករណីដែលខ្លឹមសារនៃកិច្ចសន្យាម៉ៅការ គឺត្រូវសាងសង់អាគារ អាគារនេះ មិនអាចក្លាយជាកម្មវត្ថុនៃសិទ្ធិប្រត្យក្សដាច់ដោយឡែកពីដីបានឡើយ (មាត្រា ១២២)។ ដូចនេះ គេ អាចនិយាយបានថា ទោះបីជាអ្នកម៉ៅការ បានផ្តល់នូវសំភារៈសំរាប់សាងសង់អាគារក៏ដោយ ក៏កម្មសិទ្ធិនៃអាគារនោះ គឺជារបស់ម្ចាស់ការតាំងពីដើមដំបូងតែម្តង។ នៅក្នុងករណីនេះ គាត់ អាចធានានូវសិទ្ធិក្នុងការទាមទារនូវប្រាក់កំរៃបាន តាមរយៈសិទ្ធិឃាត់ទុក ឬ ឯកសិទ្ធិនៅលើអចលនវត្ថុ។

ចំពោះករណីដែលខ្លឹមសារនៃកិច្ចសន្យា គឺដើម្បីផលិតនូវចលនវត្ថុ ដូចជា សំលៀកបំពាក់ ឬ ស្បែកជើង តើ មានលក្ខណៈយ៉ាងដូចម្តេច ? ឧទាហរណ៍ ម្ចាស់ការ បានផ្តល់នូវសំភារៈសំរាប់កាត់សំលៀកបំពាក់ ទៅអោយអ្នកម៉ៅការ ហើយ បញ្ជាគាត់អោយកាត់សំលៀកបំពាក់ ដូច្នេះ តើអ្នកណា ត្រូវទទួលបាននូវកម្មសិទ្ធិ ? ហើយនៅក្នុងករណីដែល អ្នកម៉ៅការ បានផ្តល់នូវសំភារៈ ឬ ក្រណាត់ សំរាប់កាត់សំលៀកបំពាក់វិញ តើវា នឹងទៅជាយ៉ាងណា ?

វា មានគោលគំនិតដែលអាចគិតទៅបានចំនួន ៣ គឺ :

គំនិតទី ១ គឺថា ម្ចាស់ការ ត្រូវទទួលបាននូវកម្មសិទ្ធិ។ មូលដ្ឋានសំរាប់គំនិតនេះ គឺថា អ្នកម៉ៅការ អាចគិតថា គាត់ បានផលិតនូវ "ទ្រព្យសម្បត្តិរបស់ម្ចាស់ការ" និង មិនមែនជាទ្រព្យសម្បត្តិផ្ទាល់របស់គាត់ទេ។ ដោយពិចារណាទៅលើឆន្ទៈរបស់អ្នកម៉ៅការ កម្មសិទ្ធិ ត្រូវបានទៅលើម្ចាស់ការ នៅពេលដែលអ្នកម៉ៅការ បានបញ្ចប់ការងារ។

គំនិតទី ២ គឺថាអ្នកម៉ៅការ ត្រូវទទួលបាននូវកម្មសិទ្ធិ ហើយ គាត់ ត្រូវផ្ទេរកម្មសិទ្ធិដោយការប្រគល់។ គំនិតនេះ មានគោលដៅ ការពារអ្នកម៉ៅការ នៅក្នុងករណីដែល ម្ចាស់ការ មិនអាចបង់នូវប្រាក់កំរៃបាន ដោយសារក្ស័យធន ឬ កង្វះទ្រព្យធន។ នៅក្នុងករណីនេះ អ្នកម៉ៅការ អាចដកទុកនូវសោហ៊ុយ តាមរយៈការលក់នូវវត្ថុនោះ។

គំនិតទី ៣ គឺថា បុគ្គលដែលផ្តល់នូវសំភារៈទាំងអស់ ឬ សំភារៈចំបង ត្រូវទទួលបាននូវកម្មសិទ្ធិ។ នេះគឺជាគំនិតមួយ ដែលសំរបសំរួលនូវគំនិតពីរខាងលើ។ ការអនុវត្តនៅប្រទេសជប៉ុន ជាគោលការណ៍ គឺយកតាមគំនិតនេះ។ ក៏ប៉ុន្តែ មាត្រានេះ ប៉ះពាល់ទៅដល់មាត្រាទាក់ទងនឹងការកែច្នៃចលនវត្ថុ។ ខុសពីមាត្រា ១៩៩ នៃក្រមរដ្ឋប្បវេណីកម្ពុជា ដែលវា បានបញ្ញត្តិថា "ប្រសិនបើ អ្នកកែច្នៃ បានចូលរួមចំណែកក្នុងការផលិតនូវចលនវត្ថុ ដែលជារបស់អ្នកដទៃ នោះកម្មសិទ្ធិនៅលើវត្ថុនោះ គឺជារបស់ម្ចាស់នៃវត្ថុធាតុដើម ប៉ុន្តែ ប្រសិនបើ តំលៃដែលបានមក

ពីការងារនោះ ច្រើនជាងតំលៃនៃវត្ថុធាតុដើម នោះ អ្នកកែច្នៃ ត្រូវទទួលបានកម្មសិទ្ធិលើវត្ថុ ដែលបានកែច្នៃនោះ" ។ ដូច្នេះ គំនិតនេះ មិនអាចអនុវត្តបានជាចាំបាច់ទៅនឹងករណីនេះទេ ដោយផ្អែកទៅលើក្រមរដ្ឋប្បវេណី ។

## ៤. កាតព្វកិច្ចរបស់ម្ចាស់ការ

### ៤.១ ករណីយកិច្ចបង់កម្រៃ

ម្ចាស់ការ ត្រូវបង់កំរៃទៅឱ្យអ្នកម៉ៅការ ដំណាលគ្នានឹងការប្រគល់វត្ថុ ដែលជាកម្មវត្ថុនៃការងារ ( មាត្រា ៦៥៣) ។ ប្រសិនជា ការប្រគល់វត្ថុ មិនមែនជាលក្ខខណ្ឌតំរូវអោយមាននោះទេ ម្ចាស់ការ ត្រូវបង់ប្រាក់កំរៃ នៅពេលដែលអ្នកម៉ៅការ បានសំរេចការងារ ។ គូភាគី អាចបង្កើតការព្រមព្រៀងពិសេស ទាក់ទងនឹងពេលវេលានៃការបង់កំរៃ ព្រោះ វា មិនមែនជាបញ្ញត្តិដែលអនុវត្តដោយបង្ខំឡើយ ។

### ៤.២ ករណីយកិច្ចទទួលវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា

ម្ចាស់ការ មានករណីយកិច្ចទទួលនូវវត្ថុ ដែលជាកម្មវត្ថុនៃកិច្ចសន្យា ក្រោយពេលដែល អ្នកម៉ៅការ បានសំរេចការងាររបស់ខ្លួន ។ ប្រសិនបើម្ចាស់ការ មិនបានទទួលវត្ថុ ដោយមានកំហុស នោះ គាត់ ទទួលបន្ទុកកាតព្វកិច្ច នៅក្នុងករណីការយឺតយ៉ាវក្នុងការទទួល (មាត្រា ៤៥៦) ។

## ៥. ការបញ្ចប់កិច្ចសន្យាម៉ៅការ

### ៥.១ សិទ្ធិរំលាយរបស់ម្ចាស់ការ នៅក្នុងពេលដែលការងារមិនទាន់បានសំរេច

ម្ចាស់ការ អាចរំលាយកិច្ចសន្យា នៅពេលណាក៏បាន រហូតដល់ពេលដែលអ្នកម៉ៅការ បានសំរេចការងារ ។ គោលបំណងនៃបញ្ញត្តិនេះ គឺដើម្បីអោយម្ចាស់ការ និង អ្នកម៉ៅការ រួចផុតពីកាតព្វកិច្ច ប្រសិនបើ ម្ចាស់ការ មិនចង់បន្តការងារនោះទៀតទេ ។ ក៏ប៉ុន្តែ ម្ចាស់ការ ត្រូវសងសំណងនៃការខូចខាតទៅអោយអ្នកម៉ៅការ ។ ឧទាហរណ៍ ប្រសិនបើម្ចាស់ការ រំលាយកិច្ចសន្យា ដែលបានបញ្ញត្តិថា អ្នកម៉ៅការ ត្រូវផ្តល់នូវសំភារៈសំរាប់កាត់ស្បែកជើង និង ត្រូវកាត់ស្បែកជើង នោះ ម្ចាស់ការ ត្រូវបង់នូវចំណាយលើសោហ៊ុយសំភារៈ និង ប្រាក់កំរៃ រហូតដល់ពេលរំលាយកិច្ចសន្យា ។

### ៥.២ ការរំលាយកិច្ចសន្យា ដោយផ្អែកលើការមិនអនុវត្តកាតព្វកិច្ច

ទាំងម្ចាស់ការ និង អ្នកម៉ៅការ អាចរំលាយកិច្ចសន្យាម៉ៅការ ដោយផ្អែកលើបញ្ញត្តិទូទៅ នៃការរំលាយកិច្ចសន្យាបាន ប្រសិនបើភាគីម្ខាងទៀត បានបំពានកិច្ចសន្យាធ្ងន់ធ្ងរ ។ ក៏ប៉ុន្តែ ការសំរេចការងារភ្លាម ឬ បន្ទាន់ គឺជាខ្លឹមសារនៃកិច្ចសន្យា ដូចជាការកាត់សក់ ឬ ការជូនដំណើរទៅដល់កន្លែង នោះ ភាគី មិនអាចរំលាយកិច្ចសន្យាបានទេ ក្រោយពីការសំរេចការងារ ។

# ឧបសម្ព័ន្ធ

**[ឧបសម្ព័ន្ធ ១] ទិដ្ឋភាពទូទៅនៃសិទ្ធិលើបំណុល និង កាតព្វកិច្ច**



[ឧបសម្ព័ន្ធ ២] លក្ខណៈនៃកិច្ចសន្យាមានឈ្មោះ

| | យកកំរៃ ឬ មិនយកកំរៃ | ទ្វេភាគី ឬ ឯកតោភាគី | ព្រមព្រៀង ឬ ប្រគល់វត្ថុ ឬ ទំរង់ | ប្រភេទនៃកិច្ចសន្យា | |
|---|---|---|---|---|---|
| ការលក់ទិញ | យកកំរៃ | ទ្វេភាគី | ព្រមព្រៀង※ | ផ្ទេរ | អនុវត្តម្តង |
| ការដូរ | យកកំរៃ | ទ្វេភាគី | ព្រមព្រៀង※ | ផ្ទេរ | អនុវត្តម្តង |
| ប្រទានកម្ម | មិនយកកំរៃ | ឯកតោភាគី | ព្រមព្រៀង※ | ផ្ទេរ | អនុវត្តម្តង |
| ការខ្ចីបរិភោគ (គ្មានការប្រាក់ : គោលការណ៍) | មិនយកកំរៃ | ទ្វេភាគី | ព្រមព្រៀង | ប្រើប្រាស់ | អនុវត្តបន្តបន្ទាប់ |
| ការខ្ចីបរិភោគ (មានការប្រាក់ : ករណីលើកលែង) | យកកំរៃ | ទ្វេភាគី | ទំរង់ | | |
| ភតិសន្យា | យកកំរៃ | ទ្វេភាគី | ព្រមព្រៀង | ប្រើប្រាស់ | អនុវត្តបន្តបន្ទាប់ |
| ការខ្ចីប្រើ | មិនយកកំរៃ | ឯកតោភាគី | ប្រគល់វត្ថុ | ប្រើប្រាស់ | អនុវត្តបន្តបន្ទាប់ |
| អាណត្តិ (មិនយកកំរៃ : គោលការណ៍) | មិនយកកំរៃ | ឯកតោភាគី | ព្រមព្រៀង | សេវាកម្ម | អនុវត្តបន្តបន្ទាប់ |
| អាណត្តិ (យកកំរៃ : ករណីលើកលែង) | យកកំរៃ | ទ្វេភាគី | | | |
| កិច្ចសន្យាម៉ៅការ | យកកំរៃ | ទ្វេភាគី | ព្រមព្រៀង | សេវាកម្ម | អនុវត្តបន្តបន្ទាប់ |
| កិច្ចសន្យាការងារ | យកកំរៃ | ទ្វេភាគី | ព្រមព្រៀង | សេវាកម្ម | អនុវត្តបន្តបន្ទាប់ |

※ នៅក្នុងករណីនៃការផ្ទេរ ឬ ធ្វើលទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុ វា ត្រូវធ្វើឡើងដោយកិច្ចសន្យាជាលក្ខណៈទំរង់

## 【ឧបសម្ព័ន្ធ ៣】 ការបង្កើត និង សុពលភាពនៃកិច្ចសន្យា



【ឧបសម្ព័ន្ធ ៤】 ការទទួលខុសត្រូវក្នុងការធានារបស់អ្នកលក់

| | ភាពសុចរិត និងគ្មានកំហុសរបស់អ្នកទិញ | បន្ថយថ្លៃ | រំលាយកិច្ចសន្យាដោយអ្នកទិញ | ទាមទារសំណងការខូចខាត | ទាមទារប្រគល់វត្ថុជំនួស | ទាមទារឱ្យជួសជុល. | អំឡុងពេលសំរាប់អនុវត្តសិទ្ធិ | |
|---|---|---|---|---|---|---|---|---|
| នៅពេលដែលសិទ្ធិទាំងមូលជាសិទ្ធិរបស់តតិយជន (531,532) | សុចរិត | ▬ | ○ | ○ | ▬ | ▬ | គ្មានការកំរិតជាពិសេស | |
| | ទុច្ចរិត | ▬ | ○ | × | ▬ | ▬ | គ្មានការកំរិតជាពិសេស | ・ អ្នកលក់សុចរិត មានសិទ្ធិរំលាយ (532) |
| នៅពេលដែលសិទ្ធិមួយភាគជាសិទ្ធិរបស់តតិយជន (533) | សុចរិត | ○ | ○※ | ○ | ▬ | ▬ | អំឡុងពេល ១ឆ្នាំ គិតពីពេលដែលអ្នកទិញ បានដឹងការពិត (533-4) | ※ មានតែក្នុងករណីដែលអ្នកទិញនឹងមិនទិញតែភាគដែលនៅសល់ (533-2) |
| | ទុច្ចរិត | ○ | × | × | ▬ | ▬ | អំឡុងពេល ១ ឆ្នាំ គិតពីពេលបង្កើតកិច្ចសន្យា (533-4) | |
| នៅពេលដែលមានសិទ្ធិប្រត្យក្សជាផលុបភោគ (534) | សុចរិត | ▬ | ○<br>(មានតែករណីដែលអ្នកទិញមិនអាចសំរេចគោលបំណងនៃកិច្ចសន្យា) | ○ | ▬ | ▬ | អំឡុងពេល ១ឆ្នាំ គិតពីពេលដែលអ្នកទិញ បានដឹងការពិត (534-4) | |
| | ទុច្ចរិត | ▬ | × | × | ▬ | ▬ | ▬ | |
| នៅពេលមានសិទ្ធិប្រាតិភោគប្រត្យក្ស (535) | សុចរិត | ▬ | ○<br>(មានតែករណីដែលអ្នកទិញបាត់បង់កម្មសិទ្ធិ) | ○ | ▬ | ▬ | គ្មានការកំរិតជាពិសេស | ・ អ្នកទិញ អាចទាមទារអោយសងថ្លៃចំណាយដែល គាត់ បានចំណាយសំរាប់រក្សាកម្មសិទ្ធិ (535-2) |
| | ទុច្ចរិត | ▬ | | | ▬ | ▬ | | |

| | ភាពសុចរិត និងគ្មានកំហុសរបស់អ្នកទិញ | បន្ថយថ្លៃ | រំលាយកិច្ចសន្យាដោយអ្នកទិញ | ទាមទារសំណងការខូចខាត | ទាមទារប្រគល់វត្ថុជំនួស | ទាមទារឱ្យជួសជុល | អំឡុងពេលសំរាប់អនុវត្តសិទ្ធិ | |
|---|---|---|---|---|---|---|---|---|
| នៅពេលដែលមានវិការៈ (540) | សុចរិត | ○ | ○<br>(មានតែករណីដែលអ្នកទិញមិនអាចសំរេចគោលបំណងនៃកិច្ចសន្យា) | ○ | ○ | ○ | អំឡុងពេល ១ឆ្នាំ គិតពីពេលដែលអ្នកទិញបានដឹង ឬ គួរបានដឹងពីវិការៈ (547) | |
| | ទុច្ចរិត/កំហុសធ្ងន់ធ្ងរ | × | × | × | × | × | - | |

| | | | ភាពសុចរិត និងគ្មានកំហុសរបស់អ្នកទិញ | បន្ថយថ្លៃ | រំលាយកិច្ចសន្យាដោយអ្នកទិញ | ទាមទារសំណងការខូចខាត | ទាមទារប្រគល់វត្ថុជំនួស | ទាមទារឱ្យជួសជុល | អំឡុងពេលសំរាប់អនុវត្តសិទ្ធិ | |
|---|---|---|---|---|---|---|---|---|---|---|
| បញ្ញត្តិពិសេសស្តីពីដីដែលមានទំហំខ្វះ ឬលើស (546) | ការលក់ទិញ បានធ្វើឡើងដោយផ្អែកទៅលើតំលៃសរុប និងតំលៃតាមខ្នាតដី | នៅក្នុងករណីដែលទំហំដីពិតគឺខ្វះ (546-1) | សុចរិត | ○ | ○<br>(មានតែករណីដែលអ្នកទិញមិនអាចសំរេចគោលបំណងនៃកិច្ចសន្យា) | ○※2 | × | ○<br>(ផ្តល់តាវកាលិកនូវផ្នែកដែលខ្វះ) | អំឡុងពេល ១ឆ្នាំ គិតពីពេលដែលអ្នកទិញបានដឹង ឬ គួរបានដឹងពីវិការ: (547)※2 | ※2 មាត្រា ៤៨២ ត្រូវយកមកអនុវត្តចំពោះសិទ្ធិទាមទារសំណងការខូចខាត |
| | | | ទុច្ចរិត/កំហុសធ្ងន់ធ្ងរ | × | × | × | × | × | - | |
| | | នៅក្នុងករណីដែលទំហំដីពិតគឺលើស (546-2) | សុចរិត | - | - | - | - | - | - | ・អ្នកលក់សុចរិត អាចទាមទារឱ្យបន្ថែមតំលៃនៅក្នុងរយ:ពេល ១ ឆ្នាំ គិតចាប់ពីពេលបង្កើតកិច្ចសន្យា (546-2) |
| | | | ទុច្ចរិត/កំហុសធ្ងន់ធ្ងរ | × | × | × | × | × | - | |
| | ការលក់ទិញ បានធ្វើឡើងដោយ | នៅក្នុងករណីដែលទំហំដីពិតគឺខ្វះ (546-3) | សុចរិត | × (លើកលែងតែករណីដែលអ្នកលក់ ជាជនទុច្ចរិត, ឬអ្នកលក់ បានធានាភាពត្រឹមត្រូវនៃទំហំដីដែលបានបញ្ជាក់, ឬ ទំហំដែលខ្វះមានច្រើនជាង ៥ភាគរយ មាត្រា 546 កថាខណ្ឌទី 3 វាក្យខណ្ឌទី 2) ※2 | | | | | (ប្រសិនបើសិទ្ធិ ត្រូវបានទទួលស្គាល់តាមមាត្រា ៥៤៦ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ២ អំឡុងពេល ១ឆ្នាំ គិតពីពេលដែលអ្នកទិញបានដឹង ឬ គួរបានដឹងពីវិការ: (547)※2) | ※2 មាត្រា ៤៨២ ត្រូវយកមកអនុវត្តចំពោះសិទ្ធិទាមទារសំណងការខូចខាត |

| | | | ភាពសុចរិត និងគ្មានកំហុសរបស់អ្នកទិញ | បន្ថយថ្លៃ | រំលាយកិច្ចសន្យាដោយអ្នកទិញ | ទាមទារសំណងការខូចខាត | ទាមទារប្រគល់វត្ថុជំនួស | ទាមទារឱ្យជួសជុល | អំឡុងពេលសំរាប់អនុវត្តសិទ្ធិ | |
|---|---|---|---|---|---|---|---|---|---|---|
| | ផ្អែកទៅលើតែតំលៃសរុបតែប៉ុណ្ណោះ | | ទុច្ចរិត/កំហុសធ្ងន់ធ្ងរ | × | × | × | × | × | - | |
| | | នៅក្នុងករណីដែលទំហំដីពិតគឺលើស (546-4) | សុចរិត | - | - | - | - | - | - | · អ្នកលក់ សុចរិត និង គ្មានកំហុសធ្ងន់ធ្ងរ អាចទាមទារឱ្យបន្ថែមតំលៃដី ក្នុងរយៈពេល ១ ឆ្នាំ គិតចាប់ពីពេលបង្កើតកិច្ចសន្យា ចំពោះករណីដែលទំហំដែលលើសនោះ មានច្រើនជាង ៥ ភាគរយនៃទំហំដែលបានបញ្ជាក់ (546-4) |
| | | | ទុច្ចរិត/កំហុសធ្ងន់ធ្ងរ | - | - | - | - | - | - | |

**សំគាល់ :**

| | |
|---|---|
| ○ | មានន័យថា អាចធ្វើបាន |
| × | មានន័យថា មិនអាចធ្វើបាន |
| - | មានន័យថា មិនមានបញ្ញត្តិក្នុងក្រម ឬ មិនមានលទ្ធភាពក្នុងការពិចារណា |